

# ព្រះ
# ត្រៃបិដកបាលី
# នឹង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# អង្គុត្តរនិកាយ បញ្ចកនិបាត
# ឆដ្ឋភាគ
# ៤៥



ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព. ស. ២៤៩៧

# សុត្តន្តបិដកេ

## អង្គុត្តរនិកាយស្ស បញ្ចកនិបាតោ

## ឆដ្ឋោ ភាគោ

---

## តតិយបណ្ណាសកោ

## ផាសុវិហារវគ្គោ

---

(១) បញ្ចិមេ ភិក្ខវេ សេក្ខវេសារជ្ជករណា ធម្មា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធោ ហោតិ សីលវា ហោតិ ពហុស្សុតោ ហោតិ អារទ្ធវីរិយោ ហោតិ បញ្ញវា ហោតិ ។ យំ ហិ ភិក្ខវេ អស្សទ្ធស្ស សារជ្ជំ ហោតិ សទ្ធស្ស តំ សារជ្ជំ ន ហោតិ ។ តស្មាយំ ធម្មោ សេក្ខវេសារជ្ជករណោ ។ យំ ភិក្ខវេ ទុស្សីលស្ស សារជ្ជំ ហោតិ សីលវតោ តំ សារជ្ជំ ន ហោតិ ។ តស្មាយំ ធម្មោ សេក្ខវេសារជ្ជករណោ ។

# សុត្តន្តបិដក

# អង្គុត្តរនិកាយ បញ្ចកនិបាត

## ឆដ្ឋភាគ

## តតិយបណ្ណាសក

## ផាសុវិហារវគ្គ

(១) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយជាគ្រឿងធ្វើឲ្យក្លៀវក្លា របស់សេក្ខបុគ្គលនេះមាន ៥ យ៉ាង ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានសីល ១ បានស្តាប់ច្រើន ១ ប្រារព្ធព្យាយាម ១ មានប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានសទ្ធា មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកមានសទ្ធា ឥតមានសេចក្តីអៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកទ្រុស្តសីល មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកមានសីល ឥតមានសេចក្តីអៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។

យំ ភិក្ខវេ អប្បស្សុតស្ស សារជ្ជំ ហោតិ ពហុស្សុតស្ស តំ សារជ្ជំ ន ហោតិ ។ តស្មាយំ ធម្មោ សេក្ខវេសារជ្ជករណោ ។ យំ ភិក្ខវេ កុសីតស្ស សារជ្ជំ ហោតិ អារទ្ធវីរិយស្ស តំ សារជ្ជំ ន ហោតិ ។ តស្មាយំ ធម្មោ សេក្ខវេសារជ្ជករណោ ។ យំ ភិក្ខវេ ទុប្បញ្ញស្ស សារជ្ជំ ហោតិ បញ្ញវតោ តំ សារជ្ជំ ន ហោតិ ។ តស្មាយំ ធម្មោ សេក្ខវេសារជ្ជករណោ ។ ឥមេ ខោ ភិក្ខវេ បញ្ច សេក្ខវេសារជ្ជករណា ធម្មាតិ ។

(២) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ឧស្សង្កិតបរិសង្កិតោ ហោតិ បាបភិក្ខូតិ អបិ អកុប្បធម្មោ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ វេសិយាគោចរោ វា ហោតិ វិធវាគោចរោ វា ហោតិ ថុល្លកុមារីគោចរោ វា ហោតិ បណ្ឌកគោចរោ វា ហោតិ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចេះដឹងតិច មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកចេះដឹងច្រើន ឥតមានសេចក្តីអៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកខ្ជិលច្រអូស មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកប្រារព្ធព្យាយាម ឥតមានសេចក្តីអៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឥតប្រាជ្ញា មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកមានប្រាជ្ញា ឥតមានសេចក្តីអៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គលមាន ៥ យ៉ាង នេះឯង ។

[៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបដោយធម៌ ៥ យ៉ាង សូម្បីតែលោកអ្នកមានធម៌មិនកម្រើក (ព្រះខីណាស្រព) ក៏រមែងត្រូវគេរង្កៀសសង្ស័យថាជាភិក្ខុអាក្រក់ដែរ ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកតែងទៅកាន់សំណាក់ស្រីពេស្យា ១ តែងទៅកាន់សំណាក់ស្រីមេម៉ាយ ១ តែងទៅកាន់សំណាក់ស្រីក្រមុំចាស់ ១ តែងទៅកាន់សំណាក់មនុស្សខ្ទើយ ១

ភិក្ខុនីគោចរោ វា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ឧស្សង្កិតបរិ-សង្កិតោ ហោតិ បាបភិក្ខូតិ អបិ អកុប្បធម្មោតិ ។

(៣) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ មហា-ចោរោ សន្ធឹបិ ឆិន្ទតិ និល្លោបំបិ ហរតិ ឯកាគារិកំបិ ករោតិ បរិបន្ថេបិ តិដ្ឋតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ មហាចោរោ វិសមនិស្សិតោ ច ហោតិ គហននិស្សិតោ ច ពលវនិស្សិតោ ច ភោគចាគី ច ឯកចារី ច ។ កថញ្ច ភិក្ខវេ មហាចោរោ វិស-មនិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ មហាចោរោ នទីវិទុគ្គំ វា និស្សិតោ ហោតិ បព្វតវិសមំ វា ឯវំ ខោ ភិក្ខវេ មហាចោរោ វិសមនិស្សិតោ ហោតិ ។ កថញ្ច ភិក្ខវេ មហាចោរោ គហននិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ មហាចោរោ តិណគហនំ វា និស្សិតោ ហោតិ រុក្ខគហនំ វា រោធំ វា មហាវនសណ្ឌំ វា ឯវំ ខោ ភិក្ខវេ មហាចោរោ គហននិស្សិតោ ហោតិ ។

ត្រេចទៅកាន់សំណាក់ភិក្ខុនី ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង សូម្បីតែលោកអ្នកមានធម៌មិនកម្រើក (ព្រះខីណាស្រព) ក៏រមែងត្រូវគេរង្កៀសសង្ស័យថាជាភិក្ខុអាក្រក់មិនខានដែរ ។

[៣] ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៥ យ៉ាង រមែងកាត់ទីតខ្លះ ប្លន់ខ្លះ ប្លន់ផ្ទះ១ខ្លះ ឈរចាំស្ទាក់អ្នកដំណើរតាមផ្លូវខ្លះ ។ អង្គ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ ជាអ្នកអាស្រ័យនូវទីមិនស្មើ១ អាស្រ័យព្រៃស្បាត ១ អាស្រ័យជនអ្នកមានកំឡាំង ១ ជាអ្នកស្លុកទ្រព្យ ១ ជាអ្នកត្រេចទៅម្នាក់ឯង ១ ។

ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរ អ្នកអាស្រ័យនូវទីមិនស្មើ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ ជាអ្នកអាស្រ័យនូវដងស្ទឹង ឬអាស្រ័យនូវភ្នំដែលមិនរាបស្មើ ម្នាលភិក្ខុទាំងឡាយ មហាចោរអ្នកអាស្រ័យនូវទីមិនស្មើយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរអ្នកអាស្រ័យព្រៃស្បាត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ អាស្រ័យនូវស្បាតស្មៅខ្លះ ស្បាតឈើខ្លះ ឆ្នេរស្ទឹងខ្លះ ដងព្រៃធំខ្លះ ម្នាលភិក្ខុទាំងឡាយ មហាចោរអ្នកអាស្រ័យនូវព្រៃស្បាតយ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ មហាចោរោ ពលវនិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ មហាចោរោ រាជានំ វា រាជមហាមត្តានំ វា និស្សិតោ ហោតិ តស្ស ឯវំ ហោតិ សចេ មំ កោចិ កិញ្ចិ វក្ខតិ ឥមេ រាជានោ វា រាជមហាមត្តា វា បរិយោទាយ អត្ថំ ភណិស្សន្តីតិ សចេ នំ កោចិ កិញ្ចិ អាហ ត្យស្ស រាជានោ វា រាជមហាមត្តា វា បរិយោទាយ អត្ថំ ភណន្តិ ឯវំ ខោ ភិក្ខវេ មហាចោរោ ពលវនិស្សិតោ ហោតិ ។ កថញ្ច ភិក្ខវេ មហាចោរោ ភោគចាគី ហោតិ ។ ឥធ ភិក្ខវេ មហាចោរោ អឌ្ឍោ ហោតិ មហទ្ធនោ មហាភោគោ តស្ស ឯវំ ហោតិ សចេ មំ កោចិ កិញ្ចិ វក្ខតិ ឥតោ ភោគេន បដិសន្ថរិស្សាមីតិ សចេ នំ កោចិ កិញ្ចិ អាហ ឥតោ ភោគេន បដិសន្ថរតិ ឯវំ ខោ ភិក្ខវេ មហាចោរោ ភោគចាគី ហោតិ ។ កថញ្ច ភិក្ខវេ មហាចោរោ ឯកចារី ហោតិ ។ ឥធ ភិក្ខវេ មហាចោរោ ឯកកោ និគ្គហណានិ កត្តា ហោតិ ។ តំ កិស្ស ហេតុ ។

ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរអាស្រ័យជនអ្នកមានកំឡាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ អាស្រ័យព្រះរាជាខ្លះ អាស្រ័យរាជមហាមាត្យខ្លះ មហាចោរនោះតែងអាង យ៉ាងនេះថា បើនរណាប្តឹងអ្វី ៗ ពីអញ ពួកស្តេចឬរាជមហាមាត្យទាំងនេះ មុខជាកាត់សេចក្តីបង្គ្របចោល បើនរណាមួយប្តឹងអ្វីៗ ពីចោរនោះ ពួកស្តេច ឬរាជមហាមាត្យទាំងនោះ ក៏កាត់សេចក្តីបង្គ្របឲ្យចោរនោះ ម្នាលភិក្ខុទាំងឡាយ មហាចោរអ្នកអាស្រ័យជនមានកំឡាំងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរ សូកដោយទ្រព្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ ជាអ្នកស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើន មហាចោរនោះតែងអាង យ៉ាងនេះថា បើនរណាមួយប្តឹងអ្វី ៗ ពីអញ អញ (នឹងយក) ភោគៈអំពីទ្រព្យនេះទៅសូក បើនរណាមួយប្តឹងអ្វីៗ អំពីចោរនោះ ចោរនោះ (ក៏យក) ភោគៈអំពីទ្រព្យនោះទៅសូក ម្នាលភិក្ខុទាំងឡាយ មហាចោរអ្នកសូកដោយភោគៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរ អ្នកត្រេចទៅតែម្នាក់ឯង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ តែងធ្វើការសង្កត់សង្កិទតែម្នាក់ឯង ។ ដំណើរនោះព្រោះហេតុអ្វី ។

មា មេ គុយ្ហមន្តា ពហិទ្ធា សម្ភេទំ អគមំសូតិ ឯវំ ខោ ភិក្ខវេ មហាចោរោ ឯកចារី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតោ មហាចោរោ សន្ធឹបិ ឆិន្ទតិ និល្លោបំបិ ហរតិ ឯកាគារិកំបិ ករោតិ បរិបន្ថេបិ តិដ្ឋតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ បាបភិក្ខុ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ បាបភិក្ខុ វិសមនិស្សិតោ ច ហោតិ គហននិស្សិតោ ច ពលវនិស្សិតោ ច ភោគចាគី ច ឯកចារី ច ។ កថញ្ច ភិក្ខវេ បាបភិក្ខុ វិសមនិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ បាបភិក្ខុ វិសមេន កាយកម្មេន សមន្នាគតោ ហោតិ វិសមេន វចីកម្មេន សមន្នាគតោ ហោតិ វិសមេន មនោកម្មេន សមន្នាគតោ ហោតិ ឯវំ ខោ ភិក្ខវេ បាបភិក្ខុ វិសមនិស្សិតោ ហោតិ ។ កថញ្ច ភិក្ខវេ បាបភិក្ខុ គហននិស្សិតោ ហោតិ ។

ព្រោះមហាចោរនោះគិតថា អាថ៌កំបាំងរបស់អញ កុំខ្ចរខ្ចាយទៅក្រៅឡើយ ម្នាលភិក្ខុទាំងឡាយ មហាចោរជាអ្នកត្រេចទៅតែម្នាក់ឯងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៥ យ៉ាងនេះឯង រមែងកាត់នូវទីតខ្លះ ប្លន់ធំខ្លះ ប្លន់ផ្ទះ ១ ខ្លះ ចាំស្កាត់អ្នកដំណើរខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបដែលប្រកបដោយធម៌ ៥ យ៉ាង រមែងរក្សាខ្លួនដែលគាស់រំលើង បំផ្លាញគុណធម៌ចោលផង ប្រកបដោយទោសផង គួរជាទីតិះដៀលនៃអ្នកប្រាជ្ញទាំងឡាយផង ទទួលនូវបាបដ៏ច្រើនផង ក៏យ៉ាងនោះដែរ ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះ អាស្រ័យកិរិយាមិនស្មើ ១ អាស្រ័យសេចក្ដីយល់សាំញ៉ាំ ១ អាស្រ័យជនមានកំឡាំង ១ ស្លូកដោយទ្រព្យ ១ ត្រេចទៅតែម្នាក់ឯង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាបអាស្រ័យកិរិយាមិនស្មើ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះ ប្រកបដោយកាយកម្មមិនស្មើ ប្រកបដោយវចីកម្មមិនស្មើ ប្រកបដោយមនោកម្មមិនស្មើ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាប អាស្រ័យកិរិយាមិនស្មើយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាប អាស្រ័យសេចក្ដីយល់សាំញ៉ាំ តើដូចម្ដេច ។

ឥធ ភិក្ខវេ បាបភិក្ខុ មិច្ឆាទិដ្ឋិកោ ហោតិ អន្តគ្គាហិកាយ ទិដ្ឋិយា សមន្នាគតោ ឯវំ ខោ ភិក្ខវេ បាបភិក្ខុ គហននិស្សិតោ ហោតិ ។ កថញ្ច ភិក្ខវេ បាបភិក្ខុ ពលវនិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ បាបភិក្ខុ រាជានំ វា រាជមហាមត្តានំ វា និស្សិតោ ហោតិ តស្ស ឯវំ ហោតិ សចេ មំ កោចិ កិញ្ចិ វក្ខតិ ឥមេ រាជានោ វា រាជមហាមត្តា វា បរិយោទាយ អត្ថំ ភណិស្សន្តីតិ សចេ នំ កោចិ កិញ្ចិ អាហ តស្ស រាជានោ វា រាជមហាមត្តា វា បរិយោទាយ អត្ថំ ភណន្តិ ឯវំ ខោ ភិក្ខវេ បាបភិក្ខុ ពលវនិស្សិតោ ហោតិ ។ កថញ្ច ភិក្ខវេ បាបភិក្ខុ ភោគគាហី ហោតិ ។ ឥធ ភិក្ខវេ បាបភិក្ខុ លាភី ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ តស្ស ឯវំ ហោតិ សចេ មំ កោចិ កិញ្ចិ វក្ខតិ ឥតោ លាភេន បដិសន្ថរិស្សាមីតិ សចេ នំ កោចិ កិញ្ចិ អាហ ឥតោ លាភេន បដិសន្ថរតិ ឯវំ ខោ ភិក្ខវេ បាបភិក្ខុ ភោគគាហី ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះយល់ខុស ប្រកបដោយអន្តគ្គាហិកាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបអាស្រ័យសេចក្តីយល់សាំញ៉ាំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាបអាស្រ័យជនមានកំឡាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះ អាស្រ័យពួកស្តេច ឬពួករាជមហាមាត្យ ភិក្ខុបាបនោះតែងគិតយ៉ាងនេះថា បើនរណាមួយពោលអ្វីៗ អំពីអញ ពួកស្តេច ឬពួករាជមហាមាត្យទាំងនោះ គង់នឹងជម្រះសេចក្តីផ្គ្របឲ្យ បើនរណាមួយពោលអ្វីៗ អំពីភិក្ខុនោះ ពួកស្តេច ឬពួករាជមហាមាត្យទាំងនោះក៏ជំរះសេចក្តីផ្គ្របឲ្យភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាប អាស្រ័យជនមានកំឡាំងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាបអ្នកសូកដោយទ្រព្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះ ជាអ្នកសម្បូរចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ភិក្ខុនោះ តែងគិត យ៉ាងនេះថា បើនរណាមួយពោលអ្វីៗអំពីអញ អញនឹងយកលាភអំពីបច្ច័យនេះទៅសូក ។ បើនរណាមួយពោលអ្វីៗ អំពីភិក្ខុនោះ ភិក្ខុនោះ ក៏យកលាភអំពីបច្ច័យនោះទៅសូក ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបអ្នកសូកដោយទ្រព្យយ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ ទាយកភិក្ខុ ឯកចារី ហោតិ ។ ឥធ ភិក្ខវេ ទាយកភិក្ខុ ឯកកោ បច្ឆិមេសុ ជនបទេសុ និគមំ គច្ឆតិ សោ តត្ថ កុលានិ ឧបសង្កមន្តោ លាភំ លភតិ ឯវំ ខោ ភិក្ខវេ ទាយកភិក្ខុ ឯកចារី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ទាយកភិក្ខុ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតីតិ ។

(៤) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សមណេសុ សមណសុខុមាលោ ហោតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ យាចិតោវ ពហុលំ ចីវរំ បរិភុញ្ជតិ អប្បំ អយាចិតោ យាចិតោវ ពហុលំ បិណ្ឌបាតំ បរិភុញ្ជតិ អប្បំ អយាចិតោ យាចិតោវ ពហុលំ សេនាសនំ បរិភុញ្ជតិ អប្បំ អយាចិតោ យាចិតោវ ពហុលំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បរិភុញ្ជតិ អប្បំ អយាចិតោ យេហិ ខោ បន ស[ព្រហ្មចារីហិ សទ្ធឹ វិហរតិ

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាបត្រេចទៅម្នាក់ឯង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះ តែម្នាក់ឯង សម្រេចការនៅក្នុងជនបទទាំងឡាយជាទីបំផុតដែន ភិក្ខុនោះចូលទៅរកត្រកូលទាំង-ឡាយក្នុងជនបទនោះ រមែងបានលាភ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបត្រេចទៅម្នាក់ឯង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលគាស់រំលើងបំផ្លាញគុណធម៌ចោលផង ប្រកបដោយទោសផង គួរអ្នកប្រាជ្ញទាំងឡាយតិះដៀលផង ទទួលបាបច្រើនផង ។

(៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថាជាសមណសុខុមាលក្នុងពួកសមណៈ ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បើគេអង្វរក៏ប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរក៏ប្រើប្រាស់តិច គេអង្វរក៏បរិភោគបិណ្ឌបាតច្រើន គេមិនអង្វរក៏បរិភោគតិច គេអង្វរក៏ប្រើប្រាស់សេនាសនៈច្រើន គេមិនអង្វរក៏ប្រើប្រាស់តិច គេអង្វរក៏បរិភោគគិលានប្បច្ចយភេសជ្ជបរិក្ខារច្រើន គេមិនអង្វរក៏បរិភោគតិច ១ ភិក្ខុនោះនៅជាមួយនឹងពួកសព្រហ្មចារីណា

ត្យស្ស មនាបេនេវ ពហុលំ កាយកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបេនេវ ពហុលំ វចីកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបេនេវ ពហុលំ មនោកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបំយេវ ឧបហារំ ឧបហរន្តិ អប្បំ អមនាបំ យានិ ខោ បន តានិ វេទយិតានិ បិត្តសមុដ្ឋានានិ វា សេម្ហសមុដ្ឋានានិ វា វាតសមុដ្ឋានានិ វា សន្និបាតិកានិ វា ឧតុបរិណាមជានិ វា វិសមបរិហារជានិ វា ឱបក្កមិកានិ វា កម្មវិបាកជានិ វា តានិស្ស ន ពហុទេវ ឧប្បជ្ជន្តិ អប្បាពាធោ ហោតិ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

ពួកសព្រហ្មចារីនោះ តែងគប់រកភិក្ខុនោះដោយកាយកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្ត (នោះ) តិច តែងគប់រកដោយវចីកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច តែងគប់រកដោយមនោកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច នាំចូលទៅជិតតែរបស់ដែលគួរនាំចូលទៅជិតជាទីគាប់ចិត្ត មិនគាប់ចិត្តតិច ១ ជម្ងឺដែលតាំងឡើងអំពីប្រមាត់ក្តី តាំងឡើងអំពីស្លេស្មក្តី តាំងឡើងអំពីខ្យល់ក្តី កើតអំពីធាតុប្រជុំក្តី កើតអំពីរដូវប្រែប្រួលក្តី កើតអំពីរក្សាឥរិយាបថមិនស្មើក្តី កើតអំពីសេចក្តីព្យាយាម (របស់គេមានវាយចងជាដើម) ក្តី កើតអំពីផលនៃកម្មក្តី ជម្ងឺទាំងឡាយនោះ មិនកើតឡើងដល់ភិក្ខុនោះច្រើនទេ ជាអ្នកមានអាពាធតិច ១ ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រនូវឈានទាំង ៤ ដែលអាស្រ័យដោយចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ចូលដល់ចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែង ខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សមណេសុ សមណសុខុមាលោ ហោតិ ។ យំ ហិ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ សមណេសុ សមណសុខុមាលោតិ មមេវ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ សមណេសុ សមណ-សុខុមាលោតិ ។ អហំ ហិ ភិក្ខវេ យាចិតោវ ពហុលំ ចីវរំ បរិភុញ្ជាមិ អប្បំ អយាចិតោ យាចិតោវ ពហុលំ បិណ្ឌបាតំ បរិភុញ្ជាមិ អប្បំ អយាចិតោ យាចិតោវ ពហុលំ សេនាសនំ បរិភុញ្ជាមិ អប្បំ អយាចិតោ យាចិតោវ ពហុលំ គិលានប្បច្ចយភេសជ្ជ-បរិក្ខារំ បរិភុញ្ជាមិ អប្បំ អយាចិតោ យេហិ ខោ បន ភិក្ខូហិ សទ្ធឹ វិហរាមិ តេ មំ មនាបេនេវ ពហុលំ កាយកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបេនេវ ពហុលំ វចីកម្មេន សមុទាចរន្តិ អប្បំ អម-នាបេន មនាបេនេវ ពហុលំ មនោកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបំយេវ ឧបហារំ ឧបហរន្តិ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាសមណសុខុមាលក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ កាលបើគេពោលសរសើរសមណៈណាថា ជាសមណសុខុមាល ក្នុងពួកសមណៈដូច្នេះ ម្នាលភិក្ខុទាំងឡាយ គួរគេពោលសរសើរតថាគតថា ជាសមណសុខុមាលក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា តថាគតបើគេអង្វរក៏ប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរក៏ប្រើប្រាស់តិច បើគេអង្វរក៏បរិភោគបិណ្ឌបាតច្រើន បើគេមិនអង្វរក៏បរិភោគតិច បើគេអង្វរក៏ប្រើប្រាស់សេនាសនៈច្រើន បើគេមិនអង្វរក៏ប្រើប្រាស់តិច បើគេអង្វរក៏បរិភោគគិលានប្បច្ចយភេសជ្ជបរិក្ខារច្រើន បើគេមិនអង្វរក៏បរិភោគតិច មួយទៀត តថាគតនៅជាមួយនឹងពួកភិក្ខុណា ពួកភិក្ខុនោះ តែងគប់រកតថាគតដោយកាយកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្ត (នោះ) តិច តែងគប់រកដោយវចីកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច តែងគប់រកដោយមនោកម្មជាទីគាប់ចិត្តច្រើន ដែលមិនគាប់ចិត្តតិច តែងនាំចូលទៅជិតនូវរបស់ដែលគួរនាំចូលទៅជិត ជាទីគាប់ចិត្តច្រើន

អប្បំ អមនាបំ យានិ ខោ បន តានិ វេទយិតានិ បិត្តសមុដ្ឋានានិ វា សេម្ហសមុដ្ឋានានិ វា វាតសមុដ្ឋានានិ វា សន្និបាតិកានិ វា ឧតុបរិណាមជានិ វា វិសមបរិហារជានិ វា ឱបក្កមិកានិ វា កម្មវិបាកជានិ វា តានិ មេ ន ពហុទេវ ឧប្បជ្ជន្តិ អប្បាពាធោហមស្មិ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា ។បេ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមិ ។ យំ ហិ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ សមណេសុ សមណសុខុមាលោតិ មមេវ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ សមណេសុ សមណសុខុមាលោតិ ។

(៤) បញ្ចិមេ ភិក្ខវេ ផាសុវិហារា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុនោ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច

ដែលមិនគាប់ចិត្តតិច មួយទៀត ជម្ងឺដែលកើតអំពីប្រមាត់ក្តី កើតអំពីស្លេស្មក្តី កើតអំពីខ្យល់ក្តី កើតអំពីធាតុដែលប្រជុំគ្នាក្តី កើតអំពីរដូវប្រែប្រួលក្តី កើតអំពីរក្សាឥរិយាបថមិនស្មើក្តី កើតអំពីសេចក្តីព្យាយាម (របស់គេ មានវាយចងជាដើម) ក្តី កើតអំពីផលនៃកម្មក្តី ជម្ងឺទាំងនោះមិនកើតដល់តថាគតច្រើនទេ តថាគតក៏ឈ្មោះថា ជាអ្នកមានអាពាធតិច ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រនូវឈានទាំង ៤ ដែលអាស្រ័យដោយចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ចូលដល់ ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលពោលសរសើរសមណៈណាថា ជាសមណសុខុមាលក្នុងពួកសមណៈដូច្នេះនោះ ម្នាលភិក្ខុទាំងឡាយ គួរគេពោលសរសើរតថាគតថា ជាសមណសុខុមាលក្នុងពួកសមណៈដូច្នេះ ។

[៥] ម្នាលភិក្ខុទាំងឡាយ ការនៅសប្បាយនេះ មាន ៥ យ៉ាង ។ ៥ យ៉ាងតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ តាំងទុកនូវកាយកម្មប្រកបដោយមេត្តាក្នុងសព្រហ្មចារីទាំងឡាយ ក្នុងទីចំពោះមុខនិងទីកំបាំងមុខ ១ ភិក្ខុតាំងទុកនូវវចីកម្មប្រកបដោយមេត្តាក្នុងសព្រហ្មចារីទាំងឡាយ ក្នុងទីចំពោះមុខនិងទីកំបាំងមុខ ១

មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច យានិ តានិ សីលានិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុប្បសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ តថារូបេហិ សីលេហិ សីលសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ តថារូបាយ ទិដ្ឋិយា ទិដ្ឋិសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច ។ ឥមេ ខោ ភិក្ខវេ បញ្ច ផាសុវិហារាតិ ។

(៦) ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សិយា នុ ខោ ភន្តេ ភិក្ខុសង្ឃោ វិហរន្តោ ផាសុំ វិហរេយ្យាតិ ។

ភិក្ខុតាំងទុកនូវមនោកម្មប្រកបដោយមេត្តា ក្នុងសព្រហ្មចារីទាំងឡាយ ក្នុងទីចំពោះមុខនឹងទីកំបាំងមុខ ១ ជាភិក្ខុប្រកបដោយសីលស្មើគ្នា នឹងសព្រហ្មចារីទាំងឡាយ ដោយសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរបស់អ្នកជា ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលដែលតណ្ហានឹងទិដ្ឋិមិនប៉ះពាល់ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ទាំងក្នុងទីចំពោះមុខនឹងទីកំបាំងមុខ ១ ប្រកបដោយសេចក្ដីយល់ស្មើគ្នា នឹងសព្រហ្មចារីទាំងឡាយ ដោយសេចក្ដីយល់ដ៏ប្រសើរ ជាគ្រឿងចេញចាកទុក្ខ នាំជនអ្នកធ្វើតាមសេចក្ដីយល់នោះឲ្យអស់ទុក្ខដោយប្រពៃ បានទាំងក្នុងទីចំពោះមុខនឹងទីកំបាំងមុខ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា ការនៅសប្បាយ ៥ យ៉ាង ។

(៦) សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុគង់ក្នុងទីសមគួរហើយ បានក្រាបទូលសួរព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃគួរនៅសប្បាយបាន ដោយហេតុប៉ុន្មានយ៉ាងហ្ន៎ ។

យតោ ខោ អានន្ទ ភិក្ខុ អត្តនា សីលសម្បន្នោ ហោតិ នោ បរំ អធិសីលេ សម្បវត្តា ឯត្តាវតាបិ ខោ អានន្ទ ភិក្ខុសង្ឃោ វិហរន្តោ ផាសុំ វិហរេយ្យាតិ ។ សិយា បន ភន្តេ អញ្ញោបិ បរិយាយោ យថា ភិក្ខុសង្ឃោ វិហរន្តោ ផាសុំ វិហរេយ្យាតិ ។ សិយា អានន្ទាតិ ភគវា អវោច យតោ ខោ អានន្ទ ភិក្ខុ អត្តនា ច សីលសម្បន្នោ ហោតិ នោ បរំ អធិសីលេ សម្បវត្តា អត្តានុបេក្ខី ច ហោតិ នោ បរានុបេក្ខី ។ ឯត្តាវតាបិ ខោ អានន្ទ ភិក្ខុសង្ឃោ វិហរន្តោ ផាសុំ វិហរេយ្យាតិ ។ សិយា បន ភន្តេ អញ្ញោបិ បរិយាយោ យថា ភិក្ខុសង្ឃោ វិហរន្តោ ផាសុំ វិហរេយ្យាតិ ។ សិយា អានន្ទាតិ ភគវា អវោច យតោ ខោ អានន្ទ ភិក្ខុ អត្តនា ច សីលសម្បន្នោ ហោតិ នោ បរំ អធិសីលេ សម្បវត្តា អត្តានុបេក្ខី ច ហោតិ នោ បរានុបេក្ខី អប្បញ្ញាតោ ច ហោតិ តេន អប្បញ្ញាតកេន នោ បរិតស្សតិ ។

ម្នាលអានន្ទ កាលណាភិក្ខុបរិបូណ៌ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីល ម្នាលអានន្ទ ភិក្ខុសង្ឃដែលគួរនៅសប្បាយដោយហេតុប៉ុណ្ណោះឯង ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃគួរនៅសប្បាយបាន ដោយបរិយាយដទៃទៀត តើមានដែរឬទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ មានដែរ ។ ម្នាលអានន្ទ កាលដែលភិក្ខុបរិបូណ៌ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីលផង ជាអ្នកពិនិត្យតែខ្លួនឯង មិនពិនិត្យភិក្ខុដទៃផង ម្នាលអានន្ទ ភិក្ខុសង្ឃគួរនៅសប្បាយដោយហេតុមានប្រមាណប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃគួរនៅសប្បាយដោយបរិយាយដទៃទៀត មានដែរឬទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ នៅមានទៀត ម្នាលអានន្ទ កាលដែលភិក្ខុបរិបូណ៌ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីលផង ពិនិត្យតែខ្លួនឯង មិនពិនិត្យភិក្ខុដទៃផង ទោះជាអ្នកមិនល្បីឈ្មោះ គឺមានបុណ្យតិច ក៏មិនរន្ធត់ ព្រោះតែខ្លួនមិនល្បីឈ្មោះនោះផង ។

ឯត្តាវតាបិ ខោ អានន្ទ ភិក្ខុសង្ឃោ វិហរន្តោ ផាសុំ វិហរេយ្យាតិ ។ សិយា បន ភន្តេ អញ្ញោបិ បរិយាយោ យថា ភិក្ខុសង្ឃោ វិហរន្តោ ផាសុំ វិហរេយ្យាតិ ។ សិយា អានន្ទាតិ ភគវា អវោច យតោ ខោ អានន្ទ ភិក្ខុ អត្តនា ច សីលសម្បន្នោ ហោតិ នោ បរំ អធិសីលេ សម្បវត្តា អត្តានុបេក្ខី ច ហោតិ នោ បរានុបេក្ខី អប្បញ្ញាតោ ច ហោតិ តេន អប្បញ្ញាតកេន នោ បរិតស្សតិ ចតុន្នញ្ច ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ ឯត្តាវតា ខោ អានន្ទ ភិក្ខុសង្ឃោ វិហរន្តោ ផាសុំ វិហរេយ្យាតិ ។ សិយា បន ភន្តេ អញ្ញោបិ បរិយាយោ យថា ភិក្ខុសង្ឃោ វិហរន្តោ ផាសុំ វិហរេយ្យាតិ ។ សិយា អានន្ទាតិ ភគវា អវោច

ម្នាលអានន្ទ ភិក្ខុសង្ឃគួរនៅសប្បាយដោយហេតុប៉ុណ្ណេះឯង បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃគួរនៅសប្បាយដោយបរិយាយដទៃទៀតមានដែរឬទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ នៅមានទៀត ម្នាលអានន្ទ កាលដែលភិក្ខុបរិបូណ៌ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីលផង ពិនិត្យតែខ្លួនឯង មិនពិនិត្យភិក្ខុដទៃផង ទោះជាអ្នកមិនល្បីឈ្មោះ ក៏មិនរន្ធត់ ព្រោះតែខ្លួនមិនល្បីឈ្មោះនោះផង ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រ នូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ក្រៃលែង ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន ។ ម្នាលអានន្ទ ភិក្ខុសង្ឃគួរនៅសប្បាយ ដោយហេតុប៉ុណ្ណេះឯង ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃគួរនៅសប្បាយដោយបរិយាយដទៃទៀត មានដែរឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទ នៅមានទៀត ។

យតោ ខោ អានន្ទ ភិក្ខុ អត្តនា ច សីលសម្បន្នោ ហោតិ នោ បរំ អធិសីលេ សម្បវត្តា អត្តានុបេក្ខី ច ហោតិ នោ បរានុបេក្ខី អប្បញ្ញាតោ ច ហោតិ តេន អប្បញ្ញាតកេន នោ បរិតស្សតិ ចតុន្នញ្ច ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឯត្តាវតា ខោ អានន្ទ ភិក្ខុសេយ្យោ វិហរន្តោ ផាសុំ វិហរេយ្យ ។ ឥមម្ហា ចាហំ អានន្ទ ផាសុវិហារា អញ្ញោ ផាសុវិហារោ ឧត្តរិតរោ វា បណីតតរោ វា នត្ថីតិ វទាមីតិ ។

(៧) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលសម្បន្នោ ហោតិ សមាធិសម្បន្នោ ហោតិ បញ្ញាសម្បន្នោ ហោតិ

ម្នាលអានន្ទ កាលដែលភិក្ខុអ្នកបរិបូណ៌ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីលផង ពិនិត្យតែខ្លួនឯង មិនពិនិត្យភិក្ខុដទៃផង ទោះជាអ្នកមិនល្បីឈ្មោះ ក៏មិនរន្ធត់ផង ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រ នូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ក្រៃលែង ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្នផង បានដល់ចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងក្នុងបច្ចុប្បន្នផង ។ ម្នាលអានន្ទ ភិក្ខុសង្ឃ គួរនៅសប្បាយ ដោយហេតុប៉ុណ្ណេះឯង ។ ម្នាលអានន្ទ តថាគតពោលថា ធម៌ជាគ្រឿងនៅសប្បាយឯទៀត ជាធម៌លើសលុបជាង ឬថ្លៃថ្លាជាងធម៌ជាគ្រឿងនៅសប្បាយនេះគ្មានទេ ។

(៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកគួរទទួលគ្រឿងបូជា គួរទទួលអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសីល ១ បរិបូណ៌ដោយសមាធិ ១ បរិបូណ៌ដោយបញ្ញា ១

វិមុត្តិសម្បន្នោ ហោតិ វិមុត្តិញាណទស្សនសម្បន្នោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(៨) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន បញ្ញាខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

បរិបូណ៌ដោយវិមុត្តិ ១ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកគួរទទួលគ្រឿងបូជា គួរទទួលអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

(៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកគួរទទួលគ្រឿងបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រកបដោយសីលក្ខន្ធជាអសេក្ខ ១ ប្រកបដោយសមាធិក្ខន្ធជាអសេក្ខ ១ ប្រកបដោយបញ្ញាខន្ធជាអសេក្ខ ១ ប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខ ១ ប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកគួរទទួលគ្រឿងបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

(៩) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ បាតុទ្ធិសោ ហោតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា សន្តុដ្ឋោ ហោតិ ឥតរីតរេន ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ បាតុទ្ធិសោ ហោតីតិ ។

(៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកត្រេចទៅបានគ្រប់ទិសទាំង ៤ ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ ប្រកបដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ ទោះមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ អ្នកស្តាប់ច្រើន ចាំរឿងដែលស្តាប់ហើយ ចាំមិនភ្លេចនូវរឿងដែលស្តាប់ហើយ ពួកធម៌ណា ពីរោះខាងដើម ពីរោះកណ្តាល ពីរោះខាងចុង ប្រកាសព្រហ្មចរិយៈ ព្រមទាំងអត្ថទាំងព្យញ្ជនៈ បរិសុទ្ធពេញលេញអស់ជើង ភិក្ខុនោះបានស្តាប់ធម៌មានសភាពយ៉ាងនោះច្រើន ចាំស្ទាត់រត់មាត់ យល់ច្បាស់ដោយចិត្ត ចាក់ធ្លុះល្អដោយប្រាជ្ញា ១ ជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារតាមមានតាមបាន ១ ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រនូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ក្រៃលែង ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន ១ ជាអ្នកបានដល់ចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះក្ស័យទៅនៃអាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ នេះឯង ទើបឈ្មោះថាជាអ្នកត្រេចទៅបានគ្រប់ទិសទាំង ៤ ។

## តតិយបណ្ណាសកេ ផាសុវិហារវគ្គោ បឋមោ

[១០] បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិតុំ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។បេ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។បេ។ ទិដ្ឋិយា សុប្បដិវិទ្ធា អារទ្ធវីរិយោ វិហរតិ ។បេ។ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិតុន្តិ ។

ផាសុវិហារវគ្គោ បឋមោ ។

តតិយបណ្ណាសក ផាសុវិហារវគ្គ ទី ១

[១០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបគួរអាស្រ័យសេនាសនៈ ស្ងាត់ ជាព្រៃដែលមិនមែនជាទីឧបចារៈ របស់មនុស្ស ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ។បេ។ ចាក់ធ្លុះល្អដោយប្រាជ្ញា ១ ជាអ្នកប្រារព្ធព្យាយាម ។បេ។ មានកំឡាំងប្រឹងប្រែងយ៉ាងខ្លាំង មិនបោះបង់ធុរៈក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រ នូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ១ ជាអ្នកបានចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះក្ស័យទៅនៃអាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរអាស្រ័យសេនាសនៈស្ងាត់ ជាព្រៃដែលមិនមែនជាទីឧបចារៈរបស់មនុស្ស ។

ចប់ ផាសុវិហារវគ្គ ទី ១ ។

## តស្សុទ្ទានំ

សារជ្ជំ សង្កិតោ ចោរោ

សុខុមាលផាសុបញ្ចម

អានន្ទសីលសេខិយា

ចាតុទ្ទិសោ អរញ្ញេន ចាតិ ។

## ឧទ្ទាននៃផាសុវិហារវគ្គ នោះគឺ

ធម៌ធ្វើឲ្យរៀនអន់ ១ ភិក្ខុដែលគេរង្កៀស ១ ចោរ ១ សមណសុខុមាល ១ ជាគំរប់ ៥ នឹងភិក្ខុនៅសប្បាយ ព្រះអានន្ទ ១ ភិក្ខុប្រកបដោយសីលជាដើម ១ ភិក្ខុប្រកបដោយសីលជាសេក្ខៈជាដើម ១ ភិក្ខុត្រេចទៅបានក្នុងទិសទាំងបួន ១ ភិក្ខុនៅក្នុងព្រៃ ១ ។

## អន្ធកវិន្ទវគ្គោ ទុតិយោ

(១១) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ កុលុបកោ ភិក្ខុ កុលេសុ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ អសន្ថវវិញ្ញាបី ច ហោតិ អនិស្សរវិកប្បី ច វ្យត្តុបសេវី[១] ច ឧបកណ្ណកជប្បី ច អតិយាចនកោ ច ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ កុលុបកោ ភិក្ខុ កុលេសុ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ កុលុបកោ ភិក្ខុ កុលេសុ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ ន អសន្ថវវិញ្ញាបី ច ហោតិ ន អនិស្សរវិកប្បី ច ន វ្យត្តុបសេវី ច ន ឧបកណ្ណកជប្បី ច ន អតិយាចនកោ ច ។

---

១ ឱ. វ្យត្តូបសេវី ច ។ ម. វិសដ្ឋូបសេវី ច ។

## អន្ធកវិន្ទវគ្គ ទី ២

(១១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចូលទៅកាន់ត្រកូល ប្រកបដោយធម៌ ៥ យ៉ាង ត្រកូលទាំងឡាយ រមែងមិនស្រឡាញ់ផង មិនពេញចិត្តផង មិនគោរពផង មិនសរសើរផង ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ គឺជាអ្នកស្និទ្ធស្នាលចំពោះត្រកូល ដែលមិនមានសេចក្តីរាប់អានខ្លួន ១ ខ្លួនមិនមែនជាឥស្សរៈ តែលើកខ្លួនជាឥស្សរៈ ១ ជាអ្នកចូលទៅរាប់រកដើម្បីផ្សះផ្សាត្រកូលដែលបែកបាក់គ្នា ១ ជាអ្នកប្រឹងខ្សឹបជិតត្រចៀកអ្នកឯទៀត ១ ជាអ្នកសូមគេបៃ ៗ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចូលទៅកាន់ត្រកូល ប្រកបដោយធម៌ ៥ យ៉ាង នេះឯង ត្រកូលទាំងឡាយ រមែងមិនស្រឡាញ់ផង មិនពេញចិត្តផង មិនគោរពផង មិនសរសើរផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចូលទៅកាន់ត្រកូល ដែលប្រកបដោយធម៌ ៥ យ៉ាង ត្រកូលទាំងឡាយ រមែងស្រឡាញ់ផង ពេញចិត្តផង គោរពផង សរសើរផង ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនស្និទ្ធស្នាលចំពោះត្រកូល ដែលមិនមានសេចក្តីរាប់អានខ្លួន ១ ខ្លួនមិនមែនជាឥស្សរៈក៏មិនលើកខ្លួនជាឥស្សរៈ ១ ជាអ្នកមិនចូលទៅរាប់រកដើម្បីផ្សះផ្សាត្រកូលដែលបែកបាក់គ្នា ១ ជាអ្នកមិនខ្សឹបជិតត្រចៀកអ្នកឯទៀត ១ ជាអ្នកមិនសូមគេបៃ ៗ ១ ។

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ កុលូបកោ ភិក្ខុ កុលេសុ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ចាតិ ។

(១២) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បច្ឆាសមណោ ន អាទាតព្វោ ។ កតមេហិ បញ្ចហិ ។ អតិទូរេ វា គច្ឆតិ អច្ចាសន្នេ វា បត្តបរិយាបន្នំ ន គណ្ហាតិ អាបត្តិសាមន្តា ភណមានំ ន និវារេតិ ភណមានស្ស អន្តរន្តរា កថំ ឱបាតេតិ ទុប្បញ្ញោ ហោតិ ជឡោ ឯឡមូគោ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ បច្ឆាសមណោ ន អាទាតព្វោ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បច្ឆាសមណោ អាទាតព្វោ ។ កតមេហិ បញ្ចហិ ។ នាតិទូរេ គច្ឆតិ នាច្ចាសន្នេ បត្តបរិយាបន្នំ គណ្ហាតិ អាបត្តិសាមន្តា ភណមានំ និវារេតិ ភណមានស្ស ន អន្តរន្តរា កថំ ឱបាតេតិ បញ្ញវា ហោតិ អជឡោ អនេឡមូគោ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ បច្ឆាសមណោ អាទាតព្វោតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចូលទៅកាន់ត្រកូល ដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង ត្រកូលទាំងឡាយ រមែងស្រឡាញ់ផង ពេញចិត្តផង គោរពផង សរសើរផង ។

(១២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនគួរយកជាបច្ឆាសមណៈឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុដើរឆ្ងាយពេកឬជិតពេក ១ មិនទទួលយកបាត្រឬវត្តដែលនៅក្នុងបាត្រ ១ មិនហាមឃាត់ព្រះថេរៈដែលនិយាយជិតត្រូវអាបត្តិ ១ កាលព្រះថេរៈកំពុងនិយាយ ក៏និយាយពាក្យ កាត់ត្រង់ចន្លោះៗ ១ ជាអ្នកអ័ប្បឥតប្រាជ្ញា ល្ងង់ ខ្លៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរយកជាបច្ឆាសមណៈឡើយ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរយកជាបច្ឆាសមណៈបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុមិនដើរឆ្ងាយពេក មិនជិតពេក ១ ទទួលយកបាត្រ ឬ វត្តដែលនៅក្នុងបាត្រ ១ ហាមឃាត់ព្រះថេរៈដែលនិយាយជិតត្រូវអាបត្តិ ១ កាលព្រះថេរៈកំពុងនិយាយ មិននិយាយពាក្យ កាត់ត្រង់ចន្លោះៗ ១ ជាអ្នកមានប្រាជ្ញា មិនល្ងង់ មិនខ្លៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរយកជាបច្ឆាសមណៈបាន ។

(១៣) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ សម្មាសមាធឹ ឧបសម្បជ្ជ វិហរិតុំ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ រូបានំ អក្ខមោ សទ្ទានំ អក្ខមោ គន្ធានំ អក្ខមោ រសានំ អក្ខមោ ផោដ្ឋព្វានំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ សម្មាសមាធឹ ឧបសម្បជ្ជ វិហរិតុំ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ សម្មាសមាធឹ ឧបសម្បជ្ជ វិហរិតុំ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ ខមោ ហោតិ រូបានំ ខមោ សទ្ទានំ ខមោ គន្ធានំ ខមោ រសានំ ខមោ ផោដ្ឋព្វានំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ សម្មាសមាធឹ ឧបសម្បជ្ជ វិហរិតុន្តិ ។

(១៤) ឯកំ សមយំ ភគវា មគធេសុ វិហារតិ អន្ធកវិន្ទេ ។ អថខោ អាយស្មា អានន្ទោ

(១៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនគួរនឹងចូលកាន់សម្មាសមាធិបានឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរនឹងចូលកាន់សម្មាសមាធិបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរនឹងចូលកាន់សម្មាសមាធិបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរចូលកាន់សម្មាសមាធិបាន ។

(១៤) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងអន្ធកវិន្ទគ្រាមក្នុងដែនមគធៈ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច យេ តេ អានន្ទ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេ វោ អានន្ទ ភិក្ខូ បញ្ចសុ ធម្មេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ។ កតមេសុ បញ្ចសុ ។ ឯថ តុម្ហេ អាវុសោ សីលវា ហោថ បាតិមោក្ខសំវរសំវុតា វិហរថ អាចារគោចរសម្បន្នា អណុមត្តេសុ វជ្ជេសុ ភយទស្សាវិនោ សមាទាយ សិក្ខថ សិក្ខាបទេសូតិ ឥតិ បាតិមោក្ខសំវរេ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ឯថ តុម្ហេ អាវុសោ ឥន្ទ្រិយេសុ គុត្តទ្វារា វិហរថ អារក្ខសតិនោ និបកសតិនោ សារក្ខិតមានសា សតារក្ខេន ចេតសា សមន្នាគតាតិ ឥតិ ឥន្ទ្រិយសំវរេ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា

ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ភិក្ខុទាំងឡាយណា ទើបតែនឹងបួសថ្មី មកកាន់ធម្មវិន័យនេះ ក្នុងកាលឥឡូវនេះ ម្នាលអានន្ទ ភិក្ខុទាំងនោះ ត្រូវអ្នកពលគ្នាឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ក្នុងធម៌ ៥ យ៉ាង ។ ក្នុងធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងបាតិមោក្ខសំវរសីល ដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរមក ចូរជាអ្នកមានសីល សង្រួម ក្នុងបាតិមោក្ខសំវរៈបរិបូណ៌ដោយអាចារៈនឹងគោចរៈ ឃើញនូវភ័យក្នុងទោសបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយដូច្នេះ ១ ឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងឥន្ទ្រិយសំវរៈដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ តាំងស្មារតីរក្សា (ទ្វារ) តាំងស្មារតីប្រកបដោយញាណ ជាអ្នកមានចិត្តរក្សាស្មារតី ប្រកបដោយចិត្តរក្សាស្មារតីដូច្នេះ ១

ឯថ តុម្ហេ អាវុសោ អប្បភស្សា ហោថ ភស្សបរិយន្តការិនោតិ ឥតិ ភស្សបរិយន្តេ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ឯថ តុម្ហេ អាវុសោ អារញ្ញកា ហោថ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវថាតិ ឥតិ កាយវូបកាសេ[១] សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ឯថ តុម្ហេ អាវុសោ សម្មាទិដ្ឋិកា ហោថ សម្មាទស្សនេន សមន្នាគតាតិ ឥតិ សម្មាទស្សនេ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ។ យេ តេ អានន្ទ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេ វោ អានន្ទ ភិក្ខូ ឥមេសុ បញ្ចសុ ធម្មេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វាតិ ។

(១៥) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អាវាសមច្ឆរិនី ហោតិ កុលមច្ឆរិនី ហោតិ លាភមច្ឆរិនី ហោតិ វណ្ណមច្ឆរិនី ហោតិ ធម្មមច្ឆរិនី ហោតិ ។

---

១ ឱ កាយវូបកដ្ឋេ ។

ឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងពាក្យសំដី ឲ្យមានទីបំផុត ដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរជាអ្នកមានពាក្យសំដីតិច ធ្វើពាក្យសំដីឲ្យមានទីបំផុតដូច្នេះ ១ ឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងសេចក្ដីស្ងប់កាយ ដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរជាអ្នក នៅក្នុងព្រៃជាវត្ត គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃតូចព្រៃធំដូច្នេះ១ ឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងការយល់ឃើញត្រូវ ដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរជាអ្នកយល់ត្រូវ ប្រកបដោយការយល់ឃើញត្រូវដូច្នេះ ១ ។ ម្នាលអានន្ទ ភិក្ខុទាំងឡាយណា ទើបនឹងបួសថ្មី មកកាន់ធម្មវិន័យនេះ ក្នុងកាលឥឡូវនេះ ម្នាលអានន្ទ ភិក្ខុទាំងនោះ ត្រូវអ្នកពល់គ្នា ឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងធម៌ទាំង ៥ នេះឯង ។

(១៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺភិក្ខុនីកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ និរយេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ ន អាវាសមច្ឆរិនី ហោតិ ន កុលមច្ឆរិនី ហោតិ ន លាភមច្ឆរិនី ហោតិ ន វណ្ណមច្ឆរិនី ហោតិ ន ធម្មមច្ឆរិនី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ សគ្គេតិ ។

(១៦) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា អប្បសា-ទនីយេ ឋានេ បសាទំ ឧបទំសេតិ អននុវិច្ច អបរិយោគា-ហេត្វា បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ សទ្ធាទេយ្យំ វិនិបាតេតិ ។ ឥមេហិ ខោ ។បេ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាង ទឹងទៅកើតក្នុងស្ថានសួគ៌ដូចជាគេនាំយកទៅដំកល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនីមិនកំណាញ់អាវាស ១ មិនកំណាញ់ត្រកូល ១ មិនកំណាញ់លាភ ១ មិនកំណាញ់គុណ ១ មិនកំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌៥ យ៉ាងនេះឯង ទឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដំកល់ទុក ។

[១៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាង ទឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនីមិនពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរ បុគ្គលដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយតិះដៀល បុគ្គលដែលគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសំដែងនូវសេចក្តីជ្រះថ្លាក្នុងទីដែលមិនគួរជ្រះថ្លា ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសំដែងនូវសេចក្តីមិនជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។

បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា អប្បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ អនុវិច្ច បរិយោគាហេត្វា បសាទនីយេ ឋានេ បសាទំ ឧបទំសេតិ សទ្ធាទេយ្យំ ន វិនិបាតេតិ ។ ឥមេហិ ខោ ។ បេ ។

(១៧) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ ឥស្សុកិនី ច ហោតិ មច្ឆរិនី ច សទ្ធាទេយ្យញ្ច វិនិបាតេតិ ។ ឥមេហិ ខោ ។ បេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបព្រមដោយធម៌ ៥ យ៉ាង ទឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេ នាំយកទៅដំកល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី បានពិចារណា ស្ទាបស្ទង់មើលរួច ទើបតិះដៀល បុគ្គលដែលគួរតិះដៀល ១ បានពិចារណា ស្ទាបស្ទង់មើលរួច ទើបសរសើរ បុគ្គលដែលគួរសរសើរ ១ បានពិចារណា ស្ទាបស្ទង់មើលរួច ទើបសំដែងនូវសេចក្តីមិនជ្រះថ្លាក្នុងទី ដែលមិនគួរជ្រះថ្លា ១ បានពិចារណា ស្ទាបស្ទង់មើលរួច ទើបសំដែងនូវសេចក្តីជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។

(១៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ប្រកបដោយធម៌ ៥ យ៉ាង ទឹងធ្លាក់ទៅក្នុងនរក ដូចជាគេ នាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរ បុគ្គលដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយតិះដៀល បុគ្គលដែលគួរសរសើរ ១ ជាអ្នកច្រណែន ១ កំណាញ់ ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ប្រកបដោយធម៌ ៥ យ៉ាង ទឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេ នាំយកទៅដំកល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។

អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសតិ អនិស្សុកិនី ច ហោតិ អមច្ឆរិនី ច សទ្ធាទេយ្យញ្ច ន វិនិបាតេតិ ។ ឥមេហិ ខោ ។បេ ។

(១៨) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ មិច្ឆាទិដ្ឋិកា ច ហោតិ មិច្ឆាសង្កប្បា ច សទ្ធាទេយ្យញ្ច វិនិបាតេតិ ។ ឥមេហិ ខោ ។បេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសតិ សម្មាទិដ្ឋិកា ច ហោតិ សម្មាសង្កប្បា ច សទ្ធាទេយ្យញ្ច ន វិនិបាតេតិ ។ ឥមេហិ ខោ ។បេ ។

គឺភិក្ខុនី បានពិចារណា ស្ទាបស្ទង់មើលរួច ទើបតិះដៀល បុគ្គលដែលគួរតិះដៀល ១ បានពិចារណាស្ទាបស្ទង់មើលរួច ទើបសរសើរ បុគ្គលដែលគួរសរសើរ ១ ជាអ្នកមិនច្រណែន ១ មិនកំណាញ់ ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។

(១៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ប្រកបដោយធម៌ ៥ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេ នាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរ បុគ្គលដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយតិះដៀល បុគ្គលដែលគួរសរសើរ ១ ជាអ្នកមានសេចក្តីយល់ខុស ១ មានសេចក្តីត្រិះរិះខុស ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ប្រកបដោយធម៌ ៥ យ៉ាងនឹងទៅកើតក្នុងឋានសួគ៌ ដូចជាគេ នាំយកទៅដំកល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី បានពិចារណា ស្ទាបស្ទង់មើលរួច ទើបតិះដៀល បុគ្គលដែលគួរតិះដៀល ១ បានពិចារណាស្ទាបស្ទង់មើលរួច ទើបសរសើរ បុគ្គលដែលគួរសរសើរ ១ ជាអ្នកមានសេចក្តីយល់ឃើញត្រូវ ១ មានសេចក្តីត្រិះរិះត្រូវ ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។

តតិយបណ្ណាសកេ អន្ធកវិន្ទវគ្គោ ទុតិយោ

(១៩) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ មិច្ឆាទិដ្ឋិកា ច ហោតិ មិច្ឆាសង្កប្បា ច សទ្ធាទេយ្យញ្ច វិនិបាតេតិ ។ ឥមេហិ ខោ ។បេ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសតិ សម្មាទិដ្ឋិកា ច ហោតិ សម្មាសង្កប្បា ច សទ្ធាទេយ្យញ្ច ន វិនិបាតេតិ ។ ឥមេហិ ខោ ។បេ។

(១៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ប្រកបដោយធម៌ ៥ យ៉ាងនេះ ធ្លាក់ទៅក្នុងនរក ដូចជាគេ នាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរ បុគ្គលដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយតិះដៀល បុគ្គលដែលគួរសរសើរ ១ ជាអ្នកមានវាចាខុស ១ មានការងារខុស ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ប្រកបដោយធម៌ ៥ យ៉ាងនេះ ទៅកើតក្នុងស្ថានសួគ៌ ដូចជាគេ នាំយកទៅដាក់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី បានពិចារណា ស្ទាបស្ទង់មើលរួច ទើបតិះដៀល បុគ្គលដែលគួរតិះដៀល ១ បានពិចារណា ស្ទាបស្ទង់មើលរួច ទើបសរសើរ បុគ្គលដែលគួរសរសើរ ១ មានវាចាត្រូវ ១ មានការងារត្រូវ ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។

(៤០) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ មិច្ឆាវាយាមា ច ហោតិ មិច្ឆាសតិ ច សទ្ធាទេយ្យញ្ច វិនិបាតេតិ ។ ឥមេហិ ខោ ។បេ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី យថាភតំ និក្ខិត្តា ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសតិ សម្មាវាយាមា ច ហោតិ សម្មាសតិ ច សទ្ធាទេយ្យញ្ច ន វិនិបាតេតិ ។ ឥមេហិ ខោ ។បេ។

អន្ធកវិន្ទវគ្គោ ទុតិយោ ។

(២០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ប្រកបដោយធម៌ ៥ យ៉ាង ទំនងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរ បុគ្គលដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយតិះដៀល បុគ្គលដែលគួរសរសើរ ១ មានព្យាយាមខុស ១ មានសតិខុស ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ប្រកបដោយធម៌ ៥ យ៉ាង ទំនងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដំកល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី បានពិចារណាស្ទាបស្ទង់មើលរួច ទើបតិះដៀល បុគ្គលដែលគួរតិះដៀល ១ បានពិចារណាស្ទាបស្ទង់មើលរួច ទើបសរសើរ បុគ្គលដែលគួរសរសើរ ១ មានព្យាយាមត្រូវ ១ មានសតិត្រូវ ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។ បេ ។

ចប់ អន្ធកវិន្ទវគ្គ ទី ២ ។

តតិយបណ្ណាសកេ រត្នកវិន្ទវគ្គោ ទុតិយោ

## តស្សុទ្ធានំ

កុលុបកោ បញ្ញាសមណោ
សមាធិ អក្ខករិទ្ធិ
មច្ឆរី វណ្ណនា ឥស្សា
ទិដ្ឋិ ភតាយ ភយមោតិ ។

## ឧទ្ទាននៃអន្ធកវិន្ទវគ្គនោះគឺ

និយាយអំពីភិក្ខុ ចូលទៅកាន់ត្រកូល ១ អំពីភិក្ខុជាបច្ឆាសមណៈ១ អំពីភិក្ខុ មិនគួរចូលកាន់សម្មាសមាធិ ១ អំពីព្រះដ៏មានព្រះភាគគង់ក្នុងអន្ធកវិន្ទគ្រាម ១ អំពីសេចក្តីកំណាញ់ ១ អំពីសេចក្តីសរសើរ ១ អំពីភិក្ខុនី មានសេចក្តីច្រណែន ១ អំពីសេចក្តីយល់ខុស ១ អំពីវាចា ១ អំពីព្យាយាម ១ ។

# គិលានវគ្គោ តតិយោ

(២១) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន គិលានសាលា តេនុបសង្កមិ ។ អទ្ទសា ខោ ភគវា អញ្ញតរំ ភិក្ខុំ ទុព្វលំ គិលានកំ ទិស្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ យង្កិញ្ចិ ភិក្ខវេ ទុព្វលំ គិលានកំ បញ្ច ធម្មា ន វិជហន្តិ តស្សេតំ បាដិកង្ខំ នចិរស្សេវ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ អសុភានុបស្សី កាយេ វិហរតិ អាហារេ បដិកូលសញ្ញី សព្វលោកេ អនភិរតសញ្ញី សព្វសង្ខារេសុ អនិច្ចានុបស្សី មរណសញ្ញា ខោ បនស្ស អជ្ឈត្តំ សុបដ្ឋិតា ហោតិ ។

# គិលានវគ្គ ទី៣

(២១) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងកូដាគារសាលា នាមហាវនជិតក្រុងវេសាលី ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ចូលទៅ ឯគិលានសាលា (មន្ទីរព្យាបាលជម្ងឺ) ។ ព្រះអង្គបានឃើញភិក្ខុ ១ រូប មានជម្ងឺកម្លាំងថយ លុះឃើញហើយក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់ស៊ប់ហើយ ទើបត្រាស់ទៅ នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ (បើ) ធម៌ ៥ យ៉ាង មិនលះបង់នូវបុគ្គលណាមួយ ដែលមានជម្ងឺកំឡាំងថយទេ គុណវិសេសនុ៎ះ នឹងកើតប្រាកដដល់បុគ្គលនោះ គឺបុគ្គលនោះ មិនយូរប៉ុន្មាន នឹងធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយ ៗ ក្នុងកាយថា មិនស្អាត ១ ជាអ្នកសំគាល់ក្នុងអាហារថា ជារបស់បដិកូល ១ ជាអ្នកសំគាល់ក្នុងលោកទាំងអស់ថាជាសភាពមិនគួរត្រេកអរ ១ ជាអ្នកពិចារណាឃើញរឿយ ៗ ក្នុងសង្ខារទាំងពួងថា មិនទៀង ១ ទាំងមរណសញ្ញារបស់បុគ្គលនោះ ក៏តាំងនៅស៊ប់ក្នុងសន្តាន ១ ។

យង្កញ្ចិ ភិក្ខវេ ទុព្វលំ គិលានកំ ឥមេ បញ្ច ធម្មា ន វិជហន្តិ តស្សេតំ បាដិកង្ខំ នចិរស្សេវ អាសវានំ ខយា ។បេ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតីតិ ។

[២២] យោ ហិ កោចិ ភិក្ខវេ ភិក្ខុ វា ភិក្ខុនី វា បញ្ច ធម្មេ ភាវេតិ បញ្ច ធម្មេ ពហុលីករោតិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុនោ អជ្ឈត្តញ្ញេវ សតិ ឧបដ្ឋិតា(១) ហោតិ ធម្មានំ ឧទយត្ថគាមិនិយា បញ្ញាយ អសុភានុបស្សី កាយេ វិហរតិ អាហារេ បដិក្កូលសញ្ញី សព្វលោកេ អនភិរតសញ្ញី សព្វ-សង្ខារេសុ អនិច្ចានុបស្សី ។ យោ ហិ កោចិ ភិក្ខវេ

---

១ ឱ. ម. សតិ សូបដ្ឋិតា ។

ម្នាលភិក្ខុទាំងឡាយ (បើ) ធម៌ទាំង ៥ យ៉ាងនេះ មិនលះបង់បុគ្គលណាមួយ ដែលមានជម្ងឺកម្លាំងជាបទេ គុណវិសេសនុ៎ះ នឹងកើតប្រាកដដល់បុគ្គលនោះ គឺបុគ្គលនោះ មិនយូរប៉ុន្មាន នឹងធ្វើឲ្យជាក់ច្បាស់សម្រេច ។បេ។ ព្រោះអស់អាសវៈ ។

(២២) ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី បំរើនូវធម៌ ៥ យ៉ាង ធ្វើឲ្យច្រើននូវធម៌ ៥ យ៉ាង បណ្តាផលទាំង ២ ប្រការ ផលណាមួយនឹងកើតប្រាកដដល់បុគ្គលនោះ គឺជានឹងបានអរហត្តផល ឬកាលបើ ឧបាទាននៅមានសល់ ក៏គង់នឹងបាននូវភាពជាអនាគាមិបុគ្គល ក្នុងបច្ចុប្បន្ន ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានដំកល់ស្មារតី ក្នុងសន្តាន ១ ជាអ្នកពិចារណាឃើញរឿយ ៗ ក្នុងកាយថា មិនស្អាត ដោយបញ្ញាជាគ្រឿងកំណត់ដឹងនូវការកើត នឹងការរលត់នៃធម៌ទាំងឡាយ ១ ជាអ្នកសំគាល់ក្នុងអាហារថា ជារបស់បដិកូល ១ ជាអ្នកសំគាល់ ក្នុងលោកទាំងអស់ថា មិនគួរត្រេកអរ ១ ជាអ្នកសំគាល់ ក្នុងសង្ខារទាំងពួងថា មិនទៀង ១ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ

ភិក្ខុ វា ភិក្ខុនី វា ឥមេ បញ្ច ធម្មេ ភាវេតិ ឥមេ បញ្ច ធម្មេ ពហុលីករោតិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។

(២៣) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ គិលានោ ទុបដ្ឋាកោ ហោតិ ។ កតមេហិ បញ្ចហិ ។ អសប្បាយការី ហោតិ សប្បាយេ មត្តំ ន ជានាតិ ភេសជ្ជំ ន បដិសេវិតា ហោតិ អត្ថកាមស្ស គិលានុ-បដ្ឋាកស្ស ន យថាភូតំ អាពាធំ អាវិកត្តា ហោតិ អភិក្កមន្តំ វា អភិក្កមតីតិ បដិក្កមន្តំ វា បដិក្កមតីតិ ឋិតំ វា ឋិតោតិ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អនធិវាសកជាតិកោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ គិលានោ ទុបដ្ឋាកោ ហោតិ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ គិលានោ សុបដ្ឋាកោ ហោតិ ។

ទោះភិក្ខុក្តី ភិក្ខុនីក្តី ចំរើននូវធម៌ ៥ យ៉ាងនេះ ធ្វើឲ្យច្រើននូវធម៌ ៥ យ៉ាងនេះ បណ្តាផលទាំង ២ ប្រការ ផលណាមួយនឹងកើតប្រាកដដល់បុគ្គលនោះ គឺនឹងបានអរហត្តផល ឬកាលបើឧបាទានទៅមានសល់ ក៏គង់នឹងបាននូវភាពជាអនាគាមិបុគ្គល ក្នុងបច្ចុប្បន្ន ។

(២៣) ម្នាលភិក្ខុទាំងឡាយ អ្នកជម្ងឺប្រកបដោយធម៌ ៥ យ៉ាង ជាបុគ្គលលំបាកបម្រើ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនចេះធ្វើខ្លួនឲ្យសប្បាយ ១ មិនដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកមិនកនថ្នាំ ១ មិនប្រាប់ជម្ងឺតាមពិត ដល់អ្នកបម្រើជម្ងឺដែលប្រាថ្នានូវសេចក្តីចំរើន ឬជម្ងឺដែលចំរើនឡើងមិនប្រាប់ថាចំរើនឡើង ឬជម្ងឺដែលធូរថយ មិនប្រាប់ថាធូរថយ ឬក៏ជម្ងឺដែលនៅនឹង មិនប្រាប់ថានៅនឹង ១ ជាអ្នកមិនចេះអត់ធន់ចំពោះវេទនាប្រជុំក្នុងសរីរៈ ជាទុក្ខ ដ៏ក្លា ខ្លាំង ខ្លោចផ្សា មិនស្រួល មិនជាទីពេញចិត្ត ជាវេទនា អាចនាំយកជីវិតបានដែលកើតហើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកជម្ងឺប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាបុគ្គលលំបាកបម្រើ ។ ម្នាលភិក្ខុទាំងឡាយ អ្នកជម្ងឺប្រកបដោយធម៌ ៥ យ៉ាង ជាបុគ្គលងាយបម្រើ ។

កតមេហិ បញ្ចហិ ។ សប្បាយការី ហោតិ សប្បាយេ មត្តំ ជានាតិ ភេសជ្ជំ បដិសេវិតា ហោតិ អត្ថកាមស្ស គិលានុបដ្ឋាកស្ស យថាភូតំ អាពាធំ អាវិកត្តា ហោតិ អភិក្កមន្តំ វា អភិក្កមតីតិ បដិក្កមន្តំ វា បដិក្កមតីតិ ឋិតំ វា ឋិតោតិ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសកជា-តិកោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ គិលានោ សុបដ្ឋាកោ ហោតីតិ ។

(២៤) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ គិលានុបដ្ឋាកោ នាលំ គិលានំ ឧបដ្ឋាតុំ ។ កតមេហិ បញ្ចហិ ។ ន បដិពលោ ហោតិ ភេសជ្ជំ សំវិធាតុំ សប្បាយាសប្បាយំ ន ជានាតិ អសប្បាយំ ឧបនាមេតិ សប្បាយំ អបនាមេតិ អាមិសន្តរោ គិលានំ ឧបដ្ឋាតិ នោ មេត្តចិត្តោ

ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺជាអ្នកចេះធ្វើខ្លួនឲ្យសប្បាយ ១ ដឹងប្រមាណ ក្នុងការសប្បាយ ១ ជាអ្នកកាន់ថ្នាំ ១ ប្រាប់ជម្ងឺតាមពិត ដល់អ្នកបម្រើជម្ងឺ ដែលប្រាថ្នានូវសេចក្តីចំរើន ឬជម្ងឺដែលចំរើនឡើង ប្រាប់ថា ចំរើនឡើង ឬជម្ងឺធូរថយប្រាប់ថា ធូរថយ ឬក៏ជម្ងឺនៅទឹង ប្រាប់ថានៅទឹង ១ ជាអ្នកអត់ធន់ចំពោះវេទនាដែលប្រជុំក្នុងសរីរៈ ជាទុក្ខ ដ៏ក្លា ខ្លាំង ខ្លោចផ្សា មិនស្រួល មិនជាទីពេញចិត្ត ជាវេទនា អាចនាំយកនូវជីវិតបានដែលកើតហើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកជម្ងឺ ប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាបុគ្គលងាយបម្រើ ។

(២៤) ម្នាលភិក្ខុទាំងឡាយ អ្នកបម្រើជម្ងឺប្រកបដោយធម៌ ៥ យ៉ាង មិនគួរនឹងបម្រើជម្ងឺទេ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនប្រសប់តាក់តែងថ្នាំ ១ មិនស្គាល់នូវការសប្បាយនឹងមិនសប្បាយ ១ ធ្វើអ្នកជម្ងឺឲ្យឈមទៅរកការមិនសប្បាយ ទាំងមិននាំសេចក្តីសប្បាយចូលមក ១ បម្រើជម្ងឺដោយចង់បានអាមិស មិនបម្រើដោយមេត្តចិត្ត

ជេគុច្ឆី ហោតិ ឧច្ចារំ វា បស្សាវំ វា វន្តំ វា ខេឡំ វា នីហរិតុំ ន បដិពលោ ហោតិ គិលានំ កាលេន កាលំ ធម្មិយា កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ គិលានុបដ្ឋាកោ នាលំ គិលានំ ឧបដ្ឋាតុំ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ គិលានុបដ្ឋាកោ អលំ គិលានំ ឧបដ្ឋាតុំ ។ កតមេហិ បញ្ចហិ ។ បដិពលោ ហោតិ ភេសជ្ជំ សំវិធាតុំ សប្បាយាសប្បាយំ ជានាតិ អសប្បាយំ អបនាមេតិ សប្បាយំ ឧបនាមេតិ មេត្តចិត្តោ គិលានំ ឧបដ្ឋាតិ នោ អាមិសន្តរោ អជេគុច្ឆី ហោតិ ឧច្ចារំ វា បស្សាវំ វា វន្តំ វា ខេឡំ វា នីហរិតុំ បដិពលោ ហោតិ គិលានំ កាលេន កាលំ ធម្មិយា កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ គិលានុបដ្ឋាកោ អលំ គិលានំ ឧបដ្ឋាតុន្តិ ។

ជាអ្នកខ្ពើមចំពោះការនាំយកឧច្ចារៈបស្សាវៈ កំអួត ឬទឹកមាត់ទៅចោល ១ ជាអ្នកមិនប្រសប់ធ្វើអ្នកជម្ងឺឲ្យយល់ឃើញ ឲ្យកាន់យក ឲ្យក្លៀវក្លា ឲ្យរីករាយ ដោយធម្មីកថាតាមកាលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកបម្រើជម្ងឺប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរនឹងបម្រើជម្ងឺបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកបម្រើជម្ងឺប្រកបដោយធម៌ ៥ យ៉ាង ទើបគួរនឹងបម្រើជម្ងឺបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកប្រសប់ចាត់ចែងថ្នាំ ១ ស្គាល់នូវការសប្បាយនឹងមិនសប្បាយ ១ នាំចេញនូវសេចក្តីមិនសប្បាយធ្វើអ្នកជម្ងឺឲ្យឈមទៅរកការសប្បាយ ១ បម្រើជម្ងឺដោយមេត្តចិត្ត មិនបម្រើដោយចង់បានអាមិស ទាំងមិនខ្ពើមចំពោះការនាំយកឧច្ចារៈបស្សាវៈ កំអួត ឬទឹកមាត់ទៅចោល ១ ជាអ្នកប្រសប់ធ្វើអ្នកជម្ងឺឲ្យយល់ឃើញ ឲ្យកាន់យក ឲ្យក្លៀវក្លា ឲ្យរីករាយ ដោយធម្មីកថាតាមកាលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកបម្រើជម្ងឺប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរនឹងបម្រើជម្ងឺបាន ។

[២៥] បញ្ចិមេ ភិក្ខវេ ធម្មា អនាយុស្សា ។ កតមេ បញ្ច ។ អសប្បាយការី ហោតិ សប្បាយេ មត្តំ ន ជានាតិ អបរិណតភោជី ច ហោតិ អកាលចារី ច អព្រហ្មចារី ច ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា អនាយុស្សា ។ បញ្ចិមេ ភិក្ខវេ ធម្មា អាយុស្សា ។ កតមេ បញ្ច ។ សប្បាយការី ហោតិ សប្បាយេ មត្តំ ជានាតិ បរិណតភោជី ច ហោតិ កាលចារី ច ព្រហ្មចារី ច ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា អាយុស្សាតិ ។

[២៦] បញ្ចិមេ ភិក្ខវេ ធម្មា អនាយុស្សា ។ កតមេ បញ្ច ។ អសប្បាយការី ហោតិ សប្បាយេ មត្តំ ន ជានាតិ អបរិណតភោជី ច ហោតិ ទុស្សីលោ ច បាបមិត្តោ ច ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា អនាយុស្សា ។ បញ្ចិមេ ភិក្ខវេ ធម្មា អាយុស្សា ។

(២៥) ម្នាលភិក្ខុទាំងឡាយ អនាយុស្សធម៌ (ធម៌ធ្វើឲ្យអាយុថយ) នេះមាន ៥ យ៉ាង ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនបេះធ្វើខ្លួនឲ្យសប្បាយ ១ មិនដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកបរិភោគអាហារមិនរលួយ ១ ជាអ្នកត្រេចទៅមិនត្រូវតាមកាល ១ ជាអ្នកមិនប្រព្រឹត្តធម៌ដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ អនាយុស្សធម៌ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាយុស្សធម៌ (ធម៌ធ្វើឲ្យចំរើនអាយុ) នេះមាន ៥ យ៉ាង ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកបេះធ្វើខ្លួនឲ្យសប្បាយ ១ ដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកបរិភោគអាហាររលួយ ១ ជាអ្នកត្រេចទៅត្រូវតាមកាល ១ ប្រព្រឹត្តធម៌ដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ អាយុស្សធម៌ មាន ៥ យ៉ាងនេះឯង ។

(២៦) ម្នាលភិក្ខុទាំងឡាយ អនាយុស្សធម៌ (ធម៌ធ្វើឲ្យអាយុថយ) នេះមាន ៥ យ៉ាង ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនបេះធ្វើខ្លួនឲ្យសប្បាយ ១ មិនដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកបរិភោគអាហារមិនរលួយ ១ ជាអ្នកទ្រុស្តសីល ១ ជាអ្នកមានមិត្តអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ អនាយុស្សធម៌ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាយុស្សធម៌ (ធម៌ធ្វើឲ្យចំរើនអាយុ) នេះមាន ៥ យ៉ាង ។

កតមេ បញ្ច ។ សប្បាយការី ហោតិ សប្បាយេ មត្តំ ជានាតិ បរិណតភោជី ច ហោតិ សីលវា ច កល្យាណមិត្តោ ច ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា អាយុស្សាតិ ។

(២៧) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ នាលំ សង្ឃម្ហាវបកាសិតុំ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អសន្តុដ្ឋោ ហោតិ ឥតរីតរេន ចីវរេន អសន្តុដ្ឋោ ហោតិ ឥតរីតរេន បិណ្ឌបាតេន អសន្តុដ្ឋោ ហោតិ ឥតរីតរេន សេនាសនេន អសន្តុដ្ឋោ ហោតិ ឥតរីតរេន គិលានប្បច្ចយភេសជ្ជបរិក្ខារេន កាមសង្កប្បពហុលោ ច វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ នាលំ សង្ឃម្ហាវបកាសិតុំ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ សង្ឃម្ហាវបកាសិតុំ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន ចីវរេន សន្តុដ្ឋោ ហោតិ

ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកចេះធ្វើខ្លួនឲ្យសប្បាយ ១ ដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកបរិភោគអាហាររលួយ ១ ជាអ្នកមានសីល ១ ជាអ្នកមានកល្យាណមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ អាយុស្សធម៌ មាន ៥ យ៉ាងនេះឯង ។

[២៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនគួរនឹងចេញចាកសង្ឃ[១] (ទៅនៅតែម្នាក់ឯង) ទេ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនសន្តោសដោយចីវរ តាមមានតាមបាន ១ មិនសន្តោសដោយបិណ្ឌបាត តាមមានតាមបាន ១ មិនសន្តោសដោយសេនាសនៈ តាមមានតាមបាន ១ មិនសន្តោសដោយគិលានប្បច្ច័យភេសជ្ជបរិក្ខារ តាមមានតាមបាន ១ ជាអ្នកក្រាស់ដោយសេចក្តីត្រិះរិះក្នុងកាម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរនឹងចេញចាកសង្ឃ (ទៅនៅតែម្នាក់ឯង) ទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបគួរចេញចាកសង្ឃ (ទៅនៅតែម្នាក់ឯង) បាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរ តាមមានតាមបាន ១

---

១ ឬមិនគួរនៅក្នុងកណ្តាលសង្ឃ ។ អដ្ឋកថា ។

ឥតរីតរេន បិណ្ឌបាតេន សន្តុដ្ឋោ ហោតិ ឥតរីតរេន សេនាសនេន សន្តុដ្ឋោ ហោតិ ឥតរីតរេន គិលា-នប្បច្ចយភេសជ្ជបរិក្ខារេន នេក្ខម្មសង្កប្បពហុលោ ច វិហរតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ សព្រហ្មចារិបកាសិតុន្តិ ។

(២៨) បញ្ចិមានិ ភិក្ខវេ សមណទុក្ខានិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ អសន្តុដ្ឋោ ហោតិ ឥតរីតរេន ចីវរេន អសន្តុដ្ឋោ ហោតិ ឥតរីតរេន បិណ្ឌបាតេន អសន្តុដ្ឋោ ហោតិ ឥតរីតរេន សេនា-សនេន អសន្តុដ្ឋោ ហោតិ ឥតរីតរេន គិលានប្បច្ច-យភេសជ្ជបរិក្ខារេន អនភិរតោ ច ព្រហ្មចរិយំ ចរតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច សមណទុក្ខានិ ។ បញ្ចិមានិ ភិក្ខវេ សមណសុខានិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន ចីវរេន សន្តុដ្ឋោ ហោតិ ឥតរីតរេន បិណ្ឌបាតេន សន្តុដ្ឋោ ហោតិ ឥតរីតរេន សេនាសនេន សន្តុដ្ឋោ ហោតិ ឥតរតរេន គិលានប្បច្ចយភេសជ្ជបរិក្ខារេន

សន្តោសដោយបិណ្ឌបាត តាមមានតាមបាន១ សន្តោសដោយសេនាសនៈ តាមមានតាមបាន ១ សន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន១ ជាអ្នកក្រាស់ដោយសេចក្តីត្រិះរិះ ក្នុងការចេញចាកកាម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរចេញចាកសង្ឃ (ទៅនៅតែម្នាក់ឯង) បាន ។

[៤៨] ម្នាលភិក្ខុទាំងឡាយ សមណទុក្ខ (ទុក្ខរបស់សមណៈ) នេះមាន៥ យ៉ាង ។ ទុក្ខ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនសន្តោសដោយចីវរ តាមមានតាមបាន ១ មិនសន្តោសដោយបិណ្ឌបាត តាមមានតាមបាន ១ មិនសន្តោសដោយសេនាសនៈ តាមមានតាមបាន ១ មិនសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ១ ប្រព្រឹត្តព្រហ្មចរិយធម៌ទាំងមិនត្រេកអរ១ ។ ម្នាលភិក្ខុទាំងឡាយ សមណទុក្ខមាន៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណសុខ (សុខរបស់សមណៈ) មាន ៥ យ៉ាង ។ សុខ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរ តាមមានតាមបាន១ សន្តោសដោយបិណ្ឌបាត តាមមានតាមបាន១ សន្តោសដោយសេនាសនៈ តាមមានតាមបាន១ សន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ១

អភិរតោ ច ព្រហ្មចរិយំ ចរតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច សមណសុខានីតិ ។

(២៩) បញ្ចិមេ ភិក្ខវេ អាបាយិកា នេរយិកា បរិកុប្បា អតេកិច្ឆា ។ កតមេ បញ្ច ។ មាតា[១] ជីវិតា វោរោបិតា ហោតិ បិតា[២] ជីវិតា វោរោបិតោ ហោតិ អរហា[៣] ជីវិតា វោរោបិតោ ហោតិ តថាគតស្ស ទុដ្ឋេន ចិត្តេន លោហិតំ ឧប្បាទិតំ ហោតិ សង្ឃោ ភិន្នោ ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាបាយិកា នេរយិកា បរិកុប្បា អតេកិច្ឆាតិ ។

(៣០) បញ្ចិមានិ ភិក្ខវេ ព្យសនានិ ។ កតមានិ បញ្ច ។ ញាតិព្យសនំ ភោគព្យសនំ រោគព្យសនំ សីលព្យសនំ ទិដ្ឋិព្យសនំ ។ ន ភិក្ខវេ សត្តា ញាតិព្យសនហេតុ វា ភោគព្យសនហេតុ វា រោគព្យសនហេតុ វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ

១ ម. មាតរំ ។ ២ ម. បិតរំ ។ ៣ ឱ. អរហំ ។ ម. អរហន្តំ ។

ប្រព្រឹត្តព្រហ្មចរិយៈដោយសេចក្តីត្រេកអរ ១ ។ ម្នាលភិក្ខុទាំងឡាយ សមណសុខ មាន ៥ យ៉ាងនេះឯង ។

(២៩) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៥ ពួកនេះ ជាអ្នកទៅកាន់អបាយ ទៅកាន់នរក មានសភាពគគ្រើម ជាបុគ្គលកែប្រែមិនបាន ។ បុគ្គល ៥ ពួក តើដូចម្តេច ។ គឺបុគ្គលផ្តាច់ជីវិតមាតា ១ បុគ្គលផ្តាច់ជីវិតបិតា ១ បុគ្គលផ្តាច់ជីវិតព្រះអរហន្ត ១ បុគ្គលធ្វើលោហិតរបស់ព្រះតថាគតឲ្យពុះពងឡើងដោយចិត្តប្រទូស្ត ១ បុគ្គលបំបែកសង្ឃ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៥ ពួកនេះឯង ជាអ្នកទៅកាន់អបាយ ទៅកាន់នរក មានសភាពគគ្រើម ជាបុគ្គលកែប្រែមិនបាន ។

(៣០) ម្នាលភិក្ខុទាំងឡាយ សេចក្តីវិនាសនេះ មាន ៥ យ៉ាង ។ សេចក្តីវិនាស ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺវិនាសញាតិ ១ វិនាសទ្រព្យ ១ វិនាសព្រោះរោគ ១ វិនាសសីល ១ វិនាសទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុវិនាសញាតិ ឬព្រោះហេតុវិនាសទ្រព្យ ឬក៏ហេតុតែវិនាសព្រោះរោគក៏ទេ

សីលព្យសនហេតុ វា ភិក្ខវេ សត្តា ទិដ្ឋិព្យសនហេតុ វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ព្យសនានិ ។ បញ្ចិមា ភិក្ខវេ សម្បទា ។ កតមា បញ្ច ។ ញាតិសម្បទា ភោគសម្បទា អារោគ្យសម្បទា សីលសម្បទា ទិដ្ឋិសម្បទា ។ ន ភិក្ខវេ សត្តា ញាតិសម្បទាហេតុ វា ភោគសម្បទាហេតុ វា អារោគ្យសម្បទាហេតុ វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ សីលសម្បទាហេតុ វា ភិក្ខវេ សត្តា ទិដ្ឋិសម្បទាហេតុ វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ ឥមា ខោ ភិក្ខវេ បញ្ច សម្បទាតិ ។

តិណានវគ្គោ តតិយោ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុវិនាសសីល ឬព្រោះហេតុវិនាសទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីវិនាស មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ការបរិបូណ៌នេះ មាន ៥ យ៉ាង ។ ការបរិបូណ៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺបរិបូណ៌ដោយញាតិ ១ បរិបូណ៌ដោយទ្រព្យ ១ បរិបូណ៌ដោយការមិនមានរោគ ១ បរិបូណ៌ដោយសីល ១ បរិបូណ៌ដោយទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុបរិបូណ៌ដោយញាតិ ឬព្រោះហេតុតែបរិបូណ៌ដោយទ្រព្យ ឬក៏ព្រោះហេតុតែបរិបូណ៌ដោយការមិនមានរោគក៏ទេ ម្នាលភិក្ខុទាំងឡាយ ពួកសត្វបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុបរិបូណ៌ដោយសីល ឬព្រោះហេតុបរិបូណ៌ដោយទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ការបរិបូណ៌មាន ៥ យ៉ាងនេះឯង ។

ចប់ គិលានវគ្គ ទី ៣ ។

## តស្សុទ្ទានំ

គិលានោ សតិប្បដ្ឋានំ

ទ្វេបដ្ឋាកា ទុវាយុសា

អវប្បកាសទុក្ខានិ

បរិកុប្បោ ច សម្បទាតិ ។

## ឧទ្ទាននៃគិលានវគ្គនោះគឺ

និយាយអំពីភិក្ខុមានជម្ងឺ ១ អំពីដំកល់ស្មារតី ១ អំពីបុគ្គលបម្រើជម្ងឺ ២ លើក អំពីអាយុ ២ លើក អំពីបុគ្គលមិនគួរចេញចាកសង្ឃ ១ អំពីទុក្ខ ១ អំពីបុគ្គលជាអ្នកកម្រើក ១ អំពីការបរិបូណ៌ ១ ។

## រាជវគ្គោ ចតុត្ថោ

(៣១) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រាជា ចក្កវត្តី ធម្មេនេវ ចក្កំ បវត្តេតិ តំ ហោតិ ចក្កំ អប្បដិវត្តិយំ កេនចិ មនុស្សភូតេន បច្ចត្ថិកេន បាណិនា ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ រាជា ចក្កវត្តី អត្ថញ្ញូ ច ហោតិ ធម្មញ្ញូ ច មត្តញ្ញូ ច កាលញ្ញូ ច បរិសញ្ញូ ច ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ រាជា ចក្កវត្តី ធម្មេនេវ ចក្កំ បវត្តេតិ តំ ហោតិ ចក្កំ អប្បដិវត្តិយំ កេនចិ មនុស្សភូតេន បច្ចត្ថិកេន បាណិនា ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ធម្មេនេវ អនុត្តរំ ធម្មចក្កំ បវត្តេតិ តំ ហោតិ ចក្កំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។

## រាជវគ្គ ទី ៤

(៣១) ម្នាលភិក្ខុទាំងឡាយ ព្រះរាជាចក្រពត្តិប្រកបដោយអង្គ ៥ យ៉ាង រមែងញ៉ាំងអាណាចក្រឲ្យប្រព្រឹត្តទៅ ដោយកុសលធម៌ អាណាចក្រនោះ សត្វជាសត្រូវមានជាតិជាមនុស្សណាមួយ មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាចក្រពត្តិក្នុងលោកនេះ ទ្រង់ឈ្វេងយល់នូវប្រយោជន៍ (នៃរាជការ)១ ទ្រង់ចាំនូវប្រវេណីធម៌ ១ ទ្រង់ស្គាល់ប្រមាណក្នុងអាជ្ញាឬគ្រឿងបូជា ១ ទ្រង់ស្គាល់កាល ១[១] ទ្រង់ស្គាល់បរិសទ្យ ១[២] ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាចក្រពត្តិប្រកបដោយអង្គ ៥ យ៉ាងនេះឯង រមែងញ៉ាំងព្រះរាជអាណាចក្រឲ្យប្រព្រឹត្តទៅដោយធម៌ អាណាចក្រនោះ សត្វជាសត្រូវមានជាតិជាមនុស្សណាមួយ មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌ ៥ ប្រការដូច្នោះដែរ ទើបញ៉ាំងធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយធម៌បាន ធម្មចក្រនោះឯង ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬបុគ្គលណាមួយ ក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។

---

១ ស្គាល់ថា កាលនេះ ជាកាលគួរសោយសុខក្នុងរាជ្យ កាលនេះ ជាកាលគួរវិនិច្ឆ័យ ជាកាលគួរទៅកាន់ជនបទ ។ ២ ស្គាល់ថា អ្នកនេះ ជាក្សត្រិយ៍ ជាព្រាហ្មណ៍ ជាវេស្ស ជាសុទ្រ ។ អដ្ឋកថា ។

កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ តថាគតោ អរហំ សម្មាសម្ពុទ្ធោ អត្ថញ្ញូ ធម្មញ្ញូ មត្តញ្ញូ កាលញ្ញូ បរិសញ្ញូ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ធម្មេនេវ អនុត្តរំ ធម្មចក្កំ បវត្តេតិ តំ ហោតិ ចក្កំ(១) អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។

(៣២) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ចក្កវត្តិស្ស ជេដ្ឋោ បុត្តោ បិតរា បវត្តិតំ ចក្កំ ធម្មេនេវ អនុប្បវត្តេតិ តំ ហោតិ ចក្កំ អប្បដិវត្តិយំ កេនចិ មនុស្សភូតេន បច្ចត្ថិកេន បាណិនា ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ រញ្ញោ ចក្កវត្តិស្ស ជេដ្ឋោ បុត្តោ អត្ថញ្ញូ ច ហោតិ ធម្មញ្ញូ ច មត្តញ្ញូ ច កាលញ្ញូ ច បរិសញ្ញូ ច ។

---

១ ម. ធម្មចក្កំ ។

ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោកនេះជាអ្នកដឹងអត្ថ ១ ដឹងធម៌ ១ ដឹងប្រមាណ ១[១] ដឹងកាល ១[២] ដឹងបរិសទ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងញ៉ាំងធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅ ដោយធម៌បាន ធម្មចក្រនោះឯង ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយ ក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។

[៣២] ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះរាជាចក្រពត្តិប្រកបដោយអង្គ ៥ យ៉ាង រមែងញ៉ាំងអាណាចក្រដែលបិតាផ្ចាប់ឲ្យប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅតាមលំដាប់ដោយធម៌បាន អាណាចក្រនោះ សត្វជាសត្រូវមានជាតិជាមនុស្សណាមួយ មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ស្តេចចក្រពត្តិ ក្នុងលោកនេះ ទ្រង់ឈ្វេងយល់នូវប្រយោជន៍ (នៃរាជការ) ១ ទ្រង់ចាំនូវប្រវេណីធម៌ ១ ទ្រង់ស្គាល់ប្រមាណក្នុងអាជ្ញាឬគ្រឿងបូជា ១ ទ្រង់ស្គាល់កាល ១ ទ្រង់ស្គាល់បរិសទ្យ ១ ។

---

១ ប្រមាណក្នុងការទទួលនឹងការប្រើប្រាស់បច្ច័យ ៤ ។ ២ ដឹងថា កាលនេះជាកាលគួរពួនសម្ងំ កាលនេះគួរចូលសមាបត្តិ កាលនេះគួរសំដែងធម៌ កាលនេះគួរចេញទៅកាន់ជនបទ ។

ឯវមេវ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ រាជា ចក្កវត្តិស្ស ជេដ្ឋោ បុត្តោ បិតរា បវត្តិតំ ចក្កំ ធម្មេនេវ អនុប្បវត្តេតិ តំ ហោតិ ចក្កំ អប្បដិវត្តិយំ កេនចិ មនុស្សភូតេន បច្ចត្ថិកេន បាណិនា ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ សារីបុត្តោ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតំ សម្មទេវ អនុប្បវត្តេតិ តំ ហោតិ ចក្កំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ សារីបុត្តោ អត្ថញ្ញូ ធម្មញ្ញូ មត្តញ្ញូ កាលញ្ញូ បរិសញ្ញូ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ សារីបុត្តោ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតំ សម្មទេវ អនុប្បវត្តេតិ តំ ហោតិ ចក្កំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ។

ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះរាជាចក្រពត្តិប្រកបដោយអង្គ ៥ យ៉ាងនេះឯង រមែងញុំាងអាណាចក្រដែលបិតាធ្លាប់ឲ្យប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅតាមលំដាប់ដោយធម៌ អាណាចក្រនោះ សត្វជាសត្រូវមានជាតិជាមនុស្ស មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្រប្រកបដោយធម៌ ៥ យ៉ាងដូច្នោះដែរ ទើបញុំាងធម្មចក្រដ៏ប្រសើរ ដែលព្រះតថាគតធ្លាប់ឲ្យប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅតាមលំដាប់ ដោយប្រពៃបាន ធម្មចក្រនោះ ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយ ក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សារីបុត្រជាអ្នកដឹងអត្ថ ១ ដឹងធម៌ ១ ដឹងប្រមាណ ១ ដឹងកាល ១ ដឹងបរិសទ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្រប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបញុំាងធម្មចក្រដ៏ប្រសើរ ដែលព្រះតថាគតធ្លាប់ឲ្យប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅតាមលំដាប់ ដោយប្រពៃបាន ធម្មចក្រនោះ ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។

(៣៣) យោបិ សោ ភិក្ខវេ រាជា ចក្កវត្តិ ធម្មិកោ ធម្មរាជា សោបិ ន អរាជកំ ចក្កំ បវត្តេតីតិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច កោ បន ភន្តេ រញ្ញោ ចក្កវត្តិស្ស ធម្មិកស្ស ធម្មរញ្ញោ រាជាតិ ។ ធម្មោ ភិក្ខូតិ ភគវា អវោច ឥធ ភិក្ខុ រាជា ចក្កវត្តិ ធម្មិកោ ធម្មរាជា ធម្មញ្ញេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តិំ សំវិទហតិ អន្តោជនស្មិំ ។ បុន ចបរំ ភិក្ខុ រាជា ចក្កវត្តិ ធម្មិកោ ធម្មរាជា ។បេ។ ធម្មា-ធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តិំ សំវិទហតិ

(៣៣) ម្នាលភិក្ខុទាំងឡាយ ព្រះរាជាចក្រពត្តិណា ប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ ព្រះរាជានោះឯងមិនញុំាងអាណាចក្រដែលមិនជារបស់ព្រះរាជាឲ្យប្រព្រឹត្តទៅឡើយ(១) ។ កាលព្រះដ៏មានបុណ្យទ្រង់ត្រាស់យ៉ាងនេះ ភិក្ខុមួយរូប បានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ចុះអ្នកណា ជាស្តេចរបស់ព្រះរាជាចក្រពត្តិដែលប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ ព្រះធម៌ (ជាស្តេច) ដូច្នេះហើយត្រាស់ថា ម្នាលភិក្ខុ ព្រះរាជាចក្រពត្តិ ក្នុងលោកនេះ ប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ ទ្រង់ពឹងនូវធម៌តែមួយយ៉ាង ហើយធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាទង់ យកធម៌ជាធំ ចាត់ចែងនូវការរក្សា ការពារ គប់គ្រងប្រកបដោយធម៌ ចំពោះអន្តោជន គឺអគ្គមហេសី បុត្តធីតា ។ ម្នាលភិក្ខុ មួយទៀត ព្រះរាជាចក្រពត្តិប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ ។បេ។ យកធម៌ជាធំ ចាត់ចែងនូវការរក្សា ការពារ គប់គ្រងប្រកបដោយធម៌

---

១ ទំនៀមស្តេចចក្រពត្តិដែលផ្សាយអាណាចក្រ តែងផ្សាយដោយច្បាប់ដ៏ត្រឹមត្រូវតាមគន្លងធម៌ ហេតុនោះត្រង់ពាក្យថា មិនញុំាងអាណាចក្រដែលមិនជារបស់ព្រះរាជាឲ្យប្រព្រឹត្តទៅ ដូច្នេះនោះ បានសេចក្តីថា មិនផ្សាយអាណាចក្រដោយឥតទសពិធរាជធម៌ទេ ។

ខត្តិយេសុ អនុយន្តេសុ ពលកាយស្មឹ ព្រាហ្មណគហបតិកេសុ នេគមជានបទេសុ សមណព្រាហ្មណេសុ មិគបក្ខីសុ ។ ស ខោ សោ ភិក្ខុ រាជា ចក្កវត្តិ ធម្មិកោ ធម្មរាជា ។ បេ ។ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហិត្វា អន្តោជនស្មឹ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហិត្វា ខត្តិយេសុ អនុយន្តេសុ ពលកាយស្មឹ ព្រាហ្មណគហបតិកេសុ នេគមជានបទេសុ សមណព្រាហ្មណេសុ មិគបក្ខីសុ ធម្មេនេវ ចក្កំ បវត្តេតិ តំ ហោតិ ចក្កំ អប្បដិវត្តិយំ កេនចិ មនុស្សភូតេន បច្ចត្ថិកេន បាណិនា ។ ឯវមេវ ខោ ភិក្ខុ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ធម្មិកោ ធម្មរាជា ធម្មញ្ញេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហតិ ភិក្ខូសុ ឯវរូបំ កាយកម្មំ សេវិតព្វំ ឯវរូបំ កាយកម្មំ ន សេវិតព្វំ ឯវរូបំ វចីកម្មំ សេវិតព្វំ ឯវរូបំ វចីកម្មំ ន សេវិតព្វំ ឯវរូបំ មនោកម្មំ

ចំពោះពួកក្សត្រិយ៍ (ដែលបានមុទ្ធាភិសេក) ចំពោះពួកក្សត្រិយ៍ ដែលចុះបូល ចំពោះពួកពល ចំពោះព្រាហ្មណ៍ គហបតី ចំពោះអ្នកនិគម អ្នកជនបទ ចំពោះសមណព្រាហ្មណ៍ ចំពោះម្រឹគ បក្សី ។ ម្នាលភិក្ខុ ព្រះរាជាចក្រពត្តិនោះឯង ប្រកបដោយធម៌ ជាស្ដេចទ្រង់ធម៌ ។បេ។ យកធម៌ជាធំ លុះចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះអន្តោជន លុះចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះពួកក្សត្រិយ៍ ចំពោះពួកក្សត្រិយ៍ដែលចុះបូល ចំពោះពួកពល ចំពោះព្រាហ្មណ៍ គហបតី ចំពោះអ្នកនិគម អ្នកជនបទ ចំពោះសមណព្រាហ្មណ៍ ចំពោះពួកម្រឹគ បក្សីរួចហើយ ទើបញុំាងអាណាចក្រឲ្យប្រព្រឹត្តទៅដោយធម៌តែមួយយ៉ាង អាណាចក្រនោះឯង សត្វជាសត្រូវមានជាតិជាមនុស្សណាមួយ មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ម្នាលភិក្ខុ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ជាធម្មិកធម្មរាជក៏យ៉ាងនោះដែរ តែងទីពឹងនូវធម៌តែមួយយ៉ាង ហើយធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាទង់ យកធម៌ជាធំ ចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះភិក្ខុទាំងឡាយថា កាយកម្មបែបនេះ គួរសេព កាយកម្មបែបនេះ មិនគួរសេពទេ វចីកម្មបែបនេះ គួរសេព វចីកម្មបែបនេះ មិនគួរសេពទេ មនោកម្មបែបនេះ

សេវិតព្វំ ឯវរូបំ មនោកម្មំ ន សេវិតព្វំ ឯវរូបោ អាជីវោ សេវិតព្វោ ឯវរូបោ អាជីវោ ន សេវិតព្វោ ឯវរូបោ គាមនិគមោ សេវិតព្វោ ឯវរូបោ គាមនិគមោ ន សេវិតព្វោតិ ។ បុន ចបរំ ភិក្ខុ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ធម្មិកោ ធម្មរាជា ។បេ។ ធម្មាធិប-តេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហតិ ភិក្ខុនីសុ... ឧបាសកេសុ... ឧបាសិកាសុ ឯវរូបំ កាយកម្មំ សេវិតព្វំ ឯវរូបំ កាយកម្មំ ន សេវិតព្វំ ។បេ។ ឯវរូបោ គាមនិគមោ សេវិតព្វោ ឯវរូបោ គាមនិគមោ ន សេវិតព្វោតិ ។ ស ខោ សោ ភិក្ខុ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ធម្មិកោ ធម្មរាជា ។បេ។ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហិត្វា ភិក្ខូសុ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហិត្វា ភិក្ខុនីសុ... ឧបាសកេសុ... ឧបាសិកាសុ ធម្មេនេវ អនុត្តរំ ធម្មចក្កំ បវត្តេតិ តំ ហោតិ ចក្កំ អប្បដិវត្តិយំ សមណេន វា [ព្រា]ហ្មណេន វា ទេវេន វា មារេន វា [ព្រ]ហ្មុនា វា កេនចិ វា លោកស្មឹ ។

ត្រូវសេព មនោកម្មបែបនេះ មិនត្រូវសេពទេ ការចិញ្ចឹមជីវិតបែបនេះ ត្រូវសេព ការចិញ្ចឹមជីវិតបែបនេះ មិនត្រូវសេពទេ ស្រុកនិគមបែបនេះ ត្រូវសេព ស្រុកនិគមបែបនេះ មិនត្រូវសេពគប់ទេ ។ ម្នាលភិក្ខុ មួយទៀត ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធជាធម្មិកធម្មរាជ ។ បេ ។ យកធម៌ជាធំ ចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះភិក្ខុនី ... ចំពោះឧបាសក ... ចំពោះឧបាសិកាថា កាយកម្មបែបនេះ ត្រូវសេព កាយកម្មបែបនេះ មិនត្រូវសេពទេ ។ បេ ។ ស្រុកនិគមបែបនេះ ត្រូវសេព ស្រុកនិគមបែបនេះ មិនត្រូវសេពទេ ។ ម្នាលភិក្ខុ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធជាធម្មិកធម្មរាជនោះឯង ។ បេ ។ យកធម៌ជាធំ លុះចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះភិក្ខុ ចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះភិក្ខុនី ... ចំពោះឧបាសក ... ចំពោះឧបាសិការួចហើយ ទើបញ៉ាំងធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយធម៌តែម្យ៉ាង ធម្មចក្រនោះ ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយ ក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។

(៣៤) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រាជា ខត្តិយោ មុទ្ធាភិសិត្តោ យស្សំ យស្សំ ទិសាយំ វិហរតិ សកស្មិំយេវ វិជិតេ វិហរតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាភិសិត្តោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អឌ្ឍោ ហោតិ មហទ្ធនោ មហាភោគោ បរិបុណ្ណកោសកោដ្ឋាគារោ ពលវា ខោ បន ហោតិ ចតុរង្គិនិយា សេនាយ សមន្នាគតោ អស្សវាយ ឱវាទប្បដិករាយ បរិណាយកោ ខោ បនស្ស ហោតិ បណ្ឌិតោ ព្យត្តោ មេធាវី បដិពលោ អតីតានាគតប្បច្ចុប្បន្នេ អត្ថេ ចិន្តេតុំ តស្សិមេ ចត្តារោ ធម្មា យសំ បរិបាចេន្តិ ។ សោ ឥមិនា យសបញ្ចមេន ធម្មេន សមន្នាគតោ យស្សំ យស្សំ ទិសាយំ វិហរតិ សកស្មិំយេវ វិជិតេ វិហរតិ ។

(៣៤) ម្នាលភិក្ខុទាំងឡាយ ព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ប្រកបដោយអង្គ ៥ យ៉ាង ទ្រង់ប្រថាប់ក្នុងទិសឯណា ៗ ក៏រមែងប្រថាប់តែក្នុងដែនរបស់ព្រះអង្គដែល ៗ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ក្នុងលោកនេះ ទ្រង់មានព្រះជាតិដ៏ល្អទាំងពីរបំណែក គឺខាងព្រះមាតានឹងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធ អំពីដំណនៃអយ្យកោនឹងអយ្យិកា ជាគំរប់ ៧ មិនមានអ្នកណារិះគន់ តិះដៀល ដោយពោលដល់ព្រះជាតិបាន ១ ព្រះអង្គជាស្តេចស្តុកស្តម្ភ មានព្រះរាជទ្រព្យច្រើន មានភោគសម្ប័ទច្រើន មានឃ្លាំងនិងជង្រុកដ៏បរិបូណ៌ ១ ព្រះអង្គមានរេហ៍ពល ប្រកបដោយចតុរង្គសេនា ដែលអាចស្តាប់បង្គាប់ធ្វើតាមព្រះរាជឱវាទ ១ បរិនាយករតន៍នៃព្រះអង្គ ជាអ្នកប្រាជ្ញវាងវៃ មានប្រាជ្ញា អង់អាច តែងគិតឃើញប្រយោជន៍ដែលជាអតីត អនាគតនិងបច្ចុប្បន្ន ១ ធម៌ទាំង ៤ យ៉ាងនេះឯង រមែងញុំាងយសបរិវារ របស់ក្សត្រិយ៍នោះឲ្យចាស់ក្លា ៗ ព្រះរាជានោះ ប្រកបដោយធម៌ ដែលមានយសបរិវារជាគំរប់ ៥ នេះ ទ្រង់ប្រថាប់ក្នុងទិសឯណា ៗ រមែងប្រថាប់តែក្នុងដែនរបស់ព្រះអង្គដែល ៗ

តំ កិស្ស ហេតុ ។ ឯវញ្ហិ ភិក្ខវេ ហោតិ វិជិតាវីនំ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ យស្សំ យស្សំ ទិសាយំ វិហរតិ វិមុត្តចិត្តោវ វិហរតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សិក្ខតិ សិក្ខាបទេសុ ។ រាជាវ ខត្តិយោ មុទ្ធាភិសិត្តោ ជាតិសម្បន្នោ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា ។ រាជាវ ខត្តិយោ មុទ្ធាភិសិត្តោ អឌ្ឍោ មហទ្ធនោ មហាភោគោ បរិបុណ្ណកោសកោដ្ឋាគារោ អារទ្ធវិរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ រាជាវ ខត្តិយោ មុទ្ធាភិសិត្តោ ពលសម្បន្នោ បញ្ញវា ហោតិ

ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ដំណើរនុះឯង ជាទំនៀមរបស់បុគ្គលទាំងឡាយដែលមានជ័យជំនះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងក៏ដូច្នោះដែរ ស្ថិតនៅក្នុងទិសឯណា ៗ រមែងស្ថិតនៅដោយវិមុត្តិចិត្តតែមួយយ៉ាង ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សិក្សាក្នុងសិក្ខាបទទាំងឡាយ ដូចជាព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ទ្រង់បរិបូណ៌ដោយព្រះជាតិ ១ ជាអ្នកចេះដឹងច្រើន ។បេ។ ជាអ្នកមុតធ្លុះដោយទិដ្ឋិ ដូចព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ជាស្តេចស្តុកស្តម្ភ មានព្រះរាជទ្រព្យច្រើន មានភោគសម្បទច្រើន មានឃ្លាំងនឹងជង្រុកបរិបូណ៌ ១ មានសេចក្តីព្យាយាមប្រារព្ធដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីញុំាងកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកំឡាំងចិត្ត មានសេចក្តីខ្មីឃ្មាតដ៏មាំ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ដូចជាព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ព្រះអង្គបរិបូណ៌ដោយកំឡាំង ១ ជាអ្នកមានប្រាជ្ញា

ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្ពេធិកាយ សម្មាទុក្ខក្ខយគាមិនិយា រាជាវ ខត្តិយោ មុទ្ធាភិសិត្តោ បរិណាយកសម្បន្នោ តស្សិមេ ចត្តារោ ធម្មា វិមុត្តិំ បរិបាចេន្តិ ។ សោ ឥមិនា វិមុត្តិបញ្ចមេន ធម្មេន សមន្នាគតោ យស្សំ យស្សំ ទិសាយំ វិហរតិ វិមុត្តចិត្តោវ វិហរតិ ។ តំ កិស្ស ហេតុ ។ ឯវំ ហេតំ ភិក្ខវេ ហោតិ វិមុត្តចិត្តានន្តិ ។

(៣៨) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស ជេដ្ឋោ បុត្តោ រជ្ជំ បត្ថេតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស ជេដ្ឋោ បុត្តោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អភិរូបោ ហោតិ

ប្រកបដោយប្រាជ្ញា ជាគ្រឿងកំណត់ដឹង នូវការកើតនិងការរលត់ជា ប្រាជ្ញាដ៏ប្រសើរ អាចទំលុះទំលាយ (នូវគំនរនៃលោភៈជាដើម) ជាប្រាជ្ញា ញ៉ាំងទុក្ខឲ្យដល់នូវការអស់ទៅដោយប្រពៃ ដូចជាព្រះរាជា ជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ទ្រង់បរិបូណ៌ដោយបរិនាយករតនៈ ១ ធម៌ទាំង ៤ យ៉ាងនេះឯង រមែងញ៉ាំងវិមុត្តិរបស់ភិក្ខុនោះឲ្យចាស់ក្លា ១ ។ ភិក្ខុនោះប្រកបដោយធម៌ មានវិមុត្តិជាគំរប់ ៥ នេះ នៅក្នុងទិសឯណា ៗ រមែងស្ថិតនៅដោយវិមុត្តិចិត្តតែមួយ យ៉ាង ៗ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ដំណើរនុ៎ះឯងជាទំនៀមរបស់ភិក្ខុដែល មានចិត្តរួចស្រឡះចាកកិលេស ។

[៣៥] ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយ-រាជដែលបានមុទ្ធាភិសេកហើយ ជាព្រះរាជកុមារ ប្រកបដោយអង្គ ៥ យ៉ាង តែងប្រាថ្នានូវរាជ្យ ៗ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ៗ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជដែលបានមុទ្ធាភិសេក ជាព្រះរាជកុមារ មានព្រះជាតិដ៏ល្អទាំងពីរចំណែកគឺខាងព្រះមាតានិងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធអំពីតំណនៃអយ្យកោនិងអយ្យិកាជាគំរប់ ៧ មិនមានអ្នកណារិះគន់តិះដៀលដោយពោលដល់ព្រះជាតិបាន ១ ព្រះអង្គមានព្រះរូបល្អ

ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ មាតាបិតុន្នំ បិយោ ហោតិ មនាបោ នេគមជានបទស្ស បិយោ ហោតិ មនាបោ យានិ តានិ រញ្ញោ ខត្តិយានំ មុទ្ធាភិសិត្តានំ សិប្បដ្ឋានានិ ហត្ថិស្មឹ វា អស្សស្មឹ វា រថស្មឹ វា ធនុស្មឹ វា តត្ថ សិក្ខិតោ ហោតិ អនវយោ ។ តស្ស ឯវំ ហោតិ អហំ ខោម្ហិ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន កស្មាហំ វឌ្ឍំ ន បត្ថេយ្យំ អហំ ខោម្ហិ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ កស្មាហំ វឌ្ឍំ ន បត្ថេយ្យំ អហំ ខោម្ហិ មាតាបិតុន្នំ បិយោ មនាបោ កស្មាហំ វឌ្ឍំ ន បត្ថេយ្យំ អហំ ខោម្ហិ នេគមជានបទស្ស បិយោ មនាបោ កស្មាហំ វឌ្ឍំ ន បត្ថេយ្យំ អហំ ខោម្ហិ យានិ តានិ រញ្ញោ ខត្តិយានំ មុទ្ធាភិសិត្តានំ សិប្បដ្ឋានានិ ហត្ថិស្មឹ វា អស្សស្មឹ វា រថស្មឹ វា ធនុស្មឹ វា

គួរមើលមើល គួរជ្រះថ្លា ប្រកបដោយព្រះឆវីវណ្ណល្អក្រៃលែង ១ ព្រះអង្គជាទីស្រឡាញ់សព្វព្រះរាជហឫទ័យនៃព្រះមាតាព្រះបិតា ១ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អ្នកនិគមអ្នកជនបទ ១ ហេតុជាទីកើតនៃសិល្បសាស្ត្រឯណា សម្រាប់ខត្តិយរាជទាំងឡាយដែលបានមុទ្ធាភិសេកហើយ ទោះជាសិល្បៈខាងដំរីក្តី សេះក្តី រថក្តី ធ្នូក្តី ព្រះអង្គជាអ្នកសិក្សាឥតមានទើសទាល់ក្នុងសិល្បសាស្ត្រនោះ ១ ៗ ព្រះរាជបុត្រច្បងនោះ តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា ខ្លួនអញហ្នឹងឯង មានជាតិដ៏ល្អទាំងពីរចំណែកគឺខាងព្រះមាតានិងព្រះបិតា ប្រសូតចេញចាកព្រះគភ៌ ដ៏បរិសុទ្ធអំពីតំណនៃអយ្យកោនិងអយ្យិកាជាគំរប់ ៧ មិនមានអ្នកណារិះគន់តិះដៀលដោយពោលដល់ជាតិបាន ព្រោះហេតុអ្វី អញនឹងមិនប្រាថ្នានូវរាជ្យ អញហ្នឹងឯង ជាអ្នកមានរូបល្អ គួរមើលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង ព្រោះហេតុអ្វី អញមិនប្រាថ្នានូវរាជ្យ អញជាទីស្រឡាញ់ពេញចិត្តនៃព្រះមាតានិងព្រះបិតា ព្រោះហេតុអ្វី អញមិនប្រាថ្នានូវរាជ្យ អញជាទីស្រឡាញ់ជាទីគាប់ចិត្តនៃអ្នកនិគមអ្នកជនបទ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវរាជ្យ ហេតុជាទីកើតនៃសិល្បសាស្ត្រឯណា សម្រាប់ខត្តិយរាជទាំងឡាយដែលបានមុទ្ធាភិសេកហើយ ទោះជាសិល្បៈខាងដំរីក្តី សេះក្តី រថក្តី ធ្នូក្តី

តត្ថ សិក្ខិតោ អនវយោ កស្មាហំ រជ្ជំ ន បត្ថេយ្យន្តិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស ជេដ្ឋោ បុត្តោ រជ្ជំ បត្ថេតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាសវានំ ខយំ បត្ថេតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា ។បេ។ ពុទ្ធោ ភគវាតិ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខមាយ អសឋោ ហោតិ អមាយាវី យថាភូតំ អត្តានំ អាវិកត្តា សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ

អញជាអ្នកសិក្សាផងមានទើសទាល់ ក្នុងសិល្បសាស្ត្រនោះ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវរាជ្យ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជ ដែលបានមុទ្ធាភិសេកហើយ ជាព្រះរាជកុមារប្រកបដោយអង្គ ៥ យ៉ាងនេះឯង រមែងប្រាថ្នានូវរាជ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ តែងប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿពោធិញ្ញាណរបស់តថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ត្រកពទៀត ១ ជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយតេជោធាតុចាស់ល្មម មិនត្រជាក់ពេក មិនក្តៅពេក យ៉ាងកណ្តាល គួរដល់សេចក្តីព្យាយាម ១ មិនជាអ្នកលេងបោកប្រាស មិនមានមាយា ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវខ្លួន គួរតាមសេចក្តីពិត ក្នុងសំណាក់សាស្តា ឬក្នុងសំណាក់នៃសព្រហ្មចារីទាំងឡាយដែលជាអ្នកចេះដឹង ១ ជាបុគ្គលប្រារព្ធព្យាយាមដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីញុំាងកុសលធម៌ឲ្យដុះដាលឡើង ជាបុគ្គលមានកំឡាំងចិត្ត មានសេចក្តីសង្វាតដ៏មាំ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ១

បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ តស្ស ឯវំ ហោតិ អហំ ខោម្ហិ សទ្ធោ សទ្ទហាមិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា ។បេ។ ពុទ្ធោ ភគវាតិ កស្មាហំ អាសវានំ ខយំ ន បត្តេយ្យំ អហំ ខោម្ហិ អប្បាពាធោ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខមាយ កស្មាហំ អាសវានំ ខយំ ន បត្តេយ្យំ អហំ ខោម្ហិ អសឋោ អមាយាវី យថាភូតំ អត្តានំ អាវិកត្តា សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ កស្មាហំ អាសវានំ ខយំ ន បត្តេយ្យំ អហំ ខោម្ហិ អារទ្ធវីរិយោ វិហរាមិ អកុសលានំ ធម្មានំ បហានាយ ។បេ។ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ

ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ដែលកាត់កំណត់ដឹងនូវសេចក្តីកើតនិងការរលត់បាន ជាប្រាជ្ញាដ៏បរិសុទ្ធ អាចទំលុះទំលាយ (នូវគំនរនៃលោភៈជាដើម) ជាប្រាជ្ញាផ្តើកទុក្ខឲ្យដល់នូវការអស់ទៅដោយប្រពៃ ១ ។ ភិក្ខុនោះ រមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អញហ្នឹងឯង ជាអ្នកមានសទ្ធា ជឿព្រះពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គត្រាស់ដឹងចតុរិយសច្ច ព្រះអង្គលែងវិលមកកាន់ត្រៃភពទៀត ព្រោះអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយតេជោធាតុចាស់ល្មម មិនត្រជាក់ពេក មិនក្តៅពេក យ៉ាងកណ្តាល គួរដល់សេចក្តីព្យាយាម ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកមិនលេងបោកប្រាស មិនមានមាយា ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវខ្លួន តាមសេចក្តីពិតក្នុងសំណាក់សាស្តា ឬក្នុងសំណាក់នៃសព្រហ្មចារីទាំងឡាយដែលជាអ្នកចេះដឹង ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំង-ឡាយ អញហ្នឹងឯង ជាបុគ្គលប្រារព្ធព្យាយាម ដើម្បីលះបង់អកុសល-ធម៌ទាំងឡាយ ។ បេ ។ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ

កស្សាហំ អាសភំ ឋានំ ន បត្ថេយ្យំ អហំ ខោម្ហិ បញ្ញវា ។ បេ ។ សម្មាទុក្ខក្ខយគាមិនិយា កស្សាហំ អាសភំ ឋានំ ន បត្ថេយ្យន្តិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាសភំ ឋានំ បត្ថេតីតិ ។

(៣៦) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រាជា ខត្តិយស្ស មុទ្ធាភិសិត្តស្ស ជេដ្ឋោ បុត្តោ ឧប-រជ្ជំ បត្ថេតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ រាជា ខត្តិយស្ស មុទ្ធាភិសិត្តស្ស ជេដ្ឋោ បុត្តោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគ-ហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អភិរូបោ ហោតិ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ មាតាបិតូនំ បិយោ ហោតិ មនាបោ ពលកាយស្ស បិយោ ហោតិ មនាបោ បណ្ឌិតោ ហោតិ ព្យត្តោ មេធាវី បដិពលោ អតីតានាគតបច្ចុប្បន្នេ អត្ថេ ចិន្តេតុំ ។

ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញជាអ្នកមានប្រាជ្ញា ។ បេ ។ ជាប្រាជ្ញាធ្វើកន្លងទុកឲ្យដល់នូវការអស់ទៅដោយប្រពៃ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។

(៣៦) ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជដែលបានមុទ្ធាភិសេកហើយ ប្រកបដោយអង្គ ៥ យ៉ាង រមែងប្រាថ្នានូវឧបរាជ្យ (ភាពជាស្តេចបន្ទាប់) ។ ប្រកបដោយអង្គ ៥ យ៉ាងតើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជ ដែលបានមុទ្ធាភិសេកហើយ ជាព្រះរាជកុមារមានព្រះជាតិដ៏ល្អទាំងពីរចំណែកគឺខាងព្រះមាតានិងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធអស់ពីតំណនៃអយ្យកោនិងអយ្យិកាជាគំរប់ ៧ មិនមានអ្នកណារំគន់ តិះដៀល ដោយពោលដល់ព្រះជាតិបាន ១ មានព្រះរូបល្អគួរមិលមើល គួរជ្រះថ្លា ប្រកបដោយព្រះឆវីវណ្ណល្អក្រៃលែង ១ ជាទីស្រឡាញ់គាប់ព្រះហឫទ័យរបស់ព្រះមាតាព្រះបិតា ១ ជាទីស្រឡាញ់ពេញចិត្តរបស់ពួកពល ១ ជាអ្នកប្រាជ្ញឈ្លាសវៃ មានប្រាជ្ញាអង់អាចៗ គិតឃើញនូវប្រយោជន៍ដែលជាអតីត អនាគត បច្ចុប្បន្ន ១ ។

តស្ស ឯវំ ហោតិ អហំ ខោម្ហិ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន កស្មាហំ ឧបរជ្ជំ ន បត្ថេយ្យំ អហំ ខោម្ហិ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ កស្មាហំ ឧបរជ្ជំ ន បត្ថេយ្យំ អហំ ខោម្ហិ មាតាបិតូនំ បិយោ មនាបោ កស្មាហំ ឧបរជ្ជំ ន បត្ថេយ្យំ អហំ ខោម្ហិ ពលកាយស្ស បិយោ មនាបោ កស្មាហំ ឧបរជ្ជំ ន បត្ថេយ្យំ អហំ ខោម្ហិ បណ្ឌិតោ ព្យត្តោ មេធាវី បដិពលោ អតីតានាគតបច្ចុប្បន្នេ អត្ថេ ចិន្តេតុំ កស្មាហំ ឧបរជ្ជំ ន បត្ថេយ្យន្តិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស ជេដ្ឋោ បុត្តោ ឧបរជ្ជំ បត្ថេតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាសវានំ ខយំ បត្ថេតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។បេ។

ព្រះរាជបុត្រច្បងនោះ តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អញហ្នឹងឯង ជាអ្នកមានកំណើតល្អទាំងពីរបំណែកគឺខាងព្រះមាតានិងព្រះបិតា ប្រសូតចាកព្រះគភ៌បរិសុទ្ធអំពីតំណនៃអយ្យកោនិងអយ្យិកាជាគំរប់ ៧ មិនមានអ្នកណារិះគន់ តិះដៀល ដោយពោលដល់ជាតិបាន ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរជ្យ អញហ្នឹងឯង ជាអ្នកមានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរជ្យ អញហ្នឹងឯង ជាទីស្រឡាញ់ គាប់ព្រះហឫទ័យនៃព្រះមាតា និងព្រះបិតា ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរជ្យ អញហ្នឹងឯងជាទីស្រឡាញ់ពេញចិត្តនៃពួកពល ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរជ្យ អញហ្នឹងឯងជាអ្នកប្រាជ្ញឈ្លាសវៃ មានប្រាជ្ញាអង់អាច ។ គិតឃើញនូវប្រយោជន៍ដែលជាអតីត អនាគត បច្ចុប្បន្ន ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរជ្យ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជ ដែលបានមុទ្ធាភិសេកហើយ ប្រកបដោយអង្គ ៥ យ៉ាងនេះឯង រមែងប្រាថ្នានូវឧបរជ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ រមែងប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។

សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា ចតូសុ សតិប្បដ្ឋានេសុ សុបដ្ឋិតចិត្តោ ហោតិ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ ។ បេ ។ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ តស្ស ឯវំ ហោតិ អហំ ខោម្ហិ សីលវា ។ បេ ។ សិក្ខាមិ សិក្ខាបទេសុ តស្មាហំ អាសវានំ ខយំ ន បត្តេយ្យំ អហំ ខោម្ហិ ពហុស្សុតោ សុតធរោ សុតសន្និចយោ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា តស្មាហំ អាសវានំ ខយំ ន បត្តេយ្យំ អហំ ខោម្ហិ ចតូសុ សតិប្បដ្ឋានេសុ សុបដ្ឋិតចិត្តោ តស្មាហំ អាសវានំ ខយំ ន បត្តេយ្យំ អហំ ខោម្ហិ អារទ្ធវីរិយោ វិហរាមិ អកុសលានំ ធម្មានំ បហានាយ ។ បេ ។ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ តស្មាហំ អាសវានំ ខយំ ន បត្តេយ្យំ អហំ ខោម្ហិ បញ្ញវា ។ បេ ។

## តតិយបណ្ណាសក ភយវគ្គ ទី ៤

សិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកមានសេចក្តីចេះដឹងច្រើន ។ បេ ។ ជាអ្នកមុតធ្លុះដោយសម្មាទិដ្ឋិ ១ ជាអ្នកមានចិត្តដំកល់ស៊ប់ ក្នុងសតិប្បដ្ឋានទាំងបួន ១ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ ។ បេ ។ មិនដាក់ធុរៈចោលក្នុងកុសលធម៌ ១ ជាអ្នកមានប្រាជ្ញាប្រកបដោយប្រាជ្ញា ដែលអាចកំណត់ដឹង នូវការកើតនិងការរលត់បាន ជាប្រាជ្ញាដ៏បរិសុទ្ធ អាចទំលុះទំលាយ (នូវគំនរនៃលោភៈជាដើម) ជាប្រាជ្ញាញុំាងទុក្ខឲ្យអស់ទៅដោយប្រពៃ ១ ។ ភិក្ខុនោះ តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អញហ្នឹងឯង ជាអ្នកមានសីល ។ បេ ។ សិក្សាក្នុងសិក្ខាបទទាំងឡាយ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកមានសេចក្តីចេះដឹងច្រើន ចងចាំនូវសូត្រ បំស្ទាត់នូវសូត្រ ។ បេ ។ ជាអ្នកមុតធ្លុះដោយសម្មាទិដ្ឋិ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកមានចិត្តដម្កល់ស៊ប់ក្នុងសតិប្បដ្ឋាន ៤ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ។ បេ ។ មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកមានប្រាជ្ញា ។ បេ ។

សម្មាទុក្ខក្ខយគាមិនិយា តក្ករំ អាសវានំ ខយំ ន បត្តេយ្យន្តិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាសវានំ ខយំ បត្តេតីតិ ។

[៣៧] បញ្ចិមេ ភិក្ខវេ អប្បំ រត្តិយា សុបន្តិ ពហុំ ជគ្គន្តិ ។ កតមេ បញ្ច ។ ឥត្ថី ភិក្ខវេ បុរិសា-ធិប្បាយា អប្បំ រត្តិយា សុបតិ ពហុំ ជគ្គតិ បុរិសោ ភិក្ខវេ ឥត្ថាធិប្បាយោ អប្បំ រត្តិយា សុបតិ ពហុំ ជគ្គតិ ចោរោ ភិក្ខវេ អាទានាធិប្បាយោ អប្បំ រត្តិយា សុបតិ ពហុំ ជគ្គតិ រាជា ភិក្ខវេ រាជករណីយេសុ យុត្តោ អប្បំ រត្តិយា សុបតិ ពហុំ ជគ្គតិ ភិក្ខុ ភិក្ខវេ វិសញ្ញោគាធិប្បាយោ អប្បំ រត្តិយា សុបតិ ពហុំ ជគ្គតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អប្បំ រត្តិយា សុបន្តិ ពហុំ ជគ្គន្តីតិ ។

ជាប្រាជ្ញ ធ្វើកងទុក្ខឲ្យដល់នូវការអស់ទៅដោយប្រពៃបាន ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។

(៣៧) ម្នាលភិក្ខុទាំងឡាយ ជន ៥ ពួកនេះក្នុងវេលារាត្រី រមែងដេកលក់តិច ភ្ញាក់រលឹកច្រើន ។ ជន ៥ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺស្រីដែលមានប្រាថ្នាចំពោះបុរស (ដោយអសទ្ធម្ម) ក្នុងវេលារាត្រី រមែងដេកលក់តិច ភ្ញាក់រលឹកច្រើន ១ ម្នាលភិក្ខុទាំងឡាយ បុរសដែលមានប្រាថ្នាចំពោះស្រី (ដោយអសទ្ធម្ម) ក្នុងវេលារាត្រី រមែងដេកលក់តិច ភ្ញាក់រលឹកច្រើន ១ ម្នាលភិក្ខុទាំងឡាយ ចោរដែលប្រាថ្នាកាន់យក (ទ្រព្យរបស់គេ) ក្នុងវេលារាត្រី ដេកលក់តិច ភ្ញាក់រលឹកច្រើន ១ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាខ្វល់ខ្វាយក្នុងរាជកិច្ច ក្នុងវេលារាត្រី ដេកលក់តិច ភ្ញាក់រលឹកច្រើន ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានប្រាថ្នាដើម្បីអស់សញ្ញោជនៈ (ព្រះនិព្វាន) ក្នុងវេលារាត្រី ដេកលក់តិច ភ្ញាក់រលឹកច្រើន ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកជន ៥ ពួកនេះឯង ក្នុងវេលារាត្រី ដេកលក់តិច ភ្ញាក់រលឹកច្រើន ។

(៣៨) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ នាគោ ភត្តាទកោ ច ហោតិ ឱកាសផរណោ ច លណ្ឌសារណោ ច សលាកគ្គាហី ច រញ្ញោ នាគោត្វេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ រូបានំ អក្ខមោ សទ្ទានំ អក្ខមោ គន្ធានំ អក្ខមោ រសានំ អក្ខមោ ផោដ្ឋព្វានំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ រញ្ញោ នាគោ ភត្តាទកោ ច ហោតិ ឱកាសផរណោ ច លណ្ឌសារណោ ច សលាកគ្គាហី ច រញ្ញោ នាគោត្វេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភត្តាទកោ ច ហោតិ ឱកាសផរណោ ច បីឋមទ្ទនោ ច សលាកគ្គាហី ច ភិក្ខុត្វេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។

(៣៨) ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាង ជាសត្វបានតែខាងស៊ីអាហារផង រាតទីឱកាសផង[១] ជម្រះសំអាតអាចម៍ (ត្រង់ឱកាសនោះ) ផង កាន់យកស្លាកផង[២] តែដល់នូវការរាប់ថា ជាដំរី ដ៏ប្រសើររបស់ស្តេចដែរ ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាងនេះឯង ជាសត្វបានតែខាងស៊ីអាហារផង រាតទីឱកាសផង ជម្រះសំអាតអាចម៍ (ត្រង់ទីឱកាសនោះ) ផង ទទួលយកស្លាកផង តែដល់នូវការរាប់ថា ជាដំរី ដ៏ប្រសើររបស់ស្តេចដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ ជាអ្នកបានតែខាងបរិភោគនូវចង្ហាន់ផង ផ្សាយនូវឱកាសផង ដុសខាត់នូវតាំងផង កាន់យកនូវស្លាកផង តែដល់នូវការរាប់ថាជាភិក្ខុដែរ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។

---

១ រាតទីទុកឱ្យទូលាយត្រង់កន្លែងដែលខ្លួនឈរ ធ្វើឱ្យចង្អៀតដល់ដំរីឯទៀត ។ ២ អាចចុះបញ្ជីរាប់ចំនួនដំរីថា ដំរីប៉ុណ្ណេះប៉ុណ្ណោះ ។ អដ្ឋកថា ។

ឥធ ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ រូបានំ អក្ខមោ សទ្ទានំ អក្ខមោ គន្ធានំ អក្ខមោ រសានំ អក្ខមោ ផោដ្ឋព្វានំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភត្តាទកោ ច ហោតិ ឱកាស-ផរណោ ច បីឋមទ្ទនោ ច សលាកគ្គាហី ច ភិក្ខុត្វេវ សង្ខំ គច្ឆតិ ។

(៣៩) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ នាគោ ន រាជារហោ ហោតិ ន រាជភោគ្គោ ន រញ្ញោ អង្គន្ត្វេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ រូបានំ អក្ខមោ សទ្ទានំ អក្ខមោ គន្ធានំ អក្ខមោ រសានំ អក្ខមោ ផោដ្ឋព្វានំ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ រូបានំ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ ហត្ថិកាយំ វា ទិស្វា អស្សកាយំ វា ទិស្វា រថកាយំ វា ទិស្វា បត្តិកាយំ វា ទិស្វា សំសី-ទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ រូបានំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ជាអ្នកមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកបានតែខាងបរិភោគបង្ហាន់ផង ផ្សាយឧកាសផង ដុសខាត់នូវតាំងផង កាន់យកនូវស្លាកផង តែដល់នូវការរាប់ថា ជាភិក្ខុដែរ ។

(៣៩) ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេចប្រកបដោយអង្គ ៥ យ៉ាង មិនគួរជារាជយាន មិនសមជារាជបម្រើ មិនដល់នូវការរាប់ថា ជាអង្គរបស់ស្តេចបានឡើយ ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងរូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានឃើញពួកពលដំរីក្តី ឃើញពួកពលសេះក្តី ឃើញពួកពលរថក្តី ឃើញពួកពលថ្មើរជើងក្តី ក៏ក្រោបក្រាញ មិនរុលទៅមុខ មិនហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងរូបយ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ សទ្ទានំ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ ហត្ថិសទ្ទំ វា សុត្វា អស្សសទ្ទំ វា សុត្វា រថសទ្ទំ វា សុត្វា បត្តិសទ្ទំ វា សុត្វា ភេរិបណវសង្ខតិណវនិន្នាទសទ្ទំ វា សុត្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ សទ្ទានំ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ គន្ធានំ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ យេ តេ រញ្ញោ នាគា អភិជាតា សង្គាមាវចរា តេសំ មុត្តករីសស្ស គន្ធំ ឃាយិត្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ គន្ធានំ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ រសានំ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ

ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងសំឡេង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានឮសូរសន្ធឹកដំរីក្តី ឮសូរសន្ធឹកសេះក្តី ឮសូរសន្ធឹករថក្តី ឮសូរសន្ធឹកពលថ្មើរជើងក្តី ឮសូរគងរំពងនៃស្គរ តូច ស្គរធំ ស័ង្ខ ស្គរសឹកសង្គ្រាមក្តី ក៏ក្រាបក្រាញ មិនរុលទៅមុខ មិនហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងសំឡេងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងក្លិន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានធុំក្លិនមូត្រលាមករបស់ដំរីដែលមានជាតិខ្ពង់ខ្ពស់ ធ្លាប់ចុះស្នាម ក្នុងសង្គ្រាមរបស់ស្តេចដទៃ ក៏ក្រាបក្រាញ មិនរុលទៅមុខ មិនហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងក្លិន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម

ឯកិស្សា វា តិណោទកទត្តិយា វិមានិតោ ទ្វីហិ វា តីហិ វា ចតូហិ វា បញ្ចហិ វា តិណោទកទត្តីហិ វិមានិតោ សំសីទតិ វិសីទតិ ន សណ្ឋាតិ ន សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ រសានំ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ ផោដ្ឋព្វានំ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ ឯកេន វា សល្លេន វិទ្ធោ ទ្វីហិ វា តីហិ វា ចតូហិ វា បញ្ចហិ វា សល្លេហិ វិទ្ធោ សំសីទតិ វិសីទតិ ន សណ្ឋាតិ ន សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ អក្ខមោ ហោតិ ផោដ្ឋព្វានំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ រញ្ញោ នាគោ ន រាជារហោ ហោតិ ន រាជភោគ្គោ ន រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ន អាហុនេយ្យោ ហោតិ ន បាហុនេយ្យោ ន ទក្ខិណេយ្យោ ន អញ្ជលិករណីយោ ន អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ បញ្ចហិ ។

មិនមានគេកប់ភានដោយឲ្យស្មោនឹងទឹកម្តងក្តី មិនមានគេកប់ភានដោយឲ្យស្មោនឹងទឹក ២ ដងក្តី ៣ ដងក្តី ៤ ដងក្តី ៥ ដងក្តី ក៏ក្រោបក្រាញ មិនរុលទៅមុខ មិនហ៊ានចូលទៅកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងរសយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងផ្សព្វ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម ត្រូវមុតដោយកម្ទាំងព្រួញ ១ ក្តី ឬត្រូវមុតដោយកម្ទាំងព្រួញ ២ ក្តី ៣ ក្តី ៤ ក្តី ៥ ក្តី ក៏ក្រោបក្រាញ មិនរុលទៅមុខ មិនហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងផ្សព្វយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាងនេះឯង មិនគួរជារាជយាន មិនសមជារាជបម្រើ មិនដល់នូវការរាប់ថា ជាអង្គរបស់ស្តេចបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ ជាអ្នកមិនគួរទទួលនូវទានដែលគេនាំមកបូជា មិនគួរទទួលនូវវត្ថុដែលគេរៀបដើម្បីភ្ញៀវ មិនគួរទទួលនូវទក្ខិណាទាន មិនគួរគេធ្វើអញ្ជលិកម្ម មិនមែនជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។

ឥធ ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ រូបានំ អក្ខមោ សទ្ទានំ អក្ខមោ គន្ធានំ អក្ខមោ រសានំ អក្ខមោ ផោដ្ឋព្វានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ រូបានំ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា រជនីយេ រូបេ សារជ្ជតិ ន សក្កោតិ ចិត្តំ សមាទហិតុំ ឯវំ ខោ ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ រូបានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ សទ្ទានំ ។ ឥធ ភិក្ខវេ ភិក្ខុ សោតេន សទ្ទំ សុត្វា រជនីយេ សទ្ទេ សារជ្ជតិ ន សក្កោតិ ចិត្តំ សមាទហិតុំ ឯវំ ខោ ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ សទ្ទានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ គន្ធានំ ។ ឥធ ភិក្ខវេ ភិក្ខុ ឃានេន គន្ធំ ឃាយិត្វា រជនីយេ គន្ធេ សារជ្ជតិ ន សក្កោតិ ចិត្តំ សមាទហិតុំ ឯវំ ខោ ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ គន្ធានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ រសានំ ។ ឥធ ភិក្ខវេ ភិក្ខុ ជិវ្ហាយ រសំ សាយិត្វា រជនីយេ រសេ សារជ្ជតិ ន សក្កោតិ ចិត្តំ សមាទហិតុំ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ជាអ្នកមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ មិនអត់ធន់នឹងរូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ បានឃើញរូបដោយភ្នែក រមែងត្រេកអរក្នុងរូបដែលគួរត្រេកអរ មិនអាចដំកល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនអត់ធន់នឹងរូប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ មិនអត់ធន់នឹងសំឡេង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ បានឮសំឡេងដោយត្រចៀក រមែងត្រេកអរក្នុងសំឡេងដែលគួរត្រេកអរ មិនអាចដំកល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនអត់ធន់នឹងសំឡេង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ មិនអត់ធន់នឹងក្លិន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ធុំក្លិនដោយច្រមុះ រមែងត្រេកអរក្នុងក្លិនដែលគួរត្រេកអរ មិនអាចដំកល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនអត់ធន់នឹងក្លិន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ មិនអត់ធន់នឹងរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ លិទ្ធភ្លក្សរសដោយអណ្តាត រមែងត្រេកអរក្នុងរសដែលគួរត្រេកអរ មិនអាចដើម្បីដំកល់ចិត្តឲ្យនឹងបាន

ឯវំ ខោ ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ រសានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ ផោដ្ឋព្វានំ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេន ផោដ្ឋព្វំ ផុសិត្វា រជនីយេ ផោដ្ឋព្វេ សារជ្ជតិ ន សក្កោតិ ចិត្តំ សមាទហិតុំ ឯវំ ខោ ភិក្ខវេ ភិក្ខុ អក្ខមោ ហោតិ ផោដ្ឋព្វានំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ន អាហុនេយ្យោ ហោតិ ន បាហុនេយ្យោ ន ទក្ខិណេយ្យោ ន អញ្ជលិករណីយោ ន អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ នាគោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ ខមោ ហោតិ រូបានំ ខមោ សទ្ទានំ ខមោ គន្ធានំ ខមោ រសានំ ខមោ ផោដ្ឋព្វានំ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ ខមោ ហោតិ រូបានំ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ ហត្ថិកាយំ វា ទិស្វា អស្សកាយំ វា ទិស្វា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនអត់ធន់នឹងរស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ មិនអត់ធន់នឹងផ្សព្វ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ បានពាល់ត្រូវនូវផ្សព្វដោយកាយ រមែងត្រេកអរក្នុងផ្សព្វ ដែលគួរត្រេកអរ មិនអាចដំកល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនអត់ធន់នឹងផ្សព្វ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរទទួលនូវទាន ដែលគេនាំមកបូជា មិនគួរទទួលនូវវត្ថុ ដែលគេរៀបចំដើម្បីភ្ញៀវ មិនគួរទទួលនូវទក្ខិណាទាន មិនគួរគេធ្វើអញ្ជលីកម្ម មិនមែនជាបុញ្ញក្ខេត្ត ដ៏ប្រសើរ របស់សត្វលោកឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាង ទើបគួរជារាជយាន គួរជារាជបម្រើ ដល់នូវការរាប់ថា ជាអង្គរបស់ស្តេចបាន ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ អត់ធន់នឹងរូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានឃើញពួកពលដំរីក្តី ឃើញពួកពលសេះក្តី

រថកាយំ វា ទិស្វា បត្តិកាយំ វា ទិស្វា ន សំសីទតិ
ន វិសីទតិ សន្ថម្ភតិ សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ ខោ
ភិក្ខវេ រញ្ញោ នាគោ ខមោ ហោតិ រូបានំ ។ កថញ្ច
ភិក្ខវេ រញ្ញោ នាគោ ខមោ ហោតិ សទ្ទានំ ។ ឥធ ភិក្ខវេ
រញ្ញោ នាគោ សង្គាមគតោ ហត្ថិសទ្ទំ វា សុត្វា អស្ស‑
សទ្ទំ វា សុត្វា រថសទ្ទំ វា សុត្វា បត្តិសទ្ទំ វា សុត្វា
ភេរិបណវសង្ខតិណវនិន្នាទសទ្ទំ វា សុត្វា ន សំសីទតិ
ន វិសីទតិ សន្ថម្ភតិ សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ
ខោ ភិក្ខវេ រញ្ញោ នាគោ ខមោ ហោតិ សទ្ទានំ ។
កថញ្ច ភិក្ខវេ រញ្ញោ នាគោ ខមោ ហោតិ គន្ធានំ ។
ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ យេ តេ រញ្ញោ
នាគា អភិជាតា សង្គាមាវចរា តេសំ មុត្តករីសស្ស
គន្ធំ ឃាយិត្វា ន សំសីទតិ ន វិសីទតិ សន្ថម្ភតិ
សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ
ខមោ ហោតិ គន្ធានំ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ
ខមោ ហោតិ រសានំ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ

ឃើញពួកពលរថក្តី ឃើញពួកពលថ្មើរជើងក្តី ក៏មិនក្រាប មិនក្រាញ រវើងរវល់ទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច អត់ធន់នឹងរូប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច អត់ធន់នឹងសំឡេង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានឮសូរសន្ធឹកដំរីក្តី ឮសូរសន្ធឹកសេះក្តី ឮសូរសន្ធឹករថក្តី ឮសូរសន្ធឹកពលថ្មើរជើងក្តី ឬ ឮសូរគឹកកងរំពងស្គរតូច ស្គរធំ ស័ង្ខ ស្គរសឹកសង្គ្រាមក្តី មិនក្រាប មិនក្រាញ រវើងរវល់ទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច អត់ធន់នឹងសំឡេង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច អត់ធន់នឹងក្លិន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម ធុំក្លិនមូត្រលាមកដារបស់ដំរីដែលមានជាតិខ្ពង់ខ្ពស់ធ្លាប់ចុះសាមសង្គ្រាមរបស់ស្តេច ក៏មិនក្រាប មិនក្រាញ រវើងរវល់ទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច អត់ធន់នឹងក្លិន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច អត់ធន់នឹងរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ

សង្គាមគតោ ឯកិស្សា វា តិណោទកទត្តិយា វិមា-
និតោ ទ្វីហិ វា តីហិ វា ចតូហិ វា បញ្ចហិ វា តិណោ-
ទកទត្តីហិ វិមានិតោ ន សំសីទតិ ន វិសីទតិ សន្ថ-
ម្ភតិ សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ ខោ ភិក្ខវេ
រញ្ញោ នាគោ ខមោ ហោតិ រសានំ ។ កថញ្ច
ភិក្ខវេ រញ្ញោ នាគោ ខមោ ហោតិ ផោដ្ឋព្វានំ ។
ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ ឯកេន
វា សរវេគេន វិទ្ធោ ទ្វីហិ វា តីហិ វា ចតូហិ
វា បញ្ចហិ វា សរវេគេហិ វិទ្ធោ ន សំសីទតិ ន វិសី-
ទតិ សន្ថម្ភតិ សក្កោតិ សង្គាមំ ឱតរិតុំ ឯវំ ខោ
ភិក្ខវេ រញ្ញោ នាគោ ខមោ ហោតិ ផោដ្ឋព្វានំ ។
ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នា-
គតោ រញ្ញោ នាគោ រាជារហោ ហោតិ រាជភោគ្គោ
រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ
បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ
ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ

ទៅកាន់សង្គ្រាម មិនមានគេរាប់អានដោយឲ្យទឹកនឹងស្មៅម្ដងក្ដី មិនមានគេរាប់អានដោយឲ្យស្មៅនឹងទឹក ២ ដងក្ដី ៣ ដងក្ដី ៤ ដងក្ដី ៥ ដងក្ដី ក៏មិនក្រោប មិនក្រាញ រមែងរុលទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្ដេច អត់ធន់នឹងរស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្ដេច អត់ធន់នឹងផ្សព្វ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្ដេចក្នុងលោកនេះ ទៅកាន់សង្គ្រាម ត្រូវមុតដោយកម្ចាំងព្រួញ ១ ក្ដី ឬត្រូវមុតដោយកម្ចាំងព្រួញ ២ ក្ដី ៣ ក្ដី ៤ ក្ដី ៥ ក្ដី ក៏មិនក្រោប មិនក្រាញ រមែងរុលទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្ដេច អត់ធន់នឹងផ្សព្វ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដំរី ដ៏ប្រសើររបស់ស្ដេច ប្រកបដោយអង្គ ៥ យ៉ាងនេះឯង ទើបគួរជារាជយាន សមជារាជបម្រើ ដល់នូវការរាប់ថា ជាអង្គរបស់ស្ដេចបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ ទើបគួរទទួលនូវទានដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេធ្វើអញ្ជលីកម្ម

អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ ខមោ ហោតិ រូបានំ ខមោ សទ្ទានំ ខមោ គន្ធានំ ខមោ រសានំ ខមោ ផោដ្ឋព្វានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ ខមោ ហោតិ រូបានំ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា រជនីយេ រូបេ ន សារជ្ជតិ សក្កោតិ ចិត្តំ សមាទហិតុំ ឯវំ ខោ ភិក្ខវេ ភិក្ខុ ខមោ ហោតិ រូបានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ ខមោ ហោតិ សទ្ទានំ ។ ឥធ ភិក្ខវេ ភិក្ខុ សោតេន សទ្ទំ សុត្វា រជនីយេ សទ្ទេ ន សារជ្ជតិ សក្កោតិ ចិត្តំ សមាទហិតុំ ឯវំ ខោ ភិក្ខវេ ភិក្ខុ ខមោ ហោតិ សទ្ទានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ ខមោ ហោតិ គន្ធានំ ។ ឥធ ភិក្ខវេ ភិក្ខុ ឃានេន គន្ធំ ឃាយិត្វា រជនីយេ គន្ធេ ន សារជ្ជតិ សក្កោតិ ចិត្តំ សមាទហិតុំ ឯវំ ខោ ភិក្ខវេ ភិក្ខុ ខមោ ហោតិ គន្ធានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ ខមោ ហោតិ រសានំ ។ ឥធ ភិក្ខវេ ភិក្ខុ ជិវ្ហាយ រសំ សាយិត្វា

ជាបុញ្ញកេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់ទន់នឹងរូប ១ អត់ធន់ទន់នឹងសំឡេង ១ អត់ធន់ទន់នឹងក្លិន ១ អត់ធន់ទន់នឹងរស ១ អត់ធន់ទន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកអត់ធន់ទន់នឹងរូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូប ដោយភ្នែក មិនត្រេកអរ ក្នុងរូបដែលគួរត្រេកអរ អាចដំកល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុអត់ធន់ទន់នឹងរូបយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ អត់ធន់ទន់នឹងសំឡេង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឮនូវសំឡេង ដោយត្រចៀក មិនត្រេកអរ ក្នុងសំឡេងដែលគួរត្រេកអរ អាចដំកល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុអត់ធន់ទន់នឹងសំឡេង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ អត់ធន់ទន់នឹងក្លិន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធុំក្លិន ដោយច្រមុះ មិនត្រេកអរ ក្នុងក្លិនដែលគួរត្រេកអរ អាចដំកល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុអត់ធន់ទន់នឹងក្លិន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ អត់ធន់ទន់នឹងរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ លិទ្ធភ្លក្សរសដោយអណ្តាត

រជនីយេ រសេ ន សារជ្ជតិ សក្កោតិ ចិត្តំ សមាទហិតុំ ឯវំ ខោ ភិក្ខវេ ភិក្ខុ ខមោ ហោតិ រសានំ ។ កថញ្ច ភិក្ខវេ ភិក្ខុ ខមោ ហោតិ ផោដ្ឋព្វានំ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេន ផោដ្ឋព្វំ ផុសិត្វា រជនីយេ ផោដ្ឋព្វេ ន សារជ្ជតិ សក្កោតិ ចិត្តំ សមាទហិតុំ ឯវំ ខោ ភិក្ខវេ ភិក្ខុ ខមោ ហោតិ ផោដ្ឋព្វានំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(៤០) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ នាគោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សោតា ច ហោតិ ហន្តា ច រក្ខិតា ច ខន្តា ច គន្តា ច ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ សោតា ហោតិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ យមេនំ ហត្ថិទម្មសារថិ ការណំ ការេតិ

មិនត្រេកអរ ក្នុងរសដែលគួរត្រេកអរ អាចដំកល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុអត់ធន់នឹងរស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះភិក្ខុជាអ្នកអត់ធន់នឹងផ្សព្វ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពាល់ត្រូវនូវផ្សព្វ ដោយកាយ មិនត្រេកអរ ក្នុងផ្សព្វដែលគួរត្រេកអរ អាចដំកល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុអត់ធន់នឹងផ្សព្វ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរ ទទួលនូវទានដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

(៤០) ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាង គួរជារាជយាន សមជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចក្នុងលោកនេះ ជាសត្វប្រសប់ខាងការស្តាប់ពាក្យ ១ សម្លាប់ (សត្រូវ) ១ រក្សាខ្លួន ១ អត់ធន់ ១ ទៅកាន់ទិស ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច ជាសត្វ (ប្រសប់) ខាងការស្តាប់ពាក្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចក្នុងលោកនេះ កាលបើសារថី អ្នកបង្ហាត់ដំរី ប្រើឲ្យធ្វើការណ៍ណា

យទិ វា កតបុព្វំ យទិ វា អកតបុព្វំ តំ អដ្ឋិំ កត្វា មនសិកត្វា សព្វំ ចេតសា សមន្នាហរិត្វា ឱហិ-តសោតោ សុណាតិ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ សោតា ហោតិ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ ហន្តា ហោតិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាម-គតោ ហត្ថិម្បិ ហនតិ ហត្ថារូហម្បិ ហនតិ អស្សម្បិ ហនតិ អស្សារូហម្បិ ហនតិ រថម្បិ ហនតិ រថិកម្បិ[1] ហនតិ បត្តិកម្បិ ហនតិ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ ហន្តា ហោតិ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ រក្ខិតា ហោតិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ រក្ខតិ បុរិមំ កាយំ រក្ខតិ បច្ឆិមំ កាយំ រក្ខតិ បុរិមេ បាទេ រក្ខតិ បច្ឆិមេ បាទេ រក្ខតិ សីសំ រក្ខតិ កណ្ណេ រក្ខតិ ទន្តេ រក្ខតិ សោណ្ឌំ រក្ខតិ វាលធិំ រក្ខតិ ហត្ថារូហំ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ រក្ខិតា ហោតិ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ ខន្តា ហោតិ ។

---

១ ឱ. រថារូហម្បិ ។ ម. រថានិកម្បិ ។

នោះបើខ្លួនធ្លាប់ធ្វើក្តី មិនធ្លាប់ធ្វើក្តី ក៏ខំផិតផង់យកចិត្តទុកដាក់នូវការណ៍នោះ ប្រមូលការណ៍ទាំងអស់ដោយចិត្ត ហើយផ្ទៀងត្រចៀកស្តាប់ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វ (ប្រសប់) ខាងការស្តាប់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច ជាសត្វសម្លាប់ (សត្រូវ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម រមែងសម្លាប់ដំរីខ្លះ សម្លាប់ទម័កដំរីខ្លះ សម្លាប់សេះខ្លះ សម្លាប់អ្នកជិះសេះខ្លះ បៀតបៀនរថខ្លះ សម្លាប់អ្នកបររថខ្លះ សម្លាប់ពលថ្មើរជើងខ្លះ ម្នាលភិក្ខុទាំង-ឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វសម្លាប់ (សត្រូវ) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច ជាសត្វចេះរក្សាខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចក្នុងលោកនេះ ទៅកាន់សង្គ្រាម រមែងរក្សាកាយខាងមុខ រក្សាកាយខាងក្រោយ រក្សាជើងខាងមុខ រក្សាជើងខាងក្រោយ រក្សាក្បាល រក្សាត្រចៀក រក្សាភ្លុក រក្សាប្រមោយ រក្សាពោមកន្ទុយ រក្សាទម័ក ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វចេះរក្សា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច ជាសត្វអត់ធន់ តើដូចម្តេច ។

ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ ខមោ ហោតិ សត្តិប្បហារានំ (១) ឧសុប្បហារានំ ផរសុប្បហារានំ ភេរិបណវសង្ខតិណវនិន្នាទសទ្ទានំ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ ខន្តា ហោតិ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ គន្តា ហោតិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ យមេនំ ហត្ថិទម្មសារថិ ទិសំ បេសេតិ យទិ វា គតបុព្វំ យទិ វា អគតបុព្វំ តំ ខិប្បញ្ញេវ គន្តា ហោតិ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ គន្តា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ រញ្ញោ នាគោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សោតា ច ហោតិ ហន្តា ច រក្ខិតា ច

១ ឱ. ម. ឯត្ថន្តរេ អសិប្បហារានំ ។

ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម ជាសត្វអត់ធន់នូវការប្រហារ ដោយលំពែង ប្រហារដោយព្រួញ ប្រហារ ដោយប៉ូរថៅ ទ្រាំស្គរគឹកកងរំពងស្គរតូច ស្គរធំ ស័ង្ខ ស្គរសឹកសង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វអត់ធន់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរី ដ៏ប្រសើររបស់ស្តេច ជាសត្វទៅកាន់ទិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ កាលបើសារថីអ្នកបង្ហាត់ដំរី ប្រើឲ្យទៅកាន់ទិសណា ទោះបីខ្លួនធ្លាប់ទៅក្តី មិនធ្លាប់ទៅក្តី ទៅកាន់ទិសនោះដោយឆាប់រហ័សបាន ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វទៅកាន់ (ទិស) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ នេះឯង ទើបជាសត្វគួរជារាជយាន សមជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ ទើបគួរ ទទួលនូវទានដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រសប់ខាងការស្តាប់ ១ សម្លាប់ (អកុសលវិតក្ក) ១ រក្សាឥន្ទ្រិយ ១

ខន្តា ច គន្តា ច ។ កថញ្ច ភិក្ខវេ ភិក្ខុ សោតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ អដ្ឋិកត្វា មនសិកត្វា សព្វំ ចេតសា សមន្នាហរិត្វា ឱហិតសោតោ ធម្មំ សុណាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ សោតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ហន្តា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហាតិ វិនោទេតិ ហនតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ ... ឧប្បន្នំ វិហឹសាវិតក្កំ ... ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហាតិ វិនោទេតិ ហនតិ ព្យន្តីករោតិ អនភាវំ គមេតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ហន្តា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ រក្ខិតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា

អត់ធន់ ១ ទៅកាន់ (ទិសគឺព្រះនិព្វាន) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ជាអ្នកប្រសប់ខាងការស្តាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ខំផ្ចិតផ្ចង់យកចិត្តទុកដាក់ក្នុងធម៌វិន័យ ដែលតថាគតប្រកាសហើយសំដែងទុក ប្រមូលនូវធម៌ទាំងពួងដោយចិត្ត ហើយផ្ទៀងត្រចៀកស្តាប់ធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រសប់ខាងការស្តាប់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ អ្នកសម្លាប់ (អកុសលវិតក្ក) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទទួលទុក លះបង់ បន្ទោបង់ សម្លាប់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតនូវកាមវិតក្កដែលកើតហើយ នូវព្យាបាទវិតក្កដែលកើតហើយ ... នូវវិហឹសាវិតក្កដែលកើតហើយ ... មិនទទួលទុក លះបង់ បន្ទោបង់ សម្លាប់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតនូវធម៌ជាបាបអកុសលដែលកើតហើយរឿយ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្លាប់ (អកុសលវិតក្ក) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ អ្នករក្សា (ឥន្ទ្រិយ) តើដូច-ម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក

ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ រក្ខិតោ ហោតិ ។ កតមញ្ច ភិក្ខវេ ភិក្ខុ ខន្តា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ខមោ ហោតិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសរីសបសម្ផស្សានំ

ហើយមិនក្តោបកាន់នូវនិមិត្ត មិនក្តោបកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោ-មនស្ស ជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមបុគ្គល ដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... លិទ្ធរសដោយអណ្តាត... ពាល់ត្រូវនូវផ្សព្វដោយកាយ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ហើយមិនក្តោបកាន់នូវនិមិត្ត មិនក្តោបកាន់នូវអនុព្យញ្ជនៈ អភិ-ជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករក្សាឥន្ទ្រិយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ អ្នកអត់ធន់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់ នឹងត្រជាក់ ក្តៅ សេចក្តីឃ្លាន ស្រេក សម្ផស្ស រោម មូស ខ្យល់ កំដៅថ្ងៃ

ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសកជាតិកោ ហោតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ខន្តា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ គន្តា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យា សា ទិសា អគតបុព្វា ឥមិនា ទីឃេន អទ្ធុនា យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ តំ ខិប្បញ្ញេវ គន្តា ហោតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ គន្តា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

ភដវគ្គោ ចតុត្ថោ ។

តតិយបណ្ណាសក ភជវគ្គ ទី ៤

សត្វទីឃជាតិនិងពាក្យពោលអាក្រក់ គួរឲ្យកើតទុក្ខ ជាអ្នកប្រកបដោយជាតិចេះអត់សង្កត់នូវវេទនាដែលប្រជុំក្នុងសរីរៈ ជាទុក្ខ ដ៏ក្លាខ្លាំង ខ្លោចផ្សា មិនស្រួល មិនជាទីគាប់ចិត្ត ជាវេទនាគួរនាំយកនូវជីវិតដែលកើតឡើងហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកអត់ធន់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នក (ទៅកាន់ទិស) តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ទិសពោលគឺការរម្ងាប់សង្ខារទាំងអស់ ការលះបោលនូវឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ ការមិនមានតណ្ហាជាគ្រឿងចាក់ស្រែះឯណា ដែលបុគ្គលមិនធ្លាប់ទៅដោយកាលយូរអង្វែងនេះ ភិក្ខុក្នុងសាសនានេះ ជាអ្នកទៅកាន់ទិសនោះបានដោយឆាប់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកទៅ (កាន់ទិស) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះឯង ទើបគួរ ទទួលនូវទានដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេធ្វើអញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

ចប់ ភជវគ្គ ទី ៤ ។

## តស្សុទ្ទានំ

ចក្កានុវត្តនា រាជា

យស្សំ ទិសំ ទ្វេ ច បត្ថនា

អប្បំ សុបតិ ភត្តាទា

អក្ខមោ សោតវេន ចាតិ ។

## ឧទ្ទាននៃវគ្គនោះគឺ:

និយាយអំពីស្តេចចក្រពត្តិញុំាងអាណាចក្រឲ្យប្រព្រឹត្តទៅ ១ អំពីព្រះរាជបុត្រប្រព្រឹត្តទៅតាមអាណាចក្រ ១ អំពីស្តេចចក្រពត្តិជាធម្មរាជ ១ អំពីស្តេចចក្រពត្តិគង់នៅក្នុងទិស ១ អំពីសេចក្តីប្រាថ្នា ២ លើក អំពីបុគ្គលដេកលក់តិច ១ អំពីដំរីស៊ីនូវអាហារច្រើន ១ អំពីដំរីមិនអត់ធន់ ១ អំពីដំរីជាសត្វប្រសប់ខាងការស្តាប់ ១ ។

# តិកណ្ឌកីវគ្គោ បញ្ចមោ

(៤១) បញ្ចិមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ បញ្ច ។ ទត្វា អវជានាតិ សំវាសេន អវជានាតិ អាទេយ្យមុខោ ហោតិ លោលោ ហោតិ មន្ទោ មោមូហោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ទត្វា អវជានាតិ ។ ឥធ ភិក្ខវេ បុគ្គលោ បុគ្គលស្ស ទេតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ ។ តស្ស ឯវំ ហោតិ អហំ ទេមិ អយំ បដិគ្គណ្ហាតីតិ ។ តមេនំ ទត្វា អវជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ ទត្វា អវជានាតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សំវាសេន អវជានាតិ ។ ឥធ ភិក្ខវេ បុគ្គលោ បុគ្គលេន សទ្ធឹ សំវសតិ ទ្វេ វា តីណិ វា វស្សានិ ។ តមេនំ សំវាសេន អវជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ សំវាសេន អវជានាតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ អាទេយ្យមុខោ ហោតិ ។

## តិកណ្ណកីវគ្គ ទី ៥

(៤១) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក ដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យហើយត្រឡប់មើលងាយគេវិញ ១ មើលងាយព្រោះការនៅរួមគ្នា ១ មានការកាន់យកតាមពាក្យគេជាប្រមាណ ១ ជាអ្នកលេះឡោះ ១ ជាអ្នកល្ងង់ខ្លៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឲ្យហើយត្រឡប់មើលងាយគេវិញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ ឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកមានជម្ងឺ ដល់បុគ្គល (ដទៃ) ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញរមែងឲ្យ បុគ្គលនេះរមែងទទួល ។ លុះឲ្យរួចហើយ ត្រឡប់មើលងាយអ្នកទទួលនោះវិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យហើយត្រឡប់មើលងាយគេវិញ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមើលងាយ ព្រោះការនៅរួមគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ នៅរួមជាមួយនឹងបុគ្គលអស់ ២ ឬ ៣ ឆ្នាំ ។ មើលងាយបុគ្គលនោះ ព្រោះការនៅរួមគ្នា ម្នាលភិក្ខុទាំងឡាយ បុគ្គលមើលងាយ ព្រោះការនៅរួមគ្នា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានការកាន់យកតាមពាក្យគេជាប្រមាណ តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ បរស្ស វណ្ណោ ច អវណ្ណោ ច ភាសិយមានេ តំ ខិប្បញ្ញេវ អធិមុច្ចិតោ[១] ហោតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ អាធេយ្យមុខោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ លោលោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឥត្តរសទ្ធោ ហោតិ ឥត្តរភត្តិ ឥត្តរបេមោ ឥត្តរប្បសាទោ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ លោលោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ មន្ទោ មោមូហោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ កុសលាកុសលេ ធម្មេ ន ជានាតិ សាវជ្ជានវជ្ជេ ធម្មេ ន ជានាតិ ហីនប្បណីតេ ធម្មេ ន ជានាតិ កណ្ហសុក្កសប្បដិភាគេ ធម្មេ ន ជានាតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ មន្ទោ មោមូហោ ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

(៤២) បញ្ចិមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អារភតិ ច វិប្បដិសារី ច ហោតិ

---

១ ឱ. ម. អធិមុច្ចិតា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កាលគេពោលសរសើរ ឬតិះដៀលដល់បុគ្គលដទៃ រមែងជឿស៊ប់នូវពាក្យនោះមួយរំពេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានការកាន់យកតាមពាក្យគេជាប្រមាណ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលេះឡោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសទ្ធាតិច មានការសេពគប់តិច មានសេចក្តីស្រឡាញ់តិច មានសេចក្តីជ្រះថ្លាតិច ម្នាលភិក្ខុទាំងឡាយ បុគ្គលលេះឡោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្ងង់ខ្លៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនដឹងនូវធម៌ជាកុសល នឹងធម៌ជាអកុសល មិនដឹងនូវធម៌ប្រកបដោយទោសនឹងធម៌មិនប្រកបដោយទោស មិនដឹងនូវធម៌ថោកទាបនឹងធម៌ដ៏ឧត្តម មិនដឹងនូវធម៌មានចំណែកប្រៀបដោយខ្មៅនឹងស ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលល្ងង់ខ្លៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៥ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[៤២] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៥ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៥ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងប្រារព្ធផង មានសេចក្តីក្តៅក្រហាយផង(១)

---

១ បានដល់ការប្រព្រឹត្តិកន្លងអាបត្តិហើយក្តៅក្រហាយ ដោយការប្រព្រឹត្តិកន្លងនោះ ។

តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ អារភតិ ន វិប្បដិសារី ហោតិ តញ្ច ចេតោ-វិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេ-សា និរុជ្ឈន្តិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ន អារភតិ វិប្បដិសារី ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញា-វិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ន អារភតិ ន វិប្បដិសារី ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។

តាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ រមែងប្រារព្ធ តែមិនមានសេចក្តីក្តៅក្រហាយ[១] ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមិនប្រារព្ធ តែមានសេចក្តីក្តៅក្រហាយ[២] ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមិនប្រារព្ធ មិនមានសេចក្តីក្តៅក្រហាយ តែមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។

---

១ ព្រោះត្រូវអាបត្តិហើយ បានចេញចាកអាបត្តិ ។ ២ ត្រូវអាបត្តិម្តងហើយ បានចេញចាកអាបត្តិនោះ មិនត្រូវអាបត្តិណាមួយខាងក្រោយទៀតទេ តែមិនអាចបំបាត់នូវសេចក្តីក្តៅក្រហាយឡើយ ។ អដ្ឋកថា ។

ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ន អារភតិ ន វិប្បដិសារី ហោតិ តញ្ច ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ យថាភូតំ បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ អារភតិ ច វិប្បដិសារី ច ហោតិ តញ្ច ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោ ឯវមស្ស វចនីយោ អាយស្មតោ ខោ អារភជា អាសវា សំវិជ្ជន្តិ វិប្បដិសារជា អាសវា បវឌ្ឍន្តិ[១] សាធុ វតាយស្មា អារភជេ អាសវេ បហាយ វិប្បដិសារជេ អាសវេ បដិវិនោទេត្វា ចិត្តំ បញ្ញញ្ច ភាវេតុ[២] ឯវមាយស្មា អមុនា បញ្ចមេន បុគ្គលេន សមសមោ ភវិស្សតីតិ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ អារភតិ ន វិប្បដិសារី ហោតិ

១ ម. សំវឌ្ឍន្តិ ។ ២ ឱ. ភាវេតុំ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមិនប្រារព្ធ មិនមានសេចក្តីក្តៅក្រហាយ ដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៥ ពួកនោះ បុគ្គលណា រមែងប្រារព្ធផង មានសេចក្តីក្តៅក្រហាយផង មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ។ បុគ្គលនោះ អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះថា អាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ រមែងមានអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ រមែងចំរើនឡើងដល់លោកដ៏មានអាយុ ហេតុនោះ សូមលោកដ៏មានអាយុ លះបង់នូវអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ បន្ទោបង់នូវអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ ហើយចំរើននូវចិត្តនិងបញ្ញាដោយល្អចុះ ធ្វើយ៉ាងនេះ ទើបលោកដ៏មានអាយុស្មើគ្នានឹងបុគ្គលទី ៥ ឯណោះបាន ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៥ ពួកនោះ បុគ្គលណារមែងប្រារព្ធ តែមិនមានសេចក្តីក្តៅក្រហាយ

តញ្ច ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោ ឯវមស្ស វចនីយោ អាយស្មតោ ខោ អារភជា អាសវា សំវិជ្ជន្តិ វិប្បដិសារជា អាសវា នប្បវឌ្ឍន្តិ សាធុ វតាយស្មា អារភជេ អាសវេ បហាយ ចិត្តំ បញ្ញញ្ច ភាវេតុ ឯវមាយស្មា អមុនា បញ្ចមេន បុគ្គលេន សមសមោ ភវិស្សតីតិ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ ន អារភតិ វិប្បដិសារី ហោតិ តញ្ច ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។

មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ ។ បុគ្គលនោះ អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះថា អាសវៈទាំងឡាយ ដែលកើតអំពីសេចក្ដីប្រាព្ធ រមែងមានអាសវៈទាំង-ឡាយ ដែលកើតអំពីសេចក្ដីក្ដៅក្រហាយ មិនចំរើនឡើងដល់លោកដ៏មានអាយុៈទេ ហេតុនោះ សូមលោកដ៏មានអាយុ លះបង់នូវអាសវៈទាំង-ឡាយ ដែលកើតអំពីសេចក្ដីប្រាព្ធ ហើយចំរើននូវចិត្តនិងបញ្ញាដោយល្អចុះ ធ្វើយ៉ាងនេះ ទើបលោកដ៏មានអាយុស្មើគ្នា និងបុគ្គលទី ៥ ឯណោះបាន ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គលទាំង ៥ ពួកនោះ បុគ្គលណារមែងមិនប្រាព្ធ តែមានសេចក្ដីក្ដៅក្រហាយ មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ ។

សោ ឯវមស្ស វចនីយោ អាយស្មតោ ខោ អារភជា អាសវា ន សំវិជ្ជន្តិ វិប្បដិសារជា អាសវា បវឌ្ឍន្តិ(១) សាធុវតាយស្មា វិប្បដិសារជេ អាសវេ បដិវិនោទេត្វា ចិត្តំ បញ្ញញ្ច ភាវេតុ ឯវមាយស្មា អមុនា បញ្ចមេន បុគ្គលេន សមសមោ ភវិស្សតីតិ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ ន អារភតិ ន វិប្បដិសារី ហោតិ តញ្ច ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោ ឯវមស្ស វចនីយោ អាយស្មតោ ខោ អារភជា អាសវា ន សំវិជ្ជន្តិ វិប្បដិសារជា អាសវា នប្បវឌ្ឍន្តិ សាធុវតាយស្មា ចិត្តំ បញ្ញញ្ច ភាវេតុ ឯវមាយស្មា អមុនា បញ្ចមេន បុគ្គលេន សមសមោ ភវិស្សតីតិ ។

---

១ ឱ. នប្បវឌ្ឍន្តិ ។

បុគ្គលនោះ អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះថា អាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ រមែងមិនមានអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ តែងចំរើនឡើងដល់លោកដ៏មានអាយុ ហេតុនោះ សូមលោកដ៏មានអាយុ បន្ទោបង់នូវអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ ហើយចំរើននូវចិត្តនឹងបញ្ញាដោយល្អចុះ ធ្វើយ៉ាងនេះ ទើបលោកដ៏មានអាយុស្មើគ្នា នឹងបុគ្គលទី ៥ ឯណោះបាន ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៥ ពួកនោះ បុគ្គលណា រមែងមិនប្រារព្ធ មិនមានសេចក្តីក្តៅក្រហាយ មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ នឹងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ ។ បុគ្គលនោះ អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះថា អាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ រមែងមិនមាន អាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ ក៏មិនចំរើនឡើងដល់លោកដ៏មានអាយុទេ ហេតុនោះ សូមលោកដ៏មានអាយុ ចំរើននូវចិត្តនឹងបញ្ញាដោយល្អចុះ ធ្វើយ៉ាងនេះ ទើបលោកដ៏មានអាយុស្មើគ្នានឹងបុគ្គលទី ៥ ឯណោះបាន ។

ឥតិ ខោ ភិក្ខវេ ឥមេ ចត្តារោ បុគ្គលា អមុនា បញ្ចមេន បុគ្គលេន ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា អនុបុព្វេន អាសវានំ ខយំ បាបុណន្តីតិ ។

(៤៣) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ ។ តេន ខោ បន សមយេន បញ្ចមត្តានំ លិច្ឆវិសតានំ សារន្ទទេ ចេតិយេ សន្និសិន្នានំ សន្និបតិតានំ អយមន្តរា កថា ឧទបាទិ បញ្ចន្នំ រតនានំ បាតុភាវោ ទុល្លភោ លោកស្មឹ ។ កតមេសំ បញ្ចន្នំ ។ ហត្ថិរតនស្ស បាតុភាវោ ទុល្លភោ លោកស្មឹ អស្សរតនស្ស បាតុភាវោ ទុល្លភោ លោកស្មឹ មណិរតនស្ស បាតុភាវោ ទុល្លភោ លោកស្មឹ ឥត្ថិរតនស្ស បាតុភាវោ ទុល្លភោ លោកស្មឹ គហបតិរតនស្ស បាតុភាវោ ទុល្លភោ លោកស្មឹ ។ ឥមេសំ បញ្ចន្នំ រតនានំ បាតុភាវោ ទុល្លភោ លោកស្មិន្តិ ។ អថខោ

ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ កាលបើអ្នកទាំងឡាយ ទូន្មានប្រៀនប្រដៅតាមបុគ្គលទី ៥ ឯណោះ យ៉ាងនេះ គង់បានដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ ដោយលំដាប់ដូច្នេះឯង ។

(៤៣) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ សម័យនោះ ពួកលិច្ឆវី មានប្រមាណ ៥០០ នាក់ បានប្រជុំសន្ទនាគ្នាក្នុងសារន្ទទចេតិយ កើតមានអន្តរាកថានេះឡើងថា ការកើតប្រាកដនៃកែវទាំង ៥ ជារបស់រកបានដោយកម្រក្នុងលោក ។ កែវទាំង ៥ ដូចម្តេចខ្លះ ។ គឺការកើតប្រាកដនៃដំរីកែវ រកបានដោយកម្រក្នុងលោក ១ ការកើតប្រាកដនៃសេះកែវ រកបានដោយកម្រក្នុងលោក ១ ការកើតប្រាកដនៃកែវមណី រកបានដោយកម្រក្នុងលោក ១ ការកើតប្រាកដនៃស្រីកែវ រកបានដោយកម្រក្នុងលោក ១ ការកើតប្រាកដនៃគហបតីកែវ រកបានដោយកម្រក្នុងលោក ១ ។ ការកើតប្រាកដនៃកែវទាំង ៥ នេះឯង រកបានដោយកម្រក្នុងលោក ។ លំដាប់នោះ

តេ លិច្ឆវី មគ្គេ បុរិសំ បេសេសុំ[១] យថា ត្វំ អម្ភោ បុរិស បស្សេយ្យាសិ ភគវន្តំ អាគច្ឆន្តំ អថ អម្ហាកំ អារោចេយ្យាសីតិ ។ អទ្ទសា ខោ សោ បុរិសោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន យេន តេ លិច្ឆវី តេនុបសង្កមិ ឧបសង្កមិត្វា តេ លិច្ឆវី ឯតទវោច អយ សោ ភគវា អាគច្ឆតិ អរហំ សម្មាសម្ពុទ្ធោ យស្សទានិ កាលំ មញ្ញថាតិ ។ អថខោ តេ លិច្ឆវី យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តេ លិច្ឆវី ភគវន្តំ ឯតទវោចុំ សាធុ ភន្តេ ភគវា យេន សារន្ទទំ ចេតិយំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ភគវា យេន សារន្ទទំ ចេតិយំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។

---

១ ឱ. ឋបេសុំ ។

ពួកលិច្ឆវីទាំងនោះ បញ្ជូនបុរសម្នាក់ទៅក្នុងផ្លូវថា នែបុរស បើអ្នកឃើញព្រះដ៏មានព្រះភាគ ស្ដេចមក ក្នុងកាលណា អ្នកគប្បីប្រាប់យើងទាំង-ឡាយ ក្នុងកាលនោះ ។ បុរសនោះ បានឃើញព្រះដ៏មានព្រះភាគ ស្ដេចមកអំពីចម្ងាយ លុះឃើញហើយ ក៏ចូលទៅរកពួកលិច្ឆវីទាំងនោះ លុះចូលទៅដល់ហើយ ទើបពោលទៅនឹងពួកលិច្ឆវីទាំងនោះថា នុ៎ះហ្ន៎ ព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ កំពុងតែស្ដេចមក សូមអ្នកទាំងឡាយ សំគាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ពួកលិច្ឆវីទាំងនោះ បាននាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយស្ថិតក្នុងទីសមគួរ ។ លុះពួកលិច្ឆវីទាំងនោះ ស្ថិតក្នុងទីសមគួរហើយ បានក្រាបបង្គំទូល ព្រះដ៏មានព្រះភាគដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ស្ដេចចូលទៅកាន់សារន្ទទចេតិយ ដើម្បីសេចក្ដីអនុគ្រោះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ បានស្ដេចចូលទៅកាន់សារន្ទទចេតិយ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។

និសជ្ជ ខោ ភគវា តេ លិច្ឆវី ឯតទវោច កាយនុត្ថ លិច្ឆវី ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរា កថា វិប្បកតាតិ ។ ឥធ ភន្តេ អម្ហាកំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរា កថា ឧទបាទិ បញ្ចន្នំ រតនានំ បាតុភាវោ ទុល្លភោ លោកស្មឹ ។ កតមេសំ បញ្ចន្នំ ។ ហត្ថិរតនស្ស បាតុភាវោ ទុល្លភោ លោកស្មឹ អស្សរតនស្ស... មណិរតនស្ស... ឥត្ថីរតនស្ស... គហបតិរតនស្ស បាតុភាវោ ទុល្លភោ លោកស្មឹ ។ ឥមេសំ បញ្ចន្នំ រតនានំ បាតុភាវោ ទុល្លភោ លោកស្មិន្តិ ។ កាមាធិមុត្តានំ វត ភោ លិច្ឆវី[១] កាមញ្ញេវ អារព្ភ អន្តរា កថា ឧទបាទិ ។ បញ្ចន្នំ លិច្ឆវី រតនានំ បាតុភាវោ ទុល្លភោ លោកស្មឹ ។ កតមេសំ បញ្ចន្នំ ។ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវោ ទុល្លភោ លោកស្មឹ តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិតា បុគ្គលោ ទុល្លភោ លោកស្មឹ

---

១ ឱ. ម. ភោ លិច្ឆវីនំ ។

លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ហើយ ទើបត្រាស់ទៅនឹងពួកលិច្ឆវីទាំង-នោះដូច្នេះថា ម្នាលលិច្ឆវីទាំងឡាយ អ្នកទាំងឡាយ អង្គុយប្រជុំសន្ទនាគ្នាដោយកថា ដូចម្តេចហ្ន៎ ក្នុងកាលឥឡូវនេះ ចុះអន្តរកថា ដូចម្តេចដែលអ្នកទាំងឡាយ និយាយគ្នាមិនទាន់ស្រេច ៗ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយ អង្គុយប្រជុំសន្ទនាគ្នា ក្នុងទីនេះ កើតមានអន្តរ-កថានេះឡើងថា ការកើតប្រាកដនៃកែវទាំង ៥ ប្រការ រកបានដោយកម្រក្នុងលោក ៗ កែវ ៥ ប្រការដូចម្តេចខ្លះ ៗ គឺការកើតប្រាកដនៃដំរីកែវ រកបានដោយកម្រក្នុងលោក នៃសេះកែវ... នៃកែវមណី... នៃស្រី-កែវ... ការកើតប្រាកដនៃគហបតីកែវ រកបានដោយកម្រក្នុងលោក ៗ ការកើតប្រាកដនៃកែវទាំង ៥ នេះឯង រកបានដោយកម្រក្នុងលោក ៗ ម្នាលលិច្ឆវីទាំងឡាយ អន្តរកថាប្រារព្ធកាម កើតឡើងដល់អ្នកទាំង-ឡាយ ដែលមានចិត្តជាប់ក្នុងកាមទៅហើយហ្ន៎ ៗ ម្នាលលិច្ឆវីទាំងឡាយ ការកើតប្រាកដនៃរតនៈ ៥ ប្រការ រកបានដោយកម្រក្នុងលោក ៗ រតនៈ ៥ ដូចម្តេចខ្លះ ៗ គឺការកើតប្រាកដនៃព្រះតថាគត ជាអរហន្ត-សម្មាសម្ពុទ្ធ រកបានដោយកម្រក្នុងលោក ១ បុគ្គលអ្នកសំដែងនូវធម៌វិន័យ ដែលព្រះតថាគត ទ្រង់ប្រកាសហើយ រកបានដោយកម្រក្នុងលោក ១

តថាគតប្បវេទិតស្ស ធម្មវិនយស្ស (១) វិញ្ញាតា បុគ្គលោ ទុល្លភោ លោកស្មឹ តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិតស្ស វិញ្ញាតា(២) ធម្មានុធម្មប្បដិបន្នោ បុគ្គលោ ទុល្លភោ លោកស្មឹ កតញ្ញូ កតវេទី បុគ្គលោ ទុល្លភោ លោកស្មឹ ។ ឥមេសំ ខោ លិច្ឆវី បញ្ចន្នំ រតនានំ បាតុភាវោ ទុល្លភោ លោកស្មិន្តិ ។

[៤៤] ឯកំ សមយំ ភគវា សាកេតេ វិហរតិ តិកណ្ឌកីវនេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរេយ្យ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ បដិក្កូលេ អប្បដិក្កូលសញ្ញី វិហរេយ្យ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ អប្បដិក្កូលេ ច បដិក្កូលេ ច បដិក្កូលសញ្ញី វិហរេយ្យ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យ

១ ឱ. ម. ឯត្ថន្តរេ ទេសិតស្សាតិ ទិស្សតិ ។ ២ ឱ. វិញ្ញាតស្ស ។

បុគ្គលអ្នកដឹងនូវធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ រកបានដោយកម្រក្នុងលោក ១ បុគ្គលអ្នកដឹងនូវធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ សំដែងហើយ ៗ ប្រតិបត្តិធម៌តាមគួរដល់ធម៌ រកបានដោយកម្រក្នុងលោក ១ បុគ្គលអ្នកដឹងឧបការគុណដែលបុគ្គលដទៃធ្វើហើយ ធ្វើតបវិញ រកបានដោយកម្រក្នុងលោក ១ ។ ម្នាលលិច្ឆវីទាំងឡាយ ការកើតប្រាកដនៃរតនៈទាំង ៥ នេះឯង រកបានដោយកម្រក្នុងលោក ។

(៤៤) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងតិកណ្ឌកីវន (ព្រៃខ្ទុរ ៣ ដើម) ជិតក្រុងសាកេត ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសំគាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើម តាមកាលគួរ ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសំគាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើម តាមកាលគួរ ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសំគាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង ក្នុងអារម្មណ៍គួរខ្ពើមផង តាមកាលគួរ ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសំគាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើមផង ក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង តាមកាលគួរ ជាការប្រពៃ

សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ អប្បដិកូលញ្ច បដិកូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យ សតោ សម្បជានោ ។ កិញ្ច[១] ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច អប្បដិកូលេ បដិកូលសញ្ញី វិហរេយ្យ ។ មា មេ រជនីយេសុ ធម្មេសុ រាគោ ឧទបាទីតិ ឥទំ ខោ ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច អប្បដិកូលេ បដិកូលសញ្ញី វិហរេយ្យ ។ កិញ្ច ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច បដិកូលេ អប្បដិកូលសញ្ញី វិហរេយ្យ ។ មា មេ ទោសនីយេសុ ធម្មេសុ ទោសោ ឧទបាទីតិ ឥទំ ខោ ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច បដិកូលេ អប្បដិកូលសញ្ញី វិហរេយ្យ ។ កិញ្ច ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច អប្បដិកូលេ ច បដិកូលេ ច បដិកូលសញ្ញី វិហរេយ្យ ។

---

១ ឱ. ម. កថញ្ច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរវៀរលែងនូវអារម្មណ៍ទាំងពីរនោះ គឺអារម្មណ៍មិនគួរខ្ពើម និងអារម្មណ៍គួរខ្ពើមចេញហើយ មានស្មារតី ដឹងខ្លួន តាំងនៅជាកណ្តាល តាមកាលគួរ ជាការប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ គប្បីសំគាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើម ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសំគាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើម ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា រាគៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយជាទីតាំងនៃសេចក្តីត្រេកអរឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុគប្បីសំគាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើម ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសំគាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើម ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា ទោសៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយជាទីតាំងនៃសេចក្តីប្រទូស្តឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុគប្បីសំគាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង ក្នុងអារម្មណ៍ដែលគួរខ្ពើមផង ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។

មា មេ រជនីយេសុ ធម្មេសុ រាគោ ឧទបាទិ មា មេ ទោសនីយេសុ ធម្មេសុ ទោសោ ឧទបាទីតិ ឥទំ ខោ ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច អប្បដិក្កូលេ ច បដិក្កូលេ ច បដិក្កូលសញ្ញី វិហរេយ្យ ។ កិញ្ច ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យ ។ មា មេ ទោសនីយេសុ ធម្មេសុ ទោសោ ឧទបាទិ មា មេ រជនីយេសុ ធម្មេសុ រាគោ ឧទបាទីតិ ឥទំ ខោ ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យ ។ កិញ្ច ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច អប្បដិក្កូលញ្ច បដិក្កូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យ សតោ សម្បជានោ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសំគាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង ក្នុងអារម្មណ៍ដែលគួរខ្ពើមផង ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា រាគៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីត្រេកអរឡើយ ទោសៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីប្រទូស្តឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ គប្បីសំគាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើមផង ក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសំគាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើមផង ក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា ទោសៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីប្រទូស្តឡើយ រាគៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីត្រេកអរឡើយ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ គប្បីវៀរលែងនូវអារម្មណ៍ទាំង ២ នោះគឺអារម្មណ៍មិនគួរខ្ពើម នឹងគួរខ្ពើមចេញហើយ មានស្មារតីដឹងខ្លួនតាំងនៅជាកណ្តាល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។

មា មេ ក្វចិនិ កត្ថចិ កិញ្ចន រជនីយេសុ ធម្មេសុ រាគោ ឧទបាទិ មា មេ ក្វចិនិ កត្ថចិ កិញ្ចន ទោសនីយេសុ ធម្មេសុ ទោសោ ឧទបាទិ មា មេ ក្វចិនិ កត្ថចិ កិញ្ចន មោហនីយេសុ ធម្មេសុ មោហោ ឧទបាទីតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច អប្បដិក្កូលញ្ច បដិក្កូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យ សតោ សម្បជានោតិ ។

(៤៨) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីវៀរលែងនូវអារម្មណ៍ទាំង២នោះ គឺអារម្មណ៍មិនគួរខ្ពើម និងគួរខ្ពើមចេញ មានស្មារតីដឹងខ្លួន តាំងនៅជាកណ្តាល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា រាគៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីត្រេកអរបន្តិចបន្តួច ក្នុងអារម្មណ៍នីមួយ ក្នុងប្រទេសណាមួយឡើយ ទោសៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីប្រទូស្តបន្តិចបន្តួច ក្នុងអារម្មណ៍នីមួយ ក្នុងប្រទេសណាមួយឡើយ មោហៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីវង្វេងបន្តិចបន្តួច ក្នុងអារម្មណ៍នីមួយ ក្នុងប្រទេសណាមួយឡើយ ។

(៤៥) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង ដូចជាគេនាំទៅទម្លាក់ក្នុងនរក ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺបុគ្គលអ្នកសំឡាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាមទាំង-ឡាយ ១ ពោលពាក្យកុហក ១ ប្រកបដោយហេតុជាទីតាំងនៃសេចក្តីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង ដូចជាគេនាំទៅទម្លាក់ក្នុងនរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង ដូចជាគេនាំទៅដាក់ក្នុងស្ថានសួគ៌ ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។

បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(៤៦) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ មិត្តោ ន សេវិតព្វោ ។ កតមេហិ បញ្ចហិ ។ កម្មន្តំ ការេតិ អធិករណំ អាទិយតិ បាមោក្ខេសុ ភិក្ខូសុ បដិវិរុទ្ធោ ហោតិ ទីឃចារិកំ អវត្ថានចារិកំ[១] អនុយុត្តោ វិហរតិ ន បដិពលោ ហោតិ កាលេន កាលំ ធម្មិយា កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ មិត្តោ ន សេវិតព្វោ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ មិត្តោ សេវិតព្វោ ។ កតមេហិ បញ្ចហិ ។ ន កម្មន្តំ ការេតិ ន អធិករណំ អាទិយតិ

---

១ ឱ. ម. អនវត្ថចារិកំ ។

គឺបុគ្គលវៀរចាកការសំឡាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយកុហក ១ វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានឹងមេរ័យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង ដូចជាគេនាំទៅដាក់ក្នុងស្ថានសួគ៌ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌៥ យ៉ាង មិនគួរគប់រកយកជាមិត្រឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺភិក្ខុប្រើឲ្យធ្វើការងារ ១ បង្កអធិករណ៍ ១ ជាសឹកសត្រូវក្នុងពួកភិក្ខុជាប្រធាន១ ត្រេចទៅក្នុងទីឆ្ងាយនឹងទីមិនមានកំណត់រឿយៗ ១ មិនអាចដើម្បីពន្យល់ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាតាមកាលគួរ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ មិនគួរគប់រកយកជាមិត្រឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរគប់រកយកជាមិត្របាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺភិក្ខុមិនប្រើឲ្យធ្វើការងារ ១ មិនបង្កអធិករណ៍ ១

ន បាមោក្ខេសុ ភិក្ខូសុ បដិវិរុទ្ធោ ហោតិ ន ទីឃចារិកំ អនវត្ថចារិកំ អនុយុត្តោ វិហរតិ បដិពលោ ហោតិ កាលេន កាលំ ធម្មិយា កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ មិត្តោ សេវិតព្វោតិ ។

[៤៧] បញ្ចិមានិ ភិក្ខវេ អសប្បុរិសទានានិ ។ កតមានិ បញ្ច ។ អសក្កច្ចំ ទេតិ អចិត្តី កត្វា ទេតិ អសហត្ថា ទេតិ អបវិទ្ធំ ទេតិ អនាគមនទិដ្ឋិកោ ទេតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច អសប្បុរិសទានានិ ។ បញ្ចិមានិ ភិក្ខវេ សប្បុរិសទានានិ ។ កតមានិ បញ្ច ។ សក្កច្ចំ ទេតិ ចិត្តី កត្វា ទេតិ សហត្ថា ទេតិ អនបវិទ្ធំ ទេតិ អាគមនទិដ្ឋិកោ ទេតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច សប្បុរិសទានានីតិ ។

មិនជាសឹកសត្រូវក្នុងពួកភិក្ខុជាប្រធាន ១ មិនត្រេចទៅក្នុងទីឆ្ងាយ ទីដ៏ទៃ មិនមានកំណត់រឿយៗ ១ ជាអ្នកអង់អាចដើម្បីពន្យល់ ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាតាមកាលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរគប់រកយកជាមិត្របាន ។

(៤៧) ម្នាលភិក្ខុទាំងឡាយ អសប្បុរិសទាននេះ មាន ៥ យ៉ាង ។ អសប្បុរិសទាន ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺឲ្យទានដោយមិនគោរព (ក្នុងទេយ្យធម៌)១ ឲ្យទានដោយមិនធ្វើនូវសេចក្តីគោរព (ក្នុងបដិគ្គាហក)១ មិនឲ្យដោយដៃខ្លួន ១ ឲ្យទានដូចជាបោះចោល ១ ឲ្យទានដោយឃើញថាមិនឲ្យផល ១ ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរិសទានមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះមាន ៥ យ៉ាង ។ សប្បុរិសទាន ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺឲ្យទានដោយគោរព ១ ឲ្យដោយធ្វើនូវសេចក្តីគោរព ១ ឲ្យទានដោយដៃខ្លួនឯង ១ ឲ្យទានមិនដូចជាបោះចោល ១ ឲ្យទានដោយឃើញថាឲ្យផល ១ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសទានមាន ៥ យ៉ាងនេះឯង ។

(៤៨) បញ្ចិមានិ ភិក្ខវេ សប្បុរិសទានានិ ។ កតមានិ បញ្ច ។ សទ្ធាយ ទានំ ទេតិ សក្កច្ចំ ទានំ ទេតិ កាលេន ទានំ ទេតិ អនុគ្គហិតចិត្តោ ទានំ ទេតិ អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ ។ សទ្ធាយ ខោ បន ភិក្ខវេ ទានំ ទត្វា យត្ថ យត្ថ តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ អភិរូបោ ច ហោតិ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ។ សក្កច្ចំ ខោ បន ភិក្ខវេ ទានំ ទត្វា យត្ថ យត្ថ តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ យេបិស្ស តេ ហោន្តិ បុត្តាតិ វា ទារាតិ វា ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេបិ សុស្សុស្សន្តិ[១] សោតំ ឱទហន្តិ អញ្ញាចិត្តំ ឧបដ្ឋបេន្តិ ។ កាលេន ខោ បន ភិក្ខវេ ទានំ ទត្វា យត្ថ យត្ថ តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ កាលាគតា ចស្ស អត្ថា បរិបូរា[២] ហោន្តិ ។

---

១ ឱ. សុស្សូសន្តិ ។ ម. សុស្សូន្តិ ។ ២ ឱ. ម. បចុរា ។

(៤៨) ម្នាលភិក្ខុទាំងឡាយ សប្បុរសទាននេះមាន ៥ យ៉ាង ។ សប្បុរសទាន ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺឲ្យទានដោយសទ្ធា ១ ឲ្យទានដោយគោរព ១ ឲ្យទានតាមកាលគួរ ១ ឲ្យទានដោយចិត្តអនុគ្រោះ ១ ឲ្យទានដោយមិនបានបៀតបៀនខ្លួនឯងនិងអ្នកដទៃ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយសទ្ធា ដោយផលទាននោះ កើតក្នុងទីណា ៗ ជាបុគ្គលស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើនផង ជាបុគ្គលមានរូបល្អគួរមើល ជាទីជ្រះថ្លា ប្រកបដោយភាពជាអ្នកមានសម្បុរល្អដ៏ក្រៃលែងផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយគោរព ដោយផលទាននោះ កើតក្នុងទីណា ៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង ពួកជនណាទោះកូនក្តី ប្រពន្ធក្តី ខ្ញុំក្តី អ្នកបម្រើក្តី អ្នកធ្វើការងារក្តី របស់បុគ្គលនោះ ជនទាំងនោះ តែងស្តាប់ដោយល្អ ផ្ទៀងត្រចៀក តាំងចិត្តដើម្បីដឹងផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានតាមកាលដ៏គួរ ដោយផលទាននោះ កើតក្នុងទីណា ៗ ជាបុគ្គលស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើនផង ប្រយោជន៍គឺភោគៈដ៏ពោរពេញ រមែងមកតាមកាលដ៏គួរដល់បុគ្គលនោះផង ។

អនុគ្គហិតចិត្តោ ខោ បន ភិក្ខវេ ទានំ ទត្វា យត្ថ យត្ថ តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ ឧឡារេសុ ច បញ្ចសុ កាមគុណេសុ ភោគាយ ចិត្តំ នមតិ ។ អត្តានញ្ច បរញ្ច អនុបហច្ច ខោ បន ភិក្ខវេ ទានំ ទត្វា យត្ថ យត្ថ តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ ន ចស្ស កុតោចិ ភោគានំ ឧបឃាតោ អាគច្ឆតិ អគ្គិតោ វា ឧទកតោ វា រាជតោ វា ចោរតោ វា អប្បិយតោ វា ទាយាទតោ វា ។ ឥមានិ ខោ ភិក្ខវេ បញ្ច សប្បុរិសទានានីតិ ។

(៤៩) បញ្ចិមេ ភិក្ខវេ ធម្មា សមយវិមុត្តស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ កម្មារាមតា ភស្សារាមតា និទ្ទារាមតា សង្គណិការាមតា យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយចិត្តអនុគ្រោះ ដោយផលទាននោះ កើតក្នុងទីណា ៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង រមែងបង្អោនចិត្តទៅដើម្បីបរិភោគកាមគុណ ៥ ដ៏លើសលុបផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយមិនបៀតបៀនខ្លួនឯងនិងអ្នកដទៃ ដោយផលទាននោះ កើតក្នុងទីណា ៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង សេចក្តីអន្តរាយនៃភោគៈទាំងឡាយ មិនមានមកអំពីទីណាមួយ គឺអំពីភ្លើង អំពីទឹក អំពីស្តេច អំពីចោរ អំពីហេតុមិនជាទីស្រឡាញ់ និងអំពីមនុស្សជាទាយាទ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសទានមាន ៥ យ៉ាងនេះឯង ។

(៤៩) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសមយវិមុត្ត(១) ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺត្រេកអរក្នុងការងារ ១ ត្រេកអរក្នុងការពោលតិរច្ឆានកថា ១ ត្រេកអរក្នុងការដេកលក់ ១ ត្រេកអរក្នុងពួកគណៈ ១ មិនពិចារណាចិត្តតាមវិមុត្ត ១ ។

---

១ បានដល់ភិក្ខុដែលរកចិត្តផុតស្រឡះហើយដោយវិមុត្តជាលោកិយ ពោលគឺសមយវិមុត្ត ព្រោះភិក្ខុនោះ ជាអ្នកមានចិត្តផុតស្រឡះហើយចាកកិលេសទាំងឡាយ ដែលខ្លួនកំចាត់បង់បាន ក្នុងខណៈចិត្តដ៏ខ្ជាប់ខ្ជួនក្រៃពេក ។ អដ្ឋកថា ។

ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សមយវិមុត្តស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ បញ្ចិមេ ភិក្ខវេ ធម្មា សមយវិមុត្តស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ន កម្មារាមតា ន ភស្សារាមតា ន និទ្ទារាមតា ន សង្គណិការាមតា យថាវិមុត្តំ ចិត្តំ បច្ចវេក្ខតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សមយវិមុត្តស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។

(៥០) បញ្ចិមេ ភិក្ខវេ ធម្មា សមយវិមុត្តស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ កម្មារាមតា ភស្សារាមតា និទ្ទារាមតា ឥន្ទ្រិយេសុ អគុត្តទ្វារតា ភោជនេ អមត្តញ្ញុតា ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សមយវិមុត្តស្ស ភិក្ខុនោ បរិហា-នាយ សំវត្តន្តិ ។ បញ្ចិមេ ភិក្ខវេ ធម្មា សមយវិ-មុត្តស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ន កម្មារាមតា ន ភស្សារាមតា ន និទ្ទារាមតា

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមិនត្រេកអរក្នុងការងារ ១ មិនត្រេកអរក្នុងការពោលតិរច្ឆានកថា ១ មិនត្រេកអរក្នុងការដេកលក់ ១ មិនត្រេកអរក្នុងពួកគណៈ ១ ពិចារណាចិត្តតាមវិមុត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។

(៥០) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺត្រេកអរក្នុងការងារ ១ ត្រេកអរក្នុងការពោលតិរច្ឆានកថា ១ ត្រេកអរក្នុងការដេកលក់ ១ មិនបានគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ មិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមិនត្រេកអរក្នុងការងារ ១ មិនត្រេកអរក្នុងការពោលតិរច្ឆានកថា ១ មិនត្រេកអរក្នុងការដេកលក់ ១

៩.ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សមយវិមុត្តស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។

តិកណ្ឌកីវគ្គោ បញ្ចមោ ។

## តស្សុទ្ទានំ

ទត្វា អវជានាតិ អារភតិ ច
សារន្ទទតិកណ្ឌកិនិរយេន ច
មិត្តោ អសប្បុរិសសប្បុរិសេន
សមយវិមុត្តំ អបរេ ទ្វេតិ ។

តតិយោ បណ្ណាសកោ សមត្តោ ។

គ្រប់គ្រងរក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។

ចប់ តិកណ្ឌកីវគ្គ ទី ៤ ។

## ឧទ្ទាននៃតិកណ្ឌកីវគ្គនោះ គឺ

និយាយអំពីបុគ្គលឲ្យហើយ ត្រឡប់មើលងាយវិញ ១ អំពីភិក្ខុប្រារព្ធ ១ អំពីពួកលិច្ឆវីប្រជុំគ្នាក្នុងសារន្ទទចេតិយ ១ អំពីព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងតិកណ្ឌកីវន ១ អំពីធម៌ដែលនាំឲ្យធ្លាក់ទៅក្នុងនរក នឹងនាំឲ្យទៅកើតស្ថានសួគ៌ ១ អំពីមិត្តគួរគប់រក នឹងមិនគួរគប់រក ១ អំពីអសប្បុរិសទាន ១ អំពីសប្បុរិសទាន ១ អំពីភិក្ខុជាសមយវិមុត្ត ២ លើក ។

ចប់ បណ្ណាសក ទី ៣ ។

## ចតុត្ថបណ្ណាសកោ

## សទ្ធម្មវគ្គោ បឋមោ

(៥១) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ បញ្ចហិ ។ កថំ បរិភោតិ កថិកំ បរិភោតិ អត្តានំ បរិភោតិ វិក្ខិត្តចិត្តោ ធម្មំ សុណាតិ អនេកគ្គចិត្តោ អយោនិសោ មនសិករោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ បញ្ចហិ ។ ន កថំ បរិភោតិ ន កថិកំ បរិភោតិ ន អត្តានំ បរិភោតិ អវិក្ខិត្តចិត្តោ ធម្មំ សុណាតិ ឯកគ្គចិត្តោ យោនិសោ មនសិករោតិ ។

## ចតុត្ថបណ្ណាសក

### សទ្ធម្មវគ្គ ទី ១

[៥១] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាមគឺមគ្គ ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមើលងាយពាក្យពោល ១ មើលងាយបុគ្គលអ្នកពោល ១ មើលងាយខ្លួនឯង ១ មានចិត្តរវើរវាយស្តាប់ធម៌ ១ មានចិត្តមិននឹងនួននៅក្នុងអារម្មណ៍តែមួយ គឺមិនយកចិត្តទុកដាក់ដោយឧបាយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះ សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង កាលស្តាប់ព្រះសទ្ធម្ម គួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមិនមើលងាយពាក្យពោល ១ មិនមើលងាយបុគ្គលអ្នកពោល ១ មិនមើលងាយខ្លួនឯង ១ មានចិត្តមិនរវើរវាយស្តាប់ធម៌ ១ មានចិត្តនឹងនួននៅក្នុងអារម្មណ៍តែមួយ គឺយកចិត្តទុកដាក់ដោយឧបាយប្រាជ្ញា ១ ។

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ សុណន្តោ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។

[៥២] បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ បញ្ចហិ ។ កថំ បរិភោតិ កថិកំ បរិភោតិ អត្តានំ បរិភោតិ ទុប្បញ្ញោ ហោតិ ជឡោ ឯឡមូគោ អនញ្ញាតេ អញ្ញាតមានី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ បញ្ចហិ ។ ន កថំ បរិភោតិ ន កថិកំ បរិភោតិ ន អត្តានំ បរិភោតិ បញ្ញវា ហោតិ អជឡោ អនេឡមូគោ

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។

[៥២] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមើលងាយពាក្យពោល ១ មើលងាយបុគ្គលអ្នកពោល ១ មើលងាយខ្លួនឯង ១ អប្បឥតប្រាជ្ញា ល្ងង់ខ្លៅលលា ១ សំគាល់ថាបានដឹងក្នុងហេតុដែលខ្លួនមិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមិនមើលងាយពាក្យពោល ១ មិនមើលងាយបុគ្គលអ្នកពោល ១ មិនមើលងាយខ្លួនឯង ១ ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនលលា ១

ច អនញ្ញាតេ អញ្ញាតមានី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ សុណន្តោ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តន្តិ ។

(៨៣) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ បញ្ច-ហិ ។ មក្ខី ធម្មំ សុណាតិ មក្ខបរិយុដ្ឋិតោ សឧ-បារម្ភចិត្តោ ធម្មំ សុណាតិ រន្ធគវេសី ធម្មទេសកេ អាហតចិត្តោ ហោតិ ខិលជាតោ ទុប្បញ្ញោ ហោតិ ជឡោ ឯឡមូគោ អនញ្ញាតេ អញ្ញាតមានី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។

មិនសំគាល់ថា បានដឹងនូវហេតុដែលខ្លួនមិនបានដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។

(៩៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺជាអ្នកលុបគុណគេ មានសេចក្តីលុបគុណ ប្រកបសង្កត់ ហើយស្តាប់ធម៌ ១ មានចិត្តប្រកាន់សង្កត់សង្កិនស្វែងរកទោស ហើយស្តាប់ធម៌ ១ ជាអ្នកមានចិត្តគក់គ្រើនរំខានរុះរើ ក្នុងបុគ្គលអ្នកសំដែងធម៌ ១ ជាអ្នកអប្រាជ្ញ ល្ងង់ខ្លៅល្ងង់ខ្លៅ ១ ជាអ្នកសំគាល់ថា បានដឹងនូវហេតុដែលខ្លួនមិនបានដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។

កតមេហិ បញ្ចហិ ។ អមក្ខី ធម្មំ សុណាតិ ន មក្ខបរិយុដ្ឋិតោ អនុបារម្ភចិត្តោ ធម្មំ សុណាតិ ន រន្ធគវេសី ធម្មទេសកេ អនាហតចិត្តោ ហោតិ អខិលជាតោ បញ្ញវា ហោតិ អជឡោ អនេឡមូគោ ន អនញ្ញាតេ អញ្ញាតមានី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ សុណន្តោ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។

(៥៤) បញ្ចិមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខូ ន សក្កច្ចំ ធម្មំ សុណាតិ ន សក្កច្ចំ ធម្មំ បរិយាបុណាតិ ន សក្កច្ចំ ធម្មំ ធារេតិ ន សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខតិ ន សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។

ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺជាអ្នកមិនលុបគុណគេ មិនមានសេចក្តីលុបគុណ គ្របសង្កត់ ហើយស្តាប់ធម៌ ១ មានចិត្តមិនប្រុងសង្កត់សង្កិន មិនស្វែងរកទោស ហើយស្តាប់ធម៌ ១ ជាអ្នកមានចិត្តមិនតក់ម៉ក់ មិនរវើងរវើងរស្វ ក្នុងបុគ្គលអ្នកសំដែងធម៌ ១ ជាអ្នកមានបញ្ញា មិនល្ងង់ខ្លៅ មិនលលា ១ មិនសំគាល់ថា បានដឹងក្នុងហេតុដែលខ្លួនមិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។

[៥៤] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ មិនស្តាប់ធម៌ដោយគោរព ១ មិនរៀនធម៌ដោយគោរព ១ មិនទ្រទ្រង់ (ចាំទុក) ធម៌ដោយគោរព ១ មិនពិចារណាអត្ថនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយដោយគោរព ១ ដឹងអត្ថ ដឹងធម៌ហើយ មិនប្រតិបត្តិធម៌ តាមសមគួរដល់ធម៌ដោយគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។

បញ្ចិមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខូ សក្កច្ចំ ធម្មំ សុណន្តិ សក្កច្ចំ ធម្មំ បរិយាបុណន្តិ សក្កច្ចំ ធម្មំ ធារេន្តិ សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តីតិ ។

(៥៥) បញ្ចិមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខូ ធម្មំ ន បរិយាបុណន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ ។ អយំ ភិក្ខវេ បឋមោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ ន វិត្ថារេន បរេសំ ទេសេន្តិ ។ អយំ ភិក្ខវេ ទុតិយោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ ស្តាប់ធម៌ដោយគោរព ១ រៀនធម៌ដោយគោរព ១ ទ្រទ្រង់ធម៌ដោយគោរព ១ ពិចារណាអត្ថនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយដោយគោរព ១ ដឹងអត្ថ ដឹងធម៌ហើយ ប្រតិបត្តិធម៌តាមសមគួរដល់ធម៌ដោយគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។

[៥៥] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ មិនរៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនសំដែងធម៌តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។

បុន ចបរំ ភិក្ខវេ ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ ន វិត្ថារេន បរេសំ(១) វាចេន្តិ ។ អយំ ភិក្ខវេ តតិយោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ ន វិត្ថារេន សជ្ឈាយំ ករោន្តិ ។ អយំ ភិក្ខវេ ចតុត្ថោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ ន ចេតសា អនុវិតក្កេន្តិ អនុវិចារេន្តិ មនសានុបេក្ខន្តិ ។ អយំ ភិក្ខវេ បញ្ចមោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។ បញ្ចិមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខូ ធម្មំ បរិយាបុណន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ

---

១ ម. បរំ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនបង្ហាញធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនធ្វើនូវការស្វាធ្យាយ (ទន្ទេញ) ធម៌តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនត្រិះរិះរឿយៗ មិនពិចារណារឿយៗ ដោយចិត្ត មិនដញ្ជឹងរឿយៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ រៀនធម៌គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ

ជាតកំ អព្ភុតធម្មំ វេទល្លំ ។ អយំ ភិក្ខវេ បឋមោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេ-សេន្តិ ។ អយំ ភិក្ខវេ ទុតិយោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ វាចេន្តិ ។ អយំ ភិក្ខវេ តតិយោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធា-នាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោន្តិ ។ អយំ ភិក្ខវេ ចតុត្ថោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេន្តិ អនុវិចារេន្តិ មនសានុបេក្ខន្តិ ។

ជាតក: អព្ភូតធម្ម វេទល្ល: ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ សំដែងធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ បង្ហាញធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ធ្វើសេចក្តីស្វាធ្យាយធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ត្រិះរិះរឿយៗ ពិចារណារឿយៗ ដោយចិត្ត ជញ្ជឹងរឿយៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ។

អយំ ភិក្ខវេ បញ្ចមោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តីតិ ។

(៥៦) បញ្ចិមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស សម្មោ-សាយ អន្តរធានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខូ ទុគ្គហិតំ សុត្តន្តំ បរិយាបុណន្តិ ទុន្និក្ខិត្តេហិ បទព្យញ្ជនេហិ ទុន្និក្ខិត្តស្ស ភិក្ខវេ បទព្យញ្ជនស្ស អត្ថោបិ ទុន្នយោ ហោតិ ។ អយំ ភិក្ខវេ បឋមោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ ទុព្វចា ហោន្តិ ទោវចស្សករណេហិ ធម្មេហិ សមន្នា-គតា អក្ខមា អប្បទក្ខិណគ្គាហិនោ អនុសាសនឹ ។ អយំ ភិក្ខវេ ទុតិយោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ

ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ធម៌ ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ រៀនទូរព្រះសូត្រ ដែលខ្លួនរៀនខុស ដោយបទនិងព្យញ្ជនៈ ដែលរៀបរៀងខុស ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈដែលរៀបរៀងខុស រមែងយល់សេចក្តីបាន ដោយកម្រ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ជាអ្នកប្រដៅបានដោយក្រ ប្រកបដោយធម៌ ដែលធ្វើឲ្យគេប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ មិនទទួលពាក្យប្រៀនប្រដៅខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត

យេ តេ ភិក្ខូ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេ ច សក្កច្ចំ សុត្តន្តំ បរំ វាចេន្តិ តេសំ អច្ចយេន ឆិន្នមូលកោ សុត្តន្តោ ហោតិ អប្បដិសរណោ ។ អយំ ភិក្ខវេ តតិយោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។

បុន ចបរំ ភិក្ខវេ ថេរា ភិក្ខូ ពាហុលិកា ហោន្តិ សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ន វីរិយំ អារភន្តិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ តេសំ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ សាបិ ហោតិ ពាហុលិកា សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា

ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្ដីចេះដឹងច្រើន មានអាគមគឺនិកាយដ៏ស្ទាត់ ចងចាំនូវព្រះសូត្រ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ មិនឲ្យភិក្ខុដទៃរៀនព្រះសូត្រ ដោយគោរព លុះអំណើះតតពីភិក្ខុទាំងនោះទៅ ព្រះសូត្រក៏ដាច់ឫស មិនប្រតិស្ឋានទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយជាថេរៈជាអ្នកប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈ ក្នុងវិវេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណវិសេសដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតជាខាងក្រោយ គឺសទ្ធិវិហារិក អន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុជាថេរៈទាំងនោះ ប្រជុំជនជាខាងក្រោយទាំងនោះ ក៏ជាអ្នកប្រតិបត្តិ ដើម្បីឲ្យកើតលាភច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈ ក្នុងវិវេក មិនប្រារព្ធនូវព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់

អនភិរតស្ស អភិរមាយ អសន្ធិកតស្ស សន្ធិកិរិយាយ ។ អយំ ភិក្ខវេ ចតុត្ថោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ សង្ឃោ ភិន្នោ ហោតិ សង្ឃេ ខោ បន ភិក្ខវេ ភិន្នេ អញ្ញមញ្ញំ អក្កោសា ច ហោន្តិ អញ្ញមញ្ញំ បរិភាសា ច ហោន្តិ អញ្ញមញ្ញំ បរិក្ខេបា ច ហោន្តិ អញ្ញមញ្ញ បរិច្ចជា[១] ច ហោន្តិ តត្ថ អប្បសន្នា ចេវ នប្បសីទន្តិ បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តំ ហោតិ ។ អយំ ភិក្ខវេ បញ្ចមោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។ បញ្ចិមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខូ សុត្តន្តំ បរិយាបុណន្តិ សុនិក្ខិត្តេហិ បទព្យញ្ជនេហិ

---

១ ឱ. ម. បរិច្ចជិតា ។

ដើម្បីសម្រេចនូវគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សង្ឃបែកគ្នា ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ ការជេរគ្នានឹងគ្នា ក៏មាន ការប្រទេចផ្ដាសាគ្នានឹងគ្នា ក៏មាន ការបោះពាក្យសំដីទៅរកគ្នានឹងគ្នា ក៏មាន ការលះបង់គ្នានឹងគ្នា ក៏មាន ពួកជនដែលមិនទាន់ជ្រះថ្លា ក្នុងសង្ឃទាំងនោះ ក៏មិនមានសេចក្ដីជ្រះថ្លា ដែលជ្រះថ្លាស្រាប់ហើយ ក៏ងាកចិត្តលែងជ្រះថ្លាវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ រៀននូវព្រះសូត្រ ដែលខ្លួនរៀនត្រូវ ដោយបទនិងព្យញ្ជនៈដែលរៀបរៀងត្រូវ

សុនិក្ខិត្តស្ស ភិក្ខវេ បទព្យញ្ជនស្ស អត្ថោបិ សុនយោ ហោតិ ។ អយំ ភិក្ខវេ បឋមោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ សុវចា ហោន្តិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតា ខមា បទក្ខិណគ្គាហិនោ អនុសាសនិំ ។ អយំ ភិក្ខវេ ទុតិយោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ យេ តេ ភិក្ខូ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេ សក្កច្ចំ បរំ វាចេន្តិ តេសំ អច្ចយេន ន ឆិន្នមូលកោ សុត្តន្តោ ហោតិ សប្បដិសរណោ ។ អយំ ភិក្ខវេ តតិយោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ថេរា ភិក្ខូ ន ពាហុលិកា ហោន្តិ ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា វីរិយំ អារភន្តិ អប្បត្តស្ស បត្តិយា

ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈដែលរៀបរៀងត្រូវ រមែងយល់សេចក្តីបានងាយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ជាអ្នកប្រដៅងាយ ប្រកបដោយធម៌ធ្វើឲ្យជាអ្នកប្រដៅងាយ ជាអ្នកចេះអត់ធន់ ទទួលពាក្យប្រៀនប្រដៅខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា មានសេចក្តីចេះដឹងច្រើន មានអាគមគឺនិកាយដ៏ស្ទាត់ ចងចាំនូវព្រះសូត្រ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ ឲ្យភិក្ខុដទៃរៀនព្រះសូត្រ ដោយគោរព លុះអំណើះតពីភិក្ខុទាំងនោះទៅ ព្រះសូត្រក៏មិនបានដាច់ឫសប្រតិស្ឋាននៅបាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយជាថេរៈ មិនប្រតិបត្តិ ដើម្បីឲ្យកើតលាភច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ជាធុរៈ ក្នុងការប្រតិបត្តិបន្ធូរបន្ថយចេញ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់

អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ តេសំ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ សាបិ ហោតិ ន ពាហុលិកា ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ អយំ ភិក្ខវេ ចតុត្ថោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ សង្ឃោ សមគ្គោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុំ វិហរតិ សង្ឃេ ខោ បន ភិក្ខវេ សមគ្គេ ន ចេវ អញ្ញមញ្ញំ អក្កោសា ហោន្តិ ន ច អញ្ញមញ្ញំ បរិភាសា ហោន្តិ ន ច អញ្ញមញ្ញំ បរិក្ខេបា ហោន្តិ ន ច អញ្ញមញ្ញំ បរិច្ចជា ហោន្តិ តត្ថ អប្បសន្នា ចេវ បសីទន្តិ បសន្នានញ្ច ភិយ្យោភាវោ ហោតិ ។

ដើម្បីសម្រេចនូវគុណវិសេស ដែលខ្លួនមិនទាន់សម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតជាខាងក្រោយ គឺសទ្ធិវិហារិក អន្តេវាសិក ក៏យកតំរាប់តាមពួកភិក្ខុជាថេរៈទាំងនោះ បច្ឆិមជននោះឯង ក៏មិនជាអ្នកប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈ ក្នុងការប្រតិបត្តិបន្ធូរបន្ថយចេញ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណវិសេសដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេសដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សង្ឃព្រមព្រៀងគ្នា មានសេចក្តីរីករាយរកគ្នា មិនទាស់ទែងគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅជាសុខ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃព្រមព្រៀងគ្នាហើយ ការជេរគ្នានឹងគ្នា ក៏មិនមាន ការប្រទេចផ្តាសាគ្នានឹងគ្នា ក៏មិនមាន ការបោះពាក្យសំដីទៅរកគ្នានឹងគ្នា ក៏មិនមាន ការលះបង់គ្នានឹងគ្នា ក៏មិនមាន ពួកជនដែលមិនទាន់ជ្រះថ្លា ក្នុងសង្ឃទាំងនោះ ក៏រមែងជ្រះថ្លាឡើង ដែលជ្រះថ្លាស្រាប់ហើយ ក៏រឹងរឹតតែជ្រះថ្លាឡើង ។

អយំ ភិក្ខវេ បញ្ចមោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តីតិ ។

(៨៧) បញ្ចន្នំ ភិក្ខវេ បុគ្គលានំ កថា ទុក្កថា បុគ្គលេ បុគ្គលំ ឧបនិធាយ ។ កតមេសំ បញ្ចន្នំ ។ អស្សទ្ធស្ស ភិក្ខវេ សទ្ធាកថា ទុក្កថា ទុស្សីលស្ស សីលកថា ទុក្កថា អប្បស្សុតស្ស ពាហុសច្ចកថា ទុក្កថា មច្ឆរិស្ស ចាគកថា ទុក្កថា ទុប្បញ្ញស្ស បញ្ញាកថា ទុក្កថា ។ កស្មា ច ភិក្ខវេ អស្សទ្ធស្ស សទ្ធាកថា ទុក្កថា ។ អស្សទ្ធោ ភិក្ខវេ សទ្ធាកថាយ កច្ឆមានាយ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ច-យញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ សទ្ធាសម្បទំ អត្តនិ ន សមនុបស្សតិ ន ច លភតិ តតោនិទានំ បីតិបាមុជ្ជំ តស្មា

ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ ៥ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។

[៥៧] ម្នាលភិក្ខុទាំងឡាយ កថារបស់បុគ្គល ៥ ពួក ជាកថាអាក្រក់ ដោយការលើកយកបុគ្គលទៅប្រៀបនឹងបុគ្គល ។ កថារបស់បុគ្គល ៥ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ការពោលអំពីសទ្ធារបស់បុគ្គលមិនមានសទ្ធា ជាកថាអាក្រក់ ១ ការពោលអំពីសីលរបស់បុគ្គលទ្រុស្តសីល ជាកថាអាក្រក់ ១ ការពោលអំពីការចេះដឹងច្រើនរបស់បុគ្គលចេះដឹងតិច ជាកថាអាក្រក់ ១ ការពោលអំពីការលះរបស់បុគ្គលកំណាញ់ ជាកថាអាក្រក់ ១ ការពោលអំពីប្រាជ្ញារបស់បុគ្គលឥតប្រាជ្ញា ជាកថាអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីសទ្ធារបស់បុគ្គលមិនមានសទ្ធា ជាកថាអាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលមិនមានសទ្ធា កាលបើពោលអំពីសទ្ធា រមែងរកាំរអួល កម្រើកញាប់ញ័រ ឃ្នាន់ឃ្នាញ់ ធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលមិនមានសទ្ធានោះ មិនឃើញច្បាស់នូវសទ្ធាសម្បទានោះក្នុងខ្លួន មិនបាននូវបីតិនិងបាមោជ្ជៈ ព្រោះសទ្ធានោះជាហេតុផង ព្រោះហេតុនោះ

អស្សទ្ធស្ស សទ្ធាកថា ទុក្កថា ។ កស្មា ច ភិក្ខវេ ទុស្សីលស្ស សីលកថា ទុក្កថា ។ ទុស្សីលោ ភិក្ខវេ សីលកថាយ កច្ឆមានាយ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ សីលសម្បទំ អត្តនិ ន សមនុបស្សតិ ន ច លភតិ តតោនិទានំ បីតិបាមុជ្ជំ តស្មា ទុស្សីលស្ស សីលកថា ទុក្កថា ។ កស្មា ច ភិក្ខវេ អប្បស្សុតស្ស ពាហុសច្ចកថា ទុក្កថា ។ អប្បស្សុតោ ភិក្ខវេ ពាហុសច្ចកថាយ កច្ឆមានាយ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ សុតសម្បទំ អត្តនិ ន សមនុបស្សតិ ន ច លភតិ តតោនិទានំ បីតិបាមុជ្ជំ តស្មា អប្បស្សុតស្ស ពាហុសច្ចកថា ទុក្កថា ។

ការពោលអំពីសទ្ធា របស់បុគ្គលមិនមានសទ្ធា ទើបជាកថាអាក្រក់ ៗ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទ្រុស្តសីល ពោលអំពីសីល ជាកថាអាក្រក់ តើដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ្រុស្សីល កាលបើពោលអំពីសីល រមែងអាក់រអួល កម្រើកញាប់ញ័រ ឃ្នាន់ឃ្នាញ់ ធ្វើសេចក្តីក្រោធខឹង ទឹងសេចក្តីមិនត្រេកអរឲ្យប្រាកដ ៗ រឿងនោះព្រោះហេតុអ្វី ៗ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលទ្រុស្តសីលនោះមិនឃើញច្បាស់នូវសីលសម្បទានោះក្នុងខ្លួន ព្រមទាំងមិនបាននូវបីតិនឹងបាមោជ្ជៈ ព្រោះសីលនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីសីលរបស់បុគ្គលទ្រុស្តសីល ទើបជាកថាអាក្រក់ ៗ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងតិច ជាកថាអាក្រក់ តើដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកចេះដឹងតិច កាលពោលអំពីការចេះដឹងច្រើន រមែងអាក់រអួល កម្រើកញាប់ញ័រ ឃ្នាន់ឃ្នាញ់ ធ្វើសេចក្តីក្រោធខឹង ទឹងសេចក្តីមិនត្រេកអរឲ្យប្រាកដ ៗ រឿងនោះព្រោះហេតុអ្វី ៗ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលអ្នកចេះដឹងតិចនោះមិនឃើញច្បាស់នូវសុតសម្បទានោះក្នុងខ្លួន ព្រមទាំងមិនបាននូវបីតិនឹងបាមោជ្ជៈ ព្រោះការចេះដឹងតិចនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងតិច ទើបជាកថាអាក្រក់ ៗ

កស្មា ច ភិក្ខវេ មច្ឆរិស្ស លាភកថា ទុក្កថា ។ មច្ឆរី ភិក្ខវេ លាភកថាយ កច្ឆមានាយ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ លាភសម្បទំ អត្តនិ ន សមនុបស្សតិ ន ច លភតិ តតោនិទានំ បីតិបាមុជ្ជំ តស្មា មច្ឆរិស្ស លាភកថា ទុក្កថា ។ កស្មា ច ភិក្ខវេ ទុប្បញ្ញស្ស បញ្ញាកថា ទុក្កថា ។ ទុប្បញ្ញោ ភិក្ខវេ បញ្ញាកថាយ កច្ឆមានាយ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ បញ្ញាសម្បទំ អត្តនិ ន សមនុបស្សតិ ន ច លភតិ តតោនិទានំ បីតិបាមុជ្ជំ តស្មា ទុប្បញ្ញស្ស បញ្ញាកថា ទុក្កថា ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ បុគ្គលានំ កថា ទុក្កថា បុគ្គលេ បុគ្គលំ ឧបនិធាយ ។

ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីការលះ របស់បុគ្គលកំណាញ់ ជាកថាអាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកំណាញ់ កាលបើពោលអំពីការលះ រមែងអាក់អួល កម្រើកញាប់ញ័រ ឃ្នាន់ឃ្នាញ់ ធ្វើសេចក្តីក្រោធខឹងនឹងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលកំណាញ់នោះ មិនឃើញច្បាស់នូវចាគសម្បទានោះក្នុងខ្លួន ព្រមទាំងមិនបាននូវបីតិនិងបាមោជ្ជៈ ព្រោះមានការលះនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីការលះ របស់បុគ្គលកំណាញ់ ទើបជាកថាអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីបញ្ញា របស់បុគ្គលឥតបញ្ញា ជាកថាអាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ័ប្បឥតបញ្ញា កាលពោលអំពីបញ្ញា រមែងអាក់អួល កម្រើកញាប់ញ័រ ឃ្នាន់ឃ្នាញ់ ធ្វើសេចក្តីក្រោធខឹង នឹងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលអ័ប្បឥតបញ្ញានោះ មិនឃើញច្បាស់នូវបញ្ញាសម្បទានោះក្នុងខ្លួន ព្រមទាំងមិនបាននូវបីតិនិងបាមោជ្ជៈ ព្រោះបញ្ញានោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីបញ្ញា របស់បុគ្គលអ័ប្បឥតបញ្ញា ទើបជាកថាអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ កថារបស់បុគ្គលទាំង៥ពួកនេះឯង ជាកថាអាក្រក់ ដោយលើកយកបុគ្គលទៅប្រៀបនឹងបុគ្គល ។

បញ្ចន្នំ ភិក្ខវេ បុគ្គលានំ កថា សុកថា បុគ្គលេ បុគ្គលំ ឧបនិធាយ ។ កតមេសំ បញ្ចន្នំ ។ សទ្ធស្ស ភិក្ខវេ សទ្ធាកថា សុកថា សីលវតោ សីលកថា សុកថា ពហុស្សុតស្ស ពាហុសច្ចកថា សុកថា ចាគវតោ ចាគកថា សុកថា បញ្ញវតោ បញ្ញាកថា សុកថា ។ កស្មា ច ភិក្ខវេ សទ្ធស្ស សទ្ធាកថា សុកថា ។ សទ្ធោ ភិក្ខវេ សទ្ធាកថាយ កច្ឆមានាយ នាភិសជ្ជតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ សទ្ធាសម្បទំ អត្តនិ សមនុបស្សតិ លភតិ ច តតោនិទានំ បីតិបាមុជ្ជំ តស្មា សទ្ធស្ស សទ្ធាកថា សុកថា ។ កស្មា ច ភិក្ខវេ សីលវតោ សីលកថា សុកថា ។

ម្នាលភិក្ខុទាំងឡាយ កថារបស់បុគ្គល ៤ ពួក ជាកថាល្អ ដោយលើកយកបុគ្គលទៅប្រៀបនឹងបុគ្គល ។ កថារបស់បុគ្គល ៤ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ការពោលអំពីសទ្ធា របស់បុគ្គលមានសទ្ធា ជាកថាល្អ ១ ការពោលអំពីសីល របស់បុគ្គលមានសីល ជាកថាល្អ ១ ការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងច្រើន ជាកថាល្អ ១ ការពោលអំពីការលះ របស់បុគ្គលបរិច្ចាគ ជាកថាល្អ ១ ការពោលអំពីបញ្ញា របស់បុគ្គលមានបញ្ញា ជាកថាល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីសទ្ធា របស់បុគ្គលមានសទ្ធា ជាកថាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសទ្ធា កាលបើពោលអំពីសទ្ធា រមែងមិនអាក់អួល មិនកម្រើកញាប់ញ័រ មិនឃ្នានឃ្នាញ់ មិនធ្វើសេចក្តីក្រោធខឹង ទឹងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលមានសទ្ធានោះ ឃើញច្បាស់នូវសទ្ធាសម្បទានោះក្នុងខ្លួន ព្រមទាំងបានទទួលបីតិនិងបាមោជ្ជៈ ព្រោះសទ្ធានោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីសទ្ធា របស់បុគ្គលមានសទ្ធា ទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីសីល របស់បុគ្គលមានសីល ជាកថាល្អ តើដូចម្តេច ។

សីលវា ភិក្ខវេ សីលកថាយ កច្ឆមានាយ នាភិសជ្ជតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ សីលសម្បទំ អត្តនិ សមនុបស្សតិ លភតិ ច តតោនិទានំ បីតិប្បាមុជ្ជំ តស្មា សីលវតោ សីលកថា សុកថា ។ កស្មា ច ភិក្ខវេ ពហុស្សុតស្ស ពាហុសច្ចកថា សុកថា ។ ពហុស្សុតោ ភិក្ខវេ ពាហុសច្ចកថាយ កច្ឆមានាយ នាភិសជ្ជតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ សុតសម្បទំ អត្តនិ សមនុបស្សតិ លភតិ ច តតោនិទានំ បីតិប្បាមុជ្ជំ តស្មា ពហុស្សុតស្ស ពាហុសច្ចកថា សុកថា ។ កស្មា ច ភិក្ខវេ ចាគវតោ ចាគកថា សុកថា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសីល កាលបើពោលអំពីសីល រមែងមិនអាក់អួល មិនកម្រើកញាប់ញ័រ មិនឃ្នាន់ខ្នាញ់ មិនធ្វើសេចក្តីក្រោធខឹង ទឹងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលមានសីលនោះ ឃើញច្បាស់នូវសីលសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិនិងបាមោជ្ជៈ ព្រោះសីលនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីសីល របស់បុគ្គលមានសីល ទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងច្រើន ជាកថាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកចេះដឹងច្រើន កាលបើពោលអំពីការចេះដឹងច្រើន រមែងមិនអាក់អួល មិនកម្រើកញាប់ញ័រ មិនឃ្នាន់ខ្នាញ់ មិនធ្វើសេចក្តីក្រោធខឹង ទឹងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលចេះដឹងច្រើននោះ ឃើញច្បាស់នូវសុតសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិនិងបាមោជ្ជៈ ព្រោះការចេះដឹងច្រើននោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងច្រើន ទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីការបរិច្ចាគទាន របស់បុគ្គលអ្នកបរិច្ចាគ ជាកថាល្អ តើដូចម្តេច ។

ចាគវា ភិក្ខវេ ចាគកថាយ កច្ឆមានាយ នាភិសជ្ជតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ ចាគសម្បទំ អត្តនិ សមនុបស្សតិ លភតិ ច តតោនិទានំ បីតិបាមុជ្ជំ តស្មា ចាគវតោ ចាគកថា សុកថា ។ កស្មា ច ភិក្ខវេ បញ្ញវតោ បញ្ញាកថា សុកថា ។ បញ្ញវា ភិក្ខវេ បញ្ញាកថាយ កច្ឆមានាយ នាភិសជ្ជតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ តំ កិស្ស ហេតុ ។ តញ្ហិ សោ ភិក្ខវេ បញ្ញាសម្បទំ អត្តនិ សមនុបស្សតិ លភតិ ច តតោនិទានំ បីតិបាមុជ្ជំ តស្មា បញ្ញវតោ បញ្ញាកថា សុកថា ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ បុគ្គលានំ កថា សុកថា បុគ្គលេ បុគ្គលំ ឧបនិធាយាតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានការលះ កាលបើពោលអំពីការលះ រមែងមិនរអាក់រអួល មិនក្រេវក្រោធ មិនព្យាបាទ មិនឃ្នាន់ខ្នាញ់ មិនធ្វើសេចក្តីក្រោធខឹង ទឹងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលអ្នកមានការលះ រមែងឃើញច្បាស់នូវចាគសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិនិងបាមោជ្ជៈ ព្រោះការលះនោះ ជាហេតុ ព្រោះហេតុនោះ ការពោលអំពីការលះ របស់បុគ្គលអ្នកលះ ទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ ការពោលអំពីបញ្ញា របស់បុគ្គលមានបញ្ញា ជាកថាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានបញ្ញា កាលបើពោលអំពីបញ្ញា រមែងមិនរអាក់រអួល មិនក្រេវក្រោធ មិនព្យាបាទ មិនឃ្នាន់ខ្នាញ់ មិនធ្វើសេចក្តីក្រោធខឹង ទឹងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលមានបញ្ញានោះ ឃើញច្បាស់នូវបញ្ញាសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិនិងបាមោជ្ជៈ ព្រោះបញ្ញានោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីបញ្ញា របស់បុគ្គលមានបញ្ញា ទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ កថារបស់បុគ្គលទាំង ៥ ពួកនេះឯង ជាកថាល្អ ដោយលើកយកបុគ្គលទៅប្រៀបនឹងបុគ្គល ។

(៥៨) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សារជ្ជំ ឱក្កន្តោ ហោតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អស្សទ្ធោ ហោតិ ទុស្សីលោ ហោតិ អប្បស្សុតោ ហោតិ កុសីតោ ហោតិ ទុប្បញ្ញោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សារជ្ជំ ឱក្កន្តោ ហោតិ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ វិសារទោ ហោតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធោ ហោតិ សីលវា ហោតិ ពហុស្សុតោ ហោតិ អារទ្ធវីរិយោ ហោតិ បញ្ញវា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ វិសារទោ ហោតីតិ ។

(៥៩) ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយិ មហតិយា គិហិបរិសាយ បរិវុតោ ធម្មំ ទេសេន្តោ និសិន្នោ ហោតិ ។

(៤៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងស្រុតចុះកាន់សេចក្តីញញើតញញើម ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសទ្ធា ១ ទ្រុស្តសីល ១ មានសេចក្តីចេះដឹងតិច ១ ខ្ជិលច្រអូស ១ អប្បឥតបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង នេះឯង រមែងស្រុតចុះកាន់សេចក្តីញញើតញញើម ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងជាអ្នកក្លៀវក្លា ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានសីល ១ ចេះដឹងច្រើន ១ ប្រារព្ធព្យាយាម ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងជាអ្នកក្លៀវក្លា ។

(៤៩) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះ ព្រះឧទាយិដ៏មានអាយុ មានបរិសទ្យគ្រហស្ថជាច្រើនចោមរោម កំពុងអង្គុយសំដែងធម៌ ។

អទ្ទសា ខោ អាយស្មា អានន្ទោ អាយស្មន្តំ ឧទាយឹ មហតិយា គិហិបរិសាយ បរិវុតំ ធម្មំ ទេសេន្តំ និសិន្នំ ទិស្វាន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អាយស្មា ភន្តេ ឧទាយិ មហតិយា គិហិបរិសាយ បរិវុតោ ធម្មំ ទេសេន្តោ និសិន្នោតិ(១) ។ ន ខោ អានន្ទ សុករំ បរេសំ ធម្មំ ទេសេតុំ បរេសំ អានន្ទ ធម្មំ ទេសេន្តេន បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរេសំ ធម្មោ ទេសេតព្វោ ។ កតមេ បញ្ច ។ អនុបុព្វីកថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ បរិយាយទស្សាវី កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ អនុទយតំ បដិច្ច កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ ន អាមិសន្តរោ កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ

---

១ ឱ. ម. ធម្មំ ទេសេតីតិ ទិស្សតិ ។

ព្រះអានន្ទដ៏មានអាយុ បានឃើញព្រះឧទាយិដ៏មានអាយុ មានបរិសទ្យគ្រហស្ថជាច្រើនចោមរោម កំពុងអង្គុយសំដែងធម៌ លុះឃើញហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះឧទាយិដ៏មានអាយុ មានបរិសទ្យគ្រហស្ថជាច្រើនចោមរោម កំពុងអង្គុយសំដែងធម៌ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ការសំដែងធម៌ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ ម្នាលអានន្ទ កាលភិក្ខុសំដែងធម៌ដល់ជនដទៃ គប្បីដំកល់ធម៌ ៥ យ៉ាង ឲ្យមានក្នុងខ្លួនសិន ទើបគួរសំដែងធម៌ដល់ជនដទៃ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ភិក្ខុត្រូវសំដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងសំដែងនូវអនុបុព្វកថា ១ ភិក្ខុត្រូវសំដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងសំដែងដោយលើកអាងហេតុផល ១ ភិក្ខុត្រូវសំដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងសំដែងពាក្យដោយអាស្រ័យសេចក្តីអាណិត (ដល់អ្នកស្តាប់)១ ភិក្ខុត្រូវសំដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងមិនសំដែង ព្រោះហេតុនៃអាមិស ១

អត្តានញ្ច បរញ្ច អនុបហច្ច កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ ។ ន ខោ អានន្ទ សុករំ បរេសំ ធម្មំ ទេសេតុំ បរេសំ អានន្ទ ធម្មំ ទេសេន្តេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរេសំ ធម្មោ ទេសេតព្វោតិ ។

(៦០) បញ្ចិមេ ភិក្ខវេ ឧប្បន្នា ទុប្បដិវិនោទយា ។ កតមេ បញ្ច ។ ឧប្បន្នោ រាគោ ទុប្បដិវិនោទយោ ឧប្បន្នោ ទោសោ ទុប្បដិវិនោទយោ ឧប្បន្នោ មោហោ ទុប្បដិវិនោទយោ ឧប្បន្នំ បដិភាណំ ទុប្បដិវិនោទយំ ឧប្បន្នំ គមិកចិត្តំ ទុប្បដិវិនោទយំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ឧប្បន្នា ទុប្បដិវិនោទយាតិ ។

សទ្ធម្មវគ្គោ បឋមោ ។

ភិក្ខុត្រូវសំដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងសំដែងដោយមិនបានបៀតបៀនខ្លួនឯង នឹងបុគ្គលដទៃ ១ ។ ម្នាលអានន្ទ ការសំដែងធម៌ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ ម្នាលអានន្ទ កាលភិក្ខុសំដែងធម៌ដល់ជនដទៃ ត្រូវដំកល់ធម៌ ៥ យ៉ាងនេះ ឲ្យមានក្នុងខ្លួនសិន ទើបគួរសំដែងធម៌ដល់ជនដទៃ ។

( ៦០ ) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ កើតឡើងហើយ បន្ទោបង់បានដោយកម្រ ។ ធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺរាគៈកើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ ទោសៈកើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ មោហៈកើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ បដិភាណៈ (ការពោលតនិយាយ) កើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ គមិកចិត្ត (ចិត្តប្រាថ្នានឹងទៅ) កើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ កើតឡើងហើយ បន្ទោបង់បានដោយកម្រ ។

ចប់ សទ្ធម្មវគ្គ ទី ១ ។

## តស្សុទ្ទានំ

តយោ សទ្ធម្មនិយាមា
តយោ សទ្ធម្មសម្មោសា
ទុក្កថា ចេវ សារជ្ជំ
ឧទាយិ ទុព្វិនោទយាតិ ។

# ឧទ្ទាននៃសទ្ធម្មវគ្គនោះគឺ

និយាយអំពីការឲ្យនានខ្លួន ដោយព្រះសទ្ធម្មមាន ៣ លើក អំពីសេចក្ដីសាបសូន្យនៃព្រះសទ្ធម្មមាន ៣ លើក អំពីពាក្យពោលអាក្រក់ ១ អំពីសេចក្ដីញាញើតញាញើម ១ អំពីព្រះឧទាយិ ១ អំពីធម៌ដែលបន្ទោបង់បានដោយក្រ ១ ។

# អាឃាតវគ្គោ ទុតិយោ

(៦១) បញ្ចិមេ ភិក្ខវេ អាឃាតប្បដិវិនយា យត្ថ ភិក្ខុនោ ឧប្បន្នោ អាឃាតោ សព្វសោ បដិវិនេតព្វោ ។ កតមេ បញ្ច ។ យស្មឹ ភិក្ខវេ បុគ្គលេ អាឃាតោ ជាយេថ មេត្តា តស្មឹ បុគ្គលេ ភាវេតព្វា ។ ឯវំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ យស្មឹ ភិក្ខវេ បុគ្គលេ អាឃាតោ ជាយេថ ករុណា តស្មឹ បុគ្គលេ ភាវេតព្វា ។ ឯវំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ យស្មឹ ភិក្ខវេ បុគ្គលេ អាឃាតោ ជាយេថ ឧបេក្ខា តស្មឹ បុគ្គលេ ភាវេតព្វា ។ ឯវំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ យស្មឹ ភិក្ខវេ បុគ្គលេ អាឃាតោ ជាយេថ អសតិមនសិការោ តស្មឹ បុគ្គលេ អាបជ្ជិតព្វោ ។ ឯវំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។

# អាឃាតវគ្គ ទី ២

(៦១) ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកំចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះមាន ៥ យ៉ាង ។ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចំរើនមេត្តាចិត្តចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចំរើនករុណាចិត្តចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចំរើនឧបេក្ខាចិត្តចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវប្រតិបត្តិនូវការមិនធ្វើទុកក្នុងចិត្ត ដោយស្មារតីចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។

យស្មឹំ ភិក្ខវេ បុគ្គលេ អាឃាតោ ជាយេថ កម្មស្សកតា តស្មឹំ បុគ្គលេ អធិដ្ឋាតព្វា កម្មស្សកោ អយមាយស្មា កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សតិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សតីតិ ។ ឯវំ តស្មឹំ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាឃាតប្បដិវិនយា យត្ថ ភិក្ខុនោ ឧប្បន្នោ អាឃាតោ សព្វសោ បដិវិនេតព្វោតិ ។

(៦២) តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច បញ្ចិមេ អាវុសោ អាឃាតប្បដិវិនយា យត្ថ ភិក្ខុនោ ឧប្បន្នោ អាឃាតោ សព្វសោ បដិវិនេតព្វោ ។ កតមេ បញ្ច ។ ឥធាវុសោ ឯកច្ចោ បុគ្គលោ អបរិសុទ្ធកាយសមាចារោ ហោតិ បរិសុទ្ធវចីសមាចារោ

ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវតាំងទុកនូវភាពនៃខ្លួនជាអ្នកមានកម្មជារបស់ខ្លួនចំពោះបុគ្គលនោះថា អ្នកនេះ មានកម្មជារបស់ខ្លួន ជាអ្នកទទួលយកនូវកម្ម មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់ អ្នកនេះនឹងធ្វើកម្មណា ទោះល្អក្តី អាក្រក់ក្តី គង់អ្នកនោះទទួលយកកម្មនោះពុំខានឡើយ ។ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកំចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះមាន ៥ យ៉ាង ។

[ ៦២ ] ព្រះសារីបុត្តដ៏មានអាយុ ហៅពួកភិក្ខុ ក្នុងទីនោះថា នែអាវុសោភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ក៏ទទួលស្តាប់ពាក្យព្រះសារីបុត្តដ៏មានអាយុថា អាវុសោ ដូច្នេះ ។ ព្រះសារីបុត្តដ៏មានអាយុក៏មានថេរវាចាយ៉ាងនេះថា នែអាវុសោទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកំចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះមាន ៥ យ៉ាង ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ក្នុងលោកនេះ មានបុគ្គលខ្លះ ជាអ្នកមានការប្រព្រឹត្តិ ដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្តិ ដោយវាចាដ៏បរិសុទ្ធ

ឯវរូបេបិ អាវុសោ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ អបរិសុទ្ធវចីសមាចារោ ហោតិ បរិសុទ្ធកាយសមាចារោ ឯវរូបេបិ អាវុសោ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ អបរិសុទ្ធកាយសមាចារោ ហោតិ អបរិសុទ្ធវចីសមាចារោ លភតិ ច កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ ឯវរូបេបិ អាវុសោ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ អបរិសុទ្ធកាយសមាចារោ ហោតិ អបរិសុទ្ធវចីសមាចារោ ន ច លភតិ កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ ឯវរូបេបិ អាវុសោ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ បរិសុទ្ធកាយសមាចារោ ហោតិ បរិសុទ្ធវចីសមាចារោ លភតិ ច កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ ឯវរូបេបិ អាវុសោ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោកនេះ មានបុគ្គលខ្លះ ជាអ្នកមានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោកនេះ មានបុគ្គលខ្លះ មានការប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ តែបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗ ដែរ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោកនេះ មានបុគ្គលខ្លះ មានការប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ ទាំងមិនបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោកនេះ មានបុគ្គលខ្លះ មានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ ទាំងបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។

តត្រាវុសោ យ្វាយំ បុគ្គលោ អបរិសុទ្ធកាយសមាចារោ បរិសុទ្ធវចីសមាចារោ កថំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ សេយ្យថាបិ អាវុសោ ភិក្ខុ បំសុកូលិកោ រថិយាយ នន្តកំ ទិស្វា វាមេន បាទេន និគ្គហេត្វា(១) ទក្ខិណេន បាទេន បត្ថរិត្វា(២) យោ តត្ថ សារោ តំ បរិបាតេត្វា(៣) អាទាយ បក្កមេយ្យ ឯវមេវ ខោ អាវុសោ យ្វាយំ បុគ្គលោ អបរិសុទ្ធកាយសមាចារោ បរិសុទ្ធវចីសមាចារោ យាស្ស អបរិសុទ្ធកាយសមាចារតា ន សាស្ស តស្មឹ សមយេ មនសិកាតព្វា យា ច ខ្វាស្ស បរិសុទ្ធវចីសមាចារតា សាស្ស តស្មឹ សមយេ មនសិកាតព្វា ។ ឯវំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ តត្រាវុសោ យ្វាយំ បុគ្គលោ អបរិសុទ្ធវចីសមាចារោ បរិសុទ្ធកាយសមាចារោ កថំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។

---

១ ម. និគ្គណ្ហិត្វា ។ ២ ឱ. វិត្ថារេត្វា ។ ៣ ឱ. បរិបាចេត្វា ។

ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណា មានការប្រព្រឹត្តិ ដោយកាយមិនបរិសុទ្ធ តែមានការប្រព្រឹត្តិ ដោយវាចាដ៏បរិសុទ្ធ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ដូចជាភិក្ខុអ្នកទ្រទ្រង់សំពត់បង្សុកូល បានឃើញផែនសំពត់នៅនាច្រកផ្លូវ ហើយជាន់នឹងជើងឆ្វេង លាត្រដាងមើលដោយជើងស្តាំ ហើយហែកសំពត់យកតែត្រង់កន្លែងដែលមានសាច់ជាប់ រួចកាន់យកដើរចៀសចេញទៅ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណា មានការប្រព្រឹត្តិ ដោយកាយមិនបរិសុទ្ធ តែមានការប្រព្រឹត្តិ ដោយវាចាដ៏បរិសុទ្ធ ភិក្ខុមិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្តិ ដោយកាយមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ ត្រូវធ្វើទុកក្នុងចិត្ត តែត្រង់សេចក្តីប្រព្រឹត្តិ ដោយវាចាដ៏បរិសុទ្ធ របស់បុគ្គលនោះ ក្នុងសម័យនោះប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ។ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ។

ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណា មានការប្រព្រឹត្តិ ដោយវាចាមិនបរិសុទ្ធ តែមានការប្រព្រឹត្តិ ដោយកាយដ៏បរិសុទ្ធ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការដូចម្តេច ។

សេយ្យថាបិ អាវុសោ បោក្ខរណី សេវាលបណ-
កបរិយោនទ្ធា អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ
ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ សោ
តំ បោក្ខរណឹ ឱគាហេត្វា ឧភោហិ ហត្ថេហិ(១)
សេវាលបណកំ អបវិយូហិត្វា អញ្ជលិនា បិវិត្វា
បក្កមេយ្យ ឯវមេវ ខោ អាវុសោ យ្វាយំ បុគ្គលោ
អបរិសុទ្ធវចីសមាចារោ បរិសុទ្ធកាយសមាចារោ
យាស្ស អបរិសុទ្ធវចីសមាចារតា ន សាស្ស តស្មឹ
សមយេ មនសិកាតព្វា យា ច ខ្វស្ស បរិសុទ្ធ-
កាយសមាចារតា សាស្ស តស្មឹ សមយេ មនសិ-
កាតព្វា ។ ឯវំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេ-
តព្វោ ។ តត្រាវុសោ យ្វាយំ បុគ្គលោ អបរិសុទ្ធ-
កាយសមាចារោ អបរិសុទ្ធវចីសមាចារោ លភតិ ច
កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ
កថំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។

១ ឱ. ម. ឯត្ថន្តរេ តតិបិតិ ជាតិ បទានិ ។

ម្នាលអាវុសោទាំងឡាយ ស្រះបោក្ខរណី ពាសពេញដោយសារាយ និងចក មានបុរសក្តៅខ្លាំងដោយកំដៅថ្ងៃ ត្រូវកំដៅថ្ងៃគ្របសង្កត់ នឿយហត់ អន្ទះអន្ទែង ស្រេក ដើរមកដល់ បុរសនោះ ក៏ចុះទៅរកស្រះបោក្ខរណីនោះ ហើយរែកសារាយនិងចកដោយដៃទាំងពីរ រួចក្បង់ទឹកផឹកដោយកំបង់ដៃ ទើបដើរចេញទៅ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ ភិក្ខុមិនត្រូវធ្វើទុកក្នុងចិត្ត នូវសេចក្តីប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ ត្រូវធ្វើទុកក្នុងចិត្តតែត្រង់សេចក្តីប្រព្រឹត្តដោយកាយដ៏បរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះប៉ុណ្ណោះវិញ ក៏យ៉ាងនោះដែរ ។ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណាមានសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏មិនបរិសុទ្ធ តែបានឱកាសស្ងប់នៃចិត្តនិងជ្រះថ្លានៃចិត្ត ក្នុងកាលម្តង ៗ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការដូចម្តេច ។

សេយ្យថាបិ អាវុសោ បរិត្តំ គោបទកេ(១) ឧទកំ អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ តស្ស ឯវមស្ស ឥទំ ខោ បរិត្តំ គោបទកេ ឧទកំ សចាហំ អញ្ជលិនា វា បិវិស្សាមិ ភាជនេន វា ខោភិស្សាមិបិ តំ លោឡិស្សាមិបិ តំ អបេយ្យម្បិ តំ ករិស្សាមិ យន្នូនាហំ ចតុក្កុណ្ឌិកោ(២) និបតិត្វា គោបីតកំ បិវិត្វា បក្កាមេយ្យន្តិ សោ ចតុក្កុណ្ឌិកោ និបតិត្វា គោបីតកំ បិវិត្វា បក្កាមេយ្យ ឯវមេវ ខោ អាវុសោ យ្វាយំ បុគ្គលោ អបរិសុទ្ធកាយសមាចារោ អបរិសុទ្ធវចីសមាចារោ លភតិ ច កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ យោ តស្ស អបរិសុទ្ធកាយសមាចារោ ន សោ តស្មឹ សមយេ មនសិកាតព្វោ យោបិ តស្ស អបរិសុទ្ធវចីសមាចារោ ន សោបិ តស្មឹ សមយេ មនសិកាតព្វោ យញ្ច ខោ សោ លភតិ

១ ឱ. ម. គោបទេ ។ ២ ឱ. ចតុក្កុណ្ឌិកោ ។ ម. ចតុក្ខុណ្ឌិកោ ។

ម្នាលអាវុសោទាំងឡាយ ដូចទឹកដ៏តិចដក់ ក្នុងជាន់ជើងគោ មានបុរសក្តៅខ្លាំងដោយកំដៅថ្ងៃ ត្រូវកំដៅថ្ងៃគ្របសង្កត់ នឿយហត់ អន្ទះអន្ទែងស្រេក ដើរមកដល់ បុរសអ្នកស្រេកទឹកនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ទឹកក្នុងជាន់ជើងគោនេះមានតិច បើអាត្មាអញផងផឹកដោយកំបង់ដៃឬដោយភាជនៈ ក៏ឈ្មោះថា អាត្មាអញធ្វើទឹកនោះឲ្យកក្រើកផង ឲ្យល្អក់ផង ទាំងធ្វើទឹកនោះ ឲ្យជាទឹកផឹកមិនបានផង បើដូច្នោះ មានតែអាត្មាអញប្រត់លុតជង្គង់ឱនផឹកដូចជាគោ ហើយដើរចេញទៅចុះ ដូច្នេះ បុរសនោះ ក៏ប្រត់ដៃលុតជង្គង់ឱនផឹកដូចជាគោរួចចៀសចេញទៅ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណា មានសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏មិនបរិសុទ្ធ តែបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តង ៗ ភិក្ខុមិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ មិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ (ព្រោះ) បុគ្គលនោះបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តង ៗ ឯណា

កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ តទេវស្ស តស្មឹ សមយេ មនសិកាតុំ ។ ឯវំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ តត្រាវុសោ យ្វាយំ បុគ្គលោ អបរិសុទ្ធកាយសមាចារោ អបរិសុទ្ធវចីសមាចារោ ន លភតិ កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ កថំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ សេយ្យថាបិ អាវុសោ បុរិសោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ អទ្ធានមគ្គប្បដិបន្នោ តស្ស បុរតោបិស្ស ទូរេ គាមោ បច្ឆតោបិស្ស ទូរេ គាមោ សោ ន លភេយ្យ សប្បាយានិ ភោជនានិ ន លភេយ្យ សប្បាយានិ ភេសជ្ជានិ ន លភេយ្យ បដិរូបំ ឧបដ្ឋាកំ ន លភេយ្យ គាមន្តនាយកំ តមេនំ អញ្ញតរោ បុរិសោ បស្សេយ្យ អទ្ធានមគ្គប្បដិបន្នោ សោ តស្មឹ បុរិសេ ការុញ្ញំយេវ ឧបដ្ឋាបេយ្យ អនុទយំយេវ ឧបដ្ឋាបេយ្យ អនុកម្បំយេវ ឧបដ្ឋាបេយ្យ អហោ វតាយំ បុរិសោ

ភិក្ខុត្រូវធ្វើទុកក្នុងចិត្តតែត្រង់ការបាននូវការស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលមួយៗនោះ របស់បុគ្គលនោះ ក្នុងសម័យនោះ ប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ។ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណាមានសេចក្តីប្រព្រឹត្តិ ដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្តិ ដោយវាចាក៏មិនបរិសុទ្ធ ទាំងមិនបាននូវការស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលមួយៗទេ តើភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ដូចបុរសមានអាពាធដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ ដើរទៅកាន់ផ្លូវឆ្ងាយ ស្រុកបុរសនោះ ក៏នៅឆ្ងាយទៅមុខផង ស្រុកបុរសនោះ ក៏នៅឆ្ងាយទៅក្រោយផង បុរសនោះ មិនបាននូវភោជនទាំងឡាយជាទីសប្បាយ មិនបានភេសជ្ជៈទាំងឡាយជាទីសប្បាយ មិនបានអ្នកទំនុកបម្រុងដ៏សមគួរ មនបានជនអ្នកនាំទៅរកស្រុកសោះ ស្រាប់តែមានបុរសម្នាក់ទៀត ដើរទៅកាន់ផ្លូវឆ្ងាយដែរ ក៏ឃើញបុរសនោះ គាត់ក៏តាំងទុកនូវសេចក្តីករុណាក្នុងបុរស (មានអាពាធ) នោះ តាំងទុកនូវសេចក្តីអាណិត តាំងទុកនូវសេចក្តីអនុគ្រោះ (ដោយបំណងថា) ធ្វើដូចម្តេចហ្ន៎ ឲ្យបុរសនេះ

លភេយ្យ សប្បាយានិ ភោជនានិ លភេយ្យ សប្បាយានិ ភេសជ្ជានិ លភេយ្យ បតិរូបំ ឧបដ្ឋាកំ លភេយ្យ គាមន្តនាយកំ ។ តំ កិស្ស ហេតុ ។ មាយំ បុរិសោ ឥធេវ អនយព្យសនំ អាបជ្ជីតិ[1] ឯវមេវ ខោ អាវុសោ យ្វាយំ បុគ្គលោ អបរិសុទ្ធកាយសមាចារោ អបរិសុទ្ធវចីសមាចារោ ន ច លភតិ កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ ឯវរូបេ អាវុសោ បុគ្គលេ ការុញ្ញំយេវ ឧបដ្ឋាបេតព្វំ អនុទយាយេវ ឧបដ្ឋាបេតព្វា អនុកម្បាយេវ ឧបដ្ឋាបេតព្វា អហោ វត អយមាយស្មា កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេយ្យ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេយ្យ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេយ្យ ។ តំ កិស្ស ហេតុ ។ មាយមាយស្មា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជីតិ ។ ឯវំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។

---

១ ឱ. អាបជ្ជីតិ ។ ម. អាបជ្ជេយ្យ ។

បាននូវភោជនទាំងឡាយជាទីសប្បាយ បាននូវភេសជ្ជៈទាំងឡាយជាទីសប្បាយ បាននូវអ្នកទំនុកបម្រុងដ៏សមគួរ បាននូវជនអ្នកនាំទៅក ស្រុកផងទៅអេះ ៗ ដំណើរនោះ ព្រោះហេតុអ្វី ៗ ព្រោះថាបុរសនេះ កុំដល់នូវសេចក្តីវិនាស ត្រង់កន្លែងនេះឡើយ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏មិនបរិសុទ្ធ ទាំងមិនបានឱកាសស្ងប់នៃចិត្តនឹងសេចក្តីជ្រះថ្លានៃចិត្តក្នុងកាលម្តង ៗ ទេ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុត្រូវតាំងទុកនូវសេចក្តីករុណា ត្រូវតាំងទុកនូវសេចក្តីអាណិត ត្រូវតាំងទុកនូវសេចក្តីអនុគ្រោះ ចំពោះបុគ្គលមានសភាព យ៉ាងនេះ (ដោយបំណងថា) ធ្វើដូចម្តេចហ្ន៎ អ្នកនេះ គប្បីលះកាយទុច្ចរិត ហើយចំរើនកាយសុចរិត លះវចីទុច្ចរិត ហើយចំរើនវចីសុចរិត លះមនោទុច្ចរិត ហើយចំរើនមនោសុចរិត ទឹងគេអេះ ៗ ដំណើរនោះ ព្រោះហេតុអ្វី ៗ ព្រោះថាកុំឲ្យអ្នកនេះ បែកធ្លាយរាងកាយស្លាប់ទៅកើតក្នុងកំណើតតិរច្ឆាន បិត្តិវិស័យ អសុរកាយនឹងនរកបានឡើយក៏មានឧបមេយ្យ យ៉ាងនោះដែរ ៗ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ៗ

តត្រាវុសោ យ្វាយំ បុគ្គលោ បរិសុទ្ធកាយសមាចារោ បរិសុទ្ធវចីសមាចារោ លភតិ ច កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ កថំ តស្មឹ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ សេយ្យថាបិ អាវុសោ បោក្ខរណី អច្ឆោទកា សាតោទកា សីតោទកា សេតោទកា សុបតិត្ថា រមណីយា នានារុក្ខេហិ សញ្ឆន្នា អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ សោ តំ បោក្ខរណឹ ឱគាហេត្វា នហាត្វា ច បិវិត្វា ច បច្ចុត្តរិត្វា តត្ថេវ រុក្ខច្ឆាយាយ និសីទេយ្យ វា និបជ្ជេយ្យ វា ឯវមេវ ខោ អាវុសោ យ្វាយំ បុគ្គលោ បរិសុទ្ធកាយសមាចារោ បរិសុទ្ធវចីសមាចារោ លភតិ ច កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ យាបិស្ស បរិសុទ្ធកាយសមាចារតា សាបិស្ស តស្មឹ សមយេ មនសិកាតព្វា យាបិស្ស បរិសុទ្ធវចីសមាចារតា សាបិស្ស តស្មឹ សមយេ មនសិកាតព្វា

ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណា មានសេចក្តីប្រព្រឹត្តិ ដោយកាយបរិសុទ្ធ មានសេចក្តីប្រព្រឹត្តិ ដោយវាចាក៏បរិសុទ្ធ ទាំងបានឱកាសស្ងប់នៃចិត្តនឹងសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ តើភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះ ដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ស្រះបោក្ខរណី មានទឹកថ្លា ឆ្ងាញ់ ត្រជាក់ ស មានកំពង់រាបល្អ គួររីករាយ ដេរដាសដោយដើមឈើផ្សេងៗ ហើយមានបុរសក្តៅខ្លាំង ដោយកំដៅថ្ងៃ ត្រូវកំដៅថ្ងៃគ្របសង្កត់ នឿយហត់ អន្ទះអន្ទែង ស្រេក ដើរមកដល់ បុរសនោះ ក៏ចុះក្នុងស្រះបោក្ខរណីនោះ ងូតផង ផឹកផង ហើយត្រឡប់ឡើងមកអង្គុយឬដេកក្រោមម្លប់ឈើ ប្របស្រះបោក្ខរណីនោះឯង មានឧបមាយ៉ាងណា ម្នាលអាវុសោទាំងឡាយ បុគ្គលណា មានសេចក្តីប្រព្រឹត្តិ ដោយកាយដ៏បរិសុទ្ធ មានសេចក្តីប្រព្រឹត្តិ ដោយវាចាក៏បរិសុទ្ធ ទាំងបានឱកាសស្ងប់នៃចិត្តនឹងសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ ភិក្ខុត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្តិ ដោយកាយដ៏បរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះផង ត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្តិ ដោយវាចាដ៏បរិសុទ្ធ របស់បុគ្គលនោះ ក្នុងសម័យនោះផង

យម្ហិ សោ លភតិ កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ តម្បិស្ស តស្មិំ សមយេ មនសិកាតព្វំ ។ ឯវំ តស្មិំ បុគ្គលេ អាឃាតោ បដិវិនេតព្វោ ។ សមន្តបាសាទិកំ អាវុសោ បុគ្គលំ អាគម្ម ចិត្តំ បសីទតិ ។ ឥមេ ខោ អាវុសោ បញ្ច អាឃាតបដិវិនយា យត្ថ ភិក្ខុនោ ឧប្បន្នោ អាឃាតោ សព្វសោ បដិវិនេតព្វោតិ ។

(៦៣) តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ។ បេ ។ បញ្ចហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំសាកច្ឆោ សព្រហ្មចារីនំ ។ កតមេហិ បញ្ចហិ ។ ឥធាវុសោ ភិក្ខុ អត្តនា ច សីលសម្បន្នោ ហោតិ សីលសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច សមាធិសម្បន្នោ ហោតិ សមាធិសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច បញ្ញាសម្បន្នោ ហោតិ បញ្ញាសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច វិមុត្តិសម្បន្នោ ហោតិ វិមុត្តិសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ

(ព្រោះ) បុគ្គលនោះ បានឱកាសស្ងប់នៃចិត្តនិងសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ ឯណា ភិក្ខុត្រូវធ្វើទុកក្នុងចិត្តនូវការបាននូវឱកាសស្ងប់នៃចិត្តនិងសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ នោះ របស់បុគ្គលនោះ ក្នុងសម័យនោះផង ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ភិក្ខុត្រូវកំចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ ចិត្តជ្រះថ្លាព្រោះមកកប់ប្រសព្វនឹងបុគ្គលដែលមានគុណគួរឲ្យជ្រះថ្លាបំផុត ។ ម្នាលអាវុសោទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកំចាត់បង់សព្វគ្រប់ដោយអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះមាន ៥ យ៉ាង ។

(៦៣) ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុ ក្នុងទីនោះថា ។ បេ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរសាកសួរ (ធម៌អាថ៌) នឹងសព្រហ្មចារីទាំងឡាយបាន ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុជាអ្នកបរិបូណ៌ ដោយសីលខ្លួនឯងទាំងព្យាករនូវប្រស្នាដែលមក ក្នុងសីលសម្បទាកថា ១ បរិបូណ៌ដោយសមាធិខ្លួនឯងទាំងព្យាករនូវប្រស្នាដែលមក ក្នុងសមាធិសម្បទាកថា ១ បរិបូណ៌ដោយបញ្ញាខ្លួនឯងទាំងព្យាករនូវប្រស្នាដែលមក ក្នុងបញ្ញាសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិខ្លួនឯងទាំងព្យាករនូវប្រស្នាដែលមក ក្នុងវិមុត្តិសម្បទាកថា ១

អត្តនា ច វិមុត្តិញាណទស្សនសម្បន្នោ ហោតិ វិមុត្តិញាណទស្សនសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ ។ ឥមេហិ ខោ អាវុសោ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំសាកច្ឆោ សព្រហ្មចារីនន្តិ ។

(៦៨) តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ។បេ។ បញ្ចហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំសាជីវោ សព្រហ្មចារីនំ ។ កតមេហិ បញ្ចហិ ។ ឥធាវុសោ ភិក្ខុ អត្តនា ច សីលសម្បន្នោ ហោតិ សីលសម្បទាកថាយ ច កតំ(១) បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច សមាធិសម្បន្នោ ហោតិ សមាធិសម្បទាកថាយ ច កតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច បញ្ញាសម្បន្នោ ហោតិ បញ្ញាសម្បទាកថាយ ច កតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច វិមុត្តិសម្បន្នោ ហោតិ វិមុត្តិសម្បទាកថាយ ច កតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច វិមុត្តិញាណទស្សនសម្បន្នោ ហោតិ

---

១ ម. អាគតំ ។

បរិបូណ៌ដោយវិមុត្តិញាណទស្សនៈខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងវិមុត្តិញាណទស្សនសម្បទាកថា ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរសាកសួរនឹងសព្រហ្មចារីទាំង-ឡាយបាន ។

(៦៨) ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុ ក្នុងទីនោះថា ។ បេ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរដល់សាជីវៈជាមួយនឹងសព្រហ្មចារីទាំងឡាយបាន ។ ធម ៥ យ៉ាង តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានភិក្ខុជាអ្នកបរិបូណ៌ដោយសីលខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងសីលសម្បទាកថា ១ បរិបូណ៌ដោយសមាធិខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងសមាធិសម្បទាកថា ១ បរិបូណ៌ដោយបញ្ញាខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងបញ្ញាសម្ប-ទាកថា ១ បរិបូណ៌ដោយវិមុត្តិខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងវិមុត្តិសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈខ្លួនឯង

វិមុត្តិញាណទស្សនសម្បទាកថាយ ច គតំ បញ្ហំ ព្យាកត្តា ហោតិ ។ ឥមេហិ ខោ អាវុសោ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំសាជីវោ សព្រហ្មចារីនន្តិ ។

(៦៥) តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ។ បេ ។ យោ ហិ កោចិ អាវុសោ បរំ បញ្ហំ បុច្ឆតិ សព្វោ សោ បញ្ចហិ ឋានេហិ ឯតេសំ វា អញ្ញតរេន ។ កតមេហិ បញ្ចហិ ។ មន្ទត្តា មោមូហត្តា បរំ បញ្ហំ បុច្ឆតិ បាបិច្ឆោ ឥច្ឆាបកតោ បរំ បញ្ហំ បុច្ឆតិ បរិភវំ បរំ បញ្ហំ បុច្ឆតិ អញ្ញាតុកាមោ បរំ បញ្ហំ បុច្ឆតិ អថវា បនេវំចិត្តោ[១] បរំ បញ្ហំ បុច្ឆតិ សចេ មេ បញ្ហំ បុដ្ឋោ សម្មទេវ ព្យាករិស្សតិ ឥច្ចេតំ កុសលំ នោ ច[២] មេ បញ្ហំ បុដ្ឋោ សម្មទេវ ព្យាករិស្សតិ អហមស្ស សម្មទេវ ព្យាករិស្សាមីតិ ។

---

១ ឱ. អថ វា បកុប្បន្តោ ។ ២ ឱ. ម. បេ ។

ទាំងពាក្យតបនូវប្រស្នាដែលមក ក្នុងវិមុត្តិញាណទស្សនសម្បទាកថា ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរដល់សាជីវៈជាមួយនឹងសព្រហ្មចារីទាំងឡាយបាន ។

(៦៥) ព្រះសារីបុត្តដ៏មានអាយុ មានថេរពាចានឹងពួកភិក្ខុ ក្នុងទីនោះថា ។ បេ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាសួរប្រស្នានឹងអ្នកដទៃ ភិក្ខុអស់នោះ (រមែងសួរ) ដោយហេតុទាំង ៥ យ៉ាង ឬបណ្តាហេតុទាំង ៥ យ៉ាងនុ៎ះ ហេតុណាមួយ ។ ហេតុទាំង ៥ យ៉ាង តើដូចម្តេច ។ គឺភិក្ខុសួរប្រស្នានឹងអ្នកដទៃ ព្រោះស្មារតីទន់ ព្រោះល្ងង់ខ្លៅ ១ មានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នា ហើយសួរប្រស្នានឹងអ្នកដទៃ ១ សួរប្រស្នានឹងអ្នកដទៃ ដើម្បីសង្កត់សង្កិន ១ មិនចង់ដឹង ហើយសួរប្រស្នានឹងអ្នកដទៃ ១ មួយយ៉ាងទៀត ភិក្ខុមានគំនិតយ៉ាងនេះហើយ សួរប្រស្នានឹងអ្នកដទៃ ថាបើ ភិក្ខុដែលអាត្មាអញសួរប្រស្នាហើយ រកដោះសាដោយត្រឹមត្រូវបាន ការដោះសានុ៎ះជាការល្អ បើអាត្មាអញសួរប្រស្នាហើយ ដោះសាដោយត្រឹមត្រូវមិនបានទេ អាត្មាអញនឹងដោះសាដោយត្រឹមត្រូវ ឲ្យភិក្ខុនោះវិញ ១ ។

យោ ហិ កោចិ អាវុសោ បរំ បញ្ហំ បុច្ឆតិ សព្វោ សោ ឥមេហិ បញ្ចហិ ឋានេហិ ឯតេសំ វា អញ្ញតរេន ។ អហំ ខោ បនាវុសោ ឯវំចិត្តោ បរំ បញ្ហំ បុច្ឆាមិ សចេ មេ បញ្ហំ បុដ្ឋោ សម្មទេវ ព្យាករិស្សតិ ឥច្ចេតំ កុសលំ នោ ចេ មេ បញ្ហំ បុដ្ឋោ សម្មទេវ ព្យាករិស្សតិ អហមស្ស សម្មទេវ ព្យាករិស្សាមីតិ ។

[៦៦] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ។បេ។ ឥធាវុសោ ភិក្ខុ សីលសម្បន្នោ សមាធិសម្បន្នោ បញ្ញាសម្បន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ អត្ថេតំ ឋានំ នោ ចេ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ អតិក្កម្មេវ កពឡិង្ការាហារភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ អត្ថេតំ ឋានន្តិ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុណាសួរប្រស្នានឹងអ្នកដទៃ ភិក្ខុអស់នោះ (រមែងសួរ) ដោយហេតុទាំង ៥ យ៉ាងនេះ ឬបណ្តាហេតុទាំង ៥ យ៉ាងនុ៎ះ ហេតុណាមួយក៏មាន ។ ម្នាលអាវុសោទាំងឡាយ ចំណែកខាងខ្ញុំ មានគំនិតយ៉ាងនេះ ទើបសួរប្រស្នានឹងអ្នកដទៃ ថាបើ ភិក្ខុដែលអាត្មាអញសួរប្រស្នាហើយ គេព្យាករដោយត្រឹមត្រូវបាន ការព្យាករណ៍ដោយត្រឹមត្រូវដូច្នេះនេះ ជាការល្អ បើអាត្មាអញសួរប្រស្នាហើយ គេព្យាករដោយត្រឹមត្រូវមិនបានទេ អាត្មាអញនឹងព្យាករដោយត្រឹមត្រូវ ឲ្យភិក្ខុនោះវិញ ១ ។

(៦៦) ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុក្នុងទីនោះថា ។ បេ ។ ម្នាលអាវុសោទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា គួរចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះតែងតែមាន បើមិនបានសម្រេចអរហត្ត ក្នុងកាលជាបច្ចុប្បន្នទេ ក៏ផុះរំលងនូវការកើតរួមនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ (១) ហើយកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ (២) រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះតែងតែមាន ។

---

១ គឺរំលងពួកកាមាវចរទេវតា ។ ២ គឺកើតក្នុងពួកសុទ្ធាវាសព្រហ្មមួយពួក ដែលកើតដោយឈានចិត្ត ។ អដ្ឋកថា ។

ឯវំ វុត្តេ អាយស្មា ឧទាយិ អាយស្មន្តំ សារីបុត្តំ ឯតទវោច អដ្ឋានំ ខោ ឯតំ អាវុសោ សារីបុត្ត អនវកាសោ យំ សោ ភិក្ខុ អតិក្កម្មេវ កពឡិង្ការាហារភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ នត្ថេតំ ឋានន្តិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ឥធាវុសោ ភិក្ខុ សីលសម្បន្នោ សមាធិសម្បន្នោ បញ្ញាសម្បន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ អត្ថេតំ ឋានំ ។ សោ ចេ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ អតិក្កម្មេវ កពឡិង្ការាហារភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ អត្ថេតំ ឋានន្តិ ។ តតិយម្បិ ខោ អាយស្មា ឧទាយិ អាយស្មន្តំ សារីបុត្តំ ឯតទវោច អដ្ឋានំ ខោ ឯតំ អាវុសោ សារីបុត្ត

កាលបើព្រះសារីបុត្ត មានថេរវាទយ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏និយាយនឹងព្រះសារីបុត្តដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ដំណើរនុ៎ះមិនសមហេតុ មិនសមផលទេ ដែលថា ភិក្ខុនោះផុតរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ មិនដែលមានទេ ។ អស់វារៈជាគំរប់ ២ ដងផង ។ បេ ។ ព្រះសារីបុត្តដ៏មានអាយុ មានថេរវាទនឹងពួកភិក្ខុអស់វារៈជាគំរប់ ៣ ដងថា ម្នាលអាវុសោទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា ហើយចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ តែងតែមាន បើមិនបានសម្រេចអរហត្ត ក្នុងកាលជាបច្ចុប្បន្នទេ ក៏ផុតរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ តែងតែមាន ។ ព្រះឧទាយិដ៏មានអាយុ និយាយនឹងព្រះសារីបុត្តដ៏មានអាយុ ជាគំរប់ ៣ ដងយ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ដំណើរនុ៎ះមិនសមហេតុ សមផលទេ

អនវកាសោ យំ សោ ភិក្ខុ អតិក្កម្មេវ កពឡិង្ការាហារភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ នេតំ ឋានន្តិ ។ អថខោ អាយស្មតោ សារីបុត្តស្ស ឯតទហោសិ យាវតតិយម្បិ ខោ មេ អាយស្មា ឧទាយិ បដិក្កោសតិ ន ច មេ កោចិ ភិក្ខុ អនុមោទតិ យន្នូនាហំ យេន ភគវា តេនុបសង្កមេយ្យន្តិ ។ អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ឥធាវុសោ ភិក្ខុ សីលសម្បន្នោ សមាធិសម្បន្នោ បញ្ញាសម្បន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ អត្ថេតំ ឋានំ ។ នោ ចេ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ អតិក្កម្មេវ កពឡិង្ការាហារភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យបិ

ដែលថា ភិក្ខុនោះផុតរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ មិនដែលមានទេ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឧទាយិដ៏មានអាយុ ចេះតែហាមឃាត់ (ពាក្យ) អាត្មាអញ អស់ ៣ ដងមកហើយ ភិក្ខុណាមួយ ក៏មិនអនុមោទនា (ពាក្យ) អាត្មាអញសោះ បើដូច្នោះ មានតែអាត្មាអញចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ក៏មានថេរវាចានឹងពួកភិក្ខុថា ម្នាលអាវុសោទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា គួរចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ តែងតែមាន បើមិនបានសម្រេចអរហត្ត ក្នុងកាលជាបច្ចុប្បន្នទេ ក៏ផុតរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន

វុដ្ឋហេយ្យាបិ អត្ថេតំ ឋានន្តិ ។ ឯវំ វុត្តេ អាយស្មា ឧទាយិ អាយស្មន្តំ សារីបុត្តំ ឯតទវោច អដ្ឋានំ ខោ ឯតំ អាវុសោ សារីបុត្ត អនវកាសោ យំ សោ ភិក្ខុ អតិក្កម្មេវ កពឡីង្ការាហារភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យាបិ វុដ្ឋហេយ្យាបិ នត្ថេតំ ឋានន្តិ ។ ទុតិយម្បិ ខោ ។បេ។ តតិយម្បិ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ឥធាវុសោ ភិក្ខុ សីលសម្បន្នោ សមាធិសម្បន្នោ បញ្ញាសម្បន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យាបិ វុដ្ឋហេយ្យាបិ អត្ថេតំ ឋានំ នោ ចេ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ អតិក្កម្មេវ កពឡីង្ការាហារភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យាបិ វុដ្ឋហេយ្យាបិ អត្ថេតំ ឋានន្តិ ។ តតិយម្បិ ខោ អាយស្មា ឧទាយិ អាយស្មន្តំ សារីបុត្តំ ឯតទវោច អដ្ឋានំ ខោ ឯតំ អាវុសោ សារីបុត្ត

ចេញក៏បាន ហេតុនេះ តែងតែមាន ។ កាលបើព្រះសារីបុត្តដ៏មានអាយុ មានថេរវាចាយ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏មានថេរវាចានឹងព្រះសារីបុត្តដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ដំណើរនោះ មិនសមហេតុ មិនសមផលទេ ដែលថាភិក្ខុនោះ ផ្លោះរំលងនូវការកើតជា-មួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតាដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ មិនដែលមានទេ ។ អស់វារៈ ២ ដង ។ បេ ។ ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុ អស់វារៈ ៣ ដងថា ម្នាលអាវុសោទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា គួរចូលកាន់សញ្ញា-វេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ តែងតែមាន បើមិនបានសម្រេចអរហត្ត ក្នុងបច្ចុប្បន្ននេះទេ ក៏ផ្លោះរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតាដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ តែងតែមាន ។ ព្រះឧទាយិដ៏មានអាយុ មានថេរវាចានឹងព្រះសារីបុត្តដ៏មានអាយុ អស់វារៈជាគំរប់ ៣ ដងយ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ដំណើរនេះ មិនសមហេតុ មិនសមផលទេ

អនវកាសោ យំ សោ ភិក្ខុ អតិក្កម្មេវ កពឡឹង្ការាហារភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ សញ្ញាវេទយិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ នេតំ ឋានន្តិ ។ អថ ខោ អាយស្មតោ សារីបុត្តស្ស ឯតទហោសិ ភគវតោបិ ខោ មេ សម្មុខា អាយស្មា ឧទាយិ យាវតតិយកំ បដិក្កោសតិ ន ច មេ កោចិ ភិក្ខុ អនុមោទតិ យន្នូនាហំ តុណ្ហី អស្សន្តិ ។ អថ ខោ អាយស្មា សារីបុត្តោ តុណ្ហី អហោសិ ។ អថ ខោ ភគវា អាយស្មន្តំ ឧទាយឹ អាមន្តេសិ កំ បន ត្វំ ឧទាយិ មនោមយំ កាយំ បច្ចេសីតិ ។ យេ តេ ភន្តេ ទេវា អរូបិនោ សញ្ញាមយាតិ ។ កឹ នុ ខោ តុយ្ហំ ឧទាយិ ពាលស្ស អព្យត្តស្ស ភណិតេន ត្វំបិ នាម ភណិតព្វំ មញ្ញសីតិ ។ អថ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ

ដែលថា ភិក្ខុនោះ ផ្លោះរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ មិនដែលមានទេ ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា អម្បាលទីចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ម្តេចព្រះឧទាយិដ៏មានអាយុ ក៏នៅតែពាំងពាក្យរបស់អាត្មាអញ អស់វារៈជាគំរប់ ៣ ដង រកភិក្ខុណាមួយ អនុមោទនាពាក្យរបស់អាត្មាអញគ្មាន សោះ បើដូច្នោះ គួរតែអាត្មាអញនៅស្ងៀមទៅចុះ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ក៏នៅស្ងៀម ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះឧទាយិដ៏មានអាយុថា ម្នាលឧទាយិ តើអ្នក យល់ពួកទេវតា ដែលសម្រេចដោយចិត្តដូចម្តេច ។ ព្រះឧទាយិដ៏មានអាយុក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពួកទេវតាណា មិនមានរូប មានតែសញ្ញា (ខ្ញុំព្រះអង្គយល់ពួកទេវតានោះ) ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលឧទាយិ ប្រយោជន៍អ្វី ដោយការនិយាយ ជាមួយនឹងអ្នកដែលជាបុគ្គលពាលមិនឈ្លាស ខ្លួនអ្នកដឹងបានតែពាក្យ ដែលខ្លួនត្រូវពោល ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា

អត្ថិ នាម អានន្ទ ថេរំ ភិក្ខុំ វិហេសិយមានំ អជ្ឈុបេក្ខិស្សថ ន ហិ នាម អានន្ទ ការុញ្ញំបិ ភវិស្សតិ ព្យត្តម្ហិ ភិក្ខុម្ហិ វិហេសិយមានម្ហីតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ឥធ ភិក្ខវេ ភិក្ខុ សីល-សម្បន្នោ សមាធិសម្បន្នោ បញ្ញាសម្បន្នោ សញ្ញា-វេទយិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ អត្ថេតំ ឋានំ នោ ចេ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ អតិក្កម្មេវ កពឡិង្ការាហារភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ សញ្ញាវេទ-យិតនិរោធំ សមាបជ្ជេយ្យបិ វុដ្ឋហេយ្យបិ អត្ថេតំ ឋានន្តិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ អាយស្មា អានន្ទោ អចិរបក្កន្តស្ស ភគវតោ យេនាយស្មា ឧបវាណោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបវាណំ ឯតទវោច ឥធាវុសោ ឧបវាណ អញ្ញេ ថេរ ភិក្ខូ[១] វិហេសេន្តិ មយន្តេ ន បុច្ឆាម ។

---

១ ឱ. អញ្ញេ ថេរំ ភិក្ខុំ ។

មើលចុះអានន្ទ (តទៅ) ពួកអ្នកគង់ព្រងើយកន្តើយនឹងភិក្ខុជាថេរៈ ដែលគេបៀតបៀន ម្នាលអានន្ទ មិនគួរបើនឹងមិនមានសេចក្តីករុណា ចំពោះភិក្ខុអ្នកផ្លាស់ដែលគេបៀតបៀនសោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា គួរចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ តែងតែមាន បើមិនបានសម្រេចអរហត្ត ក្នុងកាលជាបច្ចុប្បន្ននេះទេ ក៏ផុតរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ តែងតែមាន ។ ព្រះដ៏មានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះហើយ លុះព្រះសុគតទ្រង់ត្រាស់ព្រះពុទ្ធដីកានេះហើយ ទើបក្រោកចាកអាសនៈ រួចចូលទៅកាន់គន្ធកុដិ ។ កាលព្រះដ៏មានព្រះភាគចេញទៅមិនយូរប៉ុន្មាន ព្រះអានន្ទដ៏មានអាយុ ក៏ចូលទៅរកព្រះឧបវានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏មានថេរវាចានឹងព្រះឧបវានៈដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោឧបវានៈ ឥឡូវនេះ ពួកភិក្ខុដទៃបៀតបៀនពួកភិក្ខុជាថេរៈ យើងមិនទាន់បានសួរពួកភិក្ខុទាំងនោះទេ ។

អនច្ឆរិយំ ខោ បនេតំ អាវុសោ ឧបវាណ យំ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ ឯតទេវ អារព្ភ ឧទាហរេយ្យ យថា អាយស្មន្តញ្ញេវ ឧបវាណំ បដិភាសេយ្យ ។ ឥទានេវ អម្ហាកំ សារជ្ជំ ឱក្កន្តិ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ឧបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ ឧបវាណំ ឯតទវោច កតីហិ នុ ខោ ឧបវាណ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ចាតិ ។ បញ្ចហិ ភន្តេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ ឥធ ភន្តេ ថេរោ ភិក្ខុ សីលវា ហោតិ ។ បេ ។ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ

ម្នាលអាវុសោឧបវាន: ហេតុនេះ មិនជាអស្ចារ្យទេ ដែលព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទីស្ងាត់ ក្នុងសាយណ្ហសម័យ ហើយត្រាស់ប្រារព្ធនូវហេតុនេះឯង ដូចជាទ្រង់ត្រាស់បំភ្លឺនូវព្រះឧបវាន:ដ៏មានអាយុ ក្នុងហេតុនុះដែរ ។ ឥឡូវនេះ សេចក្តីសោមនស្ស ក៏ប្រៀតចូល (ក្នុងចិត្ត) របស់យើងដែរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទីស្ងាត់ ក្នុងសាយណ្ហសម័យ ហើយស្តេចយាងចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុកថ្វាយ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ស្រេចហើយ ក៏បានត្រាស់នឹងព្រះឧបវាន:ដ៏មានអាយុ យ៉ាងនេះថា ម្នាលឧបវាន: ភិក្ខុជាថេរៈ ប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបជាទីស្រឡាញ់ ជាទីគាប់ចិត្ត គួរគោរពនឹងគួរសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាង ទើបជាទីស្រឡាញ់ ជាទីគាប់ចិត្ត គួរគោរពនឹងគួរសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងសាសនានេះ ភិក្ខុជាថេរៈ ជាអ្នកមានសីល ។ បេ ។ សិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកចេះដឹងច្រើន ។ បេ ។ ជាអ្នកចាក់ធ្លុះល្អដោយប្រាជ្ញា ១ ជាអ្នកមានវាចាដ៏ពីរោះ មានសំដីដ៏ផ្អែមល្ហែម ប្រកបដោយវាចារបស់អ្នកក្រុង

វិសុទ្ធាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភន្តេ បញ្ចហិ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ចាតិ ។ សាធុ សាធុ ឧបាលិ ឥមេហិ ខោ ឧបាលិ បញ្ចហិ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ ឥមេ ចេ ឧបាលិ បញ្ច ធម្មា ថេរស្ស ភិក្ខុនោ ន សំវិជ្ជេយ្យុំ កេន នំ សព្រហ្មចារី សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ(១) ខណ្ឌិច្ចេន ផាលិច្ចេន វលិត្តចតាយ ។ យស្មា ច ខោ ឧបាលិ ឥមេ បញ្ច ធម្មា ថេរស្ស ភិក្ខុនោ សំវិជ្ជន្តិ តស្មា តំ សព្រហ្មចារី សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តីតិ ។

---

១ ម. តំ សព្រហ្មចារី ន សក្ករេយ្យុំ ន គរុករេយ្យុំ ន មានេយ្យុំ ន បូជេយ្យុំ ។

ជាវាចាក្បោះក្បាយ មិនមានទោស គួរធ្វើអ្នកដទៃឲ្យដឹងសេចក្តីច្បាស់លាស់បាន ១ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រ នូវឈានទាំង ៤ ជាគ្រឿងនៅជាសុខ ក្នុងកាលជាបច្ចុប្បន្ន ដែលប្រកបដោយចេតសិកដ៏ថ្លៃថ្លា ១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាងនេះ ទើបជាទីស្រឡាញ់ ជាទីគាប់ចិត្ត គួរគោរព និងគួរសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ម្នាលឧបវានៈ ត្រូវណាស់ហើយ ត្រូវណាស់ហើយ ម្នាលឧបវានៈ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបជាទីស្រឡាញ់ ជាទីគាប់ចិត្ត គួរគោរពនិងគួរសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ម្នាលឧបវានៈ បើធម៌ ៥ យ៉ាងនេះ មិនមានដល់ភិក្ខុជាថេរៈទេ តើពួកសព្រហ្មចារី គួរធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុជាថេរៈនោះ ត្រង់ធ្មេញបាក់ សក់ស្កូវ និងស្បែកជ្រួញជ្រីវ ឬដូចម្តេច ។ ម្នាលឧបវានៈ ព្រោះហេតុនោះ ធម៌ ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុជាថេរៈ ទើបពួកសព្រហ្មចារី ធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុជាថេរៈនោះបាន ។

[៦៧] អថ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ចោទកេន អាវុសោ ភិក្ខុនា បរំ ចោទេតុកាមេន បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោ ។ កតមេ បញ្ច ។ កាលេន វក្ខាមិ នោ អកាលេន ភូតេន វក្ខាមិ នោ អភូតេន សណ្ហេន វក្ខាមិ នោ ផរុសេន អត្ថសញ្ហិតេន វក្ខាមិ នោ អនត្ថសញ្ហិតេន មេត្តចិត្តោ[១] វក្ខាមិ នោ ទោសន្តរោ[២] ។ ចោទកេន អាវុសោ ភិក្ខុនា បរំ ចោទេតុកាមេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោ ។ ឥធាហំ អាវុសោ ឯកច្ចំ បុគ្គលំ បស្សាមិ អកាលេន ចោទិយមានំ នោ កាលេន កុបិតំ អភូតេន ចោទិយមានំ នោ ភូតេន កុបិតំ ផរុសេន ចោទិយមានំ

---

១ ឱ. ម. មេត្តចិត្តេន ។ ២ ឱ. ម. ទោសន្តរេន ។

(៦៧) ព្រះសារីបុត្តដ៏មានអាយុ បានហៅពួកភិក្ខុ ក្នុងទីនោះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿន ចង់ដាស់តឿនភិក្ខុដទៃ គួរដំកលធម៌ ៥ យ៉ាងទុកក្នុងខ្លួន ហើយសឹមដាស់តឿនភិក្ខុដទៃ ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ (គឺភិក្ខុគិតថា) អាត្មាអញនយាយដាស់តឿនក្នុងកាលគួរ មិននិយាយដាស់តឿនក្នុងកាលមិនគួរ ១ អាត្មាអញនិយាយដាស់តឿនដោយពាក្យពិត មិននិយាយដាស់តឿនដោយពាក្យមិនពិត ១ អាត្មាអញនិយាយដាស់តឿនដោយពាក្យពីរោះ មិននិយាយដាស់តឿនដោយពាក្យទ្រគោះ ១ អាត្មាអញនិយាយដាស់តឿនដោយពាក្យដែលប្រកបដោយប្រយោជន៍ មិននិយាយដាស់តឿនដោយពាក្យដែលមិនប្រកបដោយប្រយោជន៍ ១ អាត្មាអញនិយាយដាស់តឿនដោយចិត្តមេត្តា មិននិយាយដាស់តឿនដោយទោសចិត្ត ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿន ចង់ដាស់តឿនភិក្ខុដទៃ គួរដំកល់ធម៌ ៥ យ៉ាងនេះទុកក្នុងខ្លួន ហើយសឹមដាស់តឿនភិក្ខុដទៃ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំឃើញបុគ្គលខ្លះ ក្នុងលោកនេះ ដែលគេដាស់តឿនក្នុងកាលមិនគួរ មិនដាស់តឿនក្នុងកាលគួរ ហើយមានសេចក្តីខឹង ១ ដែលគេដាស់តឿនដោយពាក្យមិនពិត មិនដាស់តឿនដោយពាក្យពិត ហើយមានសេចក្តីខឹង ១

នោ សណ្ហេន ចុទិតំ អនត្ថសញ្ហិតេន ហោតិយមានំ
នោ អត្ថសញ្ហិតេន ចុទិតំ ទោសន្តរេន ហោតិយមានំ
នោ មេត្តចិត្តេន ចុទិតំ ។ អធម្មចុទិតស្ស
អាវុសោ ភិក្ខុនោ បញ្ចហាការេហិ អវិប្បដិសារោ
ឧបទហិតព្វោ អកាលេនាយស្មា ចុទិតោ នោ
កាលេន អលន្តេ អវិប្បដិសារាយ អភូតេនាយស្មា
ចុទិតោ នោ ភូតេន អលន្តេ អវិប្បដិសារាយ
ផរុសេនាយស្មា ចុទិតោ នោ សណ្ហេន អលន្តេ
អវិប្បដិសារាយ អនត្ថសញ្ហិតេនាយស្មា ចុទិតោ នោ
អត្ថសញ្ហិតេន អលន្តេ អវិប្បដិសារាយ ទោសន្តរេ-
នាយស្មា ចុទិតោ នោ មេត្តចិត្តេន អលន្តេ អវិប្បដិ-
សារាយាតិ ។ អធម្មចុទិតស្ស អាវុសោ ភិក្ខុនោ ឥមេហិ
បញ្ចហាការេហិ អវិប្បដិសារោ ឧបទហិតព្វោ ។

ដែលគេដាស់តឿនដោយពាក្យទ្រគោះ មិនដាស់តឿនដោយពាក្យពីរោះ ហើយមានសេចក្តីខឹង ១ ដែលគេដាស់តឿនដោយពាក្យមិនប្រកបដោយប្រយោជន៍ មិនដាស់តឿនដោយពាក្យដែលប្រកបដោយប្រយោជន៍ ហើយមានសេចក្តីខឹង ១ ដែលគេដាស់តឿនដោយទោសចិត្ត មិនដាស់តឿនដោយចិត្តមេត្តា ហើយមានសេចក្តីខឹង ១ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុមានគេដាស់តឿន មិនប្រកបដោយធម៌ គួរតាំងទុកនូវសេចក្តីមិនក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាង ដោយគិតថា គេដាស់តឿនអ្នកក្នុងកាលមិនគួរ មិនដាស់តឿនក្នុងកាលគួរ គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ គេដាស់តឿនអ្នកដោយពាក្យមិនពិត មិនដាស់តឿនដោយពាក្យពិត គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ គេដាស់តឿនអ្នកដោយពាក្យទ្រគោះ មិនដាស់តឿនដោយពាក្យពីរោះ គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ គេដាស់តឿនអ្នកដោយពាក្យមិនប្រកបដោយប្រយោជន៍ មិនដាស់តឿនដោយពាក្យដែលប្រកបដោយប្រយោជន៍ គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ គេដាស់តឿនអ្នកដោយទោសចិត្ត មិនដាស់តឿនដោយចិត្តមេត្តា គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុមានគេដាស់តឿន មិនប្រកបដោយធម៌ គួរតាំងទុកនូវសេចក្តីមិនក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាងនេះ ។

អធម្មចោទកស្ស អាវុសោ ភិក្ខុនោ បញ្ចហាការេហិ វិប្បដិសារោ ឧបទហិតព្វោ អកាលេន តេ អាវុសោ ចុទិតោ នោ កាលេន អលន្តេ វិប្បដិសារាយ អភូតេន តេ អាវុសោ ចុទិតោ នោ ភូតេន អលន្តេ វិប្បដិសារាយ ផរុសេន តេ អាវុសោ ចុទិតោ នោ សណ្ហេន អលន្តេ វិប្បដិសារាយ អនត្ថសញ្ហិតេន តេ អាវុសោ ចុទិតោ នោ អត្ថសញ្ហិតេន អលន្តេ វិប្បដិសារាយ ទោសន្តរេន តេ អាវុសោ ចុទិតោ នោ មេត្តចិត្តេន អលន្តេ វិប្បដិសារាយាតិ ។ អធម្មចោទកស្ស អាវុសោ ភិក្ខុនោ ឥមេហិ បញ្ចហាការេហិ វិប្បដិសារោ ឧបទហិតព្វោ ។ តំ កិស្ស ហេតុ ។ យថា នាញ្ញោបិ ភិក្ខុ អភូតេន ចោទេតព្វំ មញ្ញេយ្យាតិ ។ ឥធ បនាហំ អាវុសោ ឯកច្ចំ បុគ្គលំ បស្សាមិ

ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿនគេ មិនប្រកបដោយធម៌ ត្រូវបានសេចក្តីក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាង ដោយគិតថា ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ក្នុងកាលមិនគួរ មិនដាស់តឿនគេ ក្នុងកាលគួរ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេដោយពាក្យមិនពិត មិនដាស់តឿនគេដោយពាក្យពិត ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេដោយពាក្យទ្រគោះ មិនដាស់តឿនគេដោយពាក្យពីរោះ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេដោយពាក្យមិនប្រកបដោយប្រយោជន៍ មិនដាស់តឿនគេដោយពាក្យដែលប្រកបដោយប្រយោជន៍ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ។ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេដោយទោសចិត្ត មិនដាស់តឿនគេដោយចិត្តមេត្តា ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿនគេ មិនប្រកបដោយធម៌ ត្រូវបានសេចក្តីក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាងនេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះហេតុថា ដូចយ៉ាងភិក្ខុដទៃ ក៏មិនត្រូវសំគាល់នូវភិក្ខុ ដែលខ្លួនត្រូវដាស់តឿនដោយពាក្យមិនពិតដែរ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំឃើញបុគ្គលខ្លះ ក្នុងលោកនេះ

កាលេន ចោទិយមានំ នោ អកាលេន កុបិតំ ភូតេន ចោទិយមានំ នោ អភូតេន កុបិតំ សណ្ហេន ចោទិយមានំ នោ ផរុសេន កុបិតំ អត្ថសញ្ហិតេន ចោទិយមានំ នោ អនត្ថសញ្ហិតេន កុបិតំ មេត្តចិត្តេន ចោទិយមានំ នោ ទោសន្តរេន កុបិតំ ។ ធម្មចុទិតស្ស អាវុសោ ភិក្ខុនោ បញ្ចហាការេហិ វិប្បដិសារោ ឧបទហាតព្វោ កាលេនាយស្មា ចុទិតោ នោ អកាលេន អលត្ថ វិប្បដិសារាយ ភូតេនាយស្មា ចុទិតោ នោ អភូតេន អលត្ថ វិប្បដិសារាយ សណ្ហេនាយស្មា ចុទិតោ នោ ផរុសេន អលត្ថ វិប្បដិសារាយ អត្ថសញ្ហិតេនាយស្មា ចុទិតោ នោ អនត្ថសញ្ហិតេន អលត្ថ វិប្បដិសារាយ មេត្តចិត្តេនាយស្មា ចុទិតោ នោ ទោសន្តរេន

ដែលគេដាស់តឿន ក្នុងកាលគួរ មិនដាស់តឿន ក្នុងកាលមិនគួរ ហើយមានសេចក្តីខឹង១ ដែលគេដាស់តឿន ដោយពាក្យពិត មិនដាស់តឿន ដោយពាក្យមិនពិត ហើយមានសេចក្តីខឹង១ ដែលគេដាស់តឿន ដោយពាក្យពីរោះ មិនដាស់តឿន ដោយពាក្យទ្រគោះ ហើយមានសេចក្តីខឹង១ ដែលគេដាស់តឿន ដោយពាក្យប្រកបដោយប្រយោជន៍ មិនដាស់តឿន ដោយពាក្យមិនប្រកបដោយប្រយោជន៍ ហើយមានសេចក្តីខឹង១ ដែលគេដាស់តឿន ដោយចិត្តមេត្តា មិនដាស់តឿន ដោយទោសចិត្ត ហើយមានសេចក្តីខឹង១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុដែលគេដាស់តឿនប្រកបដោយធម៌ ត្រូវបានសេចក្តីក្តៅក្រហាយ ដោយអាការៈ៥ យ៉ាង ដោយគិតថា គេដាស់តឿនអ្នក ក្នុងកាលគួរ គេមិនដាស់តឿនអ្នក ក្នុងកាលមិនគួរ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ គេដាស់តឿនអ្នក ដោយពាក្យពិត មិនដាស់តឿន ដោយពាក្យមិនពិត ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ១ គេដាស់តឿនអ្នក ដោយពាក្យពីរោះ មិនដាស់តឿនអ្នក ដោយពាក្យទ្រគោះ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ១ គេដាស់តឿនអ្នក ដោយពាក្យប្រកបដោយប្រយោជន៍ មិនដាស់តឿន ដោយពាក្យដែលមិនប្រកបដោយប្រយោជន៍ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ដែលគេដាស់តឿនអ្នក ដោយចិត្តមេត្តា មិនដាស់តឿន ដោយទោសចិត្ត

អលន្តេ វិប្បដិសារាយាតិ ។ ធម្មចុទិតស្ស អាវុសោ ភិក្ខុនោ ឥមេហិ បញ្ចហាការេហិ វិប្បដិសារោ ឧបទហិតព្វោ ។ ធម្មចោទកស្ស អាវុសោ ភិក្ខុនោ បញ្ចហាការេហិ អវិប្បដិសារោ ឧបទហិតព្វោ កាលេន តេ អាវុសោ ចុទិតោ នោ អកាលេន អលន្តេ អវិប្បដិសារាយ ភូតេន តេ អាវុសោ ចុទិតោ នោ អភូតេន អលន្តេ អវិប្បដិសារាយ សណ្ហេន តេ អាវុសោ ចុទិតោ នោ ផរុសេន អលន្តេ អវិប្បដិសារាយ អត្ថសញ្ហិតេន តេ អាវុសោ ចុទិតោ នោ អនត្ថសញ្ហិតេន អលន្តេ អវិប្បដិសារាយ មេត្តចិត្តេន តេ អាវុសោ ចុទិតោ នោ ទោសន្តរេន អលន្តេ អវិប្បដិសារាយាតិ ។ ធម្មចោទកស្ស អាវុសោ ភិក្ខុនោ ឥមេហិ បញ្ចហាការេហិ អវិប្បដិសារោ ឧបទហិតព្វោ ។ តំ កិស្ស ហេតុ ។

ត្រូវតែអ្នកឯងក៏បានសេចក្ដីក្ដៅក្រហាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុដែលគេដាស់តឿនប្រកបដោយធម៌ ត្រូវបានសេចក្ដីក្ដៅក្រហាយ ដោយអាការៈ ៥ យ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿនគេប្រកបដោយធម៌ ត្រូវបានសេចក្ដីមិនក្ដៅក្រហាយ ដោយអាការៈ ៥ យ៉ាង ដោយគិតថា ម្នាលអាវុសោ អ្នកឯងដាស់តឿនគេក្នុងកាលគួរ មិនដាស់តឿនគេ ក្នុងកាលមិនគួរ ត្រូវតែអ្នកឯងមិនបានសេចក្ដីក្ដៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ដោយពាក្យពិត មិនដាស់តឿនគេ ដោយពាក្យមិនពិត ត្រូវតែអ្នកឯងមិនបានសេចក្ដីក្ដៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ដោយពាក្យពីរោះ មិនដាស់តឿនគេ ដោយពាក្យទ្រគោះ ត្រូវតែអ្នកឯងមិនបានសេចក្ដីក្ដៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ដោយពាក្យប្រកបដោយប្រយោជន៍ មិនដាស់តឿនគេ ដោយពាក្យមិនប្រកបដោយប្រយោជន៍ ត្រូវតែអ្នកឯងមិនបានសេចក្ដីក្ដៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ដោយចិត្តមេត្តា មិនដាស់តឿនគេ ដោយទោសចិត្ត ត្រូវតែអ្នកឯងមិនបានសេចក្ដីក្ដៅក្រហាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿនគេ ប្រកបដោយធម៌ ត្រូវបានសេចក្ដីមិនក្ដៅក្រហាយ ដោយអាការៈ ៥ យ៉ាងនេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។

យថា អញ្ញោបិ ភិក្ខុ ភូតេន ចោទិតត្តំ មញ្ញោយ្រតិ ។ ចុទិតេន អាវុសោ ចុទិតកេន ទ្វីសុ ធម្មេសុ បតិដ្ឋាតព្វំ សច្ចេ ច អកុប្បេ ច ។ បញ្ចហិ អាវុសោ បរំ ចោទេយ្យុំ កាលេន វា អកាលេន វា ភូតេន វា អភូតេន វា សណ្ហេន វា ផរុសេន វា អត្ថសញ្ហិតេន វា អនត្ថសញ្ហិតេន វា មេត្តចិត្តា[១] វា ទោសន្តរា[២] វា ។ អហំបិ ទ្វីសុយេវ ធម្មេសុ បតិដ្ឋហេយ្យំ សច្ចេ ច អកុប្បេ ច ។ សចេ ជានេយ្យំ អត្ថេសោ មយិ ធម្មោតិ អត្ថីតិ នំ វទេយ្យំ សំវិជ្ជតេ ឯសោ មយិ ធម្មោតិ ។ សចេ ជានេយ្យំ នត្ថេសោ មយិ ធម្មោតិ នត្ថីតិ នំ វទេយ្យំ នេសោ ធម្មោ មយិ សំវិជ្ជតីតិ ។ ឯវំបិ ខោ តេ សារីបុត្ត វុច្ចមានា អថ ច បនិធេកច្ចេ មោឃបុរិសា ន បទក្ខិណំ គណ្ហន្តិ ។

---

១ ឱ. ម. មេត្តចិត្តេន វា ។ ២ ឱ. ម. ទោសន្តរេន វា ។

ព្រោះថា ដូចយ៉ាងភិក្ខុដទៃ ក៏ត្រូវសំគាល់ភិក្ខុដែលខ្លួនត្រូវដាស់តឿនដោយពាក្យពិតដែរ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលដែលគេដាស់តឿន ត្រូវប្រតិស្ឋានក្នុងធម៌ ២ យ៉ាង គឺសច្ចៈ ១ សេចក្តីមិនខឹង ១ ។ ម្នាលអាវុសោទាំងឡាយ ពួកភិក្ខុគប្បីដាស់តឿនពួកបុគ្គលដទៃ ដោយអាការៈ ៥ យ៉ាង គឺ (ដាស់តឿន) ក្នុងកាលគួរក៏មាន មិនគួរក៏មាន ១ ដោយពាក្យពិតក៏មាន មិនពិតក៏មាន ១ ដោយពាក្យពីរោះក៏មាន ពាក្យទ្រគោះក៏មាន ១ ដោយពាក្យប្រកបដោយប្រយោជន៍ក៏មាន មិនប្រកបដោយប្រយោជន៍ក៏មាន ១ ដោយចិត្តមេត្តាក៏មាន ដោយទោសចិត្តក៏មាន ១ ។ (ភិក្ខុអ្នកដាស់តឿនគេត្រូវតាំងចិត្ត) ថា ទោះបីអាត្មាអញ ក៏គួរប្រតិស្ឋានក្នុងធម៌ ២ យ៉ាង គឺសច្ចៈ ១ សេចក្តីមិនខឹង ១ ដែរ ។ បើអាត្មាអញដឹងថា ធម៌នុ៎ះមាននៅក្នុងអាត្មាអញ អាត្មាអញគួរនិយាយប្រាប់គេថាមាន (ព្រោះ) ធម៌នុ៎ះ មាននៅក្នុងអាត្មាអញមែន ។ បើអាត្មាអញដឹងថា ធម៌នុ៎ះមិនមានក្នុងអាត្មាអញទេ គួរអាត្មាអញនិយាយប្រាប់គេថាមិនមាន (ព្រោះ) ធម៌នុ៎ះ មិនមានក្នុងអាត្មាអញមែន ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត កាលដែលអ្នកពោលយ៉ាងនេះហើយ មានពួកមោឃបុរសខ្លះក្នុងសាសនានេះ មិនទទួលយកដោយផ្ចិតផ្ចង់ឡើយ ។

យេ តេ ភន្តេ បុគ្គលា អស្សទ្ធា ជីវិកត្ថា ន សទ្ធា អគារស្មា អនគារិយំ បព្វជិតា សឋា មាយាវិនោ កេដុភិនោ ឧទ្ធតា ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា ឥន្ទ្រិយេសុ អគុត្តទ្វារា ភោជនេ អមត្តញ្ញុនោ ជាគរិយំ អននុយុត្តា សាមញ្ញេ អនបេក្ខវន្តោ សិក្ខាយ ន តិព្វគារវា ពាហុលិកា សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា កុសីតា ហីនវីរិយា មុដ្ឋស្សតិនោ អសម្បជានា អសមាហិតា វិព្ភន្តចិត្តា ទុប្បញ្ញា ឯឡមូគា តេ មយា សំ វុច្ចមានា ន បទក្ខិណំ គណ្ហន្តិ ។ យេ បន តេ ភន្តេ កុលបុត្តា សទ្ធា អគារស្មា អនគារិយំ បព្វជិតា អសឋា អមាយាវិនោ អកេដុភិនោ អនុទ្ធតា អនុន្នឡា អចបលា អមុខរា អវិកិណ្ណវាចា ឥន្ទ្រិយេសុ គុត្តទ្វារា ភោជនេ មត្តញ្ញុនោ

ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកណា ដែលមិនមានសទ្ធា ត្រូវការតែទីពឹងចិញ្ចឹមជីវិត ចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួសដោយមិនមានសទ្ធា ជាអ្នកអួតអាង មានមាយា បោកប្រាស មានចិត្តរាយមាយ លើកកំពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសំដីផ្តេសផ្តាស មិនគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបនូវការភ្ញាក់រលឹក មិនបានក្រឡេកមើល ក្នុងភាពនៃខ្លួនជាសមណៈ មិនមានសេចក្តីគោរពដ៏ក្លៀវក្លាក្នុងសិក្ខា ជាអ្នកល្ហោក មានសេចក្តីព្យាយាម ក្នុងការប្រព្រឹត្តិធូរថយ ជាប្រធានខាងការប្រព្រឹត្តិព្រើកព្រាក ដាក់ចោលនូវធុរៈ ក្នុងវិវេក ខ្ជិលច្រអូស មានព្យាយាមថោកថយ មានស្មារតីភ្លេចភ្លាំង មិនមានសម្បជញ្ញៈ មិនបានតាំងចិត្តមាំ មានចិត្តរវើរវាយ ជាមនុស្សអប្បឥតប្រាជ្ញា ជាមនុស្សលលា បុគ្គលពួកនោះ កាលដែលខ្ញុំព្រះអង្គពោលយ៉ាងនេះ រមែងមិនទទួលយកដោយផ្ចិតផ្ចង់ឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ន័យមួយទៀត ពួកកុលបុត្តណាដែលចេញចាកផ្ទះហើយ ចូលមកកាន់ផ្នួសដោយសទ្ធា ជាអ្នកមិនអួតអាង មិនមានមាយា មិនបោកប្រាស មិនមានចិត្តរាយមាយ មិនលើកកំពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានសំដីផ្តេសផ្តាស គ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន

ជាគរិយំ អនុយុត្តា សាមញ្ញេ អបេក្ខវន្តោ សិក្ខាយ តិព្វគារវា ន ពាហុលិកា ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា អារទ្ធវីរិយា បហិតត្តា ឧបដ្ឋិតស្សតិនោ សម្បជានា សមាហិតា ឯកគ្គចិត្តា បញ្ញវន្តោ អនេឡមូគា តេ មយា ឯវំ វុច្ចមានា បទក្ខិណំ គណ្ហន្តិ ។ យេ តេ សារីបុត្ត បុគ្គលា អស្សទ្ធា ជីវិកត្ថា ន សទ្ធា អគារស្មា អនគារិយំ បព្វជិតា សឋា មាយាវិនោ កេដុភិនោ ឧទ្ធតា ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា ឥន្ទ្រិយេសុ អគុត្តទ្វារា ភោជនេ អមត្តញ្ញុនោ ជាគរិយំ អននុយុត្តា សាមញ្ញេ អនបេក្ខវន្តោ សិក្ខាយ ន តិព្វគារវា ពាហុលិកា សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា កុសីតា ហីនវីរិយា

ប្រកបក្នុងការភ្ញាក់រលឹក មានការក្រឡេកមើលក្នុងភាពនៃខ្លួនជាសមណៈ មានសេចក្ដីគោរពដ៏ក្រៀវក្លា ក្នុងសិក្ខា មិនលោភ មានព្យាយាម ក្នុងការប្រព្រឹត្តិមិនធូរថយ ដាក់ការប្រព្រឹត្តិជ្រោកជ្រាកចោល ជាអ្នកនាំអាទ៍ក្នុងសេចក្ដីស្ងប់ស្ងាត់ (ព្រះនិព្វាន) ជាអ្នកប្រារព្ធនូវព្យាយាម មានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ប្រុងស្មារតី មានសម្បជញ្ញៈ បានតាំងទុកនូវចិត្តដ៏មាំមួន មានចិត្តនឹងនៅ ក្នុងអារម្មណ៍តែមួយ មានបញ្ញាមិនលលា កុលបុត្តពួកនោះ កាលដែលខ្ញុំព្រះអង្គពោលយ៉ាងនេះហើយ រមែងទទួលយកដោយផ្ចិតផ្ចង់ ៗ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត ពួកបុគ្គលណា មិនមានសទ្ធា មានសេចក្ដីត្រូវការតែនឹងចិញ្ចឹមជីវិត ចេញចាកផ្ទះ ចូលមកកាន់ផ្នួសដោយមិនមានសទ្ធា ជាអ្នកអួតអាង មានមាយា បោកប្រាស មានចិត្តរាយមាយ លើកកំពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសំដីផ្ដេសផ្ដាស មិនបានគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ មិនស្គាល់ប្រមាណ ក្នុងភោជន មិនប្រកបនូវការភ្ញាក់រលឹក មិនបានក្រឡេកមើល ក្នុងភាពនៃខ្លួនជាសមណៈ មិនមានសេចក្ដីគោរពដ៏ក្រៀវក្លា ក្នុងសិក្ខា ជាអ្នកលោភ មានសេចក្ដីព្យាយាម ក្នុងការប្រព្រឹត្តិធូរថយ ជាប្រធានខាងការប្រព្រឹត្តិដ៏ជ្រោកជ្រាក ដាក់ចោលនូវធុរៈក្នុងវិវេក ខ្ជិលច្រអូស មានព្យាយាមថោកថយ

មុដ្ឋស្សតិនោ អសម្បជានា អសមាហិតា វិព្ភន្តចិត្តា
ទុប្បញ្ញា ឯឡមូគា តិដ្ឋន្តុ[១] យេ ច ខោ តេ សារីបុត្ត
កុលបុត្តា សទ្ធា អគារស្មា អនគារិយំ បព្វជិតា
អសឋា អមាយាវិនោ អកេដុភិនោ អនុទ្ធតា
អនុន្នឡា អចបលា អមុខរា អវិកិណ្ណវាចា ឥន្ទ្រិយេសុ
គុត្តទ្វារា ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តា
សាមញ្ញេ អបេក្ខវន្តោ សិក្ខាយ តិព្វគារវា ន
ពាហុលិកា ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា
បវិវេកេ បុព្វង្គមា អារទ្ធវីរិយា បហិតត្តា ឧបដ្ឋិ-
តស្សតិនោ សម្បជានា សមាហិតា ឯកគ្គចិត្តា
បញ្ញវន្តោ អនេឡមូគា តេ ត្វំ សារីបុត្ត វទេយ្យាសិ ។
ឱវទ សារីបុត្ត សព្រហ្មចារី អនុសាស សារីបុត្ត
សព្រហ្មចារី អសទ្ធម្មា វុដ្ឋាបេត្វា សទ្ធម្មេ បតិដ្ឋា-
បេស្សាមិ សព្រហ្មចារីតិ ។ ឯវំ ហិ តេ សារីបុត្ត
សិក្ខិតព្វន្តិ ។

---

១ ឱ. ម. ឯត្ថន្តរេ តេតិ បទំ ។

មានស្មារតីភ្លេចភ្លាំង មិនមានសម្បជញ្ញៈ មិនបានតាំងចិត្តមាំ មានចិត្តរវើរវាយ ជាមនុស្សអប្បឥតបញ្ញា ជាមនុស្សលលា ពួកបុគ្គលនោះលើកទុកដោយឡែកសិន ម្នាលសារីបុត្ត ពួកកុលបុត្តណា ដែលចេញចាកផ្ទះហើយ ចូលមកកាន់ផ្នួសដោយសទ្ធា មិនជាអ្នកអួតអាង មិនមានមាយា មិនបោកប្រាស មិនរពឹយមាយ មិនលើកកំពស់ មិនមានចិត្តឃ្លេងឃ្លោង មិនជាអ្នកមាត់រឹង មិនមានសំដីផ្ដេសផ្ដាស ជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ស្គាល់ប្រមាណក្នុងភោជន ប្រឹងប្រែកបនូវការភ្ញាក់រលឹក ក្រឡេកមើល ក្នុងភាពនៃខ្លួនជាសមណៈ មានសេចក្ដីគោរពដ៏ក្លៀវក្លា ក្នុងសិក្ខា មិនល្មោភ មិនប្រព្រឹត្តធូរថយ ដាក់ចោលនូវធុរៈក្នុងការប្រព្រឹត្តិជ្រោកជ្រាក ជាអ្នកនាំអាទិ៍ក្នុងវិវេក ប្រារព្ធនូវព្យាយាម មានចិត្តស្ងប់ទៅកាន់ព្រះនិព្វាន ប្រុងស្មារតី មានសម្បជញ្ញៈ តាំងចិត្តមាំ មានចិត្តនឹងក្នុងអារម្មណ៍តែមួយ មានបញ្ញា មិនលលា ម្នាលសារីបុត្ត អ្នកត្រូវនិយាយទៅរកតែពួកកុលបុត្តនោះបានហើយ ។ ម្នាលសារីបុត្ត អ្នកចូរទូន្មានពួកសព្រហ្មចារី ម្នាលសារីបុត្ត អ្នកចូរប្រៀនប្រដៅពួកសព្រហ្មចារី ដោយតាំងចិត្តថា អាត្មាអញនឹងធ្វើពួកសព្រហ្មចារីឲ្យចេញផុតចាកអសទ្ធម្ម ហើយឲ្យប្រតិស្ឋាន ក្នុងព្រះសទ្ធម្ម ។ ម្នាលសារីបុត្ត អ្នកត្រូវសិក្សាយ៉ាងនេះឯង ៕

(៦៨) តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ។បេ។ ទុស្សីលស្ស អាវុសោ សីលវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតូបនិសំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ យថាភូតញាណទស្សនវិបន្នស្ស ហតូបនិសោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ អសតិ និព្វិទាវិរាគវិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញាណទស្សនំ ។ សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលាសវិបន្នោ តស្ស បបដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ន បារិបូរឹ គច្ឆតិ ឯវមេវ ខោ អាវុសោ ទុស្សីលស្ស សីលវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតូបនិសំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ យថាភូតញាណទស្សនវិបន្នស្ស ហតូបនិសោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ អសតិ

(១៦៨) ព្រះសារីបុត្តដ៏មានអាយុ មានថេរដីកាហៅពួកភិក្ខុមកក្នុងទីនោះ ។ បេ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុទ្រុស្តសីល វិបត្តិចាកសីល ជាហេតុសាបសូន្យចាកសម្មាសមាធិ កាលបើសម្មាសមាធិមិនមានហើយ ភិក្ខុ វិបត្តិចាកសម្មាសមាធិ ជាហេតុសាបសូន្យចាកយថាភូតញាណ-ទស្សនៈ កាលបើយថាភូតញាណទស្សនៈមិនមានហើយ ភិក្ខុវិបត្តិចាកយថាភូតញាណទស្សនៈ ជាហេតុសាបសូន្យចាកនិព្វិទាវិរាគៈ កាលបើនិព្វិទាវិរាគៈ មិនមានហើយ ភិក្ខុវិបត្តិចាកនិព្វិទាវិរាគៈ ជាហេតុសាបសូន្យចាកវិមុត្តិញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ដូចជាដើមឈើដែលវិបត្តិចាកមែកនិងស្លឹកហើយ ក្រមរនៃដើមឈើនោះក្តី ក៏មិនបរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនបរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុទ្រុស្តសីល វិបត្តិចាកសីល ជាហេតុសាបសូន្យចាកសម្មាសមាធិ កាលបើសម្មាសមាធិ មិនមានហើយ ភិក្ខុវិបត្តិចាកសម្មា-សមាធិ ជាហេតុសាបសូន្យចាកយថាភូតញាណទស្សនៈ កាលបើយថា-ភូតញាណទស្សនៈមិនមានហើយ ភិក្ខុវិបត្តិចាកយថាភូតញាណទស្សនៈ ជាហេតុសាបសូន្យចាកនិព្វិទាវិរាគៈ កាលបើនិព្វិទាវិរាគៈ មិនមានហើយ

និព្វិទាវិរាគវិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញ្ញាណទស្សនំ ។ សីលវតោ អាវុសោ សីលសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ យថាភូតញ្ញាណទស្សនំ យថាភូតញ្ញាណទស្សនេ សតិ យថាភូតញ្ញាណទស្សនសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ សតិ និព្វិទាវិរាគសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ វិមុត្តិញ្ញាណទស្សនំ ។ សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលាសសម្បន្នោ តស្ស បបដិកាបិ បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ បារិបូរឹ គច្ឆតិ ឯវមេវ ខោ អាវុសោ សីលវតោ សីលសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ យថាភូតញ្ញាណទស្សនំ យថាភូតញ្ញាណទស្សនេ សតិ យថាភូតញ្ញាណទស្សនសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ សតិ

ភិក្ខុវិបត្តិចាកនិព្វិទាវិរាគៈ ជាហេតុសាបសូន្យចាកវិមុត្តិញាណទស្សន ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសីល បរិបូណ៌ដោយសីល ឈ្មោះថា បរិបូណ៌ដោយហេតុនៃសម្មាសមាធិ កាលបើមានសម្មាសមាធិហើយ ភិក្ខុបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា បរិបូណ៌ដោយហេតុនៃយថាភូតញាណទស្សនៈ កាលបើយថាភូតញាណទស្សនៈមានហើយ ភិក្ខុបរិបូណ៌ដោយយថាភូតញាណទស្សនៈ ឈ្មោះថា បរិបូណ៌ដោយហេតុនៃនិព្វិទាវិរាគៈ កាលបើនិព្វិទាវិរាគៈមានហើយ ភិក្ខុបរិបូណ៌ដោយនិព្វិទាវិរាគៈ ឈ្មោះថា បរិបូណ៌ដោយហេតុវិមុត្តិញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ដូចដើមឈើ ដែលបរិបូណ៌ដោយមែកនិងស្លឹកហើយ ក្រមរនៃដើមឈើនោះក្តី ក៏បរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏បរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកមានសីល បរិបូណ៌ដោយសីល ឈ្មោះថា បរិបូណ៌ដោយហេតុនៃសម្មាសមាធិ កាលបើសម្មាសមាធិមានហើយ ភិក្ខុបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា បរិបូណ៌ដោយហេតុនៃយថាភូតញាណទស្សនៈ កាលបើយថាភូតញាណទស្សនៈមានហើយ ភិក្ខុបរិបូណ៌ដោយយថាភូតញាណទស្សនៈ ឈ្មោះថា បរិបូណ៌ដោយហេតុនៃនិព្វិទាវិរាគៈ កាលបើនិព្វិទាវិរាគៈមានហើយ

និព្វិទាវិរាគសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ វិមុត្តិ-
ញាណទស្សនន្តិ ។

[៦៩] អថខោ អាយស្មា អានន្ទោ យេនាយស្មា
សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា
សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារា-
ណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នោ ខោ អាយស្មា អានន្ទោ អាយស្មន្តំ សារីបុត្តំ
ឯតទវោច កិត្តាវតា នុ ខោ អាវុសោ សារីបុត្ត ភិក្ខុ
ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុគ្គហិ-
តគ្គាហី ច ពហុញ្ច គណ្ហាតិ គហិតញ្ចស្ស នប្ប-
មុស្សតីតិ ។ អាយស្មា ខោ អានន្ទោ ពហុស្សុតោ
បដិភាតុ អាយស្មន្តញ្ញេវ អានន្ទន្តិ ។ តេនហាវុសោ
សារីបុត្ត សុណាហិ សាធុកំ មនសិការោហិ ភា-
សិស្សាមីតិ ។ ឯវមាវុសោតិ ខោ អាយស្មា សារីបុត្តោ
អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។ អាយស្មា
អានន្ទោ ឯតទវោច ឥធាវុសោ សារីបុត្ត ភិក្ខុ

ភិក្ខុបរិបូណ៌ដោយនិព្វិទាវិរាគៈ ឈ្មោះថា បរិបូណ៌ដោយហេតុនៃវិមុត្តិញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

[៦៩] គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ បានចូលទៅរក ព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យ ដែលគួររីករាយនឹងពាក្យដែលគួររលឹកហើយ ក៏គង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ ក្នុងទីដ៏សមគួរហើយ ក៏មានថេរវាចានឹងព្រះសារីបុត្តដ៏មានអាយុ យ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុជាអ្នកពិចារណាឃើញឆាប់ ក្នុងពួកធម៌ជាកុសលផង ជាអ្នកកាន់យកនូវធម៌ ដែលខ្លួនកាន់យកដោយល្អផង កាន់យកនូវធម៌បានច្រើនផង មិនភ្លេចធម៌ ដែលខ្លួនកាន់យកហើយផង តើដោយហេតុប៉ុន្មានយ៉ាង ។ ព្រះសារីបុត្តមានថេរវាចាថា អានន្ទដ៏មានអាយុ ជាពហុស្សូតស្តាប់ហើយ ចូរអានន្ទដ៏មានអាយុ សំដែង (ខ្លួនឯង) ចុះ ។ ព្រះអានន្ទមានថេរវាចាថា ម្នាលអាវុសោ សារីបុត្ត បើដូច្នោះ លោកចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ ខ្ញុំនឹងសំដែង ។ ព្រះសារីបុត្តដ៏មានអាយុ ក៏បានទទួលស្តាប់ថេរវាចាព្រះអានន្ទដ៏មានអាយុថា ករុណា អាវុសោ ។ ព្រះអានន្ទដ៏មានអាយុ មានថេរវាចាយ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុក្នុងសាសនានេះ

អត្ថកុសលោ ច ហោតិ ធម្មកុសលោ ច ព្យញ្ជន-
កុសលោ ច និរុត្តិកុសលោ ច បុព្វាបរកុសលោ
ច ។ ឯត្តាវតា ខោ អាវុសោ សារីបុត្ត ភិក្ខុ
ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុគ្គ-
ហិតគ្គាហី ច ពហុញ្ច គណ្ហាតិ គហិតញ្ចស្ស នប្ប-
មុស្សតីតិ ។ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យាវ
សុភាសិតញ្ចិទំ អាយស្មតា អានន្ទេន ឥមេហិ ច
មយំ បញ្ចហិ ធម្មេហិ សមន្នាគតំ អាយស្មន្តំ
អានន្ទំ ធារេម អាយស្មា អានន្ទោ អត្ថកុសលោ
ធម្មកុសលោ ព្យញ្ជនកុសលោ និរុត្តិកុសលោ
បុព្វាបរកុសលោតិ ។

ជាអ្នកឈ្លាសក្នុងអត្ថផង ឈ្លាសក្នុងធម៌ផង ឈ្លាសក្នុងប្រភេទអក្សរផង ឈ្លាសក្នុងភាសាផង ឈ្លាសទាំងដើម ទាំងចុង(១) (នៃអត្ថនិងធម៌ជាដើម) ផង ។ ម្នាលអាវុសោសារីបុត្ត ភិក្ខុជាអ្នកពិចារណាឃើញឆាប់ ក្នុងពួកកុសលធម៌ផង ជាអ្នកកាន់យកនូវធម៌ ដែលខ្លួនកាន់យកដោយល្អផង កាន់យកនូវធម៌បានច្រើនផង មិនភ្លេចធម៌ ដែលខ្លួនកាន់យកហើយផង ដោយហេតុប៉ុណ្ណោះឯង ។ ព្រះសារីបុត្តមានថេរដីកាថា ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចំឡែកណាស់ ពាក្យដែលអានន្ទដ៏មានអាយុពោលមកហើយនេះ ជាសុភាសិតប្រាកដ មួយទៀត យើងនឹងចាំទុកនូវព្រះអានន្ទដ៏មានអាយុថា ជាអ្នកប្រកបដោយធម៌ ៥ យ៉ាងនេះ គឺអានន្ទដ៏មានអាយុ ជាអ្នកឈ្លាសក្នុងអត្ថ ១ ឈ្លាសក្នុងធម៌ ១ ឈ្លាសក្នុងអក្ខរប្បភេទ ១ ឈ្លាសក្នុងភាសា ១ ឈ្លាសទាំងដើមទាំងចុង ១ ។

---

១ ឈ្លាសត្រង់ខាងដើមនិងខាងចុងនោះ មាន ៥ យ៉ាង គឺឈ្លាសទាំងអដ្ឋកថាខាងដើមនិងអដ្ឋកថាខាងចុង ១ ឈ្លាសទាំងបាលីខាងដើមនិងបាលីខាងចុង ១ ឈ្លាសទាំងបទខាងដើមនិងបទខាងចុង ១ ឈ្លាសទាំងអក្សរខាងដើមនិងអក្សរខាងចុង ១ ឈ្លាសទាំងអនុសន្ធិខាងដើមនិងអនុសន្ធិខាងចុង ១ ។ អដ្ឋកថា ។

(៧០) ឯកំ សមយំ អាយស្មា អានន្ទោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ អាយស្មា ភទ្ទជិ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ភទ្ទជឹ អាយស្មា អានន្ទោ ឯតទវោច កឹ នុ ខោ អាវុសោ ភទ្ទជិ ទស្សនានំ អគ្គំ កឹ សវនានំ អគ្គំ កឹ សុខានំ អគ្គំ កឹ សញ្ញានំ អគ្គំ កឹ ភវានំ អគ្គន្តិ ។ អត្ថាវុសោ ព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី ។ យោ តំ ព្រហ្មានំ បស្សតិ ឥទំ ទស្សនានំ អគ្គំ ។ អត្ថាវុសោ អាភស្សរា នាម ទេវា

(៧០) សម័យ ១ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះឯង ព្រះភទ្ទជិដ៏មានអាយុ បានចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានរីករាយជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យ គួររីករាយនឹងពាក្យគួររលឹកហើយ ក៏គង់ក្នុងទីសមគួរ ។ លុះព្រះភទ្ទជិដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ព្រះអានន្ទដ៏មានអាយុ ក៏មានថេរវាចាយ៉ាងនេះថា ម្នាលអាវុសោភទ្ទជិ ការឃើញដូចម្តេច ដែលប្រសើរលើសជាងការឃើញទាំងឡាយ ការស្តាប់ដូចម្តេច ដែលប្រសើរលើសជាងការស្តាប់ទាំងឡាយ សុខដូចម្តេច ដែលប្រសើរលើសជាងសុខទាំងឡាយ ការសំគាល់ដូចម្តេច ដែលប្រសើរលើសជាងការសំគាល់ទាំងឡាយ ទីកើតដូចម្តេច ដែលប្រសើរលើសជាងទីកើតទាំងឡាយ ។ ព្រះភទ្ទជិដ៏មានអាយុមានថេរវាចាតបថា ម្នាលអាវុសោ មានព្រហ្មដែលជាអ្នកគ្របសង្កត់ (លើព្រហ្មឯទៀត) ដែលព្រហ្មឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួងឲ្យលុះក្នុងអំណាចខ្លួន ។ បុគ្គលណាឃើញនូវព្រហ្មនោះ ការឃើញនេះ ឈ្មោះថា ប្រសើរលើសជាងការឃើញទាំងឡាយ ។ ម្នាលអាវុសោ មានពួកទេវតា ឈ្មោះអាភស្សរៈ

សុខេន អភិសន្នា បរិសន្នា តេ កទាចិ ករហចិ ឧទានំ ឧទានេន្តិ អហោ សុខំ អហោ សុខន្តិ ។ យោ តំ សទ្ទំ សុណាតិ ឥទំ សវនានំ អគ្គំ ។ អត្ថាវុសោ សុភកិណ្ហា នាម ទេវា តេ សន្តញ្ញេវ តុសិតា សុខំ បដិសំវេទេន្តិ ឥទំ សុខានំ អគ្គំ ។ អត្ថាវុសោ អាកិញ្ចញ្ញាយតនូបគា ទេវា ឥទំ សញ្ញានំ អគ្គំ ។ អត្ថាវុសោ នេវសញ្ញានាសញ្ញាយតនូបគា ទេវា ឥទំ ភវានំ អគ្គន្តិ ។ សមេតិ ខោ ឥទំ អាយស្មតោ ភទ្ទជិស្ស យទិទំ ពហុនា ជនេនាតិ ។ អាយស្មា ខោ អានន្ទោ ពហុស្សុតោ បដិភាតុ អាយស្មន្តញ្ញេវ អានន្ទន្តិ ។ តេនហាវុសោ ភទ្ទជិ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ អាយស្មា ភទ្ទជិ អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។ អាយស្មា អានន្ទោ ឯតទវោច យថា បស្សតោ ខោ អាវុសោ អនន្តរា អាសវានំ ខយោ ហោតិ

ជ្រួតជ្រាប ស្កប់ស្កល់ ដោយសេចក្ដីសុខ ពួកទេវតាទាំងនោះ តែងបន្លឺឡើងនូវឧទាន ក្នុងកាលម្ដង ៗ ថា ឱហ្ន៎ ចំជាសុខ ចំជាសុខមែន ៗ បុគ្គលណា ឮសំឡេងនោះ ការឮនេះឈ្មោះថា ប្រសើរលើសជាងការឮទាំងឡាយ ៗ ម្នាលអាវុសោ មានពួកទេវតាឈ្មោះសុភកិណ្ហៈ ពួកទេវតាទាំងនោះ ត្រេកអរតែនឹងសេចក្ដីស្ងប់ សោយសេចក្ដីសុខ សុខនេះឈ្មោះថា ប្រសើរលើសជាងសុខទាំងឡាយ ៗ ម្នាលអាវុសោ មានពួកទេវតា ដែលទៅកើតក្នុងអាកិញ្ចញ្ញាយតនភព សេចក្ដីសំគាល់ (របស់ពួកទេវតា) នេះឈ្មោះថា ប្រសើរលើសជាងសេចក្ដីសំគាល់ទាំង-ឡាយ ៗ ម្នាលអាវុសោ មានពួកទេវតា ដែលទៅកើតក្នុងនេវសញ្ញា-នាសញ្ញាយតនភពនេះ ឈ្មោះថា ប្រសើរលើសជាងភពទាំងឡាយ ៗ សំដីព្រះភទ្ទជិដ៏មានអាយុនេះ សមគ្នានឹងសំដីរបស់ជនច្រើន ៗ អានន្ទដ៏មានអាយុ ជាពហុស្សុតស្រាប់ហើយ ឬអានន្ទដ៏មានអាយុ សំដែង (ខ្លួនឯង)ចុះ ៗ ម្នាលភទ្ទជិ បើដូច្នោះ អ្នកចូរប្រុងស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសំដែង ៗ ព្រះភទ្ទជិដ៏មានអាយុ បានទទួលស្ដាប់ថេរវាចាព្រះអានន្ទដ៏មានអាយុថា ករុណា អាវុសោ ៗ ព្រះអានន្ទដ៏មានអាយុ បានសំដែងយ៉ាងនេះថា ម្នាលអាវុសោ បុគ្គលឃើញយ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់

ឥទំ ទស្សនានំ អគ្គំ ។ យថា សុណតោ អនន្តរា អាសវានំ ខយោ ហោតិ ឥទំ សវនានំ អគ្គំ ។ យថា សុខិតស្ស អនន្តរា អាសវានំ ខយោ ហោតិ ឥទំ សុខានំ អគ្គំ ។ យថាសញ្ញិស្ស អនន្តរា អាសវានំ ខយោ ហោតិ ឥទំ សញ្ញានំ អគ្គំ ។ យថាភូតស្ស អនន្តរា អាសវានំ ខយោ ហោតិ ឥទំ ភវានំ អគ្គន្តិ ។

អាយាចវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

ទ្វេ អាយាចវិនយា
សាកច្ឆា សាជីវតោ បញ្ហា
បុច្ឆា និរោធោ ចោទនា
សីលំ និសន្តិ ភទ្ទជីតិ ។

ការឃើញនេះ ឈ្មោះថា ប្រសើរជាងការឃើញទាំងឡាយ ។ បុគ្គលស្តាប់យ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់ ការស្តាប់នេះឈ្មោះថា ប្រសើរលើសជាងការស្តាប់ទាំងឡាយ ។ បុគ្គលបានសុខយ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់ សុខនេះឈ្មោះថា ប្រសើរលើសជាងសុខទាំងឡាយ ។ បុគ្គលមានសេចក្តីសំគាល់យ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់ សេចក្តីសំគាល់នេះ ឈ្មោះថា ប្រសើរលើសជាងសេចក្តីសំគាល់ទាំងឡាយ ។ បុគ្គលកើតយ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់ ទីកើតនេះឈ្មោះថា ប្រសើរលើសជាងទីកើតទាំងឡាយ ។

ចប់ អាឃាតវគ្គ ទី ២ ។

## ឧទ្ទាននៃអាឃាតវគ្គនោះគឺ:

និយាយអំពីធម៌សម្រាប់កំចាត់បង់នូវគំនុំ ២ លើក ភិក្ខុគួរសាកច្ឆា ១ ភិក្ខុគួរដល់សាជីវៈ ១ ការបុច្ឆា ១ ការចូលសញ្ញាវេទយិតនិរោធ ១ ការដាស់តឿន ១ ភិក្ខុវិបត្តិចាកសីល ១ ការពិចារណាធម៌ ១ រឿងព្រះភទ្ទជិ ១ ។

# ឧបាសកវគ្គោ

(៧១) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឧបាសកោ សារជ្ជំ ឱក្កន្តោ ហោតិ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ឧបាសកោ សារជ្ជំ ឱក្កន្តោ ហោតិ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឧបាសកោ វិសារទោ ហោតិ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ

# ឧបាសកវគ្គ

[ ៧១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគ ត្រាស់ហៅពួកភិក្ខុក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ឧបាសក ប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមានចិត្តចុះកាន់សេចក្តីញញើតញញើម ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកសម្លាប់សត្វ ១ ជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ ជាអ្នកនិយាយពាក្យកុហក ១ ជាអ្នកផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកមានចិត្តចុះកាន់សេចក្តីញញើតញញើម ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកក្លៀវក្លា ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១

សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ឧបាសកោ វិសារទោ ហោតីតិ ។

(៧២) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឧបាសកោ អវិសារទោ អគារំ អជ្ឈាវសតិ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតី ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ឧបាសកោ អវិសារទោ អគារំ អជ្ឈាវសតិ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឧបាសកោ វិសារទោ អគារំ អជ្ឈាវសតិ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ឧបាសកោ វិសារទោ អគារំ អជ្ឈាវសតីតិ ។

វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកក្លៀវក្លា ។

(៧៦) ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមិនក្លៀវក្លា នៅគ្រប់គ្រងផ្ទះ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកសម្លាប់សត្វ ១ ។ បេ ។ ជាអ្នកផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកមិនក្លៀវក្លា នៅគ្រប់គ្រងផ្ទះ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកក្លៀវក្លា នៅគ្រប់គ្រងផ្ទះ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺ ឧបាសកជាអ្នកវៀរចាកបាណាតិបាត ១ ។ បេ ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកក្លៀវក្លា នៅគ្រប់គ្រងផ្ទះ ។

(៧៣) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឧបាសកោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតី ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ឧបាសកោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឧបាសកោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ឧបាសកោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(៧៤) អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតិំ ភគវា ឯតទវោច

(៧៣) ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ចោល ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកសម្លាប់សត្វ ១ ។ បេ ។ ជាអ្នកផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ចោល ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកវៀរចាកបាណាតិបាត ១ ។ បេ ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។

(៧៤) គ្រានោះឯង អនាថបិណ្ឌិកគហបតី បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ បានត្រាស់យ៉ាងនេះថា

បញ្ច គហបតិ ភយានិ វេរានិ អប្បហាយ ទុស្សីលោ ឥតិ វុច្ចតិ និរយញ្ច ឧបបជ្ជតិ ។ កតមានិ បញ្ច ។ បាណាតិបាតំ អទិន្នាទានំ កាមេសុ មិច្ឆាចារំ មុសាវាទំ· សុរាមេរយមជ្ជប្បមាទដ្ឋានំ ។ ឥមានិ ខោ គហបតិ បញ្ច ភយានិ វេរានិ អប្បហាយ ទុស្សីលោ ឥតិ វុច្ចតិ និរយញ្ច ឧបបជ្ជតិ ។ បញ្ច គហបតិ ភយានិ វេរានិ បហាយ សីលវា ឥតិ វុច្ចតិ សុគតិញ្ច ឧបបជ្ជតិ ។ កតមានិ បញ្ច ។ បាណាតិបាតំ អទិន្នាទានំ កាមេសុ មិច្ឆាចារំ មុសាវាទំ សុរាមេរយមជ្ជប្បមាទដ្ឋានំ ។ ឥមានិ ខោ គហបតិ បញ្ច ភយានិ វេរានិ បហាយ សីលវា ឥតិ វុច្ចតិ សុគតិញ្ច ឧបបជ្ជតិ ។ យំ គហបតិ បាណាតិបាតី បាណាតិបាតបច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បាណាតិបាតា បដិវិរតោ

ម្នាលគហបតី បុគ្គលមិនបានលះបង់នូវភ័យ នូវពៀរ ៥ យ៉ាង ហៅថា ជាអ្នកទ្រុស្តសីលផង តែងទៅកើតក្នុងនរកផង ។ ពៀរ ៥ យ៉ាង តើដូចម្តេច ។ គឺ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលគហបតី បុគ្គលមិនបានលះនូវភ័យ នូវពៀរ ៥ យ៉ាងនេះឯង ហៅថា ជាអ្នកទ្រុស្តសីលផង តែងទៅកើតក្នុងនរកផង ។ ម្នាលគហបតី បុគ្គលបានលះនូវភ័យ នូវពៀរ ៥ យ៉ាង ហៅថា ជាអ្នកមានសីលផង តែងទៅកើតក្នុងសុគតិផង ។ ពៀរ ៥ យ៉ាង តើដូចម្តេច ។ គឺ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលគហបតី បុគ្គលលះនូវភ័យ នូវពៀរ ៥ យ៉ាងនេះឯង ហៅថា ជាអ្នកមានសីលផង តែងទៅកើតក្នុងសុគតិផង ។ ម្នាលគហបតី បុគ្គលអ្នកសម្លាប់សត្វ តែងបាននូវភ័យ នូវពៀរជាបច្ចុប្បន្នផង បាននូវភ័យ នូវពៀរទៅខាងមុខផង ទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះបច្ច័យ គឺ បាណាតិបាតណា បុគ្គលវៀរចាកបាណាតិបាតនោះហើយ

នេវ ទិដ្ឋធម្មិកំ ភយំ វេរំ បសវតិ ន សម្បរាយិកំ ភយំ វេរំ បសវតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បាណាតិបាតា បដិវិរតស្ស ឯវន្តំ ភយំ វេរំ វូបសន្តំ ហោតិ ។ យំ គហបតិ អទិន្នាទាយី... យំ គហបតិ កាមេសុ មិច្ឆាចារី... យំ គហបតិ មុសាវាទី... យំ គហបតិ សុរាមេរយមជ្ជប្បមាទដ្ឋាយី សុរាមេរយមជ្ជប្បមាទដ្ឋានប្បច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ នេវ ទិដ្ឋធម្មិកំ ភយំ វេរំ បសវតិ ន សម្បរាយិកំ ភយំ វេរំ បសវតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតស្ស ឯវន្តំ ភយំ វេរំ វូបសន្តំ ហោតីតិ ។

រមែងមិនបាននូវភ័យ នូវពៀរជាបច្ចុប្បន្នផង មិនបាននូវភ័យ នូវពៀរទៅខាងមុខផង មិនទទួលទុក្ខទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តផង ។ បុគ្គលវៀរចាកបាណាតិបាតហើយ ភ័យ ពៀរនោះ រមែងស្ងប់រម្ងាប់ ដោយប្រការយ៉ាងនេះ ។ ម្នាលគហបតី បុគ្គលអ្នកកាន់យករបស់ដែលគេមិនបានឲ្យ ... ម្នាលគហបតី បុគ្គលអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ .. ម្នាលគហបតី បុគ្គលអ្នកនិយាយកុហក ... ម្នាលគហបតី បុគ្គលអ្នកផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្តីធ្វេសប្រហែស រមែងបាននូវភ័យ នូវពៀរជាបច្ចុប្បន្នផង បាននូវភ័យ នូវពៀរទៅខាងមុខផង ទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះបច្ច័យគឺសុរាមេរយមជ្ជប្បមាទដ្ឋានណា បុគ្គលវៀរចាកសុរាមេរយ-មជ្ជប្បមាទដ្ឋាននោះ រមែងមិនបាននូវភ័យ នូវពៀរជាបច្ចុប្បន្នផង មិនបាននូវភ័យ នូវពៀរទៅខាងមុខផង មិនទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តផង ។ បុគ្គលវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានហើយ ភ័យ ពៀរនោះ រមែងស្ងប់រម្ងាប់ ដោយប្រការយ៉ាងនេះ ។

យោ បាណមតិបាតេតិ មុសាវាទញ្ច ភាសតិ
លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ
សុរាមេរយបានញ្ច យោ នរោ អនុយុញ្ជតិ
អប្បហាយ បញ្ច វេរានិ ទុស្សីលោ ឥតិ វុច្ចតិ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោបបជ្ជតិ ។
យោ បាណំ នាតិបាតេតិ មុសាវាទំ ន ភាសតិ
លោកេ អទិន្នំ នាទិយតិ បរទារំ ន គច្ឆតិ
សុរាមេរយបានញ្ច យោ នរោ នានុយុញ្ជតិ
បហាយ បញ្ច វេរានិ សីលវា ឥតិ វុច្ចតិ
កាយស្ស ភេទា សប្បញ្ញោ សុគតឹ សោបបជ្ជតិ ។

(៧៥) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឧបាសកោ ឧបាសកចណ្ឌាលោ ច ហោតិ ឧបាសកមលញ្ច ឧបាសកប្បដិកិដ្ឋោ ច ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ហោតិ ទុស្សីលោ ហោតិ

នរៈណាសម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកទ្រព្យដែលគេមិនបានឲ្យក្នុងលោកផង ក្បត់នឹងប្រពន្ធជនដទៃផង ប្រកបនូវការផឹកសុរានឹងមេរ័យផង នរៈ អ្នកមិនបានលះនូវពៀរ ៥ យ៉ាងនោះ ហៅថាជាអ្នកទ្រុស្តសីល ជាអ្នកអប្បឥតបញ្ញា លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។ នរៈណាមិនសម្លាប់សត្វ មិននិយាយកុហក មិនកាន់យកទ្រព្យដែលគេមិនបានឲ្យក្នុងលោក មិនក្បត់នឹងប្រពន្ធជនដទៃនឹងមិនប្រកបនូវការផឹកសុរានឹងមេរ័យ នរៈអ្នកបានលះនូវពៀរ ៥ យ៉ាងនោះ ហៅថាជាអ្នកមានសីល ជាអ្នកប្រកបដោយបញ្ញា លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងសុគតិ ។

[៧៥] ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា ចណ្ឌាលឧបាសកផង ឈ្មោះថា មលឧបាសកផង ឈ្មោះថា បដិកិដ្ឋឧបាសកផង ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺ ឧបាសក ជាអ្នកមិនមានសទ្ធា ១ ជាអ្នកទ្រុស្តសីល ១

កោតុហលមង្គលិកោ ហោតិ មង្គលំ បច្ចេតិ នោ កម្មំ ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ឧបាសកោ ឧបាសកចណ្ឌាលោ ច ហោតិ ឧបាសកមលញ្ច ឧបាសកប្បដិកិដ្ឋោ ច ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឧបាសកោ ឧបាសករតនញ្ច ហោតិ ឧបាសកបទុមញ្ច ឧបាសកបុណ្ឌរីកញ្ច ។ កតមេហិ បញ្ចហិ ។ សទ្ធោ ហោតិ សីលវា ហោតិ អកោតុហលមង្គលិកោ ហោតិ កម្មំ បច្ចេតិ នោ មង្គលំ ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ឧបាសកោ ឧបាសករតនញ្ច ហោតិ ឧបាសកបទុមញ្ច ឧបាសកបុណ្ឌរីកញ្ចាតិ ។

ប្រកាន់មង្គលភ្ញាក់ផ្អើល ១ ជឿតែមង្គល មិនជឿកម្ម ១ ស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ហើយធ្វើបុណ្យនឹងទក្ខិណេយ្យបុគ្គលនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា ចណ្ឌាលឧបាសកផង ឈ្មោះថា មលឧបាសកផង ឈ្មោះថា បដិកិដ្ឋឧបាសកផង ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា រតនឧបាសកផង ឈ្មោះថា បទុមឧបាសកផង ឈ្មោះថា បុណ្ឌរីកឧបាសកផង ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកមានសទ្ធា ១ ជាអ្នកមានសីល ១ ជាអ្នកមិនប្រកាន់មង្គលភ្ញាក់ផ្អើល ១ ជឿតែកម្ម មិនជឿមង្គល ១ មិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យតែក្នុងពុទ្ធសាសនានេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា រតនឧបាសកផង ឈ្មោះថា បទុមឧបាសកផង ឈ្មោះថា បុណ្ឌរីកឧបាសកផង ។

[៧៦] អថខោ អនាថបិណ្ឌិកោ គហបតិ បញ្ចមត្តេហិ ឧបាសកសតេហិ បរិវុតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច តុម្ហេ ខោ គហបតិ ភិក្ខុសង្ឃំ បច្ចុបដ្ឋិតា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ។ ន ខោ គហបតិ តាវតកេនេវ តុដ្ឋិ ករណីយា មយំ ភិក្ខុសង្ឃំ បច្ចុបដ្ឋិតា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេនាតិ ។ តស្មាតិហ គហបតិ ឯវំ សិក្ខិតព្វំ កិន្តិ មយំ កាលេន កាលំ បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរេយ្យាមាតិ ។ ឯវំ ហិ វោ គហបតិ សិក្ខិតព្វន្តិ ។ ឯវំ វុត្តេ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ ភន្តេ

(៧៦) គ្រានោះ អនាថបិណ្ឌិកគហបតី មានឧបាសកប្រមាណប្រាំរយ ជាបរិវារ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះថា ម្នាលគហបតី ពួកអ្នកបានទំនុកបម្រុងភិក្ខុសង្ឃ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារហើយ ។ ម្នាលគហបតី ពួកអ្នកមិនគួរធ្វើសេចក្ដីត្រេកអរ ដោយគ្រាន់តែគិតថា ពួកយើងបានទំនុកបម្រុងភិក្ខុសង្ឃ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ប៉ុណ្ណោះឡើយ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ ពួកអ្នកត្រូវសិក្សាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ពួកយើងនឹងបានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ក្នុងកាលដ៏គួរ ។ ម្នាលគហបតី ពួកអ្នកត្រូវសិក្សាយ៉ាងនេះឯង ។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ បានក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះពេញជាសុភាសិត

ភគវតា តុម្ហេ ខោ គហបតិ ភិក្ខុសង្ឃំ បច្ចុបដ្ឋិតា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ។ ន ខោ គហបតិ តាវតកេនេវ តុដ្ឋិ ករណីយា មយំ ភិក្ខុសង្ឃំ បច្ចុបដ្ឋិតា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេនាតិ ។ តស្មាតិហ គហបតិ ឯវំ សិក្ខិតព្វំ កិន្តិ មយំ កាលេន កាលំ បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរេយ្យាមាតិ ។ ឯវំ ហិ វោ គហបតិ សិក្ខិតព្វន្តិ ។ យស្មឹ ភន្តេ សមយេ អរិយសាវកោ បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរតិ បញ្ចស្ស ឋានានិ តស្មឹ សមយេ ន ហោន្តិ យម្បិស្ស កាមុបសំហិតំ ទុក្ខំ ទោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ យម្បិស្ស កាមុបសំហិតំ សុខំ សោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ យម្បិស្ស អកុសលុបសំហិតំ ទុក្ខំ ទោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ

ដែលព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលគហបតី ពួកអ្នកបានទំនុកបម្រុងភិក្ខុសង្ឃ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារហើយ ៗ ម្នាលគហបតី ពួកអ្នកមិនគួរធ្វើសេចក្តីត្រេកអរ ដោយគ្រាន់តែគិតថា ពួកយើងបានទំនុកបម្រុងភិក្ខុសង្ឃ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ប៉ុណ្ណោះឡើយ ៗ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ ពួកអ្នកត្រូវសិក្សាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកយើងនឹងបានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ក្នុងកាលដ៏គួរ ៗ ម្នាលគហបតី ពួកអ្នកត្រូវសិក្សាយ៉ាងនេះឯង ៗ បពិត្រព្រះអង្គដ៏ចំរើន សម័យណា អរិយសាវក បានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ សម័យនោះ ហេតុ ៥ យ៉ាង មិនមានដល់អរិយសាវកនោះឡើយ គឺទុក្ខ ទោមនស្សណា ដែលជាគ្រឿងប្រកបដោយកាមរបស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ សុខ សោមនស្សណា ដែលប្រកបដោយកាមរបស់អរិយសាវកនោះ សុខ សោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ទុក្ខ ទោមនស្សណា ដែលប្រកបដោយអកុសល របស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១

យម្បិស្ស អកុសលុបសញ្ហិតំ សុខំ សោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ យម្បិស្ស កុសលុបសញ្ហិតំ ទុក្ខំ ទោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ ។ យស្មឹ ភន្តេ សមយេ អរិយ-សាវកោ បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរតិ ឥមានិ បញ្ចស្ស ឋានានិ តស្មឹ សមយេ ន ហោន្តីតិ ។ សាធុ សាធុ សារីបុត្ត យស្មឹ សារីបុត្ត សមយេ អរិយសាវកោ បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរតិ បញ្ចស្ស ឋានានិ តស្មឹ សមយេ ន ហោន្តិ យម្បិស្ស កាមុបសញ្ហិតំ ទុក្ខំ ទោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ យម្បិស្ស កាមុបសញ្ហិតំ សុខំ សោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ យម្បិស្ស អកុសលុបសញ្ហិតំ ទុក្ខំ ទោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ

សុខ សោមនស្សណា ដែលប្រកបដោយអកុសល របស់អរិយសាវកនោះ សុខ សោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ទុក្ខ ទោមនស្សណា ដែលប្រកបដោយកុសលរបស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ។ បពិត្រព្រះអង្គដ៏ចំរើន សម័យណា អរិយសាវកបានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ សម័យនោះ ហេតុ ៥ យ៉ាងនេះ មិនមានដល់អរិយសាវកនោះឡើយ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត ត្រូវហើយ ត្រូវហើយ ម្នាលសារីបុត្ត សម័យណា អរិយសាវក បានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ សម័យនោះ ហេតុ ៥ យ៉ាង មិនមានដល់អរិយសាវកនោះឡើយ គឺ ទុក្ខ ទោមនស្សណា ដែលប្រកបដោយកាម របស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ សុខ សោមនស្សណា ដែលប្រកបដោយកាម របស់អរិយសាវកនោះ សុខ សោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ទុក្ខ ទោមនស្សណា ដែលប្រកបដោយអកុសល របស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១

យម្បិស្ស អកុសលុបសញ្ហិតំ សុខំ សោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ យម្បិស្ស កុសលុបសញ្ហិតំ ទុក្ខំ ទោមនស្សំ តម្បិស្ស តស្មឹ សមយេ ន ហោតិ ។ យស្មឹ សារីបុត្ត សមយេ អរិយសាវកោ បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរតិ ឥមានិ បញ្ចស្ស ឋានានិ តស្មឹ សមយេ ន ហោន្តីតិ ។

(៧៧) បញ្ចិមា ភិក្ខវេ វណិជ្ជា ឧបាសកេន អករណីយា ។ កតមា បញ្ច សត្ថវណិជ្ជា សត្តវណិជ្ជា មំសវណិជ្ជា មជ្ជវណិជ្ជា វិសវណិជ្ជា ។ ឥមា ខោ ភិក្ខវេ បញ្ច វណិជ្ជា ឧបាសកេន អករណីយាតិ ។

(៧៨) តំ កឹ មញ្ញថ ភិក្ខវេ អបិនុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា អយំ បុរិសោ បាណាតិបាតំ បហាយ បា-ណាតិបាតា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា

សុខ សោមនស្សណា ដែលប្រកបដោយអកុសល របស់អរិយ-សាវកនោះ សុខ សោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ទុក្ខ ទោមនស្សណា ដែលប្រកបដោយកុសល របស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ។ ម្នាលសារីបុត្ត សម័យណា អរិយសាវកបានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ សម័យនោះ ហេតុ ៥ យ៉ាងនេះឯង មិនមានដល់អរិយសាវកនោះឡើយ ។

(៧៧) ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាងនេះ ឧបាសកមិនគួរធ្វើឡើយ ។ ជំនួញ ៥ យ៉ាង តើដូចម្តេច ។ គឺការជួញគ្រឿងសស្ត្រាវុធ ១ ការជួញមនុស្ស ១ ការជួញ (សត្វដែលគេសម្លាប់យក) សាច់ ១ ការជួញគ្រឿងស្រវឹង ១ ការជួញថ្នាំពិស ១ ។ ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ ប្រការនេះឯង ឧបាសកមិនគួរធ្វើឡើយ ។

(៧៨) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្តេច អ្នកទាំងឡាយដែលឃើញ ឬដែលឮថា បុរសនេះបានលះបាណា-តិបាត វៀរចាកបាណាតិបាត ស្តេចទាំងឡាយចាប់បុរសនោះហើយ

បាណាតិបាតាវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ អយំ បុរិសោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា បាណាតិបាតាវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ អបិច ខ្វស្ស តថេវ បាបកម្មំ បវេទេន្តិ អយំ បុរិសោ ឥត្ថឹ វា បុរិសំ វា ជីវិតា វោរោបេតីតិ(១) ។ តមេនំ រាជានោ គហេត្វា បាណាតិបាតហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តិ ។ អបិនុ តុម្ហេហិ ឯវរូបំ ទិដ្ឋំ វា សុតំ វាតិ ។ ទិដ្ឋញ្ច នោ ភន្តេ សុតញ្ច សុយ្យិស្សតិ ចាតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិនុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា អយំ បុរិសោ អទិន្នាទានំ បហាយ

១ ឱ, ម. វោរោបេសីតិ ។

សម្លាប់ ចង បណ្តេញ ឬធ្វើឲ្យគួរតាមទោស ព្រោះហេតុតែ វៀរចាក បាណាតិបាតដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនោះមិនដែលមាន ទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបី តថាគតក៏មិនដែលឃើញ មិនដែលឮហេតុនុះថា បុរសនេះបានលះបង់ បាណាតិបាត វៀរចាកបាណាតិបាត ស្តេចទាំងឡាយ ចាប់នូវបុរសនោះ ហើយ សម្លាប់ ចង បណ្តេញ ឬធ្វើឲ្យគួរតាមទោស ព្រោះហេតុតែ វៀរចាកបាណាតិបាតដែរ ។ មួយទៀត អ្នកផងតែងដឹងនូវបាបកម្ម របស់បុរសនោះថា បុរសនេះសម្លាប់ប្រុសឬស្រីចាកជីវិត ស្តេចទាំង ឡាយចាប់បុរសនោះ សម្លាប់ ចង បណ្តេញ ឬធ្វើឲ្យសមគួរតាមទោស ព្រោះហេតុតែបាណាតិបាត ។ អ្នកទាំងឡាយដែលឃើញ ដែលឮ បែបនេះ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គដែលឃើញ ដែលឮរួចមកហើយ គង់នឹងឮតទៅទៀត មិនខាន ។ ម្នាលភិក្ខុទាំង ឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះ ថាដូចម្តេច អ្នកទាំង ឡាយ ដែលឃើញ ដែលឮថា បុរសនេះ បានលះនូវអទិន្នាទាន

អទិន្នាទានា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា អទិន្នាទានាវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ អយំ បុរិសោ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា អទិន្នាទានាវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ អបិច ខ្វស្ស តថេវ បាបកម្មំ បវេទេន្តិ អយំ បុរិសោ គាមា វា អរញ្ញា វា អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ តមេនំ រាជានោ គហេត្វា អទិន្នាទានហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តិ ។ អបិនុ តុម្ហេហិ ឯវរូបំ ទិដ្ឋំ វា សុតំ វាតិ ។ ទិដ្ឋញ្ច នោ ភន្តេ សុតញ្ច សុយ្យិស្សតិ ចាតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិនុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា

វៀរចាកអទិន្នាទាន ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកអទិន្នាទាន ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន មិនដែលបានឃើញ មិនដែលបានឮសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគត ក៏មិនដែលបានឃើញ មិនដែលបានឮ នូវហេតុនុ៎ះថា បុរសនេះ បានលះអទិន្នាទាន វៀរចាកអទិន្នាទាន ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកអទិន្នាទានដែរ ។ មួយទៀត អ្នកផងតែងដឹងនូវបាបកម្មរបស់បុរសនោះថា បុរសនេះ កាន់យកទ្រព្យដែលគេមិនបានឲ្យក្នុងស្រុកឬក្នុងព្រៃ ដោយចំណែកនៃចិត្តលួច ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែអទិន្នាទាន ។ អ្នកទាំងឡាយ ដែលបានឃើញ ឬបានឮបែបយ៉ាងនេះ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គបានឃើញ បានឮរួចមកហើយ គង់នឹងឮតទៅទៀតមិនខាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះថាដូចម្តេច អ្នកទាំងឡាយ ដែលបានឃើញ បានឮថា

អយំ បុរិសោ កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា កាមេសុ មិច្ឆាចារវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ អយំ បុរិសោ កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា កាមេសុ មិច្ឆាចារវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ អបិច ខ្វស្ស តថេវ បាបកម្មំ បវេទេតិ អយំ បុរិសោ បរិត្ថីសុ បរកុមារីសុ ចារិត្តំ អាបជ្ជតិ(១) តមេនំ រាជានោ គហេត្វា កាមេសុ មិច្ឆាចារហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តិ ។ អបិនុ តុម្ហេហិ ឯវរូបំ ទិដ្ឋំ វា សុតំ វាតិ ។ ទិដ្ឋញ្ច នោ ភន្តេ សុតញ្ច សុយ្យិស្សតិ ចាតិ ។

---

១ ឱ. ម. អាបជ្ជីតិ ។

បុរសនេះ បានលះបង់នូវកាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ ស្តេចទាំងឡាយ ចាប់បុរសនោះហើយសម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកកាមេសុមិច្ឆាចារ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន មិនដែលបានឃើញ មិនដែលបានឮសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគតក៏មិនដែលបានឃើញ មិនដែលបានឮ នូវហេតុនុ៎ះថា បុរសនេះបានលះបង់នូវកាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ ស្តេចទាំងឡាយចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកកាមេសុមិច្ឆាចារដែរ ។ មួយទៀត អ្នកផងតែងដឹងនូវបាបកម្ម របស់បុរសនោះថា បុរសនេះដល់នូវសេចក្តីប្រព្រឹត្តកន្លងស្ត្រីនៃជនដទៃ នឹងពួកកុមារីនៃជនដទៃ ស្តេចទាំងឡាយចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែកាមេសុមិច្ឆាចារ ។ អ្នកទាំងឡាយ ដែលបានឃើញបានឮបែបនេះ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គបានឃើញ បានឮរួចមកហើយ គង់នឹងឮតទៅទៀត មិនខាន ។

តំ កឹ មញ្ញថ ភិក្ខវេ អបិនុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា អយំ បុរិសោ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា មុសាវាទាវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ អយំ បុរិសោ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា មុសាវាទាវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ អបិច ខ្វស្ស តថេវ បាបកម្មំ បវេទេន្តិ អយំ បុរិសោ គហបតិស្ស វា គហបតិបុត្តស្ស វា មុសាវាទេន អត្ថំ ភញ្ជតិ(១) តមេនំ រាជានោ គហេត្វា មុសាវាទហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តិ ។ អបិនុ តុម្ហេហិ ឯវរូបំ ទិដ្ឋំ វា សុតំ វាតិ ។

---

១ ឱ. ម. ភញ្ជីតិ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះថាដូចម្តេច អ្នកទាំងឡាយ ដែលបានឃើញ បានឮថា បុរសនេះបានលះមុសាវាទ វៀរចាកមុសាវាទ ស្តេចទាំងឡាយ ចាប់នូវបុរសនោះហើយសម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកមុសាវាទដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន មិនដែលបានឃើញ មិនដែលបានឮសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគត ក៏មិនដែលបានឃើញ មិនដែលបានឮ នូវហេតុនុះថា បុរសនេះបានលះមុសាវាទ វៀរចាកមុសាវាទ ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែ វៀរចាកមុសាវាទដែរ ។ មួយទៀត អ្នកផងដទៃតែងដឹងនូវបាបកម្មរបស់បុរសនោះថា បុរសនេះកាប់បង់នូវប្រយោជន៍របស់គហបតី ឬគហបតិបុត្ត ដោយពាក្យមុសាវាទ ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ។ អ្នកទាំងឡាយ ដែលបានឃើញ បានឮបែបនេះដែរឬទេ ។

ទិដ្ឋញ្ច នោ ភន្តេ សុតញ្ច សុយ្យិស្សតិ ចាតិ ។ តំ កិំ មញ្ញថ ភិក្ខវេ អបិ នុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា អយំ បុរិសោ សុរាមេរយមជ្ជប្បមាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា សុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ អយំ បុរិសោ សុរាមេរយមជ្ជប្បមាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ តមេនំ រាជានោ គហេត្វា សុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណីហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តីតិ ។ អបិច ខ្វស្ស តថេវ បាបកម្មំ បវេទេតិ អយំ បុរិសោ សុរាមេរយមជ្ជប្បមាទដ្ឋានំ អនុយុត្តោ ឥត្ថឹ វា បុរិសំ វា ជីវិតា វោរោបេតិ (១) អយំ បុរិសោ សុរាមេរយមជ្ជប្បមាទដ្ឋានំ អនុយុត្តោ

---

១ ឱ. ម. វោរោបេសិ ។

បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គ ដែលបានឃើញ បានឮរួបមកហើយ គង់នឹងឮតទៅទៀតមិនខាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្ដីនោះថាដូចម្ដេច អ្នកទាំងឡាយដែលបានឃើញ បានឮថា បុរសនេះ បានលះបង់នូវសុរាមេរយមជ្ជប្បមាទដ្ឋាន វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ស្ដេចទាំងឡាយចាប់បុរសនោះហើយ សម្លាប់ ចង បណ្ដេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន មិនដែលបានឃើញ មិនដែលបានឮសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគតក៏មិនដែលបានឃើញ មិនដែលបានឮនូវហេតុនុះថា បុរសនេះបានលះនូវសុរាមេរយមជ្ជប្បមាទដ្ឋាន វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ស្ដេចទាំងឡាយ ចាប់នូវបុរសនោះហើយ សម្លាប់ ចង បណ្ដេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានដែរ ។ មួយទៀត អ្នកផងដទៃតែងដឹងនូវបាបកម្មរបស់បុរសនោះថា បុរសនេះប្រកបនូវសុរាមេរយមជ្ជប្បមាទដ្ឋានហើយ ផ្ដាច់ផ្ដិលនូវស្ត្រីបុរសចាកជីវិត បុរសនេះ ប្រកបនូវសុរាមេរយមជ្ជប្បមាទដ្ឋានហើយ

គាមា វា អរញ្ញា វា អទិន្នំ ថេយ្យសង្ខាតំ អាទិ-យតិ អយំ បុរិសោ សុរាមេរយមជ្ជប្បមាទដ្ឋានំ អនុយុត្តោ បរិត្ថីសុ បរកុមារីសុ ចារិត្តំ អាបជ្ជតិ(១) អយំ បុរិសោ សុរាមេរយមជ្ជប្បមាទដ្ឋានំ អនុយុត្តោ គហបតិស្ស វា គហបតិបុត្តស្ស វា មុសាវាទេន អត្ថំ ភញ្ជតិ តមេនំ រាជានោ គហេត្វា សុរាមេរយមជ្ជប្បមាទដ្ឋានហេតុ ហនន្តិ វា ពន្ធន្តិ វា បព្វាជេន្តិ វា យថាបច្ចយំ វា ករោន្តិ ។ អបិ នុ តុម្ហេហិ ឯវរូបំ ទិដ្ឋំ វា សុតំ វាតិ ។ ទិដ្ឋញ្ច នោ ភន្តេ សុតញ្ច សុយ្យិស្សតិ ចាតិ ។

[៧៩] អថខោ អនាថបិណ្ឌិកោ គហបតិ បញ្ចមត្តេហិ ឧបាសកសតេហិ បរិវុតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ អថខោ ភគវា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ យំ កញ្ចិ សារីបុត្ត ជានេយ្យាថ គិហី ឱទាតវសនំ

១ ឱ. ម. អាបជ្ជិ ។

កាន់យកនូវទ្រព្យដែលគេមិនបានឲ្យ ក្នុងស្រុកឬក្នុងព្រៃដោយចំណែកនៃចិត្តលួច បុរសនេះ ប្រកបនូវសុរាមេរយមជ្ជប្បមាទដ្ឋានហើយ ដល់នូវការប្រព្រឹត្ត ក្នុងពួកស្រីនៃជនដទៃ ក្នុងពួកកុមារីនៃជនដទៃ បុរសនេះ ប្រកបនូវសុរាមេរយមជ្ជប្បមាទដ្ឋានហើយ កាច់បង់នូវប្រយោជន៍របស់គហបតី ឬគហបតិបុត្តដោយមុសាវាទ ស្ដេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្ដេញ ឬធ្វើតាមទោស ព្រោះហេតុតែសុរាមេរយមជ្ជប្បមាទដ្ឋាន ។ អ្នកទាំងឡាយ ដែលបានឃើញ បានឮបែបនេះដែរឬទេ ។ បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គ បានឃើញ បានឮរួចមកហើយ គង់នឹងឮតទៅទៀត មិនខាន ។

(៧៩) គ្រានោះ អនាថបិណ្ឌិកគហបតី មានឧបាសកប្រមាណ ៥០០ ជាបរិវារ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ បានត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ពួកអ្នកគួរដឹងនូវគ្រហស្ថណាមួយ ដែលស្លៀកស

បញ្ចសុ សិក្ខាបទេសុ សំវុតកម្មន្តំ ចតុន្នញ្ច អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី សោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិ ខីណបេត្តិវិសយោ ខីណាបាយ-ទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។ កតមេសុ បញ្ចសុ សិក្ខាបទេសុ សំវុតកម្មន្តោ ហោតិ ។ ឥធ សារីបុត្ត អរិយសាវកោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឥមេសុ បញ្ចសុ សិក្ខាបទេសុ សំវុតកម្មន្តោ ហោតិ ។ កតមេសំ ចតុន្នំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហា-រានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។

មានការសង្រួម ក្នុងសិក្ខាបទទាំង ៥ ប្រការផង បានតាមប្រាថ្នា បានមិនលំបាក បានមិនក្រ នូវការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ទាំង ៤ ផង កាលបើគ្រហស្ថនោះប្រាថ្នា ព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល មិនមានការធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខ ។ គ្រហស្ថដែលមានការសង្រួម ក្នុងសិក្ខាបទទាំង ៥ ប្រការ តើដូចម្តេច ។ ម្នាលសារីបុត្ត អរិយសាវក ក្នុងសាសនានេះ ជាអ្នកវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ គ្រហស្ថ ជាអ្នកមានការសង្រួម ក្នុងសិក្ខាបទទាំង ៥ នេះ ។ គ្រហស្ថ ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានមិនក្រ នូវការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ទាំង ៤ តើដូចម្តេច ។

ឥធ សារីបុត្ត អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោក-វិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ អយមស្ស បឋមោ អាភិចេតសិកោ ទិដ្ឋធម្មសុខវិហារោ អធិគតោ ហោតិ អវិសុទ្ធស្ស ចិត្តស្ស វិសុទ្ធិយា អបរិយោទាតស្ស ចិត្តស្ស បរិ-យោទបនាយ ។ បុន ចបរំ សារីបុត្ត អរិយសាវកោ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ អយមស្ស ទុតិយោ អាភិចេត-សិកោ ទិដ្ឋធម្មសុខវិហារោ អធិគតោ ហោតិ

ម្នាលសារីបុត្ត អរិយសាវក ក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយប្រពៃ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ប្រសើរបំផុត ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវអរិយសច្ចធម៌ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ដូច្នេះ ។ នេះជាការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ទី ១ ដែលអរិយសាវកនោះ បានចូលប្រទះហើយ នាំឲ្យចិត្ត ដែលមិនទាន់បរិសុទ្ធឲ្យបរិសុទ្ធ និងនាំឲ្យចិត្ត ដែលមិនទាន់ផូរផង់ឲ្យផូរផង់ ។ ម្នាលសារីបុត្ត មួយទៀត អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះធម៌ថា ធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយដោយប្រពៃ ជាធម៌ដែលព្រះអរិយបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌ គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជន គប្បីដឹងដោយខ្លួនឯង ។ នេះជាការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន ដ៏ប្រកបដោយចេតសិកដ៏ខ្ពង់ខ្ពស់ ទី ២ ដែលអរិយសាវកនោះបានចូលប្រទះហើយ

អវិសុទ្ធស្ស ចិត្តស្ស វិសុទ្ធិយា អបរិយោទាតស្ស ចិត្តស្ស បរិយោទបនាយ ។ បុន ចបរំ សារីបុត្ត អរិយសាវកោ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អយមស្ស តតិយោ អាភិចេតសិកោ ទិដ្ឋធម្មសុខវិហារោ អធិគតោ ហោតិ អវិសុទ្ធស្ស ចិត្តស្ស វិសុទ្ធិយា អបរិយោទាតស្ស ចិត្តស្ស បរិយោទបនាយ ។ បុន ចបរំ សារីបុត្ត អរិយសាវកោ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ

នាំឲ្យចិត្ត ដែលមិនទាន់បរិសុទ្ធឲ្យបរិសុទ្ធ ទឹងនាំឲ្យចិត្ត ដែលមិនទាន់ផូរផង់ឲ្យផូរផង់ ។ ម្នាលសារីបុត្ត មួយទៀត អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះសង្ឃថា ពួកសាវករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយប្រពៃ ពួកសាវករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយត្រង់ ពួកសាវករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីព្រះនិព្វាន ពួកសាវករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិដ៏សមគួរ ពួកសាវកនោះ បើរាប់ជាគូនៃបុរសមាន ៤ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ពួកសាវករបស់ព្រះដ៏មានព្រះភាគនុ៎ះ លោកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា លោកគួរទទួលនូវអាគន្តុកទាន លោកគួរទទួលនូវទក្ខិណាទាន ជាបុគ្គលដែលសត្វលោក គប្បីធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកដ៏ប្រសើរ ។ នេះជាការសម្រេចសម្រាន្តជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ទី ៣ ដែលអរិយ-សាវកនោះ បានចួបប្រទះហើយ នាំឲ្យចិត្ត ដែលមិនទាន់បរិសុទ្ធឲ្យបរិសុទ្ធ ទឹងនាំឲ្យចិត្ត ដែលមិនទាន់ផូរផង់ឲ្យផូរផង់ ។ ម្នាលសារីបុត្ត មួយទៀត អរិយសាវកប្រកបដោយសីលទាំងឡាយ ជាទីគាប់ចិត្តរបស់ព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស

ភុជិស្សេហិ វិញ្ញុប្បសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ ។ អយមស្ស ចតុត្ថោ អាភិចេតសិកោ ទិដ្ឋធម្មសុខវិហារោ អធិគតោ ហោតិ អវិសុទ្ធស្ស ចិត្តស្ស វិសុទ្ធិយា អបរិយោទាតស្ស ចិត្តស្ស បរិយោទបនាយ ។ ឥមេសំ ចតុន្នំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ យំ កញ្ចិ សារីបុត្ត ជានេយ្យាថ គិហឹ ឱទាតវសនំ ឥមេសុ បញ្ចសុ សិក្ខាបទេសុ សំវុតកម្មន្តំ ឥមេសញ្ច ចតុន្នំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភឹ អកិច្ឆលាភឹ អកសិរលាភឹ សោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិ ខីណបិត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។

ជាសីលរបស់មនុស្សអ្នកជា ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលមិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ជាសីលញុំាងសមាធិឲ្យប្រព្រឹត្តទៅបាន ។ នេះជាការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន ដ៏ប្រកបដោយចេតសិកដ៏ខ្ពង់ខ្ពស់ទាំង ៤ ដែលអរិយសាវកនោះ បានចួបប្រទះហើយ នាំឲ្យចិត្ត ដែលមិនទាន់បរិសុទ្ធឲ្យបរិសុទ្ធ និងនាំឲ្យចិត្ត ដែលមិនទាន់ផូរផង់ឲ្យផូរផង់ ។ គ្រហស្ថដែលជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានមិនក្រ នូវការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ ៤ យ៉ាងនេះឯង ។ ម្នាលសារីបុត្ត អ្នកត្រូវដឹងនូវគ្រហស្ថណាមួយ ដែលជាអ្នកស្លៀកស មានការរ៉ារសង្រួម ក្នុងសិក្ខាបទទាំង ៥ នេះផង បានតាមប្រាថ្នា បានមិនលំបាក បានមិនក្រ នូវការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ ៤ យ៉ាងនេះផង កាលបើគ្រហស្ថនោះប្រាថ្នាព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយ-ទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល មានការមិនបានធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខ ដូច្នេះ ។

ធិរយស្ស កាយំ និស្សាយ  ទានានិ បរិវជ្ជយេ
អរិយធម្មំ សមាទាយ  បណ្ឌិតោ បរិវជ្ជយេ ។
ន ហីសេ ទានភោគានិ  វិជ្ជមានេ បរក្កមេ
ឃុសភ ច ន ករោ ជានំ  អតិទ្ធំ ន បកាមសេ ។
សេហិ នាគេហិ សន្តុដ្ឋា  បរទារញ្ច នារមេ
មេរយំ ភុរសី ជន្តុ  ន បិវេ ចិត្តមោហនឹ ។
អនុស្សរេយ្យ សត្តន្នំ  ធម្មំ តានុវិតក្កយេ
អព្យាបជ្ឈំ ហិតំ ចិត្តំ  ទេវលោកាយ ភាវយេ ។
ឧបដ្ឋិតេ ទេយ្យធម្មេ  បុញ្ញត្ថស្ស ជិគីសតោ
សង្ឃេសុ បឋមំ ទិន្នា  វិបុលា ហោតិ ទក្ខិណា ។
សន្តោ ហវេ បវក្ខាមិ  សារីបុត្ត សុណោហិ មេ

បើអ្នកប្រាជ្ញ ឃើញភ័យក្នុងនរកហើយ ត្រូវវៀរបាប ទាំងឡាយ សមាទាននូវអរិយធម៌ (សីល ៥) ។ កាលបើមានសេចក្ដីព្យាយាម មិនត្រូវបៀតបៀនសត្វទាំងឡាយផង កាលដឹង មិនត្រូវនិយាយកុហកផង មិនត្រូវកាន់យកទ្រព្យដែលគេមិនបានឲ្យផង ត្រូវសន្ដោសតែនឹងភរិយារបស់ខ្លួន មិនត្រូវត្រេកត្រអាលនឹងភរិយារបស់ជនដទៃផង មិនត្រូវផឹកមេរ័យនឹងសុរា ដែលនាំចិត្តឲ្យវង្វេងផង ។ បុគ្គលគួររលឹកនូវព្រះសម្ពុទ្ធផង ត្រិះរិះនូវធម៌ឲ្យរឿយផង ចំរើនចិត្តដែលជាប្រយោជន៍ មិនមានព្យាបាទ ដើម្បីប្រយោជន៍ដល់ទេវលោកផង ។ កាលបើមានទេយ្យធម៌គ្រប់គ្រាន់ បុគ្គលអ្នកត្រូវការបុណ្យ អ្នកស្វែងរកបុណ្យ បានឲ្យទាន ចំពោះពួកសប្បុរសជាមុនហើយ ទាននោះជាទានមានផលបរិបូណ៌ ។ ម្នាលសារីបុត្ត តថាគតនឹងសំដែងនូវពួកសប្បុរស អ្នកចូរស្ដាប់តថាគតចុះ

ឥតិ កណ្ហាសុ សេតាសុ រោហិណីសុ ហរីសុ វា ។
កម្មាសាសុ សរូបាសុ គោសុ បារេវតាសុ វា
យាសុ កាសុចិ ឯតាសុ ទន្តោ ជាយតិ បុង្គវោ ។
ធោរយ្ហោ ពលសម្បន្នោ កល្យាណជវនិក្កមោ
តមេវ ភារេ យុញ្ជន្តិ នាស្ស វណ្ណំ បរិក្ខរេ ។
ឯវមេវ មនុស្សេសុ យស្មឹ កស្មិញ្ចិ ជាតិយេ
ខត្តិយេ ព្រាហ្មណេ វេស្សេ សុទ្ទេ ចណ្ឌាលបុក្កុសេ ។
យាសុ កាសុចិ ឯតាសុ ទន្តោ ជាយតិ សុព្វតោ
ធម្មដ្ឋោ សីលសម្បន្នោ សច្ចវាទី ហិរីមនោ ។
បហីនជាតិមរណោ ព្រហ្មចរិយស្ស កេវលី
បន្នភារោ វិសំយុត្តោ កតកិច្ចោ អនាសវោ ។
បារគូ សព្វធម្មានំ អនុបាទាយ និព្វុតោ
តស្មិញ្ហិ វិរជេ ខេត្តេ វិបុលា ហោតិ ទក្ខិណា ។

គោឈ្មោលកើតក្នុងមេគោណាមួយ ទោះសម្បុរខ្មៅក្តី សក្តី ក្រហមក្តី លឿងក្តី ពព្រុសក្តី មានរូបប្រហែលនឹងកូនរបស់ខ្លួនក្តី ប្រផេះក្តី ដែលគេបង្វឹកបានបទហើយ ជាសត្វអាចនាំទៅនូវធុរៈបាន បរិបូណ៌ដោយកំឡាំង មានល្បឿនដ៏ពូកែ ពួកជនទឹមគោនោះក្នុងភារៈ គេមិនរើសអើងសម្បុរនៃគោនោះឡើយ មានឧបមាយ៉ាងណាមិញ បុគ្គលមានមារ-យាទល្អ កើតក្នុងស្ត្រីណាមួយ ទោះបីជាក្ស័ត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាល បុក្កសៈ តែបានទូន្មានល្អ ប្រដៅងាយ តាំងនៅក្នុងធម៌ បរិបូណ៌ដោយសីល ពោលពាក្យសច្ចៈ មានចិត្តប្រកបដោយហិរិ លះបង់នូវការកើតនឹងស្លាប់ មានព្រហ្មចរិយៈពេញលេញ ទំលាក់ចោលនូវភារៈ ប្រាសចាកគ្រឿងសៅហ្មង ធ្វើនូវកិច្ចស្រេច មិនមានអាសវៈ ចេះចប់ធម៌ទាំងពួង រលត់ទុក្ខ ព្រោះមិនប្រកាន់ ទាន (ដែលទាយកឲ្យ) បំពោះបុគ្គលដែលជាបុញ្ញក្ខេត្ត ប្រាសចាកធូលីនោះ ជាទានមានផលពេញបរិបូណ៌ ក៏បានឧបមេយ្យយ៉ាងនោះដែរ ។

ពាលា ច អវិជានន្តា ទុម្មេធា អស្សុតាវិនោ
ពហិទ្ធា ទេន្តិ ទានានិ ន ហិ សន្តេ ឧបាសរេ ។
យេ ច សន្តេ ឧបាសន្តិ សប្បញ្ញេ ធីរសម្មតេ
សទ្ធា ច នេសំ សុគតេ មូលជាតា បតិដ្ឋិតា
ទេវលោកញ្ច តេ យន្តិ កុលេ វា ឥធ ជាយរេ
អនុបុព្វេន និព្វានំ អធិគច្ឆន្តិ បណ្ឌិតាតិ ។

[៨០] ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ អទ្ទសា ខោ ភគវា អទ្ធានមគ្គប្បដិបន្នោ អញ្ញតរស្មឹ បទេសេ មហន្តំ សាលវនំ ទិស្វាន មគ្គា ឱក្កម្ម យេន តំ សាលវនំ តេនុបសង្កមិ ឧបសង្កមិត្វា តំ សាលវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ បទេសេ សិតំ បាត្វាកាសិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ កោ នុ ខោ ហេតុ

ពួកជនពាល ដែលមិនដឹង ឥតប្រាជ្ញា គ្មានការស្តាប់ តែងឲ្យទានខាងក្រៅ មិនចូលទៅអង្គុយជិតពួកសប្បុរសឡើយ ។ ជនពួកណា តែងចូលទៅអង្គុយជិតពួកសប្បុរស ដែលប្រកបដោយប្រាជ្ញា ដែលអ្នកប្រាជ្ញសន្មតហើយ ជនពួកនោះ រមែងមានសទ្ធាជាមូល ប្រតិស្ឋានក្នុងព្រះសុគត មិនតែប៉ុណ្ណោះ ជនពួកនោះ រមែងទៅកាន់ទេវលោក ឬកើតក្នុងត្រកូលនាលោកនេះ រមែងជាបណ្ឌិតដល់នូវព្រះនិព្វាន ដោយលំដាប់ ។

(៨០) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ត្រាច់ទៅកាន់ចារិក ក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃជាច្រើន ។ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរ ទៅកាន់ផ្លូវឆ្ងាយ ' បានទតឃើញព្រៃសាលព្រឹក្សដ៏ធំ ក្នុងប្រទេសមួយ លុះទ្រង់ទតឃើញហើយ ក៏យាងចុះអំពីផ្លូវ ស្តេចទៅកាន់ព្រៃសាលព្រឹក្សនោះ លុះចូលទៅដល់ហើយ ក៏អាស្រ័យនៅនឹងព្រៃសាលព្រឹក្សនោះ រួចទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ត្រង់ប្រទេសមួយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានបរិវិតក្កយ៉ាងនេះថា អ្វីហ្ន៎ ដែលជាហេតុ

កោ បច្ចយោ ភគវតោ សិតស្ស បាតុកម្មាយ ។ ន អការណេន តថាគតា សិតំ បាតុករោន្តិ[1] ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ ភគវតោ សិតស្ស បាតុកម្មាយ ។ ន អការណេន តថាគតា សិតំ បាតុករោន្តីតិ ។ ភូតបុព្វំ អានន្ទ ឥមស្មឹ បទេសេ នគរំ អហោសិ ឥទ្ធញ្ចេវ ផីតញ្ច ពហុជនំ អាកិណ្ណមនុស្សំ ។ តំ ខោ បនានន្ទ នគរំ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ ឧបនិស្សាយ វិហរតិ ។ កស្សបស្ស ខោ បនានន្ទ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស គវេសី នាម ឧបាសកោ អហោសិ សីលេសុ អបរិបូរការី ។ គវេសិនា ខោ អានន្ទ ឧបាសកេន បញ្ចមត្តានិ ឧបាសកសតានិ បដិទេសិតានិ សមាទបិតានិ អហេសុំ សីលេសុ អបរិបូរការិនោ ។ អថខោ អានន្ទ គវេសិស្ស ឧបាសកស្ស ឯតទហោសិ

១ ឱ. ម. បាតុករោន្តីតិ ។

អ្វីហ្ន៎ ដែលជាបច្ច័យ នាំឲ្យព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ។ (ព្រោះ) ព្រះតថាគតទាំងឡាយ មិនដែលធ្វើនូវការញញឹម ដោយឥតហេតុឡើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុបានក្រាបទូលសួរព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន អ្វីហ្ន៎ ជាហេតុ អ្វីហ្ន៎ ជាបច្ច័យ នាំឲ្យព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ។ (ព្រោះ) ព្រះតថាគតទាំងឡាយ មិនដែលធ្វើនូវការញញឹមឲ្យប្រាកដ ដោយឥតហេតុឡើយ ។ ម្នាលអានន្ទ ហេតុធ្លាប់មានមកហើយថា ត្រង់ប្រទេសនេះមាននគរមួយ ជានគរស្តុកស្តម្ភ ម៉ាំមួន មានជនច្រើន មានមនុស្សកុះករ ។ ម្នាលអានន្ទ មួយទៀត ព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ ទ្រង់ចូលទៅអាស្រ័យក្នុងនគរនោះ ។ ម្នាលអានន្ទ ព្រះដ៏មានព្រះភាគព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ មានឧបាសកម្នាក់ ឈ្មោះគវេសី ជាអ្នកមិនបានធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយទេ ។ ម្នាលអានន្ទ ទាំងពួកឧបាសកចំនួនប្រាំរយ ដែលគវេសីឧបាសក បានសំដែងពន្យល់ឲ្យសមាទានហើយ ក៏ជាអ្នកមិនបានធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយដែរ ។ ម្នាលអានន្ទ គ្រានោះ គវេសីឧបាសក មានសេចក្តីត្រិះរិះយ៉ាងនេះថា

អហំ ខោ ឥមេសំ បញ្ចន្នំ ឧបាសកសតានំ ពហូប-
ការោ បុព្វង្គមោ សមាទបេតា អហញ្ហិ សីលេសុ
អបរិបូរការី ឥមានិបិ បញ្ច ឧបាសកសតានិ សីលេសុ
អបរិបូរការិនោ ឥច្ចេតំ សមសមំ នត្ថិ កិញ្ចិ អតិរេកំ
ហន្ទាហំ អតិរេកាយាមិ ។ អថខោ អានន្ទ គវេសី
ឧបាសកោ យេន តានិ បញ្ច ឧបាសកសតានិ
តេនុបសង្កមិ ឧបសង្កមិត្វា តានិ បញ្ច ឧបាសក-
សតានិ ឯតទវោច អជ្ជតគ្គេ មំ អាយស្មន្តោ
សីលេសុ បរិបូរការឹ ធារេថាតិ ។ អថខោ អានន្ទ
តេសំ បញ្ចន្នំ ឧបាសកសតានំ ឯតទហោសិ អយ្យោ
ខោ គវេសី អម្ហាកំ ពហូបការោ បុព្វង្គមោ
សមាទបេតា អយ្យោ ហិ នាម គវេសី សីលេសុ
បរិបូរការី ភវិស្សតិ កិមង្គំ បន មយន្តិ ។ អថខោ
អានន្ទ តានិ បញ្ច ឧបាសកសតានិ យេន គវេសី
ឧបាសកោ តេនុបសង្កមឹសុ ឧបសង្កមិត្វា គវេសឹ
ឧបាសកំ ឯតទវោចុំ អជ្ជតគ្គេ អយ្យោ គវេសី

អាត្មាអញមានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យពួកឧបាសកទាំងប្រាំរយនេះសមាទាន តែអាត្មាអញ មិនទាន់ជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយទេ ឯពួកឧបាសកទាំងប្រាំរយនេះ ក៏មិនជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយឡើយ សុទ្ធតែស្មើៗគ្នាដូច្នេះ មិនមានលើសលុបជាងគ្នាតិចតួចឡើយ បើដូច្នោះ គួរតែអាត្មា (ធ្វើ) ឲ្យលើសលុបជាងចុះ ។ ម្នាលអានន្ទ លំដាប់នោះ គហបតីឧបាសក បានចូលទៅរកពួកឧបាសកទាំងប្រាំរយនោះ លុះចូលទៅដល់ហើយ បាននិយាយទៅរកពួកឧបាសកទាំងប្រាំរយនោះ យ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ អ្នកដ៏មានអាយុទាំងឡាយ ចូរចាំទុកនូវខ្ញុំថាជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយ ។ ម្នាលអានន្ទ គ្រានោះឯង ពួកឧបាសកទាំងប្រាំរយនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា គហបតីជាម្ចាស់ហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យពួកយើងសមាទាន អម្បាលគហបតីជាម្ចាស់ម្តេច គង់ជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយទៅហើយ ចុះពួកយើងចាំអ្វីទៀត ។ ម្នាលអានន្ទ លំដាប់នោះឯង ពួកឧបាសកទាំងប្រាំរយនោះ បានចូលទៅរកគហបតីឧបាសក លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងគហបតីឧបាសកយ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ គហបតីជាម្ចាស់

ឥមានិបិ បញ្ច ឧបាសកសតានិ សីលេស បរិបូរការិនោ នាហេសុន្តិ ។ អថខោ អានន្ទ គវេសិស្ស ឧបាសកស្ស ឯតទហោសិ អហំ ខោ ឥមេសំ បញ្ចន្នំ ឧបាសកសតានំ ពហូបការោ បុព្វង្គមោ សមាទបេតា អហញ្ចម្ហិ សីលេសុ បរិបូរការី ឥមានិបិ បញ្ច ឧបាសកសតានិ សីលេសុ បរិបូរការិនោ ឥច្ចេតំ សមសមំ នត្ថិ កិញ្ចិ អតិរេកំ ហន្ទាហំ អតិរេកាយាតិ ។ អថខោ អានន្ទ គវេសី ឧបាសកោ យេន តានិ បញ្ច ឧបាសកសតានិ តេនុបសង្កមិ ឧបសង្កមិត្វា តានិ បញ្ច ឧបាសកសតានិ ឯតទវោច អជ្ជតគ្គេ មំ អាយស្មន្តោ ព្រហ្មចារី ធារេថ អារាចារី វិរតំ មេថុនា គាមធម្មាតិ ។ អថខោ អានន្ទ តេសំ បញ្ចន្នំ ឧបាសកសតានំ ឯតទហោសិ អយ្យោ ខោ គវេសី អម្ហាកំ ពហូបការោ បុព្វង្គមោ សមាទបេតា អយ្យោ ហិ នាម គវេសី ព្រហ្មចារី ភវិស្សតិ អារាចារី វិរតោ មេថុនា

សូមចាំទុកនូវពួកឧបាសកទាំងប្រាំរយនេះ ថាជាអ្នកធ្វើឲ្យបរិបូណ៌ គុណសីលទាំងឡាយដែរ ។ ម្នាលអានន្ទ លំដាប់នោះ គវេសីឧបាសកមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ៍ ឲ្យពួកឧបាសកទាំងប្រាំរយនេះ សមាទាន ឯអាត្មាអញ ជាអ្នកធ្វើឲ្យបរិបូណ៌ គុណសីលទាំងឡាយ ទាំងពួកឧបាសកប្រាំរយនេះ ក៏ជាអ្នកធ្វើឲ្យបរិបូណ៌ គុណសីលទាំងឡាយដែរ សុទ្ធតែស្មើៗគ្នាដូច្នេះ មិនមានលើសលុប ជាងគ្នាតិចតួចឡើយ បើដូច្នោះគួរតែអាត្មាអញ (ធ្វើ) ឲ្យលើសលុបជាងបុះ ។ ម្នាលអានន្ទ លំដាប់នោះឯង គវេសីឧបាសកបានចូលទៅរកពួកឧបាសកទាំងប្រាំរយនោះ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងពួកឧបាសកទាំងប្រាំរយនោះយ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ ពួកអ្នកដ៏មានអាយុ ចូរចាំទុកនូវខ្ញុំថាជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុក ។ ម្នាលអានន្ទ លំដាប់នោះឯង ឧបាសកទាំងប្រាំរយនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា គវេសីជាម្ចាស់ហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ៍ ឲ្យពួកយើងសមាទាន អម្បាលគវេសីជាម្ចាស់ម្តេច គង់ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន

គាមធម្មា កិមង្គំ បន មយន្តិ ។ អថខោ អានន្ទ តានិ បញ្ច ឧបាសកសតានិ យេន គវេសី ឧបាសកោ តេនុបសង្កមឹសុ ឧបសង្កមិត្វា គវេសឹ ឧបាសកំ ឯតទវោចុំ អជ្ជតគ្គេ អយ្យោ គវេសី អម្ហេបិ បញ្ច ឧបាសកសតានិ ព្រហ្មចារិនោ ធារេតុ អារាចារិនោ វិរតេ មេថុនា គាមធម្មាតិ ។ អថខោ អានន្ទ គវេសិស្ស ឧបាសកស្ស ឯតទហោសិ អហំ ខោ ឥមេសំ បញ្ចន្នំ ឧបាសកសតានំ ពហុបការោ បុព្វង្គមោ សមាទបេតា អហញ្ចម្ហិ សីលេសុ បរិបូរការី ឥមានិបិ បញ្ច ឧបាសកសតានិ សីលេសុ បរិបូរការិនោ អហញ្ចម្ហិ ព្រហ្មចារី អារាចារី វិរតោ មេថុនា គាមធម្មា ឥមានិបិ បញ្ច ឧបាសកសតានិ ព្រហ្មចារិនោ អារាចារិនោ វិរតា មេថុនា គាមធម្មា ឥច្ចេតំ សមសមំ នត្ថិ កិញ្ចិ ឧត្តរិតរំ ហន្ទាហំ ឧត្តរិតរំ ករោមីតិ ។ អថខោ អានន្ទ គវេសី ឧបាសកោ

ជាធម៌របស់អ្នកស្រុកទៅហើយ ចុះពួកយើងចាំអ្វីទៀត ។ ម្នាលអានន្ទ គ្រានោះ ឧបាសកទាំងប្រាំរយនោះ បានចូលទៅរកកវេសីឧបាសក លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងកវេសីឧបាសកយ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ កវេសីជាម្ចាស់ ចូរចាំទុកនូវឧបាសកទាំងប្រាំរយនេះថាជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុកដែរហើយ ។ ម្នាលអានន្ទ លំដាប់នោះឯង កវេសីឧបាសក មានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិឲ្យឧបាសកទាំងប្រាំរយនេះសមាទាន តែថាអាត្មាអញ ជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយ សូម្បីឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកធ្វើឲ្យពេញលេញ ក្នុងសីលទាំងឡាយដែរ មួយទៀត អាត្មាអញជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុក សូម្បីពួកឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុកដែរ សុទ្ធតែស្មើៗ គ្នាដូច្នេះ មិនមានលើសលុប ជាងគ្នាតិចតួចឡើយ បើដូច្នេះ គួរតែអាត្មាអញប្រតិបត្តិ ឲ្យលើសលុបជាងទៅចុះ ។ ម្នាលអានន្ទ លំដាប់នោះឯង កវេសីឧបាសក

យេន តានិ បញ្ច ឧបាសកសតានិ តេនុបសង្កមិ ឧបសង្កមិត្វា តានិ បញ្ច ឧបាសកសតានិ ឯតទវោច អជ្ឈត្តេ មំ អាយស្មន្តោ ឯកភត្តិកំ ធារេថ រត្តូបរតំ វិរតំ វិកាលភោជនាតិ ។ អថខោ អានន្ទ តេសំ បញ្ចន្នំ ឧបាសកសតានំ ឯតទហោសិ អយ្យោ ខោ ភវេសី អម្ហាកំ ពហូបការោ បុព្វង្គមោ សមាទបេតា អយ្យោ ហិ នាម ភវេសិ ឯកភត្តិកោ ភវិស្សតិ រត្តូបរតោ វិរតោ វិកាលភោជនា កិមង្គំ បន មយន្តិ ។ អថខោ អានន្ទ តានិ បញ្ច ឧបាសកសតានិ យេន ភវេសី ឧបាសកោ តេនុបសង្កមឹសុ ឧបសង្កមិត្វា ភវេសឹ ឧបាសកំ ឯតទវោចុំ អជ្ឈត្តេ អយ្យោ ភវេសី ឥមានិបិ បញ្ច ឧបាសកសតានិ ឯកភត្តិកេ ធារេន្តុ រត្តូបរតេ វិរតេ វិកាលភោជនាតិ ។ អថខោ អានន្ទ ភវេសិស្ស ឧបាសកស្ស ឯតទហោសិ

បានចូលទៅរកពួកឧបាសកទាំងប្រាំរយនោះ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងឧបាសកទាំងប្រាំរយនោះ យ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ ពួកអ្នកដ៏មានអាយុ ចូរចាំទុកនូវខ្ញុំថា ជាអ្នកបរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគ ក្នុងវេលាវិកាល ៗ ម្នាលអានន្ទ លំដាប់នោះឯង ឧបាសកទាំងប្រាំរយនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា គវេសីជាម្ចាស់ មានឧបការៈច្រើន ជាអ្នកនាំរាទិ ឲ្យពួកយើងសមាទាន អម្បាលគវេសីជាម្ចាស់ម្តេច គង់ជាអ្នកបរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងវេលាវិកាលទៅហើយ ចុះពួកយើងចាំអ្វីទៀតហ្ន៎ ៗ ម្នាលអានន្ទ លំដាប់នោះឯង ឧបាសកទាំងប្រាំរយនោះ បានចូលទៅរកគវេសីឧបាសក លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងគវេសីឧបាសកយ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ គវេសីជាម្ចាស់ សូមចាំទុកនូវឧបាសកទាំងប្រាំរយនេះ ថាជាអ្នកបរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគ ក្នុងវេលាវិកាលដែរហើយ ៗ ម្នាលអានន្ទ លំដាប់នោះ គវេសីឧបាសក មានសេចក្តីត្រិះរិះយ៉ាងនេះថា

អហំ ខោ ឥមេសំ បញ្ចន្នំ ឧបាសកសតានំ ពហូបការោ បុព្វង្គមោ សមាទបេតា អហម្បិ សីលេសុ បរិបូរការី ឥមានិបិ បញ្ច ឧបាសកសតានិ សីលេសុ បរិបូរការិនោ អហម្បិ ព្រហ្មចារី អារាចារី វិរតោ មេថុនា គាមធម្មា ឥមានិបិ បញ្ច ឧបាសកសតានិ ព្រហ្មចារិនោ អារាចារិនោ វិរតា មេថុនា គាមធម្មា អហម្បិ ឯកភត្តិកោ រត្តូបរតោ វិរតោ វិកាលភោជនា ឥមានិបិ បញ្ច ឧបាសក-សតានិ ឯកភត្តិកា រត្តូបរតា វិរតា វិកាល-ភោជនា ឥច្ចេតំ សមសមំ នត្ថិ កិញ្ចិ អតិរេកំ ហន្ទាហំ អតិរេកាយាតិ ។ អថខោ អានន្ទ គវេសី ឧបាសកោ យេន កស្សបោ ភគវា អរហំ សម្មា-សម្ពុទ្ធោ តេនុបសង្កមិ ឧបសង្កមិត្វា កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។

អាត្មាអញហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យឧបាសកទាំងប្រាំរយនេះសមាទាន តែថាអាត្មាអញ ជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយ សូម្បីឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយដែរ មួយទៀត អាត្មាអញជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុក សូម្បីឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុកដែរ មួយទៀត អាត្មាអញ ជាអ្នកបរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងវេលាវិកាល សូម្បីឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកបរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងវេលាវិកាលដែរ សុទ្ធតែស្មើៗគ្នាដូច្នេះ មិនមានលើសលុប ជាងគ្នាតិចតួចឡើយ បើដូច្នោះគួរតែអាត្មាអញ (ធ្វើ) ឲ្យលើសលុបជាងទៅចុះ ។ ម្នាលអានន្ទ លំដាប់នោះ កវេសីឧបាសក បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ៗ

អលត្ថ ខោ អានន្ទ កវេសី ឧបាសកោ កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ បនានន្ទ កវេសី ភិក្ខុ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ អញ្ញតរោ ច បនានន្ទ កវេសី ភិក្ខុ អរហតំ អហោសិ ។ អថខោ អានន្ទ តេសំ បញ្ចន្នំ ឧបាសកសតានំ ឯតទហោសិ អយ្យោ ខោ កវេសី អម្ហាកំ ពហូបការោ បុព្វង្គមោ សមាទបេតា អយ្យោ ហិ នាម កវេសី កេស-មស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា

ម្នាលអានន្ទ កវេសីឧបាសក ក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលអានន្ទ កវេសីភិក្ខុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង មិនប្រមាទ ខំប្រឹងដុតបំផ្លាញនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្ត ដែលចេញចាកផ្ទះហើយ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរគុណណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរគុណនោះ ដែលមានព្រហ្មចរិយៈជាទីបំផុតដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងកាលជាបច្ចុប្បន្ន រួចបានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តចប់ហើយ សោឡសកិច្ចដែលត្រូវធ្វើ អាត្មាអញបានធ្វើស្រេចហើយ កិច្ចដទៃក្រៅអំពីមគ្គភាវនាកិច្ចនេះ មិនមានទៀតឡើយ ម្នាលអានន្ទ ឯកវេសីភិក្ខុ ក៏បានជាព្រះអរហន្តមួយអង្គក្នុងពួកព្រះអរហន្តទាំងឡាយដែរ ។ ម្នាលអានន្ទ លំដាប់នោះ ឧបាសកទាំងប្រាំរយនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កវេសីជាម្ចាស់ហ៊ឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យពួកយើងសមាទាន អម្បាលកវេសីជាម្ចាស់ម្តេច គង់កោរសក់និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់នូវសម្ពត់ដែលជ្រលក់ដោយទឹកចត់

អគារស្មា អនគារិយំ បព្វជិស្សតិ កិមង្គំ បន មយន្តិ ។
អថខោ អានន្ទ តានិ បញ្ច ឧបាសកសតានិ យេន
កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ តេនុបសង្កមឹសុ
ឧបសង្កមិត្វា កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ
ឯតទវោចុំ លភេយ្យាម មយំ ភន្តេ ភគវតោ សន្តិកេ
បព្វជ្ជំ លភេយ្យាម ឧបសម្បទន្តិ ។ អលភឹសុ ខោ
អានន្ទ តានិ បញ្ច ឧបាសកសតានិ កស្សបស្ស
ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សន្តិកេ បព្វជ្ជំ
អលភឹសុ ឧបសម្បទំ ។ អថខោ អានន្ទ គវេសិស្ស
ភិក្ខុនោ ឯតទហោសិ អហំ ខោ ឥមស្ស អនុត្តរស្ស
វិមុត្តិសុខស្ស និកាមលាភី អកិច្ឆលាភី អកសិរលាភី
អហោវតិមានិបិ បញ្ច ភិក្ខុសតានិ ឥមស្ស អនុត្ត-
រស្ស វិមុត្តិសុខស្ស និកាមលាភិនោ អស្សុ អកិច្ឆលា-
ភិនោ អកសិរលាភិនោតិ ។ អថខោ អានន្ទ តានិ
បញ្ច ភិក្ខុសតានិ ឯកកា វូបកដ្ឋា អប្បមត្តា
អាតាបិនោ បហិតត្តា វិហរន្តា ន ចិរស្សេវ យស្សត្ថាយ
កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ

រួចចេញចាកផ្ទះ ចូលកាន់ផ្នួសទៅហើយ ចុះពួកយើងចាំអ្វីទៀត ។ ម្នាលអានន្ទ លំដាប់នោះ ឧបាសកទាំងប្រាំរយនោះ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ ក៏បានក្រាបទូលព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គ គួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគដែរ ។ ម្នាលអានន្ទ ឧបាសកទាំងប្រាំរយនោះ ក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគ ព្រះនាមកស្សប៖ អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលអានន្ទ លំដាប់នោះ គវេសីភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រ នូវវិមុត្តិសុខដ៏ប្រសើរបំផុតនេះ ធ្វើម្តេចហ្ន៎ ភិក្ខុទាំងប្រាំរយនេះ គប្បីបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រ នូវវិមុត្តិសុខដ៏ប្រសើរបំផុតនេះផងអេះ ។ ម្នាលអានន្ទ លំដាប់នោះ ភិក្ខុទាំងប្រាំរយនោះ ក៏ចៀសចេញទៅតែម្នាក់ៗ ឯងមិនប្រមាទ ខំប្រឹងដុតបំផ្លាញនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្ត ដែលចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរគុណណា មិនយូរប៉ុន្មាន

តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិំសុ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញិំសុ ។ ឥតិ ខោ អានន្ទ តានិ បញ្ច ភិក្ខុសតានិ គវេសិប្បមុខានិ ឧត្តរុត្តរិំ បណីតប្បណីតំ វាយមមានា អនុត្តរំ វិមុត្តិំ សច្ឆាកំសុ ។ តស្មាតិហ អានន្ទ ឯវំ សិក្ខិតព្វំ ឧត្តរុត្តរិំ បណីតប្បណីតំ វាយមមានា អនុត្តរំ វិមុត្តិំ សច្ឆិករិស្សាមាតិ ។ ឯវំ ហិ វោ អានន្ទ សិក្ខិតព្វន្តិ ។

ឧបាសកវគ្គោ តតិយោ ។

## តស្សុទ្ទានំ

សារជ្ជំ វិសារទោ និរយំ
វេរំ ចណ្ឌាលបញ្ចមំ
បីតិ វណិជ្ជា រាជានោ
គិហី ចេវ គវេសិនាតិ ។

ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរគុណនោះ ដែលមានព្រហ្មចរិយៈជាទីបំផុត ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងកាលជាបច្ចុប្បន្ន រួចបានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តចប់ហើយ សោឡសកិច្ចដែលត្រូវធ្វើ អាត្មាអញបានធ្វើស្រេចហើយ កិច្ចដទៃក្រៅអំពីមគ្គភាវនាកិច្ចនេះ មិនមានទៀតឡើយ ។ ម្នាលអានន្ទ ភិក្ខុទាំងប្រាំរូបនោះមានគវេសីភិក្ខុជាប្រធាន កាលប្រឹងប្រែងឲ្យម៉ត់ចត់លើសលុបឡើងទៅ ក៏បានធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរ ដោយប្រការដូច្នេះឯង ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងសាសនានេះ ពួកអ្នក ត្រូវសិក្សាយ៉ាងនេះថា ពួកយើង កាលប្រឹងប្រែងឲ្យម៉ត់ចត់លើសលុបឡើងទៅ គង់ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរបាន ។ ម្នាលអានន្ទ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះចុះ ។

ចប់ ឧបាសកវគ្គ ទី ៣ ។

## ឧទ្ទាននៃឧបាសកវគ្គនោះគឺ

និយាយអំពីការញញើតញញើម ១ ក្លៀវក្លា ១ ទារក ១
ពៀរ ១ ចណ្ឌាលឧបាសកជាគំរប់ប្រាំ បីតិ ១ ជំនួញ ១
ពួកស្តេច ១ គ្រហស្ថអ្នកស្លៀកស ១ គវេសីឧបាសក ១ ។

# អរញ្ញវគ្គោ

(៨១) បញ្ចិមេ ភិក្ខវេ អារញ្ញកា ។ កតមេ បញ្ច ។ មន្ទត្តា មោមូហត្តា អារញ្ញកោ ហោតិ បាបិច្ឆោ ឥច្ឆាបកតោ អារញ្ញកោ ហោតិ ឧម្មាទា ចិត្តក្ខេបា អារញ្ញកោ ហោតិ វណ្ណិតំ ពុទ្ធេហិ ពុទ្ធសាវកេហីតិ អារញ្ញកោ ហោតិ អប្បិច្ឆតញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ និស្សាយ អារញ្ញកោ ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អារញ្ញកា ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ អារញ្ញកានំ យ្វាយំ អារញ្ញកោ អប្បិច្ឆតញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ និស្សាយ អារញ្ញកោ ហោតិ អយំ ឥមេសំ បញ្ចន្នំ អារញ្ញកានំ អគ្គោ ច សេដ្ឋោ ច មោក្ខោ ច

# អរញ្ញវគ្គ

(៨១) ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកនៅក្នុងព្រៃ (ប្រព្រឹត្តអារញ្ញិកង្គ) នេះមាន ៥ ពួក ។ ភិក្ខុអ្នកនៅក្នុងព្រៃ ៥ ពួក តើដូចម្តេច ។ គឺភិក្ខុអ្នកនៅក្នុងព្រៃ ព្រោះមិនដឹង ព្រោះខ្លៅល្ងង់ ១ នៅក្នុងព្រៃ ព្រោះប្រាថ្នាលាមក លុះក្នុងសេចក្តីប្រាថ្នា ១ នៅក្នុងព្រៃ ព្រោះឆ្កួតកាយមាយចិត្ត ១ នៅក្នុងព្រៃ ព្រោះគិតថា ការនៅក្នុងព្រៃ ព្រះពុទ្ធទាំងឡាយនឹងពួកពុទ្ធសាវកសរសើរហើយ ១ នៅក្នុងព្រៃ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីដុសខាត់ (កិលេស) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅក្នុងព្រៃមាន ៥ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុណាអ្នកនៅក្នុងព្រៃ ដែលជាអ្នកនៅក្នុងព្រៃ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីដុសខាត់ (កិលេស) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុអ្នកនៅក្នុងព្រៃបែបនេះ ឈ្មោះថាខ្ពង់ខ្ពស់ផង ប្រសើរផង ជាចំបងផង

ឧត្តមោ ច បវរោ ច ។ សេយ្យថាបិ ភិក្ខវេ គវា ខីរំ ខីរម្ហា ទធិ ទធិម្ហា នវនីតំ នវនីតម្ហា សប្បិ សប្បិម្ហា សប្បិមណ្ឌោ សប្បិមណ្ឌោ តត្ថ អគ្គមក្ខាយតិ ឯវមេវ ខោ ភិក្ខវេ ឥមេសំ បញ្ចន្នំ អារញ្ញកានំ យ្វាយំ អារញ្ញកោ អប្បិច្ឆតញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ និស្សាយ អារញ្ញកោ ហោតិ អយំ ឥមេសំ បញ្ចន្នំ អារញ្ញកានំ អគ្គោ ច សេដ្ឋោ ច មោក្ខោ ច ឧត្តមោ ច បវរោ ចាតិ ។

(៨២) បញ្ចិមេ ភិក្ខវេ បំសុកូលិកា ។ បេ ។

(៨៣) បញ្ចិមេ ភិក្ខវេ រុក្ខមូលិកា ។ បេ ។

(៨៤) បញ្ចិមេ ភិក្ខវេ សោសានិកា ។ បេ ។

ឧត្តមផង ថ្លៃថ្លាផង ។ ម្នាលភិក្ខុទាំងឡាយ ដូចជាទឹកដោះ កើតមកអំពីមេគោ ទធិកើតមកអំពីទឹកដោះ នវនីតកើតមកអំពីទធិ សប្បិកើតមកអំពីនវនីត សប្បិមណ្ឌកើតមកអំពីសប្បិ សប្បិមណ្ឌប្រាកដថាប្រសើរជាងយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុណាអ្នកនៅក្នុងព្រៃ ដែលជាអ្នកនៅក្នុងព្រៃ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីដុសខាត (កិលេស) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុអ្នកនៅក្នុងព្រៃបែបនេះ ឈ្មោះថាខ្ពង់ខ្ពស់ផង ប្រសើរផង ជាចំបងផង ឧត្តមផង ថ្លៃថ្លាផង ។

(៨២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបំសុកូលិកង្គនេះ មាន ៥ ពួក ។ បេ ។

(៨៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តរុក្ខមូលិកង្គនេះ មាន ៥ ពួក ។ បេ ។

(៨៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តសោសានិកង្គនេះ មាន ៥ ពួក ។ បេ ។

(៨៥) បញ្ចិមេ ភិក្ខវេ អព្ភោកាសិកា ។ បេ ។

(៨៦) បញ្ចិមេ ភិក្ខវេ នេសជ្ជិកា ។ បេ ។

(៨៧) បញ្ចិមេ ភិក្ខវេ យថាសន្ថតិកា ។ បេ ។

(៨៨) បញ្ចិមេ ភិក្ខវេ ឯកាសនិកា ។ បេ ។

(៨៩) បញ្ចិមេ ភិក្ខវេ ខលុបច្ឆាភត្តិកា ។ បេ ។

(៩០) បញ្ចិមេ ភិក្ខវេ បត្តបិណ្ឌិកា ។ កតមេ បញ្ច ។ មន្ទត្តា មោមូហត្តា បត្តបិណ្ឌិកោ ហោតិ បាបិច្ឆោ ឥច្ឆាបកតោ បត្តបិណ្ឌិកោ ហោតិ ឧម្មាទា ចិត្តក្ខេបា បត្តបិណ្ឌិកោ ហោតិ វណ្ណិតំ ពុទ្ធេហិ ពុទ្ធសាវកេហីតិ បត្តបិណ្ឌិកោ ហោតិ

(៨៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តអព្ភោកាសិកង្គនេះ មាន ៥ ពួក ។ បេ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តនេសជ្ជិកង្គនេះ មាន ៥ ពួក ។ បេ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តយថាសន្ថតិកង្គនេះ មាន ៥ ពួក ។ បេ ។

(៨៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តឯកាសនិកង្គនេះ មាន ៥ ពួក ។ បេ ។

(៨៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តខលុប្បច្ឆាភត្តិកង្គនេះ មាន ៥ ពួក ។ បេ ។

(៩០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គនេះ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ៥ ពួក តើដូចម្តេច ។ គឺ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះមិនដឹង ព្រោះខ្លៅល្ងង់ ១ ប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះប្រាថ្នាលាមក លុះក្នុងសេចក្តីប្រាថ្នា ១ ប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះឆ្កួតរាយមាយចិត្ត ១ ប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះគិតថា បត្តបិណ្ឌិកង្គនេះ ព្រះពុទ្ធទាំងឡាយនិងពួកពុទ្ធសាវកសរសើរហើយ ១

អប្បិច្ឆតញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ និស្សាយ បត្តបិណ្ឌិកោ ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច បត្តបិណ្ឌិកា ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ បត្តបិណ្ឌិកានំ យ្វាយំ បត្តបិណ្ឌិកោ អប្បិច្ឆតញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ និស្សាយ បត្តបិណ្ឌិកោ ហោតិ អយំ ឥមេសំ បញ្ចន្នំ បត្តបិណ្ឌិកានំ អគ្គោ ច សេដ្ឋោ ច មោក្ខោ ច ឧត្តមោ ច បវរោ ច ។ សេយ្យថាបិ ភិក្ខវេ គវា ខីរំ ខីរម្ហា ទធិ ទធិម្ហា នវនីតំ នវនីតម្ហា សប្បិ សប្បិម្ហា សប្បិមណ្ឌោ សប្បិមណ្ឌោ តត្ថ អគ្គមក្ខាយតិ ឯវមេវ ខោ ភិក្ខវេ ឥមេសំ បញ្ចន្នំ បត្តបិណ្ឌិកានំ

ប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីដុសខាត់ (កិលេស) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ មាន ៥ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គទាំង ៥ ពួកនេះ ភិក្ខុណាអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ជាអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីដុសខាត់ (កិលេស) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ បណ្តាភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គទាំង ៥ ពួកនេះ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គបែបនេះឈ្មោះថាខ្ពង់ខ្ពស់ផង ប្រសើរផង ចំបងផង ឧត្តមផង ថ្លៃថ្លាផង ។ ម្នាលភិក្ខុទាំងឡាយ ដូចជាទឹះកើតអំពីមេគោ ទធិកើតអំពីទឹះ នវនីតកើតអំពីទធិ សប្បិកើតអំពីនវនីត សប្បិមណ្ឌកើតអំពីសប្បិ សប្បិមណ្ឌប្រាកដថាប្រសើរលើសជាងយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គទាំង ៥ ពួកនេះ

យ្វាយំ បត្តបិណ្ឌិកោ អប្បិច្ឆតញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ និស្សាយ បត្តបិណ្ឌិកោ ហោតិ អយំ ឥមេសំ បញ្ចន្នំ បត្តបិណ្ឌិកានំ អគ្គោ ច សេដ្ឋោ ច មោក្ខោ ច ឧត្តមោ ច បវរោ ចាតិ ។

អរញ្ញវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

អរញ្ញំ ចីវរំ រុក្ខ-
សុសានំ អព្ភោកាសិកំ
នេសជ្ជំ សន្ថតំ ឯកំ
ខលុបច្ឆា បិណ្ឌិកេន ចាតិ ។

ភិក្ខុណាអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ជាអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីផុសខាត់ (កិលេស) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ បណ្តាភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គទាំង៥ពួកនេះ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ បែបនេះឈ្មោះថាខ្ពង់ខ្ពស់ផង ប្រសើរផង ជាប្រធានផង ឧត្តមផង ថ្លៃថ្លាផង ។

ចប់ អរញ្ញវគ្គ ទី ៤ ។

## ឧទ្ទាននៃអរញ្ញវគ្គនោះគឺ

និយាយអំពីភិក្ខុអ្នកប្រព្រឹត្តអារញ្ញិកង្គ ១ ប្រព្រឹត្តបំសុកូលិកង្គ ១ ប្រព្រឹត្តរុក្ខមូលិកង្គ ១ ប្រព្រឹត្តសោសានិកង្គ ១ ប្រព្រឹត្តអព្ភោកាសិកង្គ ១ ប្រព្រឹត្តនេសជ្ជិកង្គ ១ ប្រព្រឹត្តយថាសន្ថតិកង្គ ១ ប្រព្រឹត្តឯកាសនិកង្គ ១ ប្រព្រឹត្តខលុបច្ឆាភត្តិកង្គ ១ ប្រព្រឹត្តបត្តបិណ្ឌិកង្គ ១ ។

# ព្រាហ្មណវគ្គោ

(៩១) បញ្ចិមេ ភិក្ខវេ បោរាណា ព្រាហ្មណធម្មា ឯតរហិ សុនខេសុ សន្ទិស្សន្តិ នោ ព្រាហ្មណេសុ ។ កតមេ បញ្ច បុព្វេ សុទំ ភិក្ខវេ ព្រាហ្មណា ព្រាហ្មណឹ គច្ឆន្តិ នោ អព្រាហ្មណឹ ។ ឯតរហិ ភិក្ខវេ ព្រាហ្មណា ព្រាហ្មណិម្បិ គច្ឆន្តិ អព្រាហ្មណិម្បិ គច្ឆន្តិ ។ ឯតរហិ ភិក្ខវេ សុនខា សុនខិញ្ញេវ គច្ឆន្តិ នោ អសុនខឹ អយំ ភិក្ខវេ បឋមោ បោរាណោ ព្រាហ្មណធម្មោ ឯតរហិ សុនខេសុ សន្ទិស្សតិ នោ ព្រាហ្មណេសុ ។ បុព្វេ សុទំ ភិក្ខវេ ព្រាហ្មណា ព្រាហ្មណឹ ឧតុនិញ្ញេវ គច្ឆន្តិ នោ អនុតុនឹ ឯតរហិ ភិក្ខវេ ព្រាហ្មណា ព្រាហ្មណឹ ឧតុនិម្បិ គច្ឆន្តិ អនុតុនិម្បិ គច្ឆន្តិ ។ ឯតរហិ ភិក្ខវេ សុនខា សុនខឹ ឧតុនិញ្ញេវ គច្ឆន្តិ នោ អនុតុនឹ

# ព្រាហ្មណវគ្គ

(៩១) ម្នាលភិក្ខុទាំងឡាយ ទំនៀមរបស់ពួកព្រាហ្មណ៍អំពីបុរាណ នេះមាន ៥ យ៉ាង រមែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ ឥឡូវនេះទេ ។ ទំនៀមរបស់ព្រាហ្មណ៍ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បានឮមក ក្នុងកាលពីដើម ពួកព្រាហ្មណ៍តែងគប់រកនាងព្រាហ្មណី មិនគប់រកស្រីមិនមែនជាព្រាហ្មណីទេ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍គប់រកស្រីជាព្រាហ្មណីខ្លះ គប់រកស្រីមិនមែនជាព្រាហ្មណីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកសុនខ រមែងគប់រកតែសុនខញី មិនគប់រកជាតិសត្វ មិនមែនជាសុនខញីឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាទំនៀមរបស់ពួកព្រាហ្មណ៍ អំពីបុរាណទី ១ តែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ ឥឡូវនេះទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើម ពួកព្រាហ្មណ៍ រមែងគប់រកព្រាហ្មណី ដែលមានរដូវ មិនគប់រកព្រាហ្មណី ដែលមិនមានរដូវទេ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍តែងគប់រកព្រាហ្មណី ដែលមានរដូវខ្លះ គប់រកព្រាហ្មណី ដែលមិនមានរដូវខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកសុនខ រមែងគប់រកសុនខញី ដែលមានរដូវ មិនគប់រកសុនខញី ដែលមិនមានរដូវទេ

អយំ ភិក្ខវេ ទុតិយោ បោរាណោ ព្រាហ្មណធម្មោ ឯតរហិ សុនខេសុ សន្ទិស្សតិ នោ ព្រាហ្មណេសុ ។ បុព្វេ សុទំ ភិក្ខវេ ព្រាហ្មណា ព្រាហ្មណឹ នេវ កីណន្តិ នោ វិក្កីណន្តិ សម្បិយេនេវ សំវាសំ សម្ពន្ធាយ[១] សម្បវត្តេន្តិ ។ ឯតរហិ ភិក្ខវេ ព្រាហ្មណា ព្រាហ្មណឹ កីណន្តិបិ វិក្កីណន្តិបិ សម្បិយេនេវ សំវាសំ សម្ពន្ធាយ សម្បវត្តេន្តិ ឯតរហិ ភិក្ខវេ សុនខា សុនខឹ នេវ កីណន្តិ នោ វិក្កីណន្តិ សម្បិយេនេវ សំវាសំ សម្ពន្ធាយ សម្បវត្តេន្តិ អយំ ភិក្ខវេ តតិយោ បោរាណោ ព្រាហ្មណធម្មោ ឯតរហិ សុនខេសុ សន្ទិស្សតិ នោ ព្រាហ្មណេសុ ។ បុព្វេ សុទំ ភិក្ខវេ ព្រាហ្មណា ន សន្និធឹ ករោន្តិ ធនស្សបិ ធញ្ញស្សបិ រជតស្សបិ ជាតរូបស្សបិ ឯតរហិ ភិក្ខវេ ព្រាហ្មណា សន្និធឹ ករោន្តិ ធនស្សបិ ធញ្ញស្សបិ រជតស្សបិ ជាតរូបស្សបិ ឯតរហិ ភិក្ខវេ សុនខា ន សន្និធឹ ករោន្តិ

១ ឱ. សំសគ្គត្ថាយ ។

ម្នាលភិក្ខុទាំងឡាយ នេះជាទំនៀមរបស់ព្រាហ្មណ៍ អំពីបុរាណទី ២ ដែលប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ ក្នុងកាលឥឡូវនេះទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើម ពួកព្រាហ្មណ៍ មិនបានទិញ មិនបានលក់នូវនាងព្រាហ្មណីទេ គ្រាន់តែប្រព្រឹត្តទៅ ដើម្បីផ្សំផ្គុំនូវសំវាស តាមសេចក្តីស្រឡាញ់ ទឹងមិនស្រឡាញ់ប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកព្រាហ្មណ៍ ទិញខ្លះ លក់ខ្លះ នូវនាងព្រាហ្មណី ប្រព្រឹត្តទៅ ដើម្បីផ្សំផ្គុំនូវសំវាស តាមសេចក្តីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកសុនខ នៅតែមិនបានទិញ មិនបានលក់នូវសុនខញីដែរ គ្រាន់តែប្រព្រឹត្តទៅ ដើម្បីរួមនូវសំវាស តាមសេចក្តីស្រឡាញ់ប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយ នេះជាទំនៀមរបស់ព្រាហ្មណ៍ អំពីបុរាណទី ៣ ដែលប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើមមក ពួកព្រាហ្មណ៍ មិនបានធ្វើនូវការសន្សំទុកដាក់នូវទ្រព្យខ្លះ ស្រូវខ្លះ ប្រាក់ខ្លះ មាសខ្លះទេ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍ធ្វើនូវការសន្សំទុកដាក់នូវទ្រព្យខ្លះ ស្រូវខ្លះ ប្រាក់ខ្លះ មាសខ្លះ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកសុនខ មិនធ្វើនូវការសន្សំទុកដាក់

ធនស្សបិ ធញ្ញស្សបិ រជតស្សបិ ជាតរូបស្សបិ អយំ ភិក្ខវេ ចតុត្ថោ បោរាណោ ព្រាហ្មណធម្មោ ឯតរហិ សុនខេសុ សន្ទិស្សតិ នោ ព្រាហ្មណេសុ ។ បុព្វេ សុទំ ភិក្ខវេ ព្រាហ្មណា សាយំ សាយមាសាយ បាតោ បាតរាសាយ ភិក្ខំ បរិយេសន្តិ ។ ឯតរហិ ភិក្ខវេ ព្រាហ្មណា យាវទត្ថំ ឧទរាវទេហកំ ភុញ្ជិត្វា អវសេសំ អាទាយ បក្កមន្តិ ។ ឯតរហិ ភិក្ខវេ សុនខា សាយំ សាយមាសាយ បាតោ បាតរាសាយ ភិក្ខំ បរិយេសន្តិ អយំ ភិក្ខវេ បញ្ចមោ បោរាណោ ព្រាហ្មណធម្មោ ឯតរហិ សុនខេសុ សន្ទិស្សតិ នោ ព្រាហ្មណេសុ ។ ឥមេ ខោ ភិក្ខវេ បញ្ច បោរាណា ព្រាហ្មណធម្មា ឯតរហិ សុនខេសុ សន្ទិស្សន្តិ នោ ព្រាហ្មណេសូតិ ។

នូវទ្រព្យខ្លះ ស្រូវខ្លះ ប្រាក់ខ្លះ មាសខ្លះផង ម្នាលភិក្ខុទាំងឡាយ នេះជាទំនៀមរបស់ព្រាហ្មណ៍ពីបុរាណទី ៤ តែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ ក្នុងកាលឥឡូវនេះទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើម ពួកព្រាហ្មណ៍តែងស្វែងរកនូវភិក្ខា ក្នុងពេលល្ងាច តាមពេលល្ងាច ក្នុងពេលព្រឹក តាមពេលព្រឹក ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍ បរិភោគ (អាហារ) បំពេញពោះដរាបដល់ឆ្អែត ហើយកាន់យកអាហារដ៏សេសសល់ ចៀសចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកសុនខ ក៏ស្វែងរក (អាហារ) ក្នុងពេលល្ងាច តាមពេលល្ងាច ក្នុងពេលព្រឹក តាមពេលព្រឹក ម្នាលភិក្ខុទាំងឡាយ នេះជាទំនៀមរបស់ព្រាហ្មណ៍ ពីបុរាណទី ៥ រមែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ ក្នុងកាលឥឡូវនេះទេ ។ ម្នាលភិក្ខុទាំងឡាយ ទំនៀមរបស់ព្រាហ្មណ៍ពីបុរាណទាំង ៥ យ៉ាងនេះឯង រមែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ ក្នុងកាលឥឡូវនេះទេ ។

(៩២) អថខោ ទោណោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ទោណោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សុតមេតំ ភោ គោតម ន សមណោ គោតមោ ព្រាហ្មណេ ជិណ្ណេ វុឌ្ឍេ មហល្លកេ អទ្ធគតេ វយោអនុប្បត្តេ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតីតិ ។ តយិទំ ភោ គោតម តថេវ ន ហិ ភវំ គោតមោ ព្រាហ្មណេ ជិណ្ណេ វុឌ្ឍេ មហល្លកេ អទ្ធគតេ វយោ-អនុប្បត្តេ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតិ ។ តយិទំ ភោ គោតម ន សម្បន្នមេវាតិ ។ ត្វំបិ នោ ទោណ ព្រាហ្មណោ បដិជានាសីតិ ។ យំ ហិ តំ ភោ គោតម សម្មា វទមានោ វទេយ្យ

(៩២) គ្រានោះឯង ទោណព្រាហ្មណ៍ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះទោណព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គបានឮថា ព្រះសមណគោតម មិនសម្ពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុដល់ចូលមកក្នុងបច្ឆិមវ័យហើយ មិនអញ្ជើញដោយអាសនៈ ។ បពិត្រព្រះគោតមដ៏ចំរើន ពាក្យដែលខ្ញុំបានឮមកនោះជាប្រាកដជា ព្រះគោតមដ៏ចំរើន មិនសម្ពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើនរស់នៅបានយូរឆ្នាំមកហើយ មានអាយុដល់ចូលមកក្នុងបច្ឆិមវ័យហើយ មិនអញ្ជើញដោយអាសនៈ ។ បពិត្រព្រះគោតមដ៏ចំរើន កិច្ចមានការមិនសម្ពះជាដើមនោះ ជាទំនងពុំសមគួរឡើយ ។ ម្នាលទោណៈ អ្នកមិនប្តេជ្ញាថាជាព្រាហ្មណ៍ទេឬ ។ បពិត្រព្រះគោតមដ៏ចំរើន បុគ្គលកាលនឹងពោលនូវរឿងនោះឲ្យត្រូវ គួរពោលថា

ព្រាហ្មណោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អជ្ឈាយិកោ (១) មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោតិ មមេវ តំ ភោ គោតម សម្មា វទមានោ វទេយ្យ ។ អហំ ហិ ភោ គោតម ព្រាហ្មណោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អជ្ឈាយិកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោតិ ។

---

១ ឱ. ម. អជ្ឈាយកោ ។

ព្រាហ្មណ៍អ្នកមានកំណើតស្អាតទាំងពីរខាង គឺខាងមាតានិងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណរនៃដូនជីតាជាគំរប់ ៧ មិនមានអ្នកណារិះគន់តិះដៀល ដោយពោលដល់ជាតិកំណើតបាន ជាអ្នកពាយមន្ត ចេះចាំមន្ត ចេះចប់ត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុនិងគម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទគឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកដឹងនូវបទនិងវេយ្យាករណ៍ ជាអ្នកមិនថោកថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រនិងមហាបុរិសលក្ខណពយាករណសាស្ត្រ បពិត្រព្រះគោតមដ៏ចំរើន បុគ្គលកាលនឹងពោលនូវរឿងនោះឲ្យត្រូវ គប្បីពោលនូវខ្ញុំព្រះអង្គហ្នឹងឯង ។ បពិត្រព្រះគោតមដ៏ចំរើន ព្រោះថាខ្ញុំព្រះអង្គជាព្រាហ្មណ៍មានកំណើតស្អាតទាំងពីរខាង គឺខាងមាតានិងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណរនៃដូនជីតាជាគំរប់ ៧ មិនមានអ្នកណារិះគន់តិះដៀល ដោយពោលដល់ជាតិកំណើតបាន ជាអ្នកពាយមន្ត ចេះចាំមន្ត ចេះចប់ត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុនិងគម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទៈ គឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកដឹងនូវបទនិងវេយ្យាករណ៍ ជាអ្នកមិនថោកថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណពយាករណសាស្ត្រ ។

យេ ខោ តេ ទោណ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ ព្រាហ្មណា ពោរាណំ មន្តបទំ គីតំ បវុត្តំ សមិហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ វាមទេវោ វេស្សាមិត្តោ យមតគ្គិ អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ ត្យាស្សុមេ បញ្ច ព្រាហ្មណេ បញ្ញាបេន្តិ ព្រហ្មសមំ ទេវសមំ មរិយាទំ សម្ភិន្នមរិយាទំ ព្រាហ្មណចណ្ឌាលញ្ញេវ បញ្ចមំ ។ តេសំ ត្វំ ទោណ កតមោតិ ។ ន ខោ មយំ ភោ គោតម ឥមេ បញ្ច ព្រាហ្មណេ ជានាម អថខោ មយំ ព្រាហ្មណាត្វេវ ជានាម សាធុ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុ យថា អហំ ឥមេ បញ្ច ព្រាហ្មណេ ជានេយ្យន្តិ ។

ម្នាលទោណៈ ពួកឥសីទាំងអម្បាលមាណ ជាប្រធានរបស់ព្រាហ្មណ៍ទាំងឡាយ អ្នកធ្វើនូវមន្តទាំងឡាយ នឹងញុំាងមន្តទាំងឡាយ ឲ្យប្រព្រឹត្តទៅបាន ក៏បទមន្តនឹងចម្រៀងចាស់នេះ ដែលពួកឥសីបានពោលធ្វើឲ្យជាគំនរដល់ព្រាហ្មណ៍ទាំងឡាយណា ពួកព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ រមែងច្រៀងតាម ពោលតាមនូវបទមន្តនឹងចម្រៀងនោះ តែងពោលតាមបទមន្តដែលពួកឥសីពោលហើយនោះ បង្ហាញតាមបទមន្តនឹងចំរៀង ដែលពួកឥសីបង្ហាញហើយ ឥសីទាំងនោះ គឺឥសីឈ្មោះ អដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្ត ១ យមទគ្គិ ១ អង្គីរស ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ ឥសីទាំងនោះ តែងនាំគ្នាបញ្ញត្តនូវព្រាហ្មណ៍ទាំង ៥ នេះ គឺព្រហ្មសមៈ ១ ទេវសមៈ ១ មរិយាទៈ ១ សម្ភិន្នមរិយាទៈ ១ នឹងព្រាហ្មណ៍ចណ្ឌាល ជាគំរប់ ៥ ។ ម្នាលទោណៈ អ្នកជាព្រាហ្មណ៍អ្វី ក្នុងពួកព្រាហ្មណ៍ទាំង ៥ នោះ ។ បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គមិនស្គាល់ព្រាហ្មណ៍ទាំង៥នេះទេ ខ្ញុំព្រះអង្គគ្រាន់តែស្គាល់ថាជាព្រាហ្មណ៍ប៉ុណ្ណោះ ឯង ប្រពៃណាស់ហើយ ព្រះគោតមដ៏ចំរើន សូមព្រះគោតមដ៏ចំរើន សំដែងធម៌ឲ្យខ្ញុំព្រះអង្គ ស្គាល់ព្រាហ្មណ៍ទាំង ៥ នេះឲ្យបាន ។

ទេនហិ ទោណ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ឯវំ ភោតិ ខោ ទោណោ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច កថញ្ច ទោណ ព្រាហ្មណោ ព្រហ្មសមោ ហោតិ ។ ឥធ ទោណ ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន សោ អដ្ឋចត្តារីសវស្សានិ កោមារំ ព្រហ្មចរិយំ ចរតិ មន្តេ អធីយមានោ អដ្ឋចត្តារី-សវស្សានិ កោមារំ ព្រហ្មចរិយំ ចរិត្វា មន្តេ អធីយិត្វា អាចរិយស្ស អាចរិយធនំ បរិយេសតិ ធម្មេនេវ នោ អធម្មេន ។ តត្ថ ច ទោណ កោ ធម្មោ ។

ម្នាលទោណៈ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ទោណព្រាហ្មណ៍ ក៏ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ដូច្នេះឯង ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលទោណៈ ព្រាហ្មណ៍ឈ្មោះព្រហ្មសមៈ តើដូចម្តេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកមានកំណើតស្អាតទាំងពីរខាង គឺខាងមាតានឹងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីកំណើតនៃជីដូនជីតាជាគំរប់ ៧ មិនមានអ្នកណារិះគន់តិះដៀល ដោយពោលដល់ជាតិកំណើតបាន ព្រាហ្មណ៍នោះតែងរៀនយកនូវមន្ត ប្រព្រឹត្តកោមារ.(១) ព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ លុះរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំរួចហើយ ក៏ស្វែងរកនូវទ្រព្យសម្រាប់អាចារ្យ ដើម្បីអាចារ្យ ដោយធម៌ មិនស្វែងរកខុសធម៌ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្តេច ក្នុងការស្វែងរកនោះ ។

---

១ ក្នុងត្រកូលណា មាននាងទារិកាពេញរូបរាងហើយ ព្រាហ្មណ៍នោះឯង ក៏ទៅឈរទៀបផ្ទះត្រកូលនោះ កាលបើត្រកូលនោះសួរថា ហេតុអ្វីបានជាអ្នកមកឈរ ក្នុងទីនេះ ក៏ប្រាប់គេថា ខ្ញុំប្រព្រឹត្តកោមារព្រហ្មចរិយធម៌អស់ ៤៨ ឆ្នាំហើយ ឥឡូវខ្ញុំប្រគល់ព្រហ្មចរិយៈទាំងអស់នោះឲ្យទៅអ្នករាល់គ្នា អ្នកទាំងឡាយ គួរឲ្យនាងទារិកាមកខ្ញុំ ជនទាំងនោះក៏ព្រមសុខចិត្តផ្សំផ្គុំឲ្យជាភរិយានឹងគ្នាតទៅ ។ អដ្ឋកថា ។

នេវ កសិយា ន វណិជ្ជាយ ន គោរក្ខេន ន ឥស្សត្ថេន ន រាជបោរិសេន ន សិប្បញ្ញតរេន កេវលំ ភិក្ខាចរិយាយ កបាលំ អនតិមញ្ញមានោ ។ សោ អាចរិយស្ស អាចរិយធនំ និយ្យាទេត្វា កេស-មស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ។ សោ ឯវំ បព្វជិតោ សមានោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុ-លេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ករុណាសហគតេន ចេតសា... មុទិតា-សហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ

គឺព្រាហ្មណ៍នោះ មិនបានស្វែងរកដោយការភ្ជួរ មិនបានស្វែងរកដោយការជួញ មិនបានស្វែងរកដោយការរក្សាគោ មិនបានស្វែងរកដោយអំពើនៃបានៈជាទាហាន មិនបានស្វែងរកដោយភាពជារាជ-បុរស មិនបានស្វែងរកដោយសិប្បកម្មណានីមួយឡើយ គ្រាន់តែស្វែងរកដោយការត្រេចទៅ ដើម្បីភិក្ខាប៉ុណ្ណោះ មិនបានមើលងាយនូវភិក្ខាភាជនៈឡើយ ៗ ព្រាហ្មណ៍នោះ ប្រគល់ទ្រព្យសម្រាប់អាចារ្យដល់អាចារ្យ ហើយកោរសក់នឹងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈចេញចាកផ្ទះមកបួស ៗ ព្រាហ្មណ៍នោះ កាលដែលបានបួសយ៉ាងនេះហើយ ជាអ្នកមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច ៗ មានចិត្តប្រកបដោយមេត្តា ចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង មានចិត្តប្រកបដោយករុណា ... មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣

តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ ឥមេ ចត្តារោ ព្រហ្មវិហារេ ភាវេត្វា កាយស្ស ភេទា បរម្មរណា សុគតឹ ព្រហ្មលោកំ ឧបបជ្ជតិ ឯវំ ខោ ទោណ ព្រាហ្មណោ ព្រហ្មសមោ ហោតិ ។

កថញ្ច ទោណ ព្រាហ្មណោ ទេវសមោ ហោតិ ។ ឥធ ទោណ ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហាណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន សោ អដ្ឋចត្តាឡីសវស្សានិ កោមារំ ព្រហ្មចរិយំ ចរតិ មន្តេ អធីយមានោ អដ្ឋចត្តាឡីសវស្សានិ កោមារំ ព្រហ្មចរិយំ ចរិត្វា មន្តេ អធីយិត្វា អាចរិយស្ស អាចរិយធនំ បរិយេសតិ ធម្មេនេវ នោ អធម្មេន ។ តត្ថ ច ទោណ កោ ធម្មោ ។

ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច ៗ មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ។ ព្រាហ្មណ៍នោះ លុះបានចំរើននូវព្រហ្មវិហារទាំង ៤ នេះហើយ ក៏ទំលាយកាយ ស្លាប់ទៅ ទៅកើតក្នុងសុគតិទីឯព្រហ្មលោក ម្នាលទោណៈ ព្រាហ្មណ៍ជាព្រហ្មសមៈយ៉ាងនេះឯង ។ ម្នាលទោណៈ ចុះព្រាហ្មណ៍ជាទេវសមៈនោះ តើដូចម្ដេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកមានកំណើតល្អតាំងពីរខាង គឺខាងមាតានិងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណនៃដូនជីតាជាគំរប់ ៧ មិនមានអ្នកណារិះគន់ តិះដៀល ដោយពោលដល់ជាតិកំណើតបាន ព្រាហ្មណ៍នោះ ក៏រៀនយកនូវមន្ត ប្រព្រឹត្តនូវកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ លុះរៀនយកនូវមន្តប្រព្រឹត្តនូវកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំរួចហើយ ទើបស្វែងរកទ្រព្យសម្រាប់អាចារ្យ ដើម្បីអាចារ្យ ដោយគន្លងធម៌ មិនស្វែងរកខុសគន្លងធម៌ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្ដេច ក្នុងការស្វែងរកនោះ ។

នេវ កសិយា ន វណិជ្ជាយ ន គោរក្ខេន ន ឥស្សត្ថេន ន រាជបោរិសេន ន សិប្បញ្ញតរេន កេវលំ ភិក្ខាចរិយាយ កបាលំ អនតិមញ្ញមានោ ។ សោ អាចរិយស្ស អាចរិយធនំ និយ្យាតេត្វា ទារំ បរិយេសតិ ធម្មេនេវ នោ អធម្មេន ។ តត្ថ ច ទោណ កោ ធម្មោ ។ នេវ កយេន ន វិក្កយេន ព្រាហ្មណិយេវ ឧទកុបសដ្ឋំ សោ ព្រាហ្មណិយេវ គច្ឆតិ ន ខត្តិយឹ ន វេស្សឹ ន សុទ្ទឹ ន ចណ្ឌាលឹ ន នេសាទឹ ន វេណឹ ន រថការឹ ន បុក្កុសឹ គច្ឆតិ ន គព្ភិនឹ គច្ឆតិ ន បាយមានំ គច្ឆតិ ន អនុតុនឹ គច្ឆតិ ។

គឺព្រាហ្មណ៍នោះ មិនបានស្វែងរកដោយការភ្ជួរ មិនបានស្វែងរកដោយការជួញ មិនបានស្វែងរកដោយការរក្សាគោ មិនបានស្វែងរកដោយអំពើនៃឋានៈជាទាហាន មិនបានស្វែងរកដោយភាពជារាជ-បុរស មិនបានស្វែងរកដោយសិប្បកម្មណាទីមួយឡើយ គ្រាន់តែស្វែងរកដោយការត្រេចទៅដើម្បីភិក្ខាប៉ុណ្ណោះ មិនបានមើលងាយនូវភិក្ខាភាជនៈឡើយ ។ ព្រាហ្មណ៍នោះ ប្រគល់ទ្រព្យសម្រាប់អាចារ្យដល់អាចារ្យ ហើយក៏ស្វែងរកភរិយាដោយធម៌ មិនស្វែងរកខុសធម៌ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្តេច ក្នុងការស្វែងរកនោះ ។ គឺព្រាហ្មណ៍នោះ មិនបានស្វែងរកដោយការទិញ មិនបានស្វែងរកដោយការលក់ដូរ ស្វែងរកតែព្រាហ្មណីដែលគេបរិច្ចាគដោយប្រោះទឹកឲ្យ ព្រាហ្មណ៍នោះ រមែងគប់រកនាងព្រាហ្មណីផងគ្នា មិនគប់រកស្ត្រីក្សត្រិយ៍ មិនគប់រកស្ត្រីវេស្សៈ គឺស្ត្រីអ្នកជួញប្តូរធ្វើស្រែចំការ មិនគប់រកស្ត្រីសុទ្រៈ គឺស្ត្រីធ្វើគូលីស៊ីឈ្នួលគេ មិនគប់រកស្ត្រីចណ្ឌាល មិនគប់រកស្ត្រីនេសាទ មិនគប់រកស្ត្រីដែលមានក្នង់សក់ (សក់ដុក) មិនគប់រកស្ត្រីជាងរថ មិនគប់រកស្ត្រីអ្នកបោសសម្រាម មិនគប់រកស្ត្រីដែលមានគភ៌ មិនគប់រកស្ត្រីដែលមានកូននៅបៅ មិនគប់រកស្ត្រីដែលមិនមានរដូវ ។

កស្មា ច ទោណ ព្រាហ្មណោ ន គត្តឹ គច្ឆតិ ។ សចេ ទោណ ព្រាហ្មណោ គត្តឹ គច្ឆតិ អតិមិច្ឆាជោ នាម សោ ហោតិ មាណវកោ វា មាណវិកា វា តស្មា ទោណ ព្រាហ្មណោ ន គត្តឹ គច្ឆតិ ។ កស្មា ច ទោណ ព្រាហ្មណោ ន ទាយមានំ គច្ឆតិ ។ សចេ ទោណ ព្រាហ្មណោ ទាយមានំ គច្ឆតិ អសុចិប្បដីតោ នាម សោ ហោតិ មាណវកោ វា មាណវិកា វា តស្មា ទោណ ព្រាហ្មណោ ន ទាយមានំ គច្ឆតិ ។ តស្ស សា ហោតិ ព្រាហ្មណី នេវ កាមត្ថា ន ទវត្ថា ន រតត្ថា បជត្ថាវ ព្រាហ្មណស្ស ព្រាហ្មណី ហោតិ សោ មេថុនំ ឧប្បាទេត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ។ សោ ឯវំ បព្វជិតោ សមានោ វិវិច្ចេវ កាមេហិ ។ បេ ។

ម្នាលទោណៈ ចុះហេតុអ្វី បានជាព្រាហ្មណ៍ មិនគប់រកស្ត្រីដែលមានគភ៌ ។ ម្នាលទោណៈ ប្រសិនបើព្រាហ្មណ៍ គប់រកស្ត្រីដែលមានគភ៌ហើយ មាណវកៈនឹងមាណវិកានោះ ឈ្មោះថា កើតក្នុងគំនរលាមកធំ មានក្លិនអាក្រក់ក្រៃពេក ម្នាលទោណៈ ព្រោះហេតុនោះ បានជាព្រាហ្មណ៍ មិនគប់រកស្ត្រីដែលមានគភ៌ឡើយ ។ ម្នាលទោណៈ ចុះហេតុអ្វី បានជាព្រាហ្មណ៍ មិនគប់រកស្ត្រីដែលមានកូននៅបៅ ។ ម្នាលទោណៈ ប្រសិនបើព្រាហ្មណ៍ គប់រកស្ត្រីដែលមានកូននៅបៅហើយ មាណវកៈនឹងមាណវិកានោះ ឈ្មោះថា ផឹករបស់មិនស្អាត ម្នាលទោណៈ ព្រោះហេតុនោះ បានជាព្រាហ្មណ៍ មិនគប់រកស្ត្រីដែលមានកូននៅបៅ ។ ឯនាងព្រាហ្មណីរបស់ព្រាហ្មណ៍នោះ មិនមានប្រយោជន៍ដោយកាម មិនមានប្រយោជន៍ដោយការលេង មិនមានប្រយោជន៍ដោយសេចក្តីត្រេកអរក្នុងកាម នាងព្រាហ្មណីរបស់ព្រាហ្មណ៍នោះ មានប្រយោជន៍ដោយបុត្រប៉ុណ្ណោះ ព្រាហ្មណ៍នោះញុំាងមេថុនឲ្យកើតឡើង ហើយកោរសក់នឹងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះមកបួស ។ ព្រាហ្មណ៍នោះ កាលដែលបានបួសយ៉ាងនេះហើយ ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។

ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមេ ចត្តារោ ឈានេ ភាវេត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ឯវំ ខោ ទោណ ព្រាហ្មណោ ទេវសមោ ហោតិ ។ កថញ្ច ទោណ ព្រាហ្មណោ មរិយាទោ ហោតិ ។ ឥធ ទោណ ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ។ សោ អដ្ឋចត្តាឡីសវស្សានិ កោមារំ ព្រហ្មចរិយំ ចរតិ មន្តេ អធីយមានោ អដ្ឋចត្តាឡីសវស្សានិ កោមារំ ព្រហ្មចរិយំ ចរិត្វា មន្តេ អធីយិត្វា អាចរិយស្ស អាចរិយធនំ បរិយេសតិ ធម្មេនេវ នោ អធម្មេន ។ តត្ថ ច ទោណ កោ ធម្មោ ។ នេវ កសិយា ន វណិជ្ជាយ ន គោរក្ខេន ន ឥស្សត្ថេន ន រាជបោរិសេន ន សិប្បញ្ញតរេន កេវលំ ភិក្ខាចរិយាយ កបាលំ អនតិមញ្ញមានោ ។

ដល់នូវចតុត្ថជ្ឈាន ។ ព្រាហ្មណ៍នោះ រមែងចំរើននូវឈានទាំង ៤ នេះ លុះទំលាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ម្នាលទោណៈ ព្រាហ្មណ៍ ជាទេវសមៈយ៉ាងនេះឯង ។ ម្នាលទោណៈ ចុះព្រាហ្មណ៍ ជាមរិយាទៈ តើដូចម្តេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកមានកំណើតស្អាតទាំងពីរខាង គឺខាងមាតានឹងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណរនៃដីដូនដីតាជាគំរប់ ៧ មិនមានអ្នកណារិះគន់ តិះដៀលដោយពោលដល់ជាតិកំណើតបាន ។ ព្រាហ្មណ៍នោះ ក៏រៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ លុះរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ រួចហើយ ក៏ស្វែងរកទ្រព្យសម្រាប់អាចារ្យ ដើម្បីអាចារ្យ ដោយធម៌ មិនស្វែងរកខុសធម៌ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្តេច ក្នុងការស្វែងរកនោះ ។ គឺព្រាហ្មណ៍នោះ មិនបានស្វែងរក ដោយការភ្ជួរ មិនបានស្វែងរក ដោយការជួញ មិនបានស្វែងរក ដោយការរក្សាគោ មិនបានស្វែងរក ដោយអំពើនៃឋានៈជាទាហាន មិនបានស្វែងរក ដោយការៈជារាជបុរស មិនបានស្វែងរក ដោយសិប្បកម្មណានីមួយ ហើយស្វែងរកដោយការត្រេចទៅ ដើម្បីភិក្ខាតែប៉ុណ្ណោះ មិនបានមើលងាយនូវភិក្ខាភាជនៈឡើយ ។

សោ អាចរិយស្ស អាចរិយធនំ និយ្យាទេត្វា ទារំ
បរិយេសតិ ធម្មេនេវ នោ អធម្មេន ។ តត្ថ ច
ទោណ កោ ធម្មោ ។ នេវ កយេន ន វិក្កយេន
ព្រាហ្មណឹយេវ ឧទកុបសដ្ឋំ សោ ព្រាហ្មណឹយេវ
គច្ឆតិ ន ខត្តិយឹ ន វេស្សឹ ន សុទ្ទឹ ន ចណ្ឌាលឹ
ន នេសាទឹ ន វេណឹ ន រថការឹ ន បុក្កុសឹ
គច្ឆតិ ន គព្ភិនឹ គច្ឆតិ ន បាយមានំ គច្ឆតិ
ន អនុតុនឹ គច្ឆតិ ។ កស្មា ច ទោណ
ព្រាហ្មណោ ន គព្ភិនឹ គច្ឆតិ ។ សចេ ទោណ
ព្រាហ្មណោ គព្ភិនឹ គច្ឆតិ អតិមីឡ្ហជោ នាម សោ
ហោតិ មាណវកោ វា មាណវិកា វា ។ តស្មា
ទោណ ព្រាហ្មណោ នេវ គព្ភិនឹ គច្ឆតិ ។

ព្រាហ្មណ៍នោះ ប្រគល់ទ្រព្យសម្រាប់អាចារ្យ ដល់អាចារ្យ ហើយស្វែងរកភរិយាដោយធម៌ មិនស្វែងរកខុសធម៌ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្តេច ក្នុងការស្វែងរកនោះ ។ គឺព្រាហ្មណ៍នោះ មិនបានស្វែងរកដោយការទិញ មិនបានស្វែងរក ដោយការលក់ដូរ ស្វែងរកតែព្រាហ្មណីដែលគេបរិច្ចាគ ដោយស្រោចទឹកឲ្យ ព្រាហ្មណ៍នោះ គប់រកតែនាងព្រាហ្មណីផងគ្នា មិនបានគប់រកស្ត្រីក្សត្រិយ៍ មិនបានគប់រកស្ត្រីវេស្សៈ មិនបានគប់រកស្ត្រីសុទ្រៈ មិនបានគប់រកស្ត្រីចណ្ឌាល មិនបានគប់រកស្ត្រីនេសាទ មិនបានគប់រកស្ត្រីដែលមានក្ឃង៍សក់ (សក់ជុក) មិនបានគប់រកស្ត្រីជាងរថ មិនបានគប់រកស្ត្រីអ្នកចោលសម្រាម មិនបានគប់រកស្ត្រីដែលមានគភ៌ មិនបានគប់រកស្ត្រីដែលមានកូននៅបៅ មិនបានគប់រកស្ត្រីដែលមិនមានរដូវ ។ ម្នាលទោណៈ ចុះហេតុអ្វី បានជាព្រាហ្មណ៍មិនគប់រកស្ត្រីដែលមានគភ៌ ។ ម្នាលទោណៈ ប្រសិនបើព្រាហ្មណ៍គប់រកស្ត្រីដែលមានគភ៌ហើយ មាណវកៈនឹងមាណវិកានោះ ឈ្មោះថាកើតក្នុងគំនរលាមកដ៏ធំ អាក្រក់ក្រពេក ម្នាលទោណៈ ព្រោះហេតុនោះ បានជាព្រាហ្មណ៍ មិនគប់រកស្ត្រីដែលមានគភ៌ឡើយ ។

កស្មា ច ទោណ ព្រាហ្មណោ ន ទាយជ្ជំ គច្ឆតិ ។ សចេ ទោណ ព្រាហ្មណោ ទាយជ្ជំ គច្ឆតិ អសុចិប្បដិបីតោ នាម សោ ហោតិ មាណវកោ វា មាណវិកា វា តស្មា ទោណ ព្រាហ្មណោ ន ទាយជ្ជំ គច្ឆតិ តស្ស សា ហោតិ ព្រាហ្មណី នេវ កាមត្ថា ន ទវត្ថា ន រតត្ថា បជត្ថាវ ព្រាហ្មណស្ស ព្រាហ្មណី ហោតិ ។ សោ មេថុនំ ឧប្បាទេត្វា តមេវ បុត្តស្សាទំ និកាម-យមានោ កុដុម្ពំ អជ្ឈាវសតិ ន អគារស្មា អន-គារិយំ បព្វជតិ ។ យាវ បោរាណានំ ព្រាហ្មណានំ មរិយាទោ តត្ថ តិដ្ឋតិ តំ ន វីតិក្កមតិ ។ យាវ បោរាណានំ ព្រាហ្មណានំ មរិយាទោ តត្ថ ព្រាហ្មណោ ឋិតោ តំ ន វីតិក្កមតីតិ ខោ ទោណ តស្មា ព្រាហ្មណោ មរិយាទោតិ វុច្ចតិ ។ អយំ ខោ ទោណ ព្រាហ្មណោ មរិយាទោ ហោតិ ។

ម្នាលទោណៈ ចុះហេតុអ្វី បានជាព្រាហ្មណ៍ មិនគប់រកស្ត្រីដែលមានកូននៅបៅ ។ ម្នាលទោណៈ ប្រសិនបើព្រាហ្មណ៍ គប់រកស្ត្រីដែលមានកូននៅបៅហើយ មាណវកៈនឹងមាណវិកានោះ ឈ្មោះថាជាអ្នកផឹករបស់មិនស្អាត ម្នាលទោណៈ ព្រោះហេតុនោះ បានជាព្រាហ្មណ៍ មិនគប់រកស្ត្រីដែលមានកូននៅបៅ នាងព្រាហ្មណីរបស់ព្រាហ្មណ៍នោះ ជាអ្នកមិនមានប្រយោជន៍ដោយកាម មិនមានប្រយោជន៍ដោយការលេង មិនមានប្រយោជន៍ដោយសេចក្តីត្រេកអរ ក្នុងកាម នាងព្រាហ្មណីរបស់ព្រាហ្មណ៍ មានប្រយោជន៍ដោយបុត្រតែប៉ុណ្ណោះ ។ ព្រាហ្មណ៍នោះញុំាងមេថុនឲ្យកើតឡើងហើយ ក៏ប្រាថ្នាមិនជាប់នូវសេចក្តីត្រេកអរ ក្នុងបុត្រនោះឯង ក៏នៅគប់គ្រងទ្រព្យសម្បត្តិ មិនបានចេញចាកផ្ទះមកបួសឡើយ ។ ឯព្រាហ្មណ៍ ជាមរិយាទៈតាំងឋិតនៅក្នុងធម៌នោះ របស់ពួកព្រាហ្មណ៍អំពីបុរាណរៀងមក មិនបានប្រព្រឹត្តកន្លងនូវធម៌នោះឡើយ ។ មរិយាទព្រាហ្មណ៍ ឋិតនៅក្នុងធម៌នោះ របស់ពួកព្រាហ្មណ៍អំពីបុរាណរៀងមក មិនបានប្រព្រឹត្តកន្លងនូវធម៌នោះដូច្នេះឯង ម្នាលទោណៈ ព្រោះហេតុនោះ បានជាហៅថា ព្រាហ្មណ៍មរិយាទៈ ។ ម្នាលទោណៈ ព្រាហ្មណ៍ ជាមរិយាទៈយ៉ាងនេះឯង ។

កតមញ្ច ទោណ ព្រាហ្មណោ សម្ភិន្នមរិយាទោ ហោតិ ។ ឥធ ទោណ ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ។ អដ្ឋចត្តាឡីសវស្សានិ កោមារំ ព្រហ្មចរិយំ ចរតិ មន្តេ អធីយមានោ អដ្ឋចត្តាឡីសវស្សានិ កោមារំ ព្រហ្មចរិយំ ចរិត្វា មន្តេ អធីយិត្វា អាចរិយស្ស អាចរិយធនំ បរិយេសតិ ធម្មេនេវ នោ អធម្មេន ។ តត្ថ ច ទោណ កោ ធម្មោ ។ នេវ កសិយា ន វណិជ្ជាយ ន គោរក្ខេន ន ឥស្សត្ថេន ន រាជបោរិសេន ន សិប្បញ្ញតរេន កេវលំ ភិក្ខាចរិយាយ កបាលំ អនតិមញ្ញមានោ ។ សោ អាចរិយស្ស អាចរិយធនំ និយ្យាតេត្វា ទារំ បរិយេសតិ

ម្នាលទោណៈ ចុះព្រាហ្មណ៍ ជាសម្ភិន្នមរិយាទៈ តើដូចម្តេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ មានកំណើតស្អាតទាំងពីរខាង គឺខាងមាតានិងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណរនៃជីដូនជីតាជាគំរប់ ៧ មិនមានអ្នកណារិះគន់ តិះដៀលដោយពោលដល់ជាតិកំណើតបានឡើយ ។ ព្រាហ្មណ៍នោះ រមែងរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ លុះរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ រួចហើយស្វែងរកនូវទ្រព្យសម្រាប់អាចារ្យ ដើម្បីអាចារ្យ ដោយធម៌ មិនស្វែងរកខុសធម៌ឡើយ ។ ម្នាលទោណៈ បណ្តាការស្វែងរកទាំងនោះ ការស្វែងរកដោយធម៌ តើដូចម្តេច ។ គឺព្រាហ្មណ៍នោះ មិនបានស្វែងរក ដោយការភ្ជួរ មិនបានស្វែងរក ដោយការជួញ មិនបានស្វែងរក ដោយការរក្សាគោ មិនបានស្វែងរក ដោយអំពើនៃឋានៈជាទាហាន មិនបានស្វែងរក ដោយការៈជារាជបុរស មិនបានស្វែងរក ដោយសិប្បកម្មណាមួយឡើយ គ្រាន់តែស្វែងរក ដោយការត្រេចទៅដើម្បីភិក្ខាប៉ុណ្ណោះ មិនបានមើលងាយនូវភិក្ខាភាជនៈឡើយ ។ ព្រាហ្មណ៍នោះ ប្រគល់ទ្រព្យសម្រាប់អាចារ្យ ដល់អាចារ្យហើយ ក៏ស្វែងរកភរិយា

ធម្មេនបិ អធម្មេនបិ កាយេនបិ វិក្កាយេនបិ ឧទ-
កុបសដ្ឋំ សោ ព្រាហ្មណិម្បិ គច្ឆតិ ខត្តិយិម្បិ
គច្ឆតិ វេស្សិម្បិ គច្ឆតិ សុទ្ទិម្បិ គច្ឆតិ ចណ្ឌាលិម្បិ
គច្ឆតិ នេសាទិម្បិ គច្ឆតិ វេណិម្បិ គច្ឆតិ រថ-
ការិម្បិ គច្ឆតិ បុក្កុសិម្បិ គច្ឆតិ គព្ភិនិម្បិ គច្ឆតិ
ធាយមានម្បិ គច្ឆតិ ឧតុនិម្បិ គច្ឆតិ អនុតុនិម្បិ
គច្ឆតិ ។ តស្ស សា ហោតិ ព្រាហ្មណី កាមត្ថាបិ
ទវត្ថាបិ រតត្ថាបិ បជត្ថាបិ ព្រាហ្មណស្ស ព្រាហ្មណី
ហោតិ ។ យាវ បោរាណានំ ព្រាហ្មណានំ មរិយាទោ
តត្ថ ន តិដ្ឋតិ តំ វីតិក្កមតិ ។ យាវ បោរាណានំ
ព្រាហ្មណានំ មរិយាទោ តត្ថ ព្រាហ្មណោ ន
ឋិតោ តំ វីតិក្កមតីតិ ខោ ទោណ តស្មា
ព្រាហ្មណោ សម្ភិន្នមរិយាទោតិ វុច្ចតិ ។ ឯវំ ខោ
ទោណ ព្រាហ្មណោ សម្ភិន្នមរិយាទោ ហោតិ ។

ដែលគេបរិច្ចាគ ដោយស្រោចទឹកឲ្យ ដោយធម៌ខ្លះ មិនដោយធម៌ខ្លះ ដោយការទិញខ្លះ ដោយការលក់ដូរខ្លះ ព្រាហ្មណ៍នោះ រមែងគប់រកនាងព្រាហ្មណីខ្លះ គប់រកស្ត្រីក្សត្រិយ៍ខ្លះ គប់រកស្ត្រីវេស្សៈខ្លះ គប់រកស្ត្រីសុទ្ទៈខ្លះ គប់រកស្ត្រីចណ្ឌាលខ្លះ គប់រកស្ត្រីនេសាទខ្លះ គប់រកស្ត្រីដែលមានក្ឃ៏សក់ (សក់ផុក) ខ្លះ គប់រកស្ត្រីជាងរថខ្លះ គប់រកស្ត្រីអ្នកចោលសម្រាមខ្លះ គប់រកស្ត្រីដែលមានគភ៌ខ្លះ គប់រកស្ត្រីដែលមានកូននៅបៅខ្លះ គប់រកស្ត្រីដែលមានរដូវខ្លះ គប់រកស្ត្រីដែលមិនមានរដូវខ្លះ ។ ព្រាហ្មណីរបស់ព្រាហ្មណ៍នោះ ជាអ្នកមានប្រយោជន៍ដោយកាមខ្លះ មានប្រយោជន៍ដោយការលេងខ្លះ មានប្រយោជន៍ដោយការត្រេកអរក្នុងកាមខ្លះ នាងព្រាហ្មណីរបស់ព្រាហ្មណ៍ មានប្រយោជន៍ដោយបុត្រខ្លះ ។ ព្រាហ្មណ៍ ជាមរិយាទៈ មិនបានឋិតនៅក្នុងធម៌នោះ របស់ពួកព្រាហ្មណ៍អំពីបុរាណរៀងមក រមែងប្រព្រឹត្តកន្លងនូវធម៌នោះ ។ ព្រាហ្មណ៍មរិយាទៈ មិនបានឋិតនៅក្នុងធម៌នោះ ប្រព្រឹត្តកន្លងលើសនូវធម៌របស់ពួកព្រាហ្មណ៍អំពីបុរាណរៀងមក រមែងប្រព្រឹត្តកន្លងនូវធម៌នោះ ម្នាលទោណៈ ព្រោះហេតុនោះ បានជាហៅថា ព្រាហ្មណ៍ ជាសម្ភិន្នមរិយាទៈ ដូច្នេះឯង ។ ម្នាលទោណៈ ព្រាហ្មណ៍ ជាសម្ភិន្នមរិយាទៈ យ៉ាងនេះឯង ។

កតមញ្ច ទោណ ព្រាហ្មណោ ព្រាហ្មណចណ្ឌាលោ ហោតិ ។ ឥធ ទោណ ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ។ សោ អដ្ឋចត្តារីសវស្សានិ កោមារំ ព្រហ្មចរិយំ ចរតិ មន្តេ អធីយមានោ អដ្ឋចត្តារីស-វស្សានិ កោមារំ ព្រហ្មចរិយំ ចរិត្វា មន្តេ អធីយិត្វា អាចរិយស្ស អាចរិយធនំ បរិយេសតិ ធម្មេនបិ អធម្មេនបិ កសិយាបិ វណិជ្ជាយបិ គោរក្ខេនបិ ឥស្សត្ថេនបិ សិប្បញ្ញតរេនបិ រាជបោរិសេនបិ កេវលំ ភិក្ខាចរិយាយ កបាលំ អនតិមញ្ញមានោ ។ សោ អាចរិយស្ស អាចរិយធនំ និយ្យាតេត្វា ទារំ បរិយេសតិ ធម្មេនបិ អធម្មេនបិ កយេនបិ វិក្កយេនបិ ឧទកុបសដ្ឋំ ។ សោ ព្រាហ្មណិម្បិ គច្ឆតិ ខត្តិយិម្បិ គច្ឆតិ វេស្សិម្បិ គច្ឆតិ សុទ្ទិម្បិ គច្ឆតិ

ម្នាលទោណៈ ព្រាហ្មណ៍ ជាព្រាហ្មណចណ្ឌាល តើដូចម្ដេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកមានកំណើតស្អាត ទាំងពីរខាង គឺខាងមាតានិងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ អំពីតំណនៃជីដូនទួតជីតាជាគំរប់ ៧ មិនមានអ្នកណារិះគន់ តិះដៀលដោយពោលដល់ជាតិកំណើតបានឡើយ ។ ព្រាហ្មណ៍នោះ រមែងរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ លុះរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំរួចហើយ ក៏ស្វែងរកនូវទ្រព្យ សម្រាប់អាចារ្យ ដើម្បីអាចារ្យ ដោយធម៌ខ្លះ មិនដោយធម៌ខ្លះ ដោយការភ្ជួរខ្លះ ដោយការជួញខ្លះ ដោយការរក្សាគោខ្លះ ដោយអំពើនៃឋានៈជាទាហានខ្លះ ដោយសិប្បកម្មណានីមួយខ្លះ ដោយភាវៈរាជបុរសខ្លះ គាត់តែស្វែងរក ដោយការត្រេចទៅដើម្បីភិក្ខាប៉ុណ្ណោះ មិនបានមើលងាយនូវភិក្ខាភាជនៈឡើយ ។ ព្រាហ្មណ៍នោះក៏ប្រគល់ទ្រព្យ សម្រាប់អាចារ្យ ដល់អាចារ្យហើយ ក៏ស្វែងរកភរិយា ដែលគេបរិច្ចាគដោយស្រោចទឹកឲ្យ ដោយធម៌ខ្លះ មិនដោយធម៌ខ្លះ ដោយការទិញខ្លះ ដោយការលក់ដូរខ្លះ ព្រាហ្មណ៍នោះ រមែងគប់រកនាងព្រាហ្មណីខ្លះ គប់រកស្ត្រីក្សត្រិយ៍ខ្លះ គប់រកស្ត្រីវេស្សៈខ្លះ គប់រកស្ត្រីសុទ្រៈខ្លះ

ចណ្ឌាលិម្បិ គច្ឆតិ នេសាទិម្បិ គច្ឆតិ វេណិម្បិ គច្ឆតិ រថការិម្បិ គច្ឆតិ បុក្កុសិម្បិ គច្ឆតិ គព្ភិនិម្បិ គច្ឆតិ បាយមានម្បិ គច្ឆតិ ឧតុនិម្បិ គច្ឆតិ អនុតុនិម្បិ គច្ឆតិ ។ តស្ស សា ហោតិ ព្រាហ្មណី កាមត្ថាបិ ទវត្ថាបិ រតត្ថាបិ បជត្ថាបិ ព្រាហ្មណស្ស ព្រាហ្មណី ហោតិ ។ សោ សព្វកម្មេហិ ជីវិកំ កប្បេតិ តមេនំ ព្រាហ្មណា ឯវមាហំសុ កស្មា ភវំ ព្រាហ្មណោ បដិជានមានោ សព្វកម្មេហិ ជីវិកំ កប្បេតីតិ ។ សោ ឯវមាហ សេយ្យថាបិ ភោ អគ្គិ សុចិម្បិ ឌហតិ អសុចិម្បិ ឌហតិ ន ច តេន អគ្គិ ឧបលិប្បតិ ឯវមេវ ខោ ភោ សព្វកម្មេហិ ចេបិ ព្រាហ្មណោ ជីវិកំ កប្បេតិ ន ច តេន ព្រាហ្មណោ ឧបលិប្បតិ សព្វកម្មេហិ ជីវិកំ កប្បេតីតិ ខោ ទោណ តស្មា ព្រាហ្មណោ ព្រាហ្មណចណ្ឌាលោតិ វុច្ចតិ ។

គប់រកស្រីចណ្ឌាលខ្លះ គប់រកស្រីនេសាទខ្លះ គប់រកស្រីដែលមានកឆ្ឃី
សក់ខ្លះ គប់រកស្រីជាងរថខ្លះ គប់រកស្រីដែលចោលសម្រាមខ្លះ គប់រក
ស្រីដែលមានគភ៌ខ្លះ គប់រកស្រីដែលមានកូននៅបៅខ្លះ គប់រកស្រីដែល
មានរដូវខ្លះ គប់រកស្រីដែលមិនមានរដូវខ្លះ ។ នាងព្រាហ្មណីរបស់
ព្រាហ្មណ៍នោះ ជាអ្នកមានប្រយោជន៍ដោយកាមខ្លះ មានប្រយោជន៍
ដោយការលេងខ្លះ មានប្រយោជន៍ដោយសេចក្ដីត្រេកអរខ្លះ នាង
ព្រាហ្មណីរបស់ព្រាហ្មណ៍មានប្រយោជន៍ដោយបុត្រខ្លះ ។ ព្រាហ្មណ៍
នោះ រមែងចិញ្ចឹមជីវិតដោយការងារទាំងពួង ពួកព្រាហ្មណ៍ក៏បាន
និយាយនឹងព្រាហ្មណ៍នោះ យ៉ាងនេះថា ហេតុអ្វី បានជាព្រាហ្មណ៍
ដ៏ចំរើន ប្រជា ចិញ្ចឹមជីវិតដោយការងារទាំងពួង ។ ព្រាហ្មណ៍នោះ
បាននិយាយយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ប្រៀបដូចភ្លើង
រមែងឆេះ របស់ស្អាតខ្លះ ឆេះរបស់មិនស្អាតខ្លះ ភ្លើងក៏មិនបានប្រឡាក
ជាប់ដោយរបស់នោះទេ យ៉ាងណាមិញ ម្នាលអ្នកទាំងឡាយ ដ៏ចំរើន
បើទុកជាព្រាហ្មណ៍ ចិញ្ចឹមជីវិតដោយអំពើទាំងពួង ព្រាហ្មណ៍ក៏មិន
បានជាប់ប្រឡាក់ ដោយការងារទាំងពួងនោះ ព្រាហ្មណ៍តែងចិញ្ចឹម
ជីវិតដោយការងារទាំងពួងដូច្នេះ ក៏យ៉ាងនោះដែរ ម្នាលទោណៈ
ព្រោះហេតុនោះ បានជាហៅថា ព្រាហ្មណ៍ ជាព្រាហ្មណ៍ចណ្ឌាល

ឯវំ ខោ ទោណ ព្រាហ្មណោ ព្រាហ្មណចណ្ឌាលោ ហោតិ ។ យេ ខោ តេ ទោណ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមិហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ វាមទេវោ វេស្សាមិត្តោ យមទគ្គិ អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ ត្យាស្សុមេ បញ្ច ព្រាហ្មណេ បញ្ញាបេន្តិ ព្រហ្មសមំ ទេវសមំ មរិយាទំ សម្ភិន្នមរិយាទំ ព្រាហ្មណចណ្ឌាលញ្ញេវ បញ្ចមំ ។ តេសំ ត្វំ ទោណ កតមោតិ ។ ឯវំ សន្តេ មយំ ភោ គោតម ព្រាហ្មណចណ្ឌាលម្បិ ន បូរេម អភិក្កន្តំ ភោ គោតម ។បេ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

ម្នាលទោណៈ ព្រាហ្មណ៍ជាព្រាហ្មណចណ្ឌាលយ៉ាងនេះឯង ។ ម្នាលទោណៈ ពួកឥសីជាប្រធានរបស់ពួកព្រាហ្មណ៍ អ្នកធ្វើមន្ត អ្នកញុំាងបន្តឲ្យប្រព្រឹត្តទៅ ពួកព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ រមែងច្រៀងតាមមន្តនោះ ពោលតាមមន្តនោះ ពោលតាមមន្តដែលឥសីពោលហើយ បង្រៀនតាមមន្តដែលឥសីបង្រៀនហើយ ជាមន្តពីបុរាណ ជាមន្តបទដែលឥសីច្រៀងហើយ ឲ្យប្រព្រឹត្តទៅហើយ បានធ្វើឲ្យជាគំនរទុកហើយ ឥសីទាំងនោះ គឺអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមទគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ ឥសីទាំងនោះ រមែងបញ្ញត្តព្រាហ្មណ៍ទាំង ៥ នេះគឺ ព្រហ្មសមៈ ១ ទេវសមៈ ១ មរិយាទៈ ១ សម្ភិន្នមរិយាទៈ ១ គំរប់ ៥ នឹងព្រាហ្មណ-ចណ្ឌាល ។ ម្នាលទោណៈ អ្នកជាព្រាហ្មណ៍អ្វី ក្នុងព្រាហ្មណ៍ទាំងនោះ ។ បពិត្រព្រះគោតមដ៏ចំរើន បើតាមទំនងនេះ ខ្ញុំព្រះអង្គមិនពេញជាព្រាហ្មណចណ្ឌាលទេ បពិត្រព្រះគោតមដ៏ចំរើន ភាសិតនេះច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវទីពឹងស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

(៩៣) អថខោ សង្គារវោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសា-រេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សង្គារវោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេនេកទា ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។ កោ បន ភោ គោតម ហេតុ កោ បច្ចយោ យេនេកទា ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតាតិ ។ យស្មឹ ព្រាហ្មណ សមយេ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ

(៩៣) គ្រានោះឯង សង្គារវព្រាហ្មណ៍ (ព្រាហ្មណ៍ឈ្មោះសង្គារវៈ) បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសង្គារវព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ បានជាមន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង ដូនកាលមិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ។ បពិត្រព្រះគោតមដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ បានជាមន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង ដូនកាលប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ។ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តត្រូវកាមរាគរួបរឹត ត្រូវកាមរាគគ្របសង្កត់ហើយ ទាំងមិនដឹងច្បាស់តាមពិតនូវការរលាស់ចេញនូវកាមរាគ ដែលកើតឡើង សម័យនោះ ក៏មិនបានដឹង មិនបានឃើញតាមពិត នូវប្រយោជន៍របស់ខ្លួនខ្លះ សម័យនោះ មិនបានដឹង មិនបានឃើញតាមពិត នូវប្រយោជន៍អ្នកដទៃខ្លះ

តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ សំសដ្ឋោ លាខាយ វា ហលិទ្ទិយា វា នីលិយា វា មញ្ជិដ្ឋាយ វា តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ នប្បជានេយ្យ ន បស្សេយ្យ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។

សម័យនោះ មិនបានដឹង មិនបានឃើញតាមពិត នូវប្រយោជន៍ទាំងពីរខ្លះ (ព្រោះហេតុនោះ) មន្តទាំងឡាយដែលគេបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងមិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹកដែលលាយដោយល័ខ ឬរមៀត ពណ៌លៀង ឬពណ៌ហង្សបាទ បុរសមានចក្ខុ ពិចារណាមើលមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ មិនគប្បីដឹង មិនគប្បីឃើញតាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តត្រូវកាមរាគរួបរឹត ត្រូវកាមរាគគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិតនូវការរលាស់ចេញនូវកាមរាគ ដែលកើតឡើង សម័យនោះ ក៏មិនបានដឹង មិនបានឃើញតាមពិត នូវប្រយោជន៍របស់ខ្លួនខ្លះ សម័យនោះ មិនបានដឹង មិនបានឃើញតាមពិត នូវប្រយោជន៍អ្នកដទៃខ្លះ សម័យនោះ មិនបានដឹង មិនបានឃើញតាមពិត នូវប្រយោជន៍ទាំងពីរខ្លះ (ព្រោះហេតុនោះ) មន្តទាំងឡាយដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងមិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។

បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ព្យាបា-
ទបរិយុដ្ឋិតេន ចេតសា វិហរតិ ព្យាបាទបរេតេន
ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ
នប្បជានាតិ ។បេ។ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា
នប្បដិភន្តិ បគេវ អសជ្ឈាយកតា សេយ្យថាបិ
ព្រាហ្មណ ឧទបត្តោ អគ្គិនា សន្តត្តោ ឧក្កុដ្ឋិតោ
ឧស្សទកជាតោ តត្ថ ចក្ខុមា បុរិសោ សកំ
មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ នប្បជានេយ្យ ន
បស្សេយ្យ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ
ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ព្យាបាទបរេតេន
ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ
នប្បជានាតិ ។បេ។ ទីឃរត្តំ សជ្ឈាយកតាបិ
មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។ បុន ចបរំ
ព្រាហ្មណ យស្មឹ សមយេ ថីនមិទ្ធបរិយុដ្ឋិតេន
ចេតសា វិហរតិ ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច
ថីនមិទ្ធស្ស និស្សរណំ យថាភូតំ នប្បជានាតិ ។បេ។

ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្តត្រូវព្យាបាទរួបរឹត ត្រូវព្យាបាទគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវព្យាបាទដែលកើតឡើង ។បេ។ (ព្រោះហេតុនោះ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងមិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក ត្រូវភ្លើងឆេះហើយ ក៏ពុះឡើងចំហាយ បុរសមានចក្ខុពិចារណា មុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ មិនគប្បីដឹង មិនគប្បីឃើញតាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តត្រូវព្យាបាទរួបរឹត ត្រូវព្យាបាទគ្របសង្កត់ហើយ រមែងមិនដឹងច្បាស់តាមពិតនូវការរលាស់ចេញនូវព្យាបាទដែលកើតឡើង ។បេ។ (ព្រោះហេតុនោះ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងមិនមានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនស្វាធ្យាយឡើយ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្តត្រូវថីនមិទ្ធរួបរឹត ត្រូវថីនមិទ្ធគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវថីនមិទ្ធ ដែលកើតឡើង ។បេ។

ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ
បគេវ អសជ្ឈាយកតា សេយ្យថាបិ ព្រាហ្មណ
ឧទបត្តោ សេវាលបណកបរិយោនទ្ធោ តត្ថ ចក្ខុមា
បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ
នប្បជានេយ្យ ន បស្សេយ្យ ឯវមេវ ខោ ព្រាហ្មណ
យស្មឹ សមយេ ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា
វិហរតិ ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច ថីនមិទ្ធស្ស
និស្សរណំ យថាភូតំ នប្បជានាតិ ។បេ។
ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ
បគេវ អសជ្ឈាយកតា ។ បុន ចបរំ ព្រាហ្មណ
យស្មឹ សមយេ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា
វិហរតិ ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ច-
កុក្កុច្ចស្ស និស្សរណំ យថាភូតំ នប្បជានាតិ ។បេ។
ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ
បគេវ អសជ្ឈាយកតា សេយ្យថាបិ ព្រាហ្មណ
ឧទបត្តោ វាតេរិតោ ចលិតោ ភន្តោ ឩមិជាតោ

(ព្រោះហេតុនោះ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់
កាលជាយូរអង្វែង រមែងមិនប្រាកដ មិនបាច់ពោលដល់មន្តដែលមិន
បានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក
ដែលសារាយនឹងចកហ្វើត បុរសមានចក្ខុ បានពិចារណាមុខនិមិត្ត
របស់ខ្លួនក្នុងភាជនៈនោះ ក៏មិនគប្បីដឹង មិនគប្បីឃើញតាមពិត
យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តត្រូវ
ថីនមិទ្ធរួបរឹត ត្រូវថីនមិទ្ធគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត
នូវការរលាស់ចេញនូវថីនមិទ្ធដែលកើតឡើង ។ បេ ។ (ព្រោះហេតុ
នោះ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរ
អង្វែង ក៏មិនបានប្រាកដ មិនបាច់ពោលដល់មន្ត ដែលមិនបាន
ស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត
សម័យណា បុគ្គលមានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈរួបរឹត ត្រូវឧទ្ធច្ចៈ កុក្កុច្ចៈគ្រប
សង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញ នូវឧទ្ធច្ចៈ កុក្កុច្ចៈ
ដែលកើតឡើង ។ បេ ។ (ព្រោះហេតុនោះ) មន្តទាំងឡាយ ដែលបុគ្គល
បានស្វាធ្យាយ អស់កាលជាយូរអង្វែង ក៏មិនបានប្រាកដ មិនបាច់ពោល
ដល់មន្តដែលមិនបានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈ
ពេញដោយទឹក ត្រូវខ្យល់បក់កញ្ជាប់ញ័រ កម្រើក កើតទៅជារលក

តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ នប្បជានេយ្យ ន បស្សេយ្យ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ នប្បជានាតិ ។បេ។ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។ បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាតិ ។បេ។ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ អាវិលោ លុឡិតោ កលលីភូតោ អន្ធការេ និក្ខិត្តោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ នប្បជានេយ្យ ន បស្សេយ្យ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ

បុរសមានចក្ខុ បានពិចារណាមើលមុខនិមិត្តរបស់ខ្លួន ក្នុងភាជនៈនោះ មិនគប្បីដឹង មិនគប្បីឃើញ តាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈរួបរឹត ត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវឧទ្ធច្ចៈកុក្កុច្ចៈដែលកើតឡើង ។ បេ ។ (ព្រោះហេតុនោះ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង ក៏មិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្ត ត្រូវវិចិកិច្ឆារួបរឹត ត្រូវវិចិកិច្ឆាគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវវិចិកិច្ឆា ដែលកើតឡើង ។ បេ ។ (ព្រោះហេតុនោះ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង ក៏មិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹកល្អក់ មិនបាននៅនឹង កើតទៅជាភក់ បុគ្គលដំកល់ទុកក្នុងទីងងឹត បុរសមានចក្ខុ ពិចារណាមើលមុខនិមិត្តរបស់ខ្លួន ក្នុងភាជនៈនោះ ក៏មិនគប្បីដឹង មិនគប្បីឃើញតាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្ត ត្រូវវិចិកិច្ឆារួបរឹត

វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាតិ ។បេ។ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។ យស្មិញ្ច ខោ ព្រាហ្មណ សមយេ ន កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ ន កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ បជានាតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ បរត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ អសំសដ្ឋោ លាខាយ វា ហលិទ្ទិយា វា នីលិយា វា មញ្ជិដ្ឋាយ វា តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ បជានេយ្យ បស្សេយ្យ

ត្រូវវិចិកិច្ឆាគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញ នូវវិចិកិច្ឆាដែលកើតឡើង ។ល។ (ព្រោះហេតុនោះ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង ក៏មិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តដែលកាមរាគ មិនបានរួបរឹត ដែលកាមរាគមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវកាមរាគ ដែលកើតឡើង សម័យនោះ ក៏ដឹងច្បាស់ ឃើញច្បាស់តាមពិតនូវប្រយោជន៍ខ្លួនឯងខ្លះ សម័យនោះ ដឹងច្បាស់ ឃើញច្បាស់តាមពិតនូវប្រយោជន៍អ្នកដទៃខ្លះ សម័យនោះ ដឹងច្បាស់ ឃើញច្បាស់តាមពិតនូវប្រយោជន៍ទាំងពីរខ្លះ (ព្រោះហេតុនោះ) មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្ត ដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក ដែលមិនបានច្រឡំដោយល័ខ ឬរមៀត ពណ៌លឿង ឬ ពណ៌ហង្សបាទ បុរសមានចក្ខុពិចារណាមើលមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ

ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ន កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ ន កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស យថាភូតំ បជានាតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ បរត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។ បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ន ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ន ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ បជានាតិ ។ បេ ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ អគ្គិនា អសន្តត្តោ អនុក្កុដ្ឋិតោ អនុស្សទកជាតោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ ជានេយ្យ បស្សេយ្យ

ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្ត ដែលកាមរាគមិនបាន រួបរឹត ដែលកាមរាគៈមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវកាមរាគ ដែលកើតឡើង សម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ តាមពិតនូវប្រយោជន៍ខ្លួនខ្លះ សម័យនោះ ដឹងច្បាស់ ឃើញច្បាស់ តាមពិតនូវប្រយោជន៍អ្នកដទៃខ្លះ សម័យនោះ ដឹងច្បាស់ ឃើញច្បាស់ តាមពិតនូវប្រយោជន៍ទាំងពីរខ្លះ (ព្រោះហេតុនោះ) មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្តដែលព្យាបាទមិនបានរួបរឹត ដែលព្យាបាទមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវព្យាបាទ ដែលកើតឡើង ។ បេ ។ មន្តទាំងឡាយដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក មិនបានក្តៅ មិនបានពុះ មិនបានចំហាយឡើងដោយភ្លើង បុរសមានចក្ខុបានពិចារណាមើលមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ

ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ន ព្យាបាទ·
បរិយុដ្ឋិតេន ចេតសា វិហរតិ ន ព្យាបាទបរេតេន
ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ
បជានាតិ ។ បេ ។ ទីឃរត្តំ អសជ្ឈាយកតាបិ
មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។ បុន ចបរំ
ព្រាហ្មណ យស្មឹ សមយេ ន ថីនមិទ្ធបរិយុដ្ឋិតេន
ចេតសា វិហរតិ ន ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច
ថីនមិទ្ធស្ស និស្សរណំ យថាភូតំ បជានាតិ ។ បេ ។
ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ
សជ្ឈាយកតា សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ
ន សេវាលបណកបរិយោនទ្ធោ តត្ថ ចក្ខុមា
បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ
បជានេយ្យ បស្សេយ្យ ឯវមេវ ខោ ព្រាហ្មណ
យស្មឹ សមយេ ន ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា
វិហរតិ ន ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច ថីន·
មិទ្ធស្ស និស្សរណំ យថាភូតំ បជានាតិ ។ បេ ។

ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្ត ដែលព្យាបាទមិនបានរួបរឹត ដែលព្យាបាទមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិតនូវការរលាស់ចេញនូវព្យាបាទដែលកើតឡើង ។ បេ ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលបានស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្ត ដែលថីនមិទ្ធមិនបានរួបរឹត ដែលថីនមិទ្ធមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវថីនមិទ្ធ ដែលកើតឡើង ។ បេ ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក ដែលសារាយនិងចកមិនបានរួបរឹត បុរសមានចក្ខុបានពិចារណាមើលមុខនិមិត្តរបស់ខ្លួន ក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្ត ដែលថីនមិទ្ធមិនបានរួបរឹត ដែលថីនមិទ្ធមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញ នូវថីនមិទ្ធដែលកើតឡើង ។ បេ ។

ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។ បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ន ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ ន ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ បជានាតិ ។ បេ ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ ន វាតេរិតោ ន ចលិតោ ន ភន្តោ ន ឩមិជាតោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ បជានេយ្យ បស្សេយ្យ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ន ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ ន ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ បជានាតិ ។ បេ ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។

មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្ត ដែលឧទ្ធច្ចកុក្កុច្ចៈមិនបានរួបរឹត ដែលឧទ្ធច្ចកុក្កុច្ចៈមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវឧទ្ធច្ចកុក្កុច្ចៈ ដែលកើតឡើង ។ បេ ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក ដែលខ្យល់មិនបានបក់ មិនបានឲ្យកំរើក មិនបានឲ្យញាប់ញ័រ មិនមានរលក បុរសមានចក្ខុ បានពិចារណាមើលមុខនិមិត្តរបស់ខ្លួន ក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តដែលឧទ្ធច្ចកុក្កុច្ចៈ មិនបានរួបរឹត ដែលឧទ្ធច្ចកុក្កុច្ចៈ មិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើង ។ បេ ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។

បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ន វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ ន វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ បជានាតិ ។ បេ ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ អច្ឆោ វិប្បសន្នោ អនាវិលោ អាលោកេ និក្ខិត្តោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ បជានេយ្យ បស្សេយ្យ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ន វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ ន វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ បជានាតិ ។ បេ ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។ អយំ ខោ ព្រាហ្មណ ហេតុ អយំ បច្ចយោ យេនេកទា ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។ អយំ បន ព្រាហ្មណ ហេតុ

ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្តដែលវិចិកិច្ឆាមិនបានរួបរឹត ដែលវិចិកិច្ឆាមិនបានគ្របសង្កត់ហើយ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវវិចិកិច្ឆាដែលកើតឡើង ។ បេ ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹកថ្លាស្អាត មិនល្អក់ដែលបុគ្គលយកទៅដាក់ក្នុងទីមានពន្លឺ បុរសមានចក្ខុ បានពិចារណាមើលមុខនិមិត្តរបស់ខ្លួន ក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តដែលវិចិកិច្ឆា មិនបានរួបរឹត ដែលវិចិកិច្ឆា មិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវវិចិកិច្ឆា ដែលកើតឡើង ។ បេ ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយអស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាហេតុ នេះឯងជាបច្ច័យ ឲ្យមន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង មិនឲ្យប្រាកដ ក្នុងកាលខ្លះ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ។ ម្នាលព្រាហ្មណ៍ នេះឯងជាហេតុ

អយំ បច្ចយោ យេនេកទា ទីឃរត្តំ អសជ្ឈាយ-
កតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតាតិ ។
អភិក្កន្តំ ភោ គោតម ។បេ។ ឧបាសកំ មំ ភវំ
គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ
គតន្តិ ។

(៩៤) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ
មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន
សមយេន ការណបាលី ព្រាហ្មណោ លិច្ឆវីនំ កម្មន្តំ
ការេតិ ។ អទ្ទសា ខោ ការណបាលី ព្រាហ្មណោ
បិង្គិយានឹ ព្រាហ្មណំ ទូរតោវ អាគច្ឆន្តំ ទិស្វាន
បិង្គិយានឹ ព្រាហ្មណំ ឯតទវោច ហន្ទ កុតោ នុ
ភវំ បិង្គិយានី អាគច្ឆតិ ទិវា ទិវស្សាតិ ។ ឥតាហំ(១)
ភោ អាគច្ឆាមិ សមណស្ស គោតមស្ស សន្តិកាតិ ។
តំ កឹ មញ្ញតិ ភវំ បិង្គិយានី សមណស្ស គោត-
មស្ស បញ្ញាវេយ្យត្តិយំ បណ្ឌិតោ មញ្ញេតិ(២) ។

១ ឱ.ម. ឥតោហំ ។ ២ អដ្ឋកថាយំ មញ្ញតីតិ ទិស្សតិ ។

នេះឯងជាបច្ច័យ ឲ្យមន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងឲ្យប្រាកដក្នុងកាលខ្លះ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ។ បពិត្រព្រះគោតមដ៏ចំរើន ភាសិតនេះច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណៈ ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

[៩៤] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលាជិតមហាវន ក្បែរក្រុងវេសាលី ។ ក៏ក្នុងសម័យនោះឯង ការណបាលិព្រាហ្មណ៍ (ព្រាហ្មណ៍ឈ្មោះការណបាលី) តែងប្រើជនឲ្យធ្វើការងាររបស់ពួកលិច្ឆវិរាជ ។ ការណបាលិព្រាហ្មណ៍ បានឃើញបិង្គិយានិព្រាហ្មណ៍ (ព្រាហ្មណ៍ឈ្មោះបិង្គិយានិ) កំពុងដើរមកអំពីចម្ងាយ ក៏និយាយទៅនឹងបិង្គិយានិព្រាហ្មណ៍ដូច្នេះថា បិង្គិយានិដ៏ចំរើន មកពីណាហ្ន៎ ក្នុងវេលាថ្ងៃត្រង់ ។ ម្នាលអ្នកដ៏ចំរើន ខ្ញុំទើបនឹងមកអំពីសំណាក់ព្រះសមណគោតម ក្នុងទីឯណោះ ។ បិង្គិយានិដ៏ចំរើន សំគាល់នូវហេតុនោះដូចម្តេច សំគាល់ក្នុងសេចក្តីឈ្លាសវៃ ដោយប្រាជ្ញារបស់ព្រះសមណគោតមថា ជាបណ្ឌិតឬ ។

កោ ចាហំ ភោ កោ ច សមណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ ជានិស្សាមិ ។ សោបិ នូនស្ស តាទិសោវ យោ សមណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ ជានេយ្យាតិ ឧឡារាយ ខលុ ភវំ បិង្គិយានី សមណំ គោតមំ បសំសាយ បសំសតីតិ កោ ចាហំ ភោ កោ ច សមណំ គោតមំ បសំសិស្សាមិ ។ បសត្ថប្បសត្ថោ ច សោ ភវំ គោតមោ សេដ្ឋោ ទេវមនុស្សានន្តិ កឹ បន ភវំ បិង្គិយានី អត្ថវសំ សម្បស្សមានោ សមណេ គោតមេ ឯវំ អភិប្បសន្នោតិ សេយ្យថាបិ ភោ បុរិសោ អគ្គរសបរិតិត្តោ ន អញ្ញេសំ ហីនានំ រសានំ បិហេតិ ឯវមេវ ខោ ភោ យតោ យតោ តស្ស ភោតោ គោតមស្ស ធម្មំ សុណាតិ យទិ សុត្តសោ យទិ គេយ្យសោ យទិ វេយ្យាករណសោ យទិ អព្ភុតធម្មសោ តតោ តតោ ន អញ្ញេសំ បុថុស្សមណប្បវាទានំ[១] បិហេតិ សេយ្យថាបិ ភោ បុរិសោ ជិឃច្ឆាទុព្វល្យបរេតោ

១ អដ្ឋកថាយំ បន បុថុសមណព្រាហ្មណប្បវាទានន្តិ ទិស្សតិ ។

ម្នាលអ្នកដ៏ចំរើន ខ្ញុំជាអ្វី ខ្ញុំនឹងដឹងក្នុងការឈ្លាសវៃ ដោយប្រាជ្ញារបស់ព្រះសមណគោតម ដូចម្តេចបាន ៗ បុគ្គលណាដឹងក្នុងការឈ្លាសវៃ ដោយប្រាជ្ញារបស់ព្រះសមណគោតមបាន បុគ្គលនោះស្រដៀងគ្នានឹងព្រះសមណគោតមដោយពិត ព្ទថាបិង្គិយានិដ៏ចំរើន រមែងសរសើរព្រះសមណគោតម ដោយពាក្យសរសើរដ៏លើសលុបដូច្នេះ ម្នាលអ្នកដ៏ចំរើន ខ្ញុំជាអ្វី ខ្ញុំនឹងសរសើរព្រះសមណគោតម ដូចម្តេច ៗ ព្រះគោតមដ៏ចំរើននោះ ប្រសើរក្រៃពេក ប្រសើរជាងទេវតានឹងមនុស្សទាំងឡាយ ដូច្នេះ បិង្គិយានិដ៏ចំរើន ឃើញនូវអំណាចប្រយោជន៍ដូចម្តេច បានជាជ្រះថ្លាក្នុងព្រះសមណគោតមយ៉ាងនេះ ម្នាលអ្នកដ៏ចំរើន ដូចបុរសដែលឆ្អែតដោយរសដ៏ប្រសើរ រមែងមិនប្រាថ្នានូវរសទាំងឡាយដទៃដ៏ថោកទាបឡើយ យ៉ាងណាមិញ ម្នាលអ្នកដ៏ចំរើន (បុរស) រមែងស្តាប់ធម៌ ទោះបីជាសុត្តៈ ឬជាគេយ្យៈ ទោះបីជាវេយ្យាករណៈ ឬជាអព្ភូតធម្មៈ របស់ព្រះគោតមដ៏ចំរើននោះ ក្នុងកាលណា ៗ ហើយ (បុរសនោះ) ក៏មិនប្រាថ្នានូវវាទៈរបស់ពួកសមណព្រាហ្មណ៍ជាច្រើនដទៃ ក្នុងកាលនោះៗឡើយ ម្នាលអ្នកដ៏ចំរើន មួយទៀត ដូចបុរសត្រូវសេចក្តីស្រេកឃ្លាននឹងភាពនៃកម្លាំងថមថយ គ្របសង្កត់ហើយ

មធុបិណ្ឌិកំ អធិគច្ឆេយ្យ សោ យតោ យតោ សាយេថ លភតេវ សាទុរសំ អសេចនកំ ឯវមេវ ខោ ភោ យតោ យតោ តស្ស ភោតោ គោតមស្ស ធម្មំ សុណាតិ យទិ សុត្តសោ យទិ គេយ្យសោ យទិ វេយ្យាករណសោ យទិ អព្ភុតធម្មសោ តតោ តតោ លភតេវ អត្តមនតំ លភតិ ចេតសោ បសាទំ ។ សេយ្យថាបិ ភោ បុរិសោ ចន្ទនឃដិកំ អធិគច្ឆេយ្យ ហរិចន្ទនស្ស វា លោហិតចន្ទនស្ស វា សោ យតោ យតោ ឃាយេថ យទិ មូលតោ យទិ មជ្ឈតោ យទិ អគ្គតោ អធិគច្ឆតេវ សុរភិគន្ធំ អសេចនកំ ឯវមេវ ខោ ភោ យតោ យតោ តស្ស ភោតោ គោតមស្ស ធម្មំ សុណាតិ យទិ សុត្តសោ យទិ គេយ្យសោ យទិ វេយ្យាករណសោ យទិ អព្ភុតធម្មសោ តតោ តតោ អធិគច្ឆតិ បាមុជ្ជំ អធិគច្ឆតិ សោមនស្សំ ។ សេយ្យថាបិ ភោ បុរិសោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ តស្ស កុសលោ ភិសកោ ឋានសោ អាពាធំ នីហរេយ្យ

គប្បីបាននូវនំមានរសឆ្ងាញ់ បុរសនោះលិទ្ធភ្លក់ ក្នុងកាលណា ៗ ក៏បាននូវរសឆ្ងាញ់ ដ៏មិនលាយឡំក្នុងកាលនោះ ៗ យ៉ាងណាមិញ ម្នាលអ្នកដ៏ចំរើន (បុរស) ស្តាប់ធម៌ទោះបីសុត្តៈ ឬ គេយ្យៈ ទោះបីវេយ្យាករណៈ ឬអព្ភូតធម្មៈ របស់ព្រះគោតមដ៏ចំរើននោះ ក្នុងកាលណា ៗ តែងបាននូវភាវៈពេញចិត្ត តែងបាននូវសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលនោះ ៗ ក៏យ៉ាងនោះឯង ៗ ម្នាលអ្នកដ៏ចំរើន មួយទៀត ដូចបុរសបានដុំខ្លឹមចន្ទន៍ នៃខ្លឹមចន្ទន៍លឿងឬខ្លឹមចន្ទន៍ក្រហម ហើយគប្បីហិតស្រូប ទោះបីអំពីគល់ ឬអំពីកណ្តាល ឬ អំពីចុង ក្នុងកាលណា ៗ គង់បាននូវក្លិនក្រអូប មិនលាយឡំដូចគ្នា យ៉ាងណាមិញ ម្នាលអ្នកដ៏ចំរើន (បុរស) ស្តាប់ធម៌ ទោះបីសុត្តៈ ឬគេយ្យៈ ទោះបីវេយ្យាករណៈ ឬ អព្ភូតធម្មៈ របស់ព្រះគោតមដ៏ចំរើននោះ ក្នុងកាលណា ៗ ហើយតែងបាននូវបាមោជ្ជៈ តែងបាននូវសោមនស្ស ក្នុងកាលនោះ ៗ ក៏យ៉ាងនោះឯង ៗ ម្នាលអ្នកដ៏ចំរើន មួយទៀត ដូចបុរសមានអាពាធ ដល់នូវសេចក្តីទុក្ខមានជម្ងឺធ្ងន់ ពេទ្យអ្នកឈ្លាសអង់អាច គប្បីនាំបង់នូវអាពាធ របស់បុរសនោះចេញបាន ដោយឋានៈ យ៉ាងណាមិញ

ឯវមេវ ខោ ភោ យតោ យតោ តស្ស ភោតោ គោតមស្ស ធម្មំ សុណាតិ យទិ សុត្តសោ យទិ គេយ្យសោ យទិ វេយ្យាករណសោ យទិ អព្ភុតធម្មសោ តតោ តតោ សោកបរិទេវទុក្ខទោមនស្សុបាយាសា អត្ថំ គច្ឆន្តិ ។ សេយ្យថាបិ ភោ បោក្ខរណី អច្ឆោទកា សាតោទកា សីតោទកា សេតោទកា សុបតិត្ថា រមណីយា អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ សោ តំ បោក្ខរណី ឱគាហេត្វា នហាត្វា ច បិវិត្វា ច សព្វទរថកិលមថបរិឡាហំ បដិប្បស្សម្ភេយ្យ ឯវមេវ ខោ ភោ យតោ យតោ តស្ស ភោតោ គោតមស្ស ធម្មំ សុណាតិ យទិ សុត្តសោ យទិ គេយ្យសោ យទិ វេយ្យាករណសោ យទិ អព្ភុតធម្មសោ តតោ តតោ សព្វទរថកិលមថបរិឡាហា បដិប្បស្សម្ភន្តិ ។ ឯវំ វុត្តេ ការណបាលី ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា

ម្នាលអ្នកដ៏ចំរើន (បុរស) ស្តាប់នូវធម៌ ទោះបីសុត្តៈ ឬគេយ្យៈ ទោះបីវេយ្យាករណៈ ឬអព្ភូតធម្មៈ របស់ព្រះគោតមដ៏ចំរើននោះ ក្នុងកាលណាៗហើយ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ ក៏ដល់នូវសេចក្តីវិនាស ក្នុងកាលនោះៗ ក៏យ៉ាងនោះឯង ។ ម្នាលអ្នកដ៏ចំរើន មួយទៀត ដូចស្រះបោក្ខរណីមានទឹកថ្លា មានទឹកឆ្ងាញ់ មានទឹកត្រជាក់ មានទឹកស មានកំពង់រាបស្មើ គួរជាទីត្រេកអរ ដូនជាមានបុរសម្នាក់មកដល់ បុរសនោះត្រូវសេចក្តីក្តៅរោលរាល ត្រូវសេចក្តីក្តៅគ្របសង្កត់ នឿយព្រួយលំបាកតាមផ្លូវ តក់ស្លុតស្រេកឃ្លាន ក៏ចុះទៅកាន់ស្រះបោក្ខរណីនោះ ងូតផង ផឹកផង គប្បីកំចាត់បង់នូវសេចក្តីក្រវល់ក្រវាយ សេចក្តីលំបាក សេចក្តីក្តៅក្រហាយទាំងពួងបានយ៉ាងណាមិញ ម្នាលអ្នកដ៏ចំរើន (បុរស) ស្តាប់ធម៌ ទោះបីសុត្តៈឬគេយ្យៈ ទោះបីវេយ្យាករណៈ ឬ អព្ភូតធម្មៈ របស់ព្រះគោតមដ៏ចំរើននោះ ក្នុងកាលណាៗ ហើយ សេចក្តីក្រវល់ក្រវាយ សេចក្តីលំបាក សេចក្តីក្តៅក្រហាយទាំងពួង ក៏ស្ងប់រម្ងាប់ទៅ ក្នុងកាលនោះៗ ក៏យ៉ាងនោះឯង ។ កាលដែលបិង្គិយានិព្រាហ្មណ៍ពោលយ៉ាងនេះហើយ ការណបាលិព្រាហ្មណ៍ ក៏ក្រោកចាកអាសនៈធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង

ទក្ខិណជាណុមណ្ឌលំ បឋវិយំ និហន្ត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ អភិក្កន្តំ ភោ បិង្គិយានិ អភិក្កន្តំ ភោ បិង្គិយានិ សេយ្យថាបិ ភោ បិង្គិយានិ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា បិង្គិយានិនា អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯសាហំ ភោ បិង្គិយានិ តំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ បិង្គិយានី ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

ហើយលុតមណ្ឌលជង្គង់ខាងស្តាំលើផែនដី ប្រណម្យអញ្ជលីចំពោះទៅព្រះដ៏មានព្រះភាគ ហើយបន្លឺនូវឧទានជាគំរប់ ៣ ដងថា សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ម្នាលបិង្គិយានិដ៏ចំរើន ច្បាស់ណាស់ ម្នាលបិង្គិយានិដ៏ចំរើន ច្បាស់ពេកណាស់ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេង ពុំនោះសោតដូចជាគេទ្រោលប្រទីប ក្នុងទីងងឹតដោយគិតថា បុរសអ្នកមានចក្ខុ តែងឃើញនូវរូបទាំងឡាយបាន យ៉ាងណាមិញ ធម៌ដែលបិង្គិយានិដ៏ចំរើន បានប្រកាសដោយអនេកបរិយាយ ក៏យ៉ាងនោះឯង ។ ម្នាលបិង្គិយានិដ៏ចំរើន ខ្ញុំសូមដល់នូវព្រះគោតមដ៏ចំរើននោះផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ សូមបិង្គិយានិដ៏ចំរើន ចាំទុកនូវខ្ញុំថា ជាឧបាសកដល់នូវសរណៈ ស្មើដោយជីវិត តាំងដើមអំពីថ្ងៃនេះតទៅ ។

(៩៥) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន បញ្ចមត្តានិ លិច្ឆវិសតានិ ភគវន្តំ បយិរុបាសន្តិ ។ អប្បេកច្ចេ លិច្ឆវី នីលា ហោន្តិ នីលវណ្ណា នីលវត្ថា នីលាលង្ការា អប្បេកច្ចេ លិច្ឆវី បីតា ហោន្តិ បីតវណ្ណា បីតវត្ថា បីតាលង្ការា អប្បេកច្ចេ លិច្ឆវី លោហិតកា ហោន្តិ លោហិតកវណ្ណា លោហិតកវត្ថា លោហិតកាលង្ការា អប្បេកច្ចេ លិច្ឆវី ឱទាតា ហោន្តិ ឱទាតវណ្ណា ឱទាតវត្ថា ឱទាតាលង្ការា ត្យាស្សុទំ ភគវា អតិរោចតិ វណ្ណេន ចេវ យសសា ច ។ អថខោ បិង្គិយានី ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច បដិភាតិ មំ ភគវា បដិភាតិ មំ សុគតាតិ ។ បដិភាតុ តំ បិង្គិយានីតិ ភគវា អវោច ។ អថខោ បិង្គិយានី ព្រាហ្មណោ ភគវតោ សម្មុខា សារុប្បាយ គាថាយ អភិត្ថវិ

(៩៥) សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងកូដាគារសាលា ជិតព្រៃមហាវ័នក្បែរក្រុងវេសាលី ។ ក្នុងសម័យនោះឯង ពួកស្តេចលិច្ឆវីប្រមាណ ៥០០ អង្គ នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ ពួកស្តេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់ខៀវ មានសម្បុរខៀវ មានសំពត់ខៀវ មានគ្រឿងតាក់តែងខៀវ ពួកស្តេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់លឿង មានសម្បុរលឿង មានសំពត់លឿង មានគ្រឿងតាក់តែងលឿង ពួកស្តេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់ក្រហម មានសម្បុរក្រហម មានសំពត់ក្រហម មានគ្រឿងតាក់តែងក្រហម ពួកស្តេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់ស មានសម្បុរស មានសំពត់ស មានគ្រឿងតាក់តែងស ព្រះដ៏មានព្រះភាគ រមែងរុងរឿងកន្លងពួកស្តេចលិច្ឆវីនោះ ដោយសម្បុរផង ដោយយសផង ។ គ្រានោះ បិង្គិយានិព្រាហ្មណ៍ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គសំដែងបដិប បពិត្រព្រះសុគត ខ្ញុំព្រះអង្គសំដែងបដិប ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលបិង្គិយានិ អ្នកចូរសំដែងចុះ ។ គ្រានោះឯង បិង្គិយានិព្រាហ្មណ៍ ក៏ពោលសរសើរ ដោយសារូបគាថា ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា

បទុមំ យថា កោកនទំ សុគន្ធំ
បាតោ សិយា ផុល្លមវីតគន្ធំ
អង្គីរសំ បស្ស វិរោចមានំ
តបន្តមាទិច្ចមិវន្តលិក្ខេតិ ។

អថខោ តេ លិច្ឆវី បញ្ចហិ ឧត្តរាសង្គសតេហិ បិង្គិយានឹ ព្រាហ្មណំ អច្ឆាទេសុំ ។ អថខោ បិង្គិយានី ព្រាហ្មណោ តេហិ បញ្ចហិ ឧត្តរាសង្គសតេហិ ភគវន្តំ អច្ឆាទេសិ ។ អថខោ ភគវា តេ លិច្ឆវី ឯតទវោច បញ្ចន្នំ លិច្ឆវី រតនានំ បាតុភាវោ ទុល្លភោ លោកស្មឹ ។ កតមេសំ បញ្ចន្នំ ។ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវោ ទុល្លភោ លោកស្មឹ តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសេតា បុគ្គលោ ទុល្លភោ លោកស្មឹ តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិតស្ស វិញ្ញាតា បុគ្គលោ ទុល្លភោ លោកស្មឹ តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិតស្ស វិញ្ញាតា ធម្មានុធម្មប្បដិបន្នោ បុគ្គលោ

ផ្កាឈូកឈ្មោះកោកនទៈ មានក្លិនក្រអូប រីកអំពីព្រឹក មានក្លិនមិនបានទៅប្រាស យ៉ាងណាមិញ អ្នកចូរមើលព្រះដ៏មានព្រះភាគ មានរស្មីផ្សាយចេញពីព្រះអង្គ រុងរឿងដូចព្រះអាទិត្យ ដែលរុងរឿង ក្នុងកណ្តាលពពក ក៏យ៉ាងនោះឯង ។

គ្រានោះឯង ពួកស្តេចលិច្ឆវីទាំងនោះ បានញុំាងបិង្គិយានិ-ព្រាហ្មណ៍ឲ្យស្លៀកដណ្តប់ ដោយសំពត់ឧត្តរាសង្គៈ ៥០០ ។ លំដាប់នោះឯង បិង្គិយានិព្រាហ្មណ៍ បានញុំាងព្រះដ៏មានព្រះភាគឲ្យស្លៀកដណ្តប់ ដោយសំពត់ឧត្តរាសង្គៈទាំង ៥០០ នោះ ។ វេលានោះព្រះដ៏មានព្រះភាគ បានត្រាស់ទៅនឹងពួកស្តេចលិច្ឆវីទាំងនោះ ដូច្នេះថា ការកើតប្រាកដនៃរតនៈ ៥ យ៉ាង រកបានដោយកម្រ ក្នុងលោក ។ ការកើតប្រាកដនៃរតនៈទាំង ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺការកើតប្រាកដនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ រកបានដោយកម្រ ក្នុងលោក ១ បុគ្គលដែលចេះសំដែងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ រកបានដោយកម្រ ក្នុងលោក ១ បុគ្គលដែលដឹងច្បាស់លាស់នូវធម្មវិន័យដែលព្រះតថាគតប្រកាសហើយ សំដែងហើយ រកបានដោយកម្រ ក្នុងលោក ១ បុគ្គលដែលដឹងច្បាស់លាស់នូវធម្មវិន័យដែលព្រះតថាគតប្រកាសហើយ សំដែងហើយ ប្រតិបត្តិនូវធម៌តាមធម៌

ទុល្លភោ លោកស្មឹ កតញ្ញូ កតវេទី បុគ្គលោ ទុល្លភោ លោកស្មឹ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ រតនានំ បាតុភាវោ ទុល្លភោ លោកស្មិន្តិ ។

(៩៦) តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ បញ្ច មហាសុបិនា បាតុរហេសុំ ។ កតមេ បញ្ច ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ អយំ មហាបឋវី មហាសយនំ អហោសិ ហិមវា បព្វតរាជា ពិម្ពោហនំ អហោសិ បុរត្ថិមេ សមុទ្ទេ វាមោ ហត្ថោ ឱហិតោ អហោសិ បច្ឆិមេ សមុទ្ទេ ទក្ខិណោ ហត្ថោ ឱហិតោ អហោសិ ទក្ខិណេ សមុទ្ទេ ឧភោ បាទា ឱហិតា អហេសុំ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ អយំ បឋមោ មហាសុបិនោ បាតុរហោសិ ។ បុន ចបរំ ភិក្ខវេ

គេបានដោយកម្រ ក្នុងលោក ១ កតញ្ញូកតវេទីបុគ្គល គេបានដោយកម្រ ក្នុងលោក ១ ។ ម្នាលលិច្ឆវីទាំងឡាយ ការកើតប្រាកដនៃរតនៈទាំង ៥ យ៉ាងនេះឯង គេបានដោយកម្រ ក្នុងលោក ។

(៩៦) ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានមហាសុបិន ៥ យ៉ាង កើតឡើងប្រាកដ ។ មហាសុបិន ៥ នោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាប្រឹថពីនេះ ជាសំណាក់ដ៏ប្រសើរ ស្តេចភ្នំឈ្មោះហិមវន្តជាខ្នើយ ព្រះហស្តឆ្វេងសណ្តូកចុះ ក្នុងសមុទ្រខាងកើត ព្រះហស្តស្តាំសណ្តូកចុះ ក្នុងសមុទ្រខាងលិច ព្រះបាទទាំងគូសណ្តូកចុះ ក្នុងសមុទ្រខាងត្បូង ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់បានត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទី ១ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត

តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ តិរិយា នាម តិណជាតិ នាភិយា ឧគ្គន្ត្វា នភំ អាហច្ច ឋិតា អហោសិ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ អយំ ទុតិយោ មហាសុបិនោ បាតុរហោសិ ។ បុន ចបរំ ភិក្ខវេ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ សេតា កិមី កណ្ហសីសា បាទេហិ ឧស្សក្កិត្វា យាវ ជាណុមណ្ឌលា បដិច្ឆាទេសុំ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ អយំ តតិយោ មហាសុបិនោ បាតុរហោសិ ។ បុន ចបរំ ភិក្ខវេ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ចត្តារោ សកុណា នានាវណ្ណា ចតូហិ ទិសាហិ អាគន្ត្វា

កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានស្មៅចិញ្ចៀន ១ សរសៃ ដុះលេចអំពីផ្ចិតទៅទល់នឹងអាកាស ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទី ២ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានពួកសត្វដង្កូវខ្លួនស ក្បាលខ្មៅ វារចេញអំពីព្រះបាទទាំងគូ (ចាប់ដើមអំពីចុងក្រចក) ហោមពេមជិត ដរាបដល់មណ្ឌលនៃជង្គង់ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទី ៣ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានសត្វបក្សី ៤ ពួក មានសម្បុរផ្សេងៗគ្នា ហើយមកអំពីទិសទាំង ៤

ទមូលេ និបតិត្វា សព្វសេតា សម្បជ្ជឹសុ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ អយំ ចតុត្ថោ មហាសុបិនោ បាតុរហោសិ ។ បុន ចបរំ ភិក្ខវេ តថាគតោ អរហំ សម្មាសម្ពុទ្ធោ បុព្វេវ សម្ពោធា អនភិសម្ពុទ្ធោ ពោធិសត្តោវ សមានោ មហតោ មិឡ្ហ-បព្វតស្ស ឧបរូបរិ ចង្កមតិ អលិប្បមានោ មិឡ្ហេន តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ អយំ បញ្ចមោ មហាសុបិនោ បាតុរហោសិ ។

យម្បិ ភិក្ខវេ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ អយំ មហាបឋវី មហាសយនំ អហោសិ ហិមវា បព្វតរាជា ពិម្ពោហនំ អហោសិ បុរត្ថិមេ សមុទ្ទេ វាមោ ហត្ថោ ឱហិតោ អហោសិ បច្ឆិមេ សមុទ្ទេ ទក្ខិណោ ហត្ថោ ឱហិតោ អហោសិ ទក្ខិណេ សមុទ្ទេ ឧភោ បាទា ឱហិតា អហោសុំ

មកក្រោបចុះ ទៀបបាទមូល ក៏ត្រឡប់ជាមានសម្បុរសទាំងអស់ទៅវិញ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទី ៤ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង រមែងចង្ក្រមលើភ្នំលាមកធំ មិនបានប្រឡាក់ដោយលាមកឡើយ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទី ៥ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង ផែនដីធំនេះ ជាសយនៈដ៏ប្រសើរ ស្តេចភ្នំហិមវន្តជាខ្នើយ ព្រះហស្តឆ្វេងសណ្ដូកចុះ ក្នុងសមុទ្រខាងកើត ព្រះហស្តស្តាំសណ្ដូកចុះ ក្នុងសមុទ្រខាងលិច ព្រះបាទទាំងគូសណ្ដូកចុះ ក្នុងសមុទ្រខាងត្បូង

តថាគតេន ភិក្ខវេ អរហតា សម្មាសម្ពុទ្ធេន អនុត្តរា សម្មាសម្ពោធិ អភិសម្ពុទ្ធា តស្ស អភិសម្ពោធាយ អយំ បឋមោ មហាសុបិនោ បាតុរហោសិ ។ យម្បិ ភិក្ខវេ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ តិរិយា នាម តិណជាតិ នាភិយា ឧគ្គន្ត្វា នភំ អាហច្ច ឋិតា អហោសិ តថាគតេន ភិក្ខវេ អរហតា សម្មាសម្ពុទ្ធេន អរិយោ អដ្ឋង្គិកោ មគ្គោ អភិសម្ពុជ្ឈិត្វា យាវ ទេវមនុស្សេហិ សុប្បកាសិតោ តស្ស អភិសម្ពោធាយ អយំ ទុតិយោ មហាសុបិនោ បាតុរហោសិ ។ យម្បិ ភិក្ខវេ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ សេតា កិមី កណ្ហសីសា បាទេហិ ឧស្សក្កិត្វា យាវ ជាណុមណ្ឌលា បដិច្ឆាទេសុំ

ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ១ កើតឡើងប្រាកដ ដើម្បីត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ ដែលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធបានត្រាស់ដឹងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានស្មៅចិញ្ចៀន ១ សរសៃដុះលេចអំពីផ្ចិតទៅទល់នឹងអាកាស ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ២ កើតឡើងប្រាកដ ដើម្បីត្រាស់ដឹង នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ បានត្រាស់ដឹងហើយ ដរាបតែទេវតានឹងមនុស្សទាំងឡាយប្រកាសបានដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានពពួកដង្កូវខ្លួនស ក្បាលខ្មៅ វារចេញអំពីព្រះបាទទាំងគូ តោមកេមជិត ដរាបដល់មណ្ឌលនៃជង្គង់

ពហូ ភិក្ខវេ គិហី ឱទាតវសនា តថាគតំ បាណុបេតំ សរណំ គតា តស្ស អភិសម្ពោធាយ អយំ តតិយោ មហាសុបិនោ បាតុរហោសិ ។ យម្បិ ភិក្ខវេ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិ-សម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ចត្តារោ សកុណា នានាវណ្ណា ចតូហិ ទិសាហិ អាគន្ត្វា បាទមូលេ និបតិត្វា សព្វសេតា សម្បជ្ជឹសុ ចត្តារោមេ ភិក្ខវេ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា តេ តថាគត-ប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា អនុត្តរំ វិមុត្តឹ សច្ឆិករោន្តិ តស្ស អភិសម្ពោធាយ អយំ ចតុត្ថោ មហាសុបិនោ បាតុរហោសិ ។ យម្បិ ភិក្ខវេ តថាគតោ អរហំ សម្មាសម្ពុទ្ធោ បុព្វេវ សម្ពោធា អនភិសម្ពុទ្ធោ ពោធិសត្តោវ សមានោ មហតោ មិឡ្ហបព្វតស្ស ឧបរូបរិ ចង្កមតិ អលិប្បមានោ មិឡ្ហេន

ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ៣ កើតឡើងប្រាកដ ដើម្បីត្រាស់ដឹង (នូវគុណ) ដែលពួកគ្រហស្ថច្រើន ស្លៀកពាក់ក្រៀងប្រដាប់មានពណ៌ស ដល់នូវព្រះតថាគត ជាសរណៈស្មើដោយជីវិត ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានសត្វស្លាប ៤ ពួក មានសម្បុរផ្សេងៗគ្នា ហើយមកអំពីទិសទាំង ៤ មកក្រាបទៀបបាទមូល មានខ្លួនត្រឡប់ជាសទាំងអស់ ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ៤ កើតឡើងប្រាកដ ដើម្បីត្រាស់ដឹង (នូវគុណ) ដែលវណ្ណៈទាំង ៤ នេះគឺ ខត្តិយៈ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំង ៤ នោះ ចេញចាកផ្ទះមកបួស ក្នុងធម្មវិន័យដែលព្រះតថាគតបានសំដែងហើយ ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្ត-សម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង រមែងចង្ក្រមលើភ្នំលាមក មិនប្រឡាក់ដោយលាមកឡើយ

លាភី ភិក្ខវេ តថាគតោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ តត្ថ ច តថាគតោ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ តស្ស អភិសម្ពោធាយ អយំ បញ្ចមោ មហាសុបិនោ បាតុរហោសិ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឥមេ បញ្ច មហាសុបិនា បាតុរហេសុំ ។

(៩៧) បញ្ចិមេ ភិក្ខវេ វស្សស្ស អន្តរាយា យំ នេមិត្តា ន ជានន្តិ យត្ថ នេមិត្តានំ ចក្ខុំ ន ក្កមតិ ។ កតមេ បញ្ច ។ ឧបរិ ភិក្ខវេ អាកាសេ តេជោធាតុ បកុប្បតិ តេន ឧប្បន្នា មេឃា បដិវិគច្ឆន្តិ អយំ ភិក្ខវេ បឋមោ វស្សស្ស អន្តរាយោ យំ នេមិត្តា ន ជានន្តិ យត្ថ នេមិត្តានំ ចក្ខុំ ន ក្កមតិ ។

ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ៥ កើតឡើងប្រាកដ ដើម្បីត្រាស់ដឹង (នូវគុណ) ដែលព្រះតថាគត ជាបុគ្គលមានលាភដ៏បាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ តែព្រះតថាគត មិនបានជាប់ចំពាក់ មិនបានជ្រប់ មិនបានស្រុបសៅ ក្នុងលាភទាំងនោះឡើយ មានការឃើញលាភនោះថាជាទោស មានបញ្ញាជាគ្រឿងរលាស់ចេញ ហើយទើបបរិភោគ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទាំង ៥ នេះ ក៏បានកើតឡើងប្រាកដ ។

(៩៧) ម្នាលភិក្ខុទាំងឡាយ អន្តរាយនៃភ្លៀងនេះមាន ៥ យ៉ាង ដែលពួកជនអ្នកទាយនូវនិមិត្ត មិនបានដឹង ទាំងចក្ខុរបស់ពួកជន អ្នកទាយនូវនិមិត្ត ក៏មិនមុតធ្លុះ ។ អន្តរាយនៃភ្លៀង ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តេជោធាតុ កើតឡើង ក្នុងអាកាសខាងលើ ដោយហេតុនោះហើយបានជាមេឃ (ពពក) តាំងឡើងត្រឡប់ជាស្រឡះទៅវិញ ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ១ ដែលពួកជនអ្នកទាយនូវនិមិត្តមិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតធ្លុះ ។

បុន ចបរំ ភិក្ខវេ ឧបរិ អាកាសេ វាយោធាតុ បកុប្បតិ តេន ឧប្បន្នា មេឃា បដិវិគច្ឆន្តិ អយំ ភិក្ខវេ ទុតិយោ វស្សស្ស អន្តរាយោ យំ នេមិត្តា ន ជានន្តិ យត្ថ នេមិត្តានំ ចក្ខុំ នក្កមតិ ។ បុន ចបរំ ភិក្ខវេ រាហុ អសុរិន្ទោ បាណិនា ឧទកំ បដិច្ឆិត្វា មហាសមុទ្ទេ បវត្តេតិ អយំ ភិក្ខវេ តតិយោ វស្សស្ស អន្តរាយោ យំ នេមិត្តា ន ជានន្តិ យត្ថ នេមិត្តានំ ចក្ខុំ នក្កមតិ ។ បុន ចបរំ ភិក្ខវេ វស្សវលាហកា ទេវបុត្តា[១] បមត្តា ហោន្តិ អយំ ភិក្ខវេ ចតុត្ថោ វស្សស្ស អន្តរាយោ យំ នេមិត្តា ន ជានន្តិ យត្ថ នេមិត្តានំ ចក្ខុំ នក្កមតិ ។ បុន ចបរំ ភិក្ខវេ មនុស្សា អធម្មិកា ហោន្តិ អយំ ភិក្ខវេ បញ្ចមោ វស្សស្ស អន្តរាយោ យំ នេមិត្តា ន ជានន្តិ យត្ថ នេមិត្តានំ ចក្ខុំ នក្កមតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច វស្សស្ស អន្តរាយា យំ នេមិត្តា ន ជានន្តិ យត្ថ នេមិត្តានំ ចក្ខុំ នក្កមតីតិ ។

---

១ ឱ. ម. ទេវា ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត តេជោធាតុកើតឡើង ក្នុងអាកាសខាងលើ ដោយហេតុនោះហើយបានជា មេឃតាំងឡើងត្រឡប់ជាស្រឡះទៅវិញ ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ២ ដែលពួកជនអ្នកទាយនូវនិមិត្ត មិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតផុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រាហុអសុរិន្ទ ត្រងទឹកដោយដៃហើយជះទៅ ក្នុងមហាសមុទ្រ ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ៣ ដែលពួកជនអ្នកទាយនូវនិមិត្ត មិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតផុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកវស្សវលាហកទេវបុត្ត ធ្វេសប្រហែស ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ៤ ដែលពួកជនអ្នកទាយនូវនិមិត្ត មិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតផុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកមនុស្សជាអ្នកមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ៥ ដែលពួកជនអ្នកទាយនូវនិមិត្តមិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតផុះ ។ ម្នាលភិក្ខុទាំងឡាយ អន្តរាយនៃភ្លៀងមាន ៥ យ៉ាងនេះឯង ដែលពួកជនអ្នកទាយនូវនិមិត្ត មិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតផុះ ។

(៩៨) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតា វាចា សុភាសិតា ហោតិ នោ ទុព្ភាសិតា អនវជ្ជា ច អននុវជ្ជា វិញ្ញូនំ ។ កតមេហិ បញ្ចហិ ។ កាលេន ច ភាសិតា ហោតិ សច្ចា ច ភាសិតា ហោតិ សណ្ហា ច ភាសិតា ហោតិ អត្ថសញ្ហិតា ច ភាសិតា ហោតិ មេត្តចិត្តេន ច ភាសិតា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតា វាចា សុភាសិតា ហោតិ នោ ទុព្ភាសិតា អនវជ្ជា ច អននុវជ្ជា វិញ្ញូនន្តិ ។

(៩៩) យំ[១] ភិក្ខវេ សីលវន្តោ បព្ពជិតា កុលំ ឧបសង្កមន្តិ តត្ថ មនុស្សា បញ្ចហិ ឋានេហិ ពហុំ បុញ្ញំ បសវន្តិ ។ កតមេហិ បញ្ចហិ ។ យស្មឹ ភិក្ខវេ សមយេ សីលវន្តេ បព្ពជិតេ កុលំ ឧបសង្កមន្តេ មនុស្សានំ[២] ទិស្វា ចិត្តានិ បសីទន្តិ សគ្គសំវត្តនិកំ ភិក្ខវេ តំ កុលំ តស្មឹ សមយេ បដិបទំ ហោតិ ។ យស្មឹ ភិក្ខវេ សមយេ សីលវន្តេ បព្ពជិតេ កុលំ ឧបសង្កមន្តេ

---

១ ឱ. យស្មឹ ភិក្ខវេ សមយេ ។ ២ ឱ. មនុស្សា ទិស្វា ចិត្តានិ បសាទេន្តិ ។

(៩៨) ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៥ ឈ្មោះថាសុភាសិត មិនមែនជាទុព្ភាសិត ជាវាចាមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញ មិនគប្បីតិះដៀលផង ។ វាចាដែលប្រកបដោយអង្គ ៥ តើដូចម្តេច ។ គឺវាចាដែលពោលប្រកបតាមកាល ១ វាចាដែលពោលពិត ១ វាចាដែលពោលទន់ភ្លន់ ១ វាចាដែលពោលប្រកបដោយប្រយោជន៍ ១ វាចាដែលពោលប្រកបដោយមេត្តាចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៥ នេះឯង ឈ្មោះថាសុភាសិត មិនមែនជាទុព្ភាសិតទេ ជាវាចាមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញ មិនគប្បីតិះដៀលផង ។

(៩៩) ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលណាហើយ ពួកមនុស្សក្នុងត្រកូលនោះ រមែងបានបុណ្យច្រើន ដោយឋានៈ ៥ យ៉ាង ។ ឋានៈ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ មនុស្សទាំងឡាយ បានឃើញ ក៏មានចិត្តជ្រះថ្លា ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះ ក៏ប្រតិបត្តិប្រព្រឹត្តទៅ ដើម្បីទៅកាន់ស្ថានសួគ៌ ក្នុងសម័យនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ

មនុស្សា បច្ចុដ្ឋេន្តិ អភិវាទេន្តិ អាសនំ ទេន្តិ ឧច្ចាកុលិកសំវត្តនិកំ ភិក្ខវេ តំ កុលំ តស្មឹ សមយេ បដិបទំ បដិបន្នំ ហោតិ ។ យស្មឹ ភិក្ខវេ សមយេ សីលវន្តេ បព្វជិតេ កុលំ ឧបសង្កមន្តេ មនុស្សា មច្ឆេរមលំ បដិវិនេន្តិ[១] មហេសក្ខសំវត្តនិកំ ភិក្ខវេ តំ កុលំ តស្មឹ សមយេ បដិបទំ បដិបន្នំ ហោតិ ។ យស្មឹ ភិក្ខវេ សមយេ សីលវន្តេ បព្វជិតេ កុលំ ឧបសង្កមន្តេ មនុស្សា យថាសត្តិ យថាពលំ សំវិភជន្តិ មហាភោគសំវត្តនិកំ ភិក្ខវេ តំ កុលំ តស្មឹ សមយេ បដិបទំ បដិបន្នំ ហោតិ ។ យស្មឹ ភិក្ខវេ សមយេ សីលវន្តេ បព្វជិតេ កុលំ ឧបសង្កមន្តេ មនុស្សា បរិបុច្ឆន្តិ បរិបញ្ហន្តិ ធម្មំ សុណន្តិ មហាបញ្ញាសំវត្តនិកំ ភិក្ខវេ តំ កុលំ តស្មឹ សមយេ បដិបទំ បដិបន្នំ ហោតិ ។ យស្មឹ ភិក្ខវេ សមយេ សីលវន្តោ បព្វជិតា កុលំ ឧបសង្កមន្តិ តត្ថ មនុស្សា ឥមេហិ បញ្ចហិ ឋានេហិ ពហុំ បុញ្ញំ បសវន្តិ ។

---

១ ឱ. បដិវិនោទេន្តិ ។

ពួកមនុស្ស រមែងក្រោកទទួលថ្វាយបង្គំ ក្រាលអាសនៈប្រគេន ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិនូវបដិបទាប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រកូលខ្ពង់ខ្ពស់ ក្នុងសម័យនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្ស ក៏បន្ទោបង់មន្ទិលគឺសេចក្តីកំណាញ់ ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិនូវបដិបទា ប្រព្រឹត្តទៅ ដើម្បីបាននូវយសសក្តិធំ ក្នុងសម័យនោះ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្ស រមែងចែករំលែក (នូវទាន) តាមសមគួរដល់សេចក្តីអង់អាច តាមសមគួរដល់កម្លាំង ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិនូវបដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវភោគសម្បត្តិច្រើន ក្នុងសម័យនោះ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្សក៏សាកសួរសាកច្ឆាស្តាប់ធម៌ ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិនូវបដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាច្រើន ក្នុងសម័យនោះ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្សក្នុងត្រកូលនោះ រមែងបានបុណ្យច្រើនដោយឋានៈ៥ យ៉ាងនេះ ។

(១០០) បញ្ចិមា ភិក្ខវេ និស្សារណីយា ធាតុយោ ។ កតមា បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុនោ កាមេ(១) មនសិករោតោ កាមេសុ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ នេក្ខម្មំ ខោ បនស្ស មនសិករោតោ នេក្ខម្មេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ សុវិសំយុត្តំ កាមេហិ យេ ច កាមបច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទិយតិ ។ ឥទមក្ខាតំ កាមានំ និស្សរណំ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ ព្យាបាទំ មនសិករោតោ ព្យាបាទេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ អព្យាបាទំ ខោ បនស្ស មនសិករោតោ អព្យាបាទេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ សុវិសំយុត្តំ ព្យាបាទេន យេ ច ព្យាបាទបច្ចយា ឧប្បជ្ជន្តិ អាសវា

---

១ ឱ. ម. កាមំ ។

(១០០) ម្នាលភិក្ខុទាំងឡាយ ពួកធាតុដែលគួររលាស់ចេញនេះ មាន ៥ យ៉ាង ។ ធាតុដែលគួររលាស់ចេញ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវកាមទាំងឡាយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅ ក្នុងកាមទាំងឡាយ មួយទៀត កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវនេក្ខម្មៈ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ក្នុងនេក្ខម្មៈ ចិត្តនោះរបស់ភិក្ខុនោះ ក៏ប្រព្រឹត្តទៅល្អ ចំរើនល្អ ដាច់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះ ចាកកាមទាំងឡាយ អាសវៈទាំងឡាយណា មានកាមជាបច្ច័យ នាំមកនូវសេចក្តីទុក្ខនឹងសេចក្តីក្រវល់ក្រវាយកើតឡើង បុគ្គលនោះក៏ផុតចាកអាសវៈទាំងនោះ បុគ្គលនោះក៏លែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវកាមទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវសេចក្តីព្យាបាទ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅ ក្នុងសេចក្តីព្យាបាទ កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនព្យាបាទ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ក្នុងសេចក្តីមិនព្យាបាទ ចិត្តនោះរបស់ភិក្ខុនោះ ប្រព្រឹត្តទៅល្អ ចំរើនល្អ ដាច់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះ ចាកសេចក្តីព្យាបាទ អាសវៈទាំងឡាយណា មានព្យាបាទជាបច្ច័យ

វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទិយតិ ។ ឥទមក្ខាតំ ព្យាបាទស្ស និស្សរណំ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ វិហេសំ មនសិការោតោ វិហេសាយ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ អវិហេសំ ខោ បនស្ស មនសិការោតោ អវិហេសាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ សុវិសំយុត្តំ វិហេសាយ យេ ច វិហេសាបច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទិយតិ ។ ឥទមក្ខាតំ វិហេសាយ និស្សរណំ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ រូបេ មនសិការោតោ រូបេសុ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ អរូបំ ខោ បនស្ស មនសិការោតោ អរូបេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ សុវិសំយុត្តំ រូបេហិ

នាំមកនូវសេចក្តីទុក្ខនិងសេចក្តីក្រវល់ក្រវាយ កើតឡើង បុគ្គលនោះ ក៏ផុតចាកអាសវៈទាំងនោះ បុគ្គលនោះ ក៏លែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវព្យាបាទ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវសេចក្តីបៀតបៀន ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជាប់នៅក្នុងសេចក្តីបៀតបៀន កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនបៀតបៀន ចិត្តក៏ស្ទុះទៅ ជ្រះថ្លាតាំងនៅស៊ប់ក្នុងសេចក្តីមិនបៀតបៀន ចិត្តនោះរបស់ភិក្ខុនោះ ប្រព្រឹត្តទៅល្អ ចំរើនល្អ ដាច់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះ ចាកសេចក្តីបៀតបៀន ឯអាសវៈទាំងឡាយណា មានសេចក្តីបៀតបៀនជាបច្ច័យ នាំមកនូវសេចក្តីទុក្ខ និងសេចក្តីក្រវល់ក្រវាយ កើតឡើង បុគ្គលនោះ ក៏ផុតចាកអាសវៈទាំងនោះ បុគ្គលនោះលែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវសេចក្តីបៀតបៀន ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តក្នុងរូបទាំងឡាយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជាប់នៅក្នុងរូបទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវរូប ចិត្តក៏ស្ទុះទៅ. ជ្រះថ្លា តាំងនៅស៊ប់ក្នុងអរូបឋាន ចិត្តនោះរបស់ភិក្ខុនោះ ប្រព្រឹត្តទៅល្អ ចំរើនល្អ ដាច់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះចាករូបទាំងឡាយ

យេ ច រូបប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទិយតិ ។ ឥទមក្ខាតំ រូបានំ និស្សរណំ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ សក្កាយំ មនសិករោតោ សក្កាយេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ សក្កាយនិរោធំ ខោ បនស្ស មនសិករោតោ សក្កាយនិរោធេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ សុវិសំយុត្តំ សក្កាយេន យេ ច សក្កាយប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទិយតិ ។ ឥទមក្ខាតំ សក្កាយស្ស និស្សរណំ ។ តស្ស កាមនន្ទិបិ នានុសេតិ ព្យាបាទនន្ទិបិ នានុសេតិ វិហេសានន្ទិបិ នានុសេតិ រូបនន្ទិបិ នានុសេតិ សក្កាយនន្ទិបិ នានុសេតិ

អាសវៈទាំងឡាយណា មានរូបជាបច្ច័យ នាំមកនូវសេចក្តីទុក្ខនឹងក្រវល់ក្រវាយកើតឡើង ភិក្ខុនោះ ក៏ផុតចាកអាសវៈទាំងនោះ ភិក្ខុនោះលែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវរូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវសក្កាយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅក្នុងសក្កាយ កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធតែមួយយ៉ាង ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ក្នុងសក្កាយនិរោធបាន ចិត្តនោះរបស់ភិក្ខុនោះ ប្រព្រឹត្តទៅល្អ ចំរើនល្អ ដាច់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះចាកសក្កាយ អាសវៈទាំងឡាយណា មានសក្កាយជាបច្ច័យ នាំមកនូវសេចក្តីទុក្ខនឹងសេចក្តីក្រវល់ក្រវាយកើតឡើង ភិក្ខុនោះក៏ផុតចាកអាសវៈទាំងនោះ ភិក្ខុនោះលែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវសក្កាយ ។ សេចក្តីត្រេកអរ ក្នុងកាមក្តី របស់ភិក្ខុនោះ ក៏មិនបានកើត សេចក្តីត្រេកអរ ក្នុងការព្យាបាទក្តី ក៏មិនបានកើត សេចក្តីត្រេកអរ ក្នុងការបៀតបៀនក្តី ក៏មិនបានកើត សេចក្តីត្រេកអរ ក្នុងរូបក្តី ក៏មិនបានកើត សេចក្តីត្រេកអរ ក្នុងសក្កាយក្តី ក៏មិនបានកើត

សោ កាមនន្ទិយាបិ អនុសយា ព្យាបាទនន្ទិយាបិ អនុសយា វិហេសានន្ទិយាបិ អនុសយា រូបនន្ទិយាបិ អនុសយា សក្កាយនន្ទិយាបិ អនុសយា អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ និរាលយោ អច្ឆេជ្ជិ តណ្ហំ វិវត្តយិ សញ្ញោជនំ សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្ស ។ ឥមា ខោ ភិក្ខវេ បញ្ច និស្សារណីយា ធាតុយោតិ ។

ព្រាហ្មណវគ្គោ បញ្ចមោ ។

ចតុត្ថោ បណ្ណាសកោ និដ្ឋិតោ ។

## តស្សុទ្ទានំ

សោណោ ទោណោ សង្គារវោ
ការណបាលី ច បិង្គិយានី
សុបិនា ច វស្សា វាចា
កុលំ និស្សារណីយេន ចាតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះគេថាគតពោលថា មិនមានសេចក្តីអាល័យ បានផ្តាច់បង់នូវតណ្ហា បានកំចាត់កំចាយនូវសញ្ញោជនៈ ព្រោះមិនដេកត្រាំក្នុងសេចក្តីត្រេកអរក្នុងកាមផង មិនដេកត្រាំក្នុងសេចក្តីត្រេកអរក្នុងព្យាបាទផង មិនដេកត្រាំក្នុងសេចក្តីត្រេកអរក្នុងការបៀតបៀនផង មិនដេកត្រាំក្នុងសេចក្តីត្រេកអរក្នុងរូបផង មិនដេកត្រាំក្នុងសេចក្តីត្រេកអរក្នុងសក្កាយផង ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះបានត្រាស់ដឹងនូវមានះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ធាតុទាំងឡាយ ដែលគួររលាស់ចេញ មាន ៥ យ៉ាងនេះឯង ។

ចប់ ព្រាហ្មណវគ្គ ទី ៥ ។

ចប់ បណ្ណាសក ទី ៤ ។

## ឧទ្ទាននៃព្រាហ្មណវគ្គនោះគឺ

និយាយអំពីសោណព្រាហ្មណ៍ ១ ទោណព្រាហ្មណ៍ ១ សង្គារវព្រាហ្មណ៍ ១ ការណបាលិព្រាហ្មណ៍ ១ បិង្គិយានិព្រាហ្មណ៍ ១ មហាសុបិន ១ វស្សន្តរាយ ១ វាចា ១ ត្រកូល ១ ធាតុទាំងឡាយ ដែលគួររលាស់ចេញ ១ ។

## បញ្ចមបណ្ណាសកោ

## កិមិលវគ្គោ (១)

(១០១) ឯកំ សមយំ ភគវា កិមិលាយំ(២) វិហរតិ វេឡុវនេ ។ អថខោ អាយស្មា កិមិលោ(៣) យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា កិមិលោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតីតិ ។ ឥធ កិមិល តថាគតេ បរិនិព្វុតេ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ សត្ថរិ អគារវា វិហរន្តិ អប្បតិស្សា ធម្មេ អគារវា វិហរន្តិ អប្បតិស្សា សង្ឃេ អគារវា វិហរន្តិ អប្បតិស្សា សិក្ខាយ អគារវា វិហរន្តិ អប្បតិស្សា អញ្ញមញ្ញំ អគារវា វិហរន្តិ អប្បតិស្សា ។ អយំ ខោ កិមិល ហេតុ អយំ បច្ចយោ

---

១-២-៣ ឱ. កិម្ពិលវគ្គោ ។ កិម្ពិលាយំ ។ កិម្ពិលោ ។

## បញ្ចមបណ្ណាសក

## កិមិលវគ្គ

[១០១] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងវត្តវេឡុវ័ន ជិតស្រុកកិមិលា ។ គ្រានោះ ព្រះកិមិលៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះកិមិលៈដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅ ព្រះសទ្ធម្មមិនប្រតិស្ឋានទៅយូរបាន ។ ម្នាលកិមិល កាលព្រះតថាគតបរិនិព្វានទៅ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងសាសនានេះ មិនគោរព មិនកោតក្រែងក្នុងព្រះសាស្តា មិនគោរព មិនកោតក្រែង ក្នុងព្រះធម៌ មិនគោរព មិនកោតក្រែង ក្នុងព្រះសង្ឃ មិនគោរព មិនកោតក្រែង ក្នុងសិក្ខា មិនគោរព មិនកោតក្រែង នូវគ្នានឹងគ្នា ។ ម្នាលកិមិលៈ នេះឯងជាហេតុ នេះជាបច្ច័យ

យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតីតិ ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។ ឥធ កិមិល តថាគតេ បរិនិព្វុតេ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ សត្ថរិ សគារវា វិហរន្តិ សប្បតិស្សា ធម្មេ សគារវា វិហរន្តិ សប្បតិស្សា សង្ឃេ សគារវា វិហរន្តិ សប្បតិស្សា សិក្ខាយ សគារវា វិហរន្តិ សប្បតិស្សា អញ្ញមញ្ញំ សគារវា វិហរន្តិ សប្បតិស្សា ។ អយំ ខោ កិមិល ហេតុ អយំ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។

(១០២) បញ្ចិមេ ភិក្ខវេ អានិសំសា ធម្មស្សវនេ ។ កតមេ បញ្ច ។ អស្សុតំ សុណាតិ សុតំ បរិយោទបេតិ កង្ខំ វិហនតិ ទិដ្ឋឹ ឧជុំ ករោតិ ចិត្តមស្ស បសីទតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា ធម្មស្សវនេតិ ។

ដែលព្រះតថាគតបរិនិព្វានទៅ ព្រះសទ្ធម្មមិនប្រតិស្ឋាននៅយូរបាន ។ បពិត្រព្រះអង្គដ៏ចំរើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅ ព្រះសទ្ធម្មប្រតិស្ឋាននៅយូរបាន ។ ម្នាលកិមិលៈ កាលព្រះតថាគតបរិនិព្វានទៅ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងសាសនានេះ មានសេចក្តីគោរពកោតក្រែង ក្នុងព្រះសាស្តា មានសេចក្តីគោរពកោតក្រែង ក្នុងព្រះធម៌ មានសេចក្តីគោរពកោតក្រែង ក្នុងព្រះសង្ឃ មានសេចក្តីគោរពកោតក្រែង ក្នុងសិក្ខា មានសេចក្តីគោរពកោតក្រែងនូវគ្នានឹងគ្នា ។ ម្នាលកិមិលៈ នេះឯង ជាហេតុ នេះជាបច្ច័យ ដែលព្រះតថាគតបរិនិព្វានទៅ ព្រះសទ្ធម្មប្រតិស្ឋាននៅយូរបាន ។

[ ១០២ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃការស្តាប់ព្រះសទ្ធម្មនេះមាន៥យ៉ាង ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺអ្នកស្តាប់តែងបានស្តាប់រឿងមិនទាន់បានស្តាប់១ រឿងណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្តច្បាស់នឹងចូលចិត្តច្បាស់ឡើងបាន១ កំចាត់បង់សេចក្តីសង្ស័យចេញបាន១ ធ្វើសេចក្តីយល់ឃើញឲ្យត្រង់១ ចិត្តអ្នកស្តាប់ រមែងជ្រះថ្លា១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃការស្តាប់ធម៌មាន៥យ៉ាងនេះឯង ។

(១០៣) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានិយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ កតមេហិ បញ្ចហិ ។ អាជ្ជវេន ជវេន មទ្ទវេន ខន្តិយា សោរច្ចេន ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានិយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ បញ្ចហិ ។ អាជ្ជវេន ជវេន មទ្ទវេន ខន្តិយា សោរច្ចេន ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(១០៣) ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចំរើនរបស់ព្រះរាជា ប្រកបដោយអង្គ ៥ ជាសេះគួរដល់ព្រះរាជា ជាទីប្រើប្រាស់របស់ព្រះរាជា ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ប្រកបដោយអង្គ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមានចិត្តត្រង់ ១ មានសន្ទុះលឿន ១ មានចិត្តទន់ ១ មានចិត្តអត់ធន់ ១ មានចិត្តស្ងប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចំរើនរបស់ព្រះរាជា ប្រកបដោយអង្គទាំង ៥ នេះ ទើបជាសេះគួរដល់ព្រះរាជា ជាទីប្រើប្រាស់របស់ព្រះរាជា ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៥ ក៏យ៉ាងនោះដែរ ទើបជាអ្នកគួរទទួលគ្រឿងបូជា គួរទទួលអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរធ្វើអញ្ជលី ជាបុញ្ញក្ខេត្តរបស់សត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ ប្រកបដោយអង្គ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមានចិត្តត្រង់ ១ មានសន្ទុះលឿន ១ មានចិត្តទន់ ១ មានចិត្តអំណត់ ១ មានចិត្តស្ងប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ ទើបជាអ្នកគួរទទួលគ្រឿងបូជា គួរទទួលអាគន្តុកទាន គួរដល់ទក្ខិណាទាន គួរធ្វើអញ្ជលី ជាបុញ្ញក្ខេត្តរបស់សត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

(១០៤) បញ្ចិមានិ ភិក្ខវេ ពលានិ ។ កតមានិ បញ្ច ។ សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ពលានីតិ ។

(១០៥) បញ្ចិមេ ភិក្ខវេ ចេតោខីលា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បឋមោ ចេតោខីលោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេ... សង្ឃេ... សិក្ខាយ... សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ ។ យោ សោ ភិក្ខវេ ភិក្ខុ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ តស្ស ចិត្តំ

(១០៤) ម្នាលភិក្ខុទាំងឡាយ ពលៈនេះមាន ៥ យ៉ាង ។ ពលៈ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសទ្ធាពលៈ ១ ហិរិពលៈ ១ ឱត្តប្បពលៈ ១ វីរិយពលៈ ១ បញ្ញាពលៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ពលៈមាន ៥ យ៉ាងនេះឯង ។

(១០៥) ម្នាលភិក្ខុទាំងឡាយ ចំរើនចិត្តនេះមាន ៥ យ៉ាង ។ ចំរើនចិត្ត ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាសង្ស័យ ងឿងឆ្ងល់មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅ ដើម្បីផុតកំដៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីផុតកំដៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ នេះជាចំរើនចិត្តទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងព្រះធម៌... ក្នុងព្រះសង្ឃ... ក្នុងសិក្ខា... ភិក្ខុមានចិត្តខឹងអាក់អន់គ្នាន់គ្នាញ់ របឹងរឹងរូសក្នុងសព្រហ្មចារីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មានចិត្តខឹងអាក់អន់គ្នាន់គ្នាញ់ របឹងរឹងរូសក្នុងសព្រហ្មចារីទាំងឡាយ ចិត្តរបស់ភិក្ខុនោះ

ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បញ្ចមោ ចេតោខិលោ ។ ឥមេ ខោ ភិក្ខវេ បញ្ច ចេតោខិលាតិ ។

(២០៦) បញ្ចិមេ ភិក្ខវេ ចេតសោ វិនិពន្ធា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ កាមេសុ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតបេមោ អវិគតបិបាសោ អវិគតបរិឡាហោ អវិគតតណ្ហោ ។ យោ សោ ភិក្ខវេ ភិក្ខុ កាមេសុ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតបេមោ អវិគតបិបាសោ អវិគតបរិឡាហោ អវិគតតណ្ហោ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បឋមោ ចេតសោ វិនិពន្ធោ ។

មិនបង្អោនទៅ ដើម្បីផុតកំដៅកិលេស ដើម្បីប្រែកប្រឿយ ៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីផុតកំដៅកិលេស ដើម្បីប្រែកប្រឿយ ៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ នេះជាចំណងនៃចិត្តទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ចំណងនៃចិត្តមាន ៥ យ៉ាងនេះឯង ។

[១០៦] ម្នាលភិក្ខុទាំងឡាយ ចំណងនៃចិត្តនេះមាន ៥ យ៉ាង ។ ចំណងនៃចិត្ត ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកឆន្ទៈ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្រហល់ក្រហាយ មិនទាន់ប្រាសចាកតណ្ហា ក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកឆន្ទៈ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្រហល់ក្រហាយ មិនទាន់ប្រាសចាកតណ្ហា ក្នុងកាមទាំងឡាយ ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅ ដើម្បីផុតកំដៅកិលេស ដើម្បីប្រែកប្រឿយ ៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីផុតកំដៅកិលេស ដើម្បីប្រែកប្រឿយ ៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ នេះជាចំណងនៃចិត្តទី ១ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ កាយេ អវីតរាគោ ហោតិ... រូបេ អវីតរាគោ ហោតិ... យាវទត្ថំ ឧទរាវទេហកំ ភុញ្ជិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរតិ.. អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ ។ យោ សោ ភិក្ខវេ ភិក្ខុ អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បញ្ចមោ ចេតសោ វិនិពន្ធោ ។ ឥមេ ខោ ភិក្ខវេ បញ្ច ចេតសោ វិនិពន្ធាតិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ... មិនទាន់ប្រាសចាកតម្រេកក្នុងរូប... បរិភោគទាល់តែឆ្អែតពេញពោះ ប្រកបការដេកជាសុខ ផ្អែកជាសុខ លក់ជាសុខ... ប្រព្រឹត្តព្រហ្មចរិយៈដោយប្រាថ្នា នូវទេវនិកាយណាមួយថា អាត្មាអញនឹងបានជាទេវតាសក្តិធំ ឬទេវតាសក្តិតូច ដោយសីលនេះ វត្តនេះ សេចក្តីព្យាយាមនេះឬដោយព្រហ្មចរិយៈនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាប្រព្រឹត្តព្រហ្មចរិយៈដោយប្រាថ្នាទេវនិកាយណាមួយថា អាត្មាអញនឹងបានជាទេវតាសក្តិធំ ឬទេវតាសក្តិតូច ដោយសីលនេះ វត្តនេះ សេចក្តីព្យាយាមនេះឬដោយព្រហ្មចរិយៈនេះ ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅដើម្បីដុតកំដៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីដុតកំដៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ នេះជាចំណងនៃចិត្តទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ចំណងនៃចិត្តមាន ៥ យ៉ាងនេះឯង ។

(១០៧) បញ្ចិមេ ភិក្ខវេ អានិសំសា យាគុយា ។ កតមេ បញ្ច ។ ខុទ្ទំ បដិហនតិ បិបាសំ បដិវិនេតិ វាតំ អនុលោមេតិ វត្ថឹ សោធេតិ អាមាវសេសំ បាចេតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា យាគុយាតិ ។

(១០៨) បញ្ចិមេ ភិក្ខវេ អាទីនវា ទន្តកដ្ឋស្ស អខាទនេ ។ កតមេ បញ្ច ។ អចក្ខុស្សំ មុខំ ទុគ្គន្ធំ ហោតិ រសហរណិយោ ន វិសុជ្ឈន្តិ បិត្តំ សេម្ហំ ភត្តំ បរិយោនទ្ធតិ ភត្តមស្ស នច្ឆាទេតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា ទន្តកដ្ឋស្ស អខាទនេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា ទន្តកដ្ឋស្ស ខាទនេ ។ កតមេ បញ្ច ។ ចក្ខុស្សំ មុខំ ន ទុគ្គន្ធំ ហោតិ រសហរណិយោ វិសុជ្ឈន្តិ បិត្តំ សេម្ហំ ភត្តំ ន បរិយោនទ្ធតិ ភត្តមស្ស ឆាទេតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា ទន្តកដ្ឋស្ស ខាទនេតិ ។

(១០៧) ម្នាលភិក្ខុទាំងឡាយ អានិសង្សបបរនេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺកំចាត់បង់សេចក្តីឃ្លាន ១ កំចាត់បង់សេចក្តីស្រេក ១ ញុំាងខ្យល់ឲ្យប្រព្រឹត្តទៅសព្វ ១ ញុំាងសរសៃឲ្យស្អាត ១ ញុំាងអាហារថ្មីដែលនៅសល់ឲ្យឆ្អិន ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សបបរ មាន ៥ យ៉ាងនេះឯង ។

(១០៨) ម្នាលភិក្ខុទាំងឡាយ ទោសក្នុងការមិនទំពាឈើស្ទន់នេះមាន ៥ យ៉ាង ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមានចក្ខុមិនស្អាត ១ មាត់មានក្លិនស្អុយ ១ សរសៃនាំរសអាហារមិនបរិសុទ្ធ ១ ប្រមាត់ទឹកស្លេស្មរួបរឹតបាយ ១ មិនឆ្ងាញ់បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសក្នុងការមិនទំពាឈើស្ទន់មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការទំពាឈើស្ទន់នេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺនាំឲ្យមានចក្ខុស្អាត ១ មាត់មិនមានក្លិនស្អុយ ១ សរសៃនាំរសអាហារបរិសុទ្ធ ១ ប្រមាត់ទឹកស្លេស្មមិនរួបរឹតបាយ ១ ឆ្ងាញ់បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការទំពាឈើស្ទន់មាន ៥ យ៉ាងនេះឯង ។

(១០៩) បញ្ចិមេ ភិក្ខវេ អាទីនវា អាយតកេន គីតស្សរេន ធម្មំ ភណន្តស្ស ។ កតមេ បញ្ច ។ អត្តនាបិ តស្មិំ សរេ សារជ្ជតិ បរេបិ តស្មិំ សរេ សារជ្ជន្តិ គហបតិកាបិ ឧជ្ឈាយន្តិ យថេវ មយំ គាយាម ឯវមេវិមេ សមណា សក្យបុត្តិយា គាយន្តីតិ សរកុត្តិម្បិ និកាមយមានស្ស សមាធិស្ស ភង្គោ ហោតិ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា អាយតកេន គីតស្សរេន ធម្មំ ភណន្តស្សាតិ ។

(១១០) បញ្ចិមេ ភិក្ខវេ អាទីនវា មុដ្ឋស្សតិស្ស អសម្បជានស្ស និទ្ទំ ឱក្កមតោ ។ កតមេ បញ្ច ។ ទុក្ខំ សុបតិ ទុក្ខំ បដិពុជ្ឈតិ បាបកំ សុបិនំ បស្សតិ ទេវតា ន រក្ខន្តិ អសុចិ មុច្ចតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា មុដ្ឋស្សតិស្ស អសម្បជានស្ស និទ្ទំ ឱក្កមតោ ។ បញ្ចិមេ ភិក្ខវេ អានិសំសា ឧបដ្ឋិតស្សតិស្ស សម្បជានស្ស និទ្ទំ ឱក្កមតោ ។ កតមេ បញ្ច ។ សុខំ សុបតិ

(១០៩) ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលពោលធម៌ដោយសំឡេងច្រៀងវែងនេះមាន ៥ យ៉ាង ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺខ្លួនឯងក៏ត្រេកអរ ក្នុងសំឡេងនោះ ១ ជនទាំងឡាយដទៃ ក៏ត្រេកអរ ក្នុងសំឡេងនោះ ១ គហបតីទាំងឡាយ ពោលទោសថា ពួកយើងច្រៀងយ៉ាងណា ពួកសមណសក្យបុត្តិយ៍ទាំងនេះ ក៏ច្រៀងយ៉ាងនោះដែរ ១ បុគ្គលពេញចិត្តក្នុងការស្រូតរលាក់រលែកសំឡេង រមែងខូចសមាធិ ១ ពួកជនខាងក្រោយនឹងដល់នូវទិដ្ឋានុគតិ (យកតម្រាប់តាម) ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលពោលធម៌ ដោយសំឡេងច្រៀងវែង មាន ៥ យ៉ាងនេះឯង ។

(១១០) ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលដេកលក់ ភ្លេចស្មារតី មិនដឹងខ្លួននេះមាន ៥ យ៉ាង ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺដេកលក់ជាទុក្ខ ១ ភ្ញាក់ឡើងជាទុក្ខ ១ យល់សប្តិអាក្រក់ ១ ទេវតាមិនរក្សា ១ អសុចិហូរចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលដេកលក់ ភ្លេចស្មារតី មិនដឹងខ្លួន មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គលដេកលក់ ប្រុងស្មារតី ដឹងខ្លួននេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺដេកលក់ជាសុខ ១

សុខំ បដិពុជ្ឈតិ ន បាបកំ សុបិនំ បស្សតិ ទេវតា រក្ខន្តិ អសុចិ ន មុច្ចតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា ឧបដ្ឋិតស្សតិស្ស សម្បជានស្ស និទ្ទំ ឱក្កមតោតិ ។

កិមិលវគ្គោ បឋមោ ។

## តស្សុទ្ទានំ

កិមិលោ ធម្មស្សវនំ
អាជានី ច ពលំ ខីលំ
វិនិពន្ធំ យាគុ កដ្ឋំ គីតំ
មុដ្ឋស្សតីបិ ចាតិ ។

## បញ្ចមបណ្ណាសក កិមិលវគ្គ

ញាក់ឡើងជាសុខ ១ មិនយល់សប្តិអាក្រក់ ១ ទេវតារក្សា ១ អសុចិមិនហូរចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គលដេកលក់ប្រុងស្មារតី ដឹងខ្លួន មាន ៥ យ៉ាងនេះឯង ។

ចប់ កិមិលវគ្គ ទី ១ ។

## ឧទ្ទាននៃកិមិលវគ្គនោះគឺ

ពោលអំពីរឿងកិមិលត្ថេរ ១ អំពីអានិសង្សស្តាប់ធម៌ ១ អំពីសេះអាជានេយ្យ ១ អំពីធម៌ជាកម្លាំង ១ អំពីចំរើននៃចិត្ត ១ អំពីចំណាននៃចិត្ត ១ អំពីអានិសង្សបបរ ១ អំពីឈើស្ទន់ ១ អំពីការពោលធម៌ដោយសំឡេងច្រៀងវែង ១ អំពីការដេកលក់ ភ្លេចស្មារតី ១ ។

# អក្កោសកវគ្គោ

(១១១) យោ សោ ភិក្ខវេ ភិក្ខុ អក្កោសក-
បរិភាសកោ អរិយុបវាទី សព្រហ្មចារីនំ តស្ស បញ្ច
អាទីនវា បាដិកង្ខា ។ កតមេ បញ្ច ។ បារាជិកោ
វា ហោតិ ឆិន្នបរិបន្ថោ អញ្ញតរំ វា សង្កិលិដ្ឋំ អាបត្តឹ
អាបជ្ជតិ ពាឡ្ហំ វា រោគាតង្កំ ផុសតិ សម្មូឡ្ហោ
កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ
ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ យោ សោ ភិក្ខវេ
ភិក្ខុ អក្កោសកបរិភាសកោ អរិយុបវាទី សព្រហ្ម-
ចារីនំ តស្ស ឥមេ បញ្ច អាទីនវា បាដិកង្ខាតិ ។

(១១២) យោ សោ ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ
កលហការកោ វិវាទការកោ ភស្សការកោ
សង្ឃេ អធិករណការកោ តស្ស បញ្ច អាទីនវា
បាដិកង្ខា ។ កតមេ បញ្ច ។ អនធិគតំ នាធិគច្ឆតិ
អធិគតំ បរិហាយតិ បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ
សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា
អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។

# អក្កោសកវគ្គ

(១១១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជេរ ប្រទេច តិះដៀល ព្រះអរិយៈ ចំពោះសព្រហ្មចារីទាំងឡាយ ទោស ៥ យ៉ាង តែងប្រាកដឡើងដល់ភិក្ខុនោះ ៗ ទោស ៥ យ៉ាងគឺអ្វីខ្លះ ៗ គឺជាអ្នកត្រូវបារាជិក អស់ផ្លូវកែខៃ ១ ជាអ្នកត្រូវអាបត្តិដ៏សៅហ្មងណាមួយ ១ ជាអ្នកប៉ះពាល់នូវរោគយ៉ាងធ្ងន់ ១ ជាអ្នកស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជេរ ប្រទេច តិះដៀល ព្រះអរិយៈ ចំពោះសព្រហ្មចារីទាំងឡាយ ទោស ៥ យ៉ាងនេះ តែងប្រាកដឡើងដល់ភិក្ខុនោះ ៗ

(១១២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកធ្វើនូវសេចក្តីប្រកួតប្រកាន់ ធ្វើនូវជំលោះ ធ្វើនូវវិវាទ ធ្វើនូវតិរច្ឆានកថា ធ្វើនូវអធិករណ៍ក្នុងសង្ឃ ទោស ៥ យ៉ាង តែងប្រាកដឡើងដល់ភិក្ខុនោះ ៗ ទោស ៥ យ៉ាងគឺអ្វីខ្លះ ៗ គឺមិនបានគុណវិសេសដែលខ្លួនមិនទាន់បាន ១ គុណវិសេសដែលខ្លួនបានហើយសាបសូន្យទៅវិញ ១ កិត្តិសព្ទអាក្រក់រមែងខ្ចរខ្ចាយទៅ ១ ស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ៗ

យោ ហោ ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ តស្ស ឥមេ បញ្ច អាទីនវា បាដិកង្ខាតិ ។

(១១៣) បញ្ចិមេ ភិក្ខវេ អាទីនវា ទុស្សីលស្ស សីលវិបត្តិយា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ទុស្សីលោ សីលវិបន្នោ បមាទាធិករណំ មហតឹ ភោគជានឹ និគច្ឆតិ អយំ ភិក្ខវេ បឋមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ ភិក្ខវេ ទុស្សីលស្ស សីលវិបន្នស្ស បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អយំ ភិក្ខវេ ទុតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ ភិក្ខវេ ទុស្សីលោ សីលវិបន្នោ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ អវិសារទោ ឧបសង្កមតិ មង្កុភូតោ អយំ ភិក្ខវេ តតិយោ អាទីនវោ ទុស្សីលស្ស

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើជំលោះ ធ្វើវិវាទ ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ ទោស៥ យ៉ាងនេះ តែងប្រាកដឡើងដល់ភិក្ខុនោះ ។

(១១៣) ម្នាលភិក្ខុទាំងឡាយ ទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលនេះ មាន៥យ៉ាង ។ ទោស៥យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ក្នុងលោកនេះ តែងដល់នូវសេចក្តីវិនាសសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីប្រមាទ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី១ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីលហើយ តែងមានកិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី២ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា ទោះបីជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ក៏គ្មានក្លៀវក្លា តែងមានមុខឱនចុះដើរចូលទៅ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៣ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល

សីលវិបត្តិយា ។ បុន ចបរំ ភិក្ខវេ ទុស្សីលោ សីលវិបន្នោ សម្មូឡ្ហោ កាលំ ករោតិ អយំ ភិក្ខវេ ចតុត្ថោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ ភិក្ខវេ ទុស្សីលោ សីលវិបន្នោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ អយំ ភិក្ខវេ បញ្ចមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា ទុស្សីលស្ស សីលវិបត្តិយា ។ បញ្ចិមេ ភិក្ខវេ អានិសំសា សីលវតោ សីលសម្បទាយ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ សីលវា សីលសម្បន្នោ អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ អយំ ភិក្ខវេ បឋមោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ ភិក្ខវេ សីលវតោ សីលសម្បន្នស្ស កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អយំ ភិក្ខវេ ទុតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ ភិក្ខវេ សីលវា សីលសម្បន្នោ យញ្ញទេវ បរិសំ ឧបសង្កមតិ

វិបត្តិចាកសីល តែងស្លាប់វង្វេងស្មារតី ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៤ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីលហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតជាតិរច្ឆាន ប្រេត អសុរកាយ នឹងនរក ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៥ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ ទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសីលសម្បទារបស់បុគ្គលមានសីលនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសីល បរិបូណ៌ដោយសីលក្នុងលោកនេះ តែងបាននូវគំនរសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីមិនប្រមាទ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ១ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ តែងមានកិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ២ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា

យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ អយំ ភិក្ខវេ តតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ ភិក្ខវេ សីលវា សីលសម្បន្នោ អសម្មូឡ្ហោ កាលំ ករោតិ អយំ ភិក្ខវេ ចតុត្ថោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ ភិក្ខវេ សីលវា សីលសម្បន្នោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ អយំ ភិក្ខវេ បញ្ចមោ អានិសំសោ សីលវតោ សីលសម្បទាយ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា សីលវតោ សីល-សម្បទាយាតិ ។

(១១៤) បញ្ចិមេ ភិក្ខវេ អាទីនវា ពហុភាណិស្មឹ បុគ្គលេ ។ កតមេ បញ្ច ។ មុសា ភណតិ បិសុណំ ភណតិ ផរុសំ ភណតិ សម្ផប្បលាបំ ភណតិ

ទោះបីជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី តែងក្លៀវក្លា មិនឱនមុខចុះ ដើរចូលទៅ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៣ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល តែងស្លាប់ មិនវង្វេងស្មារតីឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៤ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៥ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសីលសម្បទារបស់បុគ្គលមានសីល មាន ៥ យ៉ាងនេះឯង ។

[១១៤] ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលនិយាយច្រើននេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង តើអ្វីខ្លះ ។ គឺនិយាយកុហក ១ និយាយញុះញង់ ១ និយាយពាក្យអាក្រក់ ១ និយាយពាក្យឥតប្រយោជន៍ ១

កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា ពហុភាណិស្មឹ បុគ្គលេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា មន្តភាណិស្មឹ បុគ្គលេ ។ កតមេ បញ្ច ។ ន មុសា ភណតិ ន បិសុណំ ភណតិ ន ផរុសំ ភណតិ ន សម្ផប្បលាបំ ភណតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា មន្តភាណិស្មឹ បុគ្គលេតិ ។

(១១៩) បញ្ចិមេ ភិក្ខវេ អាទីនវា អក្ខន្តិយា ។ កតមេ បញ្ច ។ ពហុនោ ជនស្ស អប្បិយោ ហោតិ អមនាបោ វេរពហុលោ ច ហោតិ វជ្ជពហុលោ ច សម្មុឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្ម-រណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា អក្ខន្តិយា ។ បញ្ចិមេ ភិក្ខវេ អានិសំសា ខន្តិយា ។

លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ នឹងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលនិយាយច្រើន មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គលនិយាយតិចនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមិននិយាយកុហក ១ មិននិយាយញុះញង់ ១ មិននិយាយពាក្យអាក្រក់ ១ មិននិយាយឥតប្រយោជន៍ ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គលនិយាយតិច មាន ៥ យ៉ាងនេះឯង ។

(១១៥) ម្នាលភិក្ខុទាំងឡាយ ទោសនៃសេចក្តីមិនអត់ធន់នេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់ជនច្រើន ១ ជាអ្នកច្រើនដោយពៀរ ១ ច្រើនដោយទោស ១ តែងស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ នឹងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសនៃសេចក្តីមិនអត់ធន់ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសេចក្តីអត់ធន់នេះ មាន ៥ យ៉ាង ។

កតមេ បញ្ច ។ ពហុនោ ជនស្ស បិយោ ហោតិ មនាបោ ន វេរពហុលោ ហោតិ ន វជ្ជពហុលោ អសម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា ខន្តិយាតិ ។

(១១៦) បញ្ចិមេ ភិក្ខវេ អាទីនវា អក្ខន្តិយា ។ កតមេ បញ្ច ។ ពហុនោ ជនស្ស អប្បិយោ ហោតិ អមនាបោ លុទ្ទោ ច ហោតិ វិប្បដិសារី ច សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា អក្ខន្តិយា ។ បញ្ចិមេ ភិក្ខវេ អានិសំសា ខន្តិយា ។ កតមេ បញ្ច ។ ពហុនោ ជនស្ស បិយោ ហោតិ មនាបោ អលុទ្ទោ ច ហោតិ អវិប្បដិសារី ច អសម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា ខន្តិយាតិ ។

អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ជនច្រើន ១ មិនច្រើនដោយពៀរ ១ មិនច្រើនដោយទោស ១ តែងស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសេចក្តីអត់ធន់ មាន ៥ យ៉ាងនេះឯង ។

[១១៦] ម្នាលភិក្ខុទាំងឡាយ ទោសនៃសេចក្តីមិនអត់ធន់ នេះមាន ៥ យ៉ាង ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់ជនច្រើន ១ ជាមនុស្សអាក្រក់ ១ ជាមនុស្សមានសេចក្តីក្តៅក្រហាយ ១ តែងស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ នឹងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសនៃសេចក្តីមិនអត់ធន់ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសេចក្តីអត់ធន់នេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ជនច្រើន ១ មិនជាមនុស្សអាក្រក់ ១ មិនក្តៅក្រហាយ ១ តែងស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសេចក្តីអត់ធន់ មាន ៥ យ៉ាងនេះឯង ។

(១១៧) បញ្ចិមេ ភិក្ខវេ អាទីនវា អបាសា-ទិកេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ឧបវទតិ អនុវិច្ច វិញ្ញូ គរហន្តិ បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា អបាសាទិកេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា បាសាទិកេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ន ឧបវទតិ អនុវិច្ច វិញ្ញូ បសំសន្តិ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អសម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា បាសាទិកេតិ ។

[ ១១៧ ] ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គល អ្នកមានអំពើមិនជាទីជ្រះថ្លា នេះមាន ៥ យ៉ាង ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺខ្លួនឯង ក៏តិះដៀលខ្លួនបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយ រមែងតិះដៀលបាន ១ កិត្តិសព្ទអាក្រក់ខ្ចរខ្ចាយទៅ ១ តែងស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ ទីងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គល អ្នកមានអំពើមិនជាទីជ្រះថ្លា មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គល អ្នកមានអំពើជាទីជ្រះថ្លា នេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺខ្លួនឯង តិះដៀលខ្លួនឯងមិនបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយ រមែងសរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ តែងស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គល អ្នកមានអំពើជាទីជ្រះថ្លា មាន ៥ យ៉ាងនេះឯង ។

[១១៨] បញ្ចិមេ ភិក្ខវេ អាទីនវា អប្បាសាទិកេ ។ កតមេ បញ្ច អប្បសន្នា នប្បសីទន្តិ បសន្នានំ ឯកច្ចានំ អញ្ញថត្តំ ហោតិ សត្ថុ សាសនំ អកតំ ហោតិ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ ចិត្តមស្ស នប្បសីទតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា អប្បាសាទិកេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា បាសាទិកេ ។ កតមេ បញ្ច ។ អប្បសន្នា បសីទន្តិ បសន្នានំ ភិយ្យោភាវោ ហោតិ សត្ថុ សាសនំ កតំ ហោតិ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ ចិត្តមស្ស បសីទតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា បាសាទិកេតិ ។

[១១៩] បញ្ចិមេ ភិក្ខវេ អាទីនវា អគ្គិស្មឹ ។ កតមេ បញ្ច ។ អចក្ខុស្សោ ទុព្វណ្ណករណោ ទុព្វលករណោ សង្គណិកាវឌ្ឍនោ(១) តិរច្ឆានកថាបវត្តនិកោ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា អគ្គិស្មិន្តិ ។

---

១ ម. សង្គណិការាមវឌ្ឍនោ ។

(១១៨) ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គល អ្នកមានអំពើមិនជាទីជ្រះថ្លា នេះមាន ៥ យ៉ាង ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺពួកជនដែលមិនទាន់ជ្រះថ្លា រមែងមិនជ្រះថ្លា ១ ពួកជនខ្លះដែលជ្រះថ្លាហើយ ក៏ត្រឡប់ជាងាកចិត្តចេញ ១ ឈ្មោះថា មិនធ្វើតាមពាក្យប្រដៅរបស់ព្រះសាស្តា ១ ប្រជុំជនខាងក្រោយនឹងយកតម្រាប់តាម ១ ចិត្តរបស់បុគ្គលនោះមិនជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលអ្នកមានអំពើមិនជាទីជ្រះថ្លា មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គល អ្នកមានអំពើជាទីជ្រះថ្លា នេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺពួកជនដែលមិនទាន់ជ្រះថ្លា រមែងជ្រះថ្លា ១ ពួកជនដែលជ្រះថ្លារួចហើយ រឹតតែជ្រះថ្លាឡើង ១ ឈ្មោះថា ធ្វើតាមពាក្យប្រដៅរបស់ព្រះសាស្តា ១ ប្រជុំជនខាងក្រោយនឹងយកតម្រាប់តាម ១ ចិត្តរបស់បុគ្គលនោះ រមែងជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គល អ្នកមានអំពើជាទីជ្រះថ្លា មាន ៥ យ៉ាងនេះឯង ។

(១១៩) ម្នាលភិក្ខុទាំងឡាយ ទោសក្នុងភ្លើងនេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺឲ្យងងឹតភ្នែក ១ ធ្វើសម្បុរឲ្យអាក្រក់ ១ ធ្វើកម្លាំងឲ្យខ្សោយ ១ គុះគរដោយពួកគណៈ ១ ប្រព្រឹត្តទៅដើម្បីតិរច្ឆានកថា ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសក្នុងភ្លើង មាន ៥ យ៉ាងនេះឯង ។

(១២០) បញ្ចិមេ ភិក្ខវេ អាទីនវា មធុរាយំ ។ កតមេ បញ្ច ។ វិសមា ពហុរជា ចណ្ឌសុនខា វាឡយក្ខា ទុល្លភបិណ្ឌា ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា មធុរាយន្តិ ។

អក្កោសកវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

អក្កោសកភណ្ឌនសីលំ
ពហុភាណី ទ្វេ អខន្តិយោ
អបាសាទិកា ទ្វេ វុត្តា
អគ្គិស្មិំ មធុរេន ចាតិ ។

(១២០) ម្នាលភិក្ខុទាំងឡាយ ទោសក្នុងដែនមធុរានេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺទីមិនស្មើ ១ មានធូលីច្រើន ១ មានឆ្កែសាហាវ ១ មានយក្សកាច ១ រកបាយបានក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសក្នុងដែនមធុរា មាន ៥ យ៉ាងនេះឯង ។

ចប់ អក្កោសកវគ្គ ទី ២ ។

## ឧទ្ទាននៃអក្កោសកវគ្គនោះគឺ

ពោលអំពីរឿងជេរប្រទេច ១ អំពីរឿងប្រកួតប្រកាន់ ១ អំពីសីល ១ អំពីរឿងនិយាយច្រើន ១ អំពីសេចក្តីមិនអត់ធន់ ២ រឿង អំពីសេចក្តីមិនជ្រះថ្លា ២ រឿង អំពីទោសក្នុងភ្លើង ១ អំពីទោសក្នុងដែនមធុរា ១ ។

# ទីឃចារិកវគ្គោ

(១២១) បញ្ចិមេ ភិក្ខវេ អាទីនវា ទីឃចារិកំ អនវត្ថចារិកំ អនុយុត្តស្ស វិហរតោ ។ កតមេ បញ្ច ។ អស្សុតំ ន សុណាតិ សុតំ ន បរិយោទបេតិ សុតេនេកច្ចេន អវិសារទោ ហោតិ គាឡ្ហំ រោគាតង្កំ ផុសតិ ន ច មិត្តវា ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា ទីឃចារិកំ អនវត្ថចារិកំ អនុយុត្តស្ស វិហរតោ ។ បញ្ចិមេ ភិក្ខវេ អានិសំសា សមវត្ថចារេ ។ កតមេ បញ្ច ។ អស្សុតំ សុណាតិ សុតំ បរិយោទបេតិ សុតេនេកច្ចេន វិសារទោ ហោតិ ន គាឡ្ហំ រោគាតង្កំ ផុសតិ មិត្តវា ច ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា សមវត្ថចារេតិ ។

(១២២) បញ្ចិមេ ភិក្ខវេ អាទីនវា ទីឃចារិកំ អនវត្ថចារិកំ អនុយុត្តស្ស វិហរតោ ។ កតមេ បញ្ច ។ អនធិគតំ នាធិគច្ឆតិ អធិគតំ បរិហាយតិ

# ទីឃចារិកវគ្គ

[ ១៦១ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រកបរឿយៗ នូវការដើរឆ្ងាយ ដើរមិនឈប់ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺខានស្តាប់រឿង ដែលខ្លួនមិនធ្លាប់ស្តាប់ ១ រឿងដែលធ្លាប់ស្តាប់ហើយ មិនចូលចិត្តច្បាស់ ១ មិនក្លៀវក្លាដោយរឿងខ្លះដែលបានស្តាប់ហើយ ១ មានរោគធ្ងន់មកប៉ះពាល់ ១ ឥតមានមិត្រសំឡាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រកបរឿយៗ នូវការដើរឆ្ងាយ ដើរមិនឈប់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលដើរតែល្មមៗ ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺបានស្តាប់រឿងដែលមិនធ្លាប់បានស្តាប់១ រឿងធ្លាប់ស្តាប់ហើយនឹងចូលចិត្តច្បាស់ ១ ក្លៀវក្លាដោយរឿងខ្លះដែលបានស្តាប់ហើយ ១ មិនមានរោគជាទម្ងន់មកប៉ះពាល់ ១ មានមិត្រសំឡាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងបុគ្គលដើរតែល្មមៗ ។

[ ១៦២ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រកបរឿយៗ នូវការដើរឆ្ងាយ ដើរមិនឈប់ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមិនបានគុណវិសេសដែលខ្លួនមិនទាន់បាន ១ គុណវិសេសដែលខ្លួនបានហើយ ក៏សាបសូន្យទៅវិញ ១

អធិគតេនេកច្ចេន អវិសារទោ ហោតិ គាឡ្ហំ រោគាតង្កំ ផុសតិ ន ច មិត្តវា ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា ទីឃចារិកំ អនវត្ថចារិកំ អនុយុត្តស្ស វិហរតោ ។ បញ្ចិមេ ភិក្ខវេ អានិសំសា សមវត្ថចារេ ។ កតមេ បញ្ច ។ អនធិគតំ អធិគច្ឆតិ អធិគតំ ន បរិហាយតិ អធិគតេនេកច្ចេន វិសារទោ ហោតិ ន គាឡ្ហំ រោគាតង្កំ ផុសតិ មិត្តវា ច ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា សមវត្ថចារេតិ ។

(១២៣) បញ្ចិមេ ភិក្ខវេ អាទីនវា អតិនិវាសេ ។ កតមេ បញ្ច ។ ពហុភណ្ឌោ ហោតិ ពហុភណ្ឌសន្និចយោ ពហុភេសជ្ជោ ហោតិ ពហុភេសជ្ជសន្និចយោ ពហុកិច្ចោ ហោតិ ពហុករណីយោ ព្យត្តោ កឹករណីយេសុ សំសដ្ឋោ វិហរតិ គហដ្ឋបព្វជិតេហិ អននុលោមិកេន គិហិសំសគ្គេន តម្ហា ច អាវាសា បក្កមន្តោ សាបេក្ខោ បក្កមតិ ។

មិនក្តៀវក្តាដោយគុណវិសេសបន្តិចបន្តួច ដែលខ្លួនបានហើយ ១ មានរោគយ៉ាងធ្ងន់មកប៉ះពាល់ ១ ឥតមិត្រសំឡាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាង រមែងមានដល់បុគ្គលប្រកបរឿយៗនូវការដើរឆ្ងាយ ដើរមិនឈប់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលដើរតែល្មមៗ ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺគុណវិសេសដែលខ្លួនមិនបាន ក៏គង់នឹងបាន ១ គុណវិសេសដែលខ្លួនបានហើយមិនសាបសូន្យទៅវិញ ១ ក្តៀវក្តាដោយគុណវិសេសបន្តិចបន្តួចដែលខ្លួនបានហើយ ១ ឥតមានរោគយ៉ាងធ្ងន់មកប៉ះពាល់ ១ មានមិត្រសំឡាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលដើរតែល្មមៗ ។

(១២៣) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅជាប់មិនដាច់ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកមានទ្រព្យសម្បត្តិច្រើន សន្សំទ្រព្យសម្បត្តិច្រើន ១ ជាអ្នកមានភេសជ្ជៈច្រើន សន្សំភេសជ្ជៈច្រើន ១ ជាអ្នកមានកិច្ចការច្រើន ត្រូវធ្វើការច្រើន មិនឈ្លាសក្នុងកិច្ចការ ១ ច្រឡូកច្រឡំដោយពួកគ្រហស្ថនឹងបព្វជិត នៅរួមតែនឹងគ្រហស្ថដែលមិនសមគួរ ១ កាលបើចេញអំពីអាវាសនោះទៅ ចេញទៅទាំងអាឡោះអាល័យ ១ ។

ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា អតិនិវាសេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា សមវត្តនិវាសេ ។ កតមេ បញ្ច ។ ន ពហុភណ្ឌោ ហោតិ ន ពហុភណ្ឌសន្និចយោ ន ពហុភេសជ្ជោ ហោតិ ន ពហុភេសជ្ជសន្និចយោ ន ពហុកិច្ចោ ហោតិ ន ពហុករណីយោ ព្យត្តោ កឹករណីយេសុ អសំសដ្ឋោ វិហរតិ គហដ្ឋបព្វជិតេហិ អននុលោមិកេន គិហិសំសគ្គេន តម្ហា ច អាវាសា បក្កមន្តោ អនបេក្ខោ បក្កមតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា សមវត្តនិវាសេតិ ។

(១២៦) បញ្ចិមេ ភិក្ខវេ អាទីនវា អតិនិវាសេ ។ កតមេ បញ្ច ។ អាវាសមច្ឆរី ហោតិ កុលមច្ឆរី ហោតិ លាភមច្ឆរី ហោតិ វណ្ណមច្ឆរី ហោតិ ធម្មមច្ឆរី ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា អតិនិវាសេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា សមវត្តនិវាសេ ។ កតមេ បញ្ច ។

ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅជាប់មិនដាច់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅតែលម្មៗ ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមិនមានទ្រព្យសម្បត្តិច្រើន មិនសន្សំទ្រព្យសម្បត្តិច្រើន ១ មិនមានភេសជ្ជៈច្រើន មិនសន្សំភេសជ្ជៈច្រើន ១ មិនមានកិច្ចការច្រើន មិនត្រូវធ្វើកិច្ចការច្រើន ជាអ្នកឈ្លាសក្នុងការងារទាំងឡាយ ១ មិនប្រឡូកប្រឡំដោយពួកគ្រហស្ថនិងបព្វជិត មិននៅរួមជាមួយនឹងគ្រហស្ថដ៏មិនសមគួរ ១ កាលបើចៀសចេញពីអាវាសនោះទៅ ចៀសចេញទៅទាំងមិនអាឡោះអាល័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងបុគ្គលនៅតែលម្មៗ ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ ទោស៥យ៉ាងនេះ រមែងមានដល់បុគ្គលនៅជាប់មិនដាច់ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាអ្នកកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស៥យ៉ាងនេះ រមែងមានដល់បុគ្គលនៅជាប់មិនដាច់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស៥យ៉ាងនេះ រមែងមានដល់បុគ្គលនៅតែលម្មៗ ។ អានិសង្ស៥ យ៉ាង គឺអ្វីខ្លះ ។

ន អាវាសមច្ឆរី ហោតិ ន កុលមច្ឆរី ហោតិ ន លាភមច្ឆរី ហោតិ ន វណ្ណមច្ឆរី ហោតិ ន ធម្មមច្ឆរី ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា សមវត្តនិវាសេតិ ។

(១២៥) បញ្ចិមេ ភិក្ខវេ អាទីនវា កុលុបកេ ។ កតមេ បញ្ច ។ អនាមន្តចារេ អាបជ្ជតិ រហោនិសជ្ជាយ អាបជ្ជតិ បដិច្ឆន្នេ អាសនេ អាបជ្ជតិ មាតុគ្គាមស្ស ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេន្តោ អាបជ្ជតិ កាមសង្កប្បពហុលោ វិហរតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា កុលុបកេតិ ។

(១២៦) បញ្ចិមេ ភិក្ខវេ អាទីនវា កុលុបកស្ស ភិក្ខុនោ អតិវេលំ កុលេសុ សំសដ្ឋស្ស វិហរតោ ។ កតមេ បញ្ច ។ មាតុគ្គាមស្ស អភិណ្ហទស្សនំ ទស្សនេ សតិ សំសគ្គោ សំសគ្គេ សតិ វិស្សាសោ វិស្សាសេ សតិ ឱតារោ ឱតិណ្ណចិត្តស្សេតំ បាដិកង្ខំ អនភិរតោ វា [ព្រហ្មចរិយំ ចរិស្សតិ

គឺជាអ្នកមិនកំណាញ់អាវាស ១ មិនកំណាញ់ត្រកូល ១ មិនកំណាញ់លាភ ១ មិនកំណាញ់គុណ ១ មិនកំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅតែល្មមៗ ។

[១៦៥] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុ អ្នកចូលទៅកាន់ត្រកូល ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺរមែងត្រូវអាបត្តិ ព្រោះត្រាច់ទៅមិនលា ១ រមែងត្រូវអាបត្តិ ព្រោះអង្គុយក្នុងទីស្ងាត់ ១ ត្រូវអាបត្តិ ព្រោះអង្គុយក្នុងទីកំបាំង ១ ត្រូវអាបត្តិ ព្រោះសំដែងធម៌ដល់មាតុគ្រាម លើសជាង ៥ ឬ ៦ ម៉ាត់ ១ ជាអ្នកច្រើនដោយសេចក្តីត្រិះរិះក្នុងកាម ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុ អ្នកចូលទៅកាន់ត្រកូល ។

[១៦៦] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុ អ្នកចូលទៅកាន់ត្រកូល ច្រឡូកច្រឡំក្នុងត្រកូលហួសវេលា ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺឃើញមាតុគ្រាមរឿយៗ ១ កាលបើឃើញហើយ រមែងជាប់ចិត្ត ១ កាលបើជាប់ចិត្តហើយ រមែងមានសេចក្តីស្និទ្ធស្នាល ១ កាលបើមានសេចក្តីស្និទ្ធស្នាលហើយ រមែងចុះចិត្ត (ស្រឡាញ់) ១ ដែលចុះចិត្តស្រឡាញ់ហើយ រមែងមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈ

សង្កិលិដ្ឋំ អាបត្តឹ អាបជ្ជិស្សតិ សិក្ខំ វា បច្ចក្ខាយ ហីនាយាវត្តិស្សតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា កុលុបកស្ស ភិក្ខុនោ អតិវេលំ កុលេសុ សំសដ្ឋស្ស វិហរតោតិ ។

(១២៧) បញ្ចិមេ ភិក្ខវេ អាទីនវា ភោគេសុ ។ កតមេ បញ្ច ។ អគ្គិសាធារណា ភោគា ឧទកសាធារណា ភោគា រាជសាធារណា ភោគា ចោរសាធារណា ភោគា អប្បិយេហិ ទាយាទេហិ សាធារណា ភោគា ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា ភោគេសុ ។ បញ្ចិមេ ភិក្ខវេ អានិសំសា ភោគេសុ ។ កតមេ បញ្ច ។ ភោគេ និស្សាយ អត្តានំ សុខេតិ បីណេតិ សម្មា សុខំ បរិហរតិ មាតាបិតរោ សុខេតិ បីណេតិ សម្មា សុខំ បរិហរតិ បុត្តទារទាសកម្មករបោរិសេ សុខេតិ បីណេតិ សម្មា សុខំ បរិហរតិ មិត្តាមច្ចេ សុខេតិ បីណេតិ សម្មា សុខំ បរិហរតិ

ទីឯត្រូវអាបត្តិ សៅហ្មង ឬទីឯណាសិក្ខាត្រឡប់ទៅកាន់ភេទថោកទាបវិញ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ត្រកូល ប្រឡូកប្រឡំក្នុងត្រកូលហួសវេលា ។

(១២៧) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈទាំងឡាយ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺភោគៈសាធារណៈដល់ភ្លើង ១ ភោគៈសាធារណៈដល់ទឹក ១ ភោគៈសាធារណៈដល់ព្រះរាជា ១ ភោគៈសាធារណៈដល់ចោរ ១ ភោគៈសាធារណៈដល់អ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈទាំងឡាយ ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺអាស្រ័យភោគៈហើយញុំាងខ្លួនឲ្យសុខ ឲ្យឆ្អែត រក្សាខ្លួនឲ្យសុខសប្បាយ ១ ញុំាងមាតានឹងបិតាឲ្យសុខ ឲ្យឆ្អែត រក្សាមាតាបិតាឲ្យសុខសប្បាយ ១ ញុំាងកូនប្រពន្ធ ខ្ញុំ នឹងបុរសជាកម្មករ ឲ្យសុខ ឲ្យឆ្អែត រក្សាកូនប្រពន្ធ ខ្ញុំ នឹងបុរសជាកម្មករ ឲ្យសុខសប្បាយ ១ ញុំាងមិត្រនឹងអាមាត្យឲ្យសុខ ឲ្យឆ្អែត រក្សាមិត្រអាមាត្យឲ្យបានសុខសប្បាយ ១

សមណព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋាបេតិ សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកំ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា ភោគេសូតិ ។

(១២៨) បញ្ចិមេ ភិក្ខវេ អាទីនវា ឧស្សូរភត្តេ កុលេ ។ កតមេ បញ្ច ។ យេ តេ អតិថី បាហុនា តេ ន កាលេន បដិបូជេន្តិ យា តា ពលិបដិគ្គាហិកា ទេវតា តា ន កាលេន បដិ-បូជេន្តិ យេ តេ សមណព្រាហ្មណា ឯកភត្តិកា រត្តូបរតា វិរតា វិកាលភោជនា តេ ន កាលេន បដិបូជេន្តិ ទាសកម្មករបោរិសា វិមុខា កម្មំ ករោន្តិ តាវតកញ្ញេវ អសមយេន ភុត្តំ អនោជវន្តំ ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា ឧស្សូរភត្តេ កុលេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា សមយភត្តេ កុលេ ។

ដំកល់ទុកនូវទាន មានផលដ៏ខ្ពស់ក្នុងពួកសមណព្រាហ្មណ៍ ជាទានឲ្យនូវអារម្មណ៍ដ៏ប្រសើរក្រៃ មានផលជាសុខ ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈទាំងឡាយ ។

(១២៨) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងត្រកូលអ្នកបរិភោគអាហារក្នុងវេលាថ្ងៃពេក ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺភ្ញៀវជាអាគន្តុកៈណា (មកកាន់ផ្ទះ) ជនក្នុងត្រកូលមិនបានបូជាភ្ញៀវជាអាគន្តុកៈនោះ តាមកាល ១ ពួកទេវតាណា ជាអ្នកទទួលពលិកម្ម ជនក្នុងត្រកូលមិនបានបូជាពួកទេវតានោះ តាមកាល ១ ពួកសមណព្រាហ្មណ៍ណា ជាអ្នកបរិភោគភត្តតែ ១ ពេល វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកវិកាលភោជន ជនក្នុងត្រកូលមិនបានបូជាពួកសមណព្រាហ្មណ៍នោះ តាមកាល ១ ខ្ញុំនឹងបុរសជាកម្មករ មុខក្រៀម ប្រឹងធ្វើការងារ ១ ភត្តដែលខ្លួនបរិភោគខុសកាលហើយ ក៏ឥតឱជារស ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងត្រកូល ដែលបរិភោគអាហារក្នុងពេលថ្ងៃពេក ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងត្រកូល អ្នកបរិភោគអាហារត្រូវវេលា ។

កតមេ បញ្ច ។ យេ តេ អតិថី ទារុណា តេ កាលេន បដិបូជេន្តិ យា តា ពលិបដិគ្គាហិកា ទេវតា តា កាលេន បដិបូជេន្តិ យេ តេ សមណព្រាហ្មណា ឯកភត្តិកា រត្តូបរតា វិរតា វិកាលភោជនា តេ កាលេន បដិបូជេន្តិ ទាសកម្មករបោរិសា អវិមុខា កម្មំ ករោន្តិ តាវតកញ្ញេវ សមយេន ភុត្តំ ឱជវន្តំ ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា សមយភត្តេ កុលេតិ ។

(១២៩) បញ្ចិមេ ភិក្ខវេ អាទីនវា កណ្ហសប្បេ ។ កតមេ បញ្ច ។ អសុចិ ទុគ្គន្ធោ សភីរុ សប្បដិភយោ មិត្តទុព្ភី ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា កណ្ហសប្បេ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ អាទីនវា មាតុគ្គាមេ ។ កតមេ បញ្ច ។ អសុចិ ទុគ្គន្ធោ

អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺពួកភ្ញៀវជាអាគន្តុកៈណា (មកកាន់ផ្ទះ) ជនក្នុងត្រកូលបានបូជាពួកភ្ញៀវ ជាអាគន្តុកៈនោះ តាមកាល១ ពួកទេវតាណា ជាអ្នកទទួលពលិកម្ម ពួកជនក្នុងត្រកូល បានបូជាពួកទេវតានោះ តាមកាល ១ ។ ពួកសមណព្រាហ្មណ៍ណា ជាអ្នកបរិភោគក្នុងតែ ១ ពេល វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកវិកាលភោជន ពួកជនក្នុងត្រកូលបានបូជា ពួកសមណព្រាហ្មណ៍នោះ តាមកាល ១ ពួកខ្ញុំនិងបុរសជាកម្មករ មានមុខមិនក្រៀម ប្រឹងធ្វើការងារ ១ ក្នុងដែលខ្លួនបរិភោគត្រូវពេលហើយ ក៏មានទុកជារសឆ្ងាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងត្រកូលអ្នកបរិភោគក្នុងត្រូវពេល ។

(១៥៩) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងពស់វែក ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺពស់វែកមិនស្អាត ១ មានក្លិនស្អុយ ១ គួរតក់ស្លុត ១ គួរខ្លាច ១ ទ្រុស្តមិត្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងពស់វែក ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងមាតុគ្រាម ដូច្នោះដែរ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមាតុគ្រាមមិនស្អាត ១ មានក្លិនស្អុយ ១

សភីរុ *សប្បដិភយោ មិត្តទុព្ភី ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា មាតុគ្គាមេតិ ។

(១៣០) បញ្ចិមេ ភិក្ខវេ អាទីនវា កណ្ហសប្បេ ។ កតមេ បញ្ច ។ កោធនោ ឧបនាហី ឃោរវិសោ ទុជ្ជិវ្ហោ មិត្តទុព្ភី ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា កណ្ហសប្បេ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ អាទីនវា មាតុគ្គាមេ ។ កតមេ បញ្ច ។ កោធនោ ឧបនាហី ឃោរវិសោ ទុជ្ជិវ្ហោ មិត្តទុព្ភី ។ តត្រិទំ ភិក្ខវេ មាតុគ្គាមស្ស ឃោរវិសតា យេភុយ្យេន ភិក្ខវេ មាតុគ្គាមោ តិព្ពរាគោ ។ តត្រិទំ ភិក្ខវេ មាតុគ្គាមស្ស ទុជ្ជិវ្ហតា យេភុយ្យេន ភិក្ខវេ មាតុគ្គាមោ បិសុណាវាចោ ។ តត្រិទំ ភិក្ខវេ មាតុគ្គាមស្ស មិត្តទុព្ភិតា យេភុយ្យេន ភិក្ខវេ មាតុគ្គាមោ អតិចារិនី ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា មាតុគ្គាមេតិ ។

ទីឃចារិកវគ្គោ តតិយោ ។

គួរតក់ស្លុត ១ គួរខ្លាច ១ ទ្រុស្តមិត្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងមាតុគ្រាម ។

[១៣០] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងពស់វែក ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺពស់វែកមានចិត្តក្រោធ ១ ចងពៀរ ១ មានពិសពន្លឹក ១ មានអណ្តាតអាក្រក់ ១ ទ្រុស្តមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងពស់វែក ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងមាតុគ្រាម ដូច្នោះដែរ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមាតុគ្រាមច្រើនក្រោធ ១ ចងគំនុំ ១ មានពិសពន្លឹក ១ មានអណ្តាតអាក្រក់ ១ ទ្រុស្តមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា មាតុគ្រាមមានពិសពន្លឹកនេះ ម្នាលភិក្ខុទាំងឡាយ ដោយច្រើនមាតុគ្រាមមានរាគៈខ្លាំងក្លា ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា មាតុគ្រាមមានអណ្តាតអាក្រក់នេះ ម្នាលភិក្ខុទាំងឡាយ ដោយច្រើនមាតុគ្រាមមានវាចាញុះញង់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា មាតុគ្រាមជាអ្នកទ្រុស្តមិត្រនេះ ម្នាលភិក្ខុទាំងឡាយ ដោយច្រើនមាតុគ្រាមប្រព្រឹត្តក្បត់ចិត្តស្វាមី ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងមាតុគ្រាម ។

ចប់ទីឃចារិកវគ្គ ទី ៣ ។

## តស្សុទ្ទានំ

ទ្វេ ទីឃចារិកា វុត្តា
អភិនិវាសមច្ឆរំ
ទុវេ កុលុបកា ភោគោ
ភត្តំ សប្បាបរេ ទុវេតិ ។

## ឧទ្ទាននៃទីឃចារិកវគ្គនោះគឺ

និយាយអំពីចារិក ទៅកាន់ទីឆ្ងាយ ២ រឿង អំពីការនៅជាប់មិនជាប់ ១ អំពីសេចក្តីកំណាញ់ ១ អំពីការចូលទៅកាន់ត្រកូល ២ រឿង អំពីភោគៈ ១ អំពីភត្ត ១ អំពីពស់វែក ២ រឿង ។

# អាវាសិកវគ្គោ

(១៣១) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ អភាវនីយោ ហោតិ ។ កតមេហិ បញ្ចហិ ។ ន អាកប្បសម្បន្នោ ហោតិ ន វត្តសម្បន្នោ ន ពហុស្សុតោ ហោតិ ន សុតធរោ ន បដិសល្លេខិតា ហោតិ ន បដិសល្លានារាមោ ន កល្យាណារាមោ ន កល្យាណវាចោ ហោតិ ន កល្យាណវាក្ករណោ ទុប្បញ្ញោ ហោតិ ជឡោ ឯឡមូគោ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ អភាវនីយោ ហោតិ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ ភាវនីយោ ហោតិ ។ កតមេហិ បញ្ចហិ ។ អាកប្បសម្បន្នោ ហោតិ វត្តសម្បន្នោ ពហុស្សុតោ ហោតិ សុតធរោ បដិសល្លេខិតា ហោតិ បដិសល្លានារាមោ កល្យាណារាមោ កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ បញ្ញវា ហោតិ អជឡោ អនេឡមូគោ ។

## អាភាសិកវគ្គ

(១៣១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង មិនគួរសរសើរឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស មិនបរិបូណ៌ដោយមារយាទ មិនបរិបូណ៌ដោយវត្ត ១ មិនជាពហុស្សូត មិនទ្រទ្រង់នូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ១ មិនត្រេកអរក្នុងទីស្ងាត់ មិនត្រេកអរក្នុងកុសលធម៌ ១ មានវាចាមិនពីរោះ និយាយមិនពីរោះ ១ ឥតប្រាជ្ញា ល្ងង់ខ្លៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរសរសើរឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង គួរសរសើរ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស បរិបូណ៌ដោយមារយាទ បរិបូណ៌ដោយវត្ត ១ ជាពហុស្សូត ទ្រទ្រង់ពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ១ ជាអ្នកផុសខាត់ចិត្ត ត្រេកអរក្នុងទីស្ងាត់ ត្រេកអរក្នុងកុសលធម៌ ១ ជាអ្នកមានវាចាពីរោះ ចេះនិយាយពីរោះ ១ ជាអ្នកមានប្រាជ្ញាមិនល្ងង់ខ្លៅ ១ ។

ឥមេ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ ភាវនីយោ ហោតីតិ ។

(១៣២) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា ចតុន្នំ ឈានានំ អាភិចេតសិកានំ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរសរសើរ ។

(១៣២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព គួរសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោស សូម្បីមានប្រមាណតិច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សុត ទ្រទ្រង់ពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ បានសន្សំហើយ ធម៌ទាំងឡាយណា មានពីរោះខាងដើម ពីរោះកណ្តាល ពីរោះខាងចុង ប្រកាសនូវព្រហ្មចរិយៈប្រកបដោយអត្ថ និងព្យញ្ជនៈបរិសុទ្ធ បរិបូណ៌សព្វគ្រប់ ធម៌មានសភាពដូច្នោះ ភិក្ខុនោះបានស្តាប់ច្រើន បានចាំរត់មាត់ រំពឹងដោយចិត្ត ចាក់ធ្លុះដោយសេចក្តីយល់ នូវធម៌មានសភាពដូច្នោះ ១ ជាអ្នកមានវាចាពីរោះ និយាយពីរោះ ប្រកបដោយវាចាជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ជាវាចាប្រាសចាកទោស អាចញុំាងមហាជន ឲ្យដឹងសេចក្តីបាន ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានមិនលំបាក

ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ អាកង្ខិតោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ចាតិ ។

(១៣៣) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាកង្ខិតោ ភិក្ខុ អាកង្ខំ សោភេតិ ។ កតមេហិ បញ្ចហិ ។ សីលវា ហោតិ ។បេ។ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។បេ។ ទិដ្ឋិយា សុប្បដិវិទ្ធា កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា បដិពលោ ហោតិ ឧបសង្កមន្តំ ធម្មិយា កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ ចតុន្នំ ឈានានំ

បានបរិបូណ៌នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ជាអ្នកធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ ទាំងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះក្ស័យអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព គួរសរសើររបស់សព្រហ្មចារីទាំងឡាយ ។

[ ១៣៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងញុំាងអាវាសឲ្យល្អ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ។ បេ ។ ចាក់ធ្លុះដោយសេចក្តីយល់ ១ ជាអ្នកមានវាចាពីរោះ និយាយពីរោះ ប្រកបដោយសំដីនៃអ្នកក្រុង ជាសំដីច្បាស់លាស់ ជាវាចាប្រាសចាកទោស អាចញុំាងមហាជនឲ្យដឹងសេចក្តីបាន ១ ជាអ្នកអង់អាច ដើម្បីពន្យល់មនុស្សដែលបានមករកខ្លួន ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានមិនលំបាក បានបរិបូណ៌នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ក្រៃលែង

អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ អាវាសំ សោភេតីតិ ។

[១៣៤] បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ អាវាសស្ស ពហុបការោ ហោតិ ។ កតមេហិ បញ្ចហិ ។ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា ខណ្ឌផុល្លំ បដិសង្ខរោតិ មហា ខោ បន ភិក្ខុសង្ឃោ អភិក្កន្តោ នានាវេរជ្ជកា ភិក្ខូ គិហីនំ ឧបសង្កមិត្វា អារោចេតិ មហា ខោ អាវុសោ ភិក្ខុសង្ឃោ អភិក្កន្តោ នានាវេ-រជ្ជកា ភិក្ខូ ករោថ បុញ្ញានិ សមយោ បុញ្ញានិ កាតុន្តិ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។

ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ នេះ រមែងញុំាងអាវាសឲ្យល្អ ។

[១៣៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងជាអ្នកមានឧបការៈច្រើនដល់អាវាស ។ ប្រកបដោយធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ។ បេ ។ ចាក់ធ្លុះដោយសេចក្តីយល់ ១ ជួសជុលទីសេនាសនៈដែលបាក់បែក ១ មានភិក្ខុសង្ឃជាច្រើននិមន្តចូលមក ភិក្ខុទាំងឡាយមកអំពីដែនផ្សេងៗគ្នា ភិក្ខុជាចៅអាវាសក៏ចូលទៅប្រាប់ដល់គ្រហស្ថទាំងឡាយថា ម្នាលអាវុសោទាំងឡាយ មានភិក្ខុសង្ឃជាច្រើន ភិក្ខុទាំងឡាយមកអំពីដែនផ្សេងៗគ្នា អ្នកទាំងឡាយ ចូរធ្វើបុណ្យ ពេលនេះជាពេលគួរធ្វើបុណ្យ ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានមិនលំបាក បានបរិបូណ៌នូវឈានទាំង ៤

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ អាវាសស្ស ពហុបការោ ហោតីតិ ។

(១៣៥) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ គិហីនំ អនុកម្បតិ ។ កតមេហិ បញ្ចហិ ។ អធិសីលេ សមាទបេតិ ធម្មទស្សនេ និវេសេតិ គិលានកេ ឧបសង្កមិត្វា សតិំ ឧប្បាទេតិ អរហគ្គតំ អាយស្មន្តោ សតិំ ឧបដ្ឋាបេថាតិ ។ ពហូ ខោ បន ភិក្ខុសង្ឃា អភិក្កន្តា នានាវេរជ្ជកា ភិក្ខូ គិហីនំ ឧបសង្កមិត្វា អារោចេតិ ពហូ ខោ អាវុសោ ភិក្ខុសង្ឃា អភិក្កន្តា នានាវេរជ្ជកា ភិក្ខូ ករោថ បុញ្ញានិ សមយោ បុញ្ញានិ កាតុន្តិ យំ ខោ បនស្ស ភោជនំ ទេន្តិ លូខំ វា បណីតំ វា តំ អត្តនា បរិភុញ្ជតិ សទ្ធាទេយ្យំ ន វិនិបាតេតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ គិហីនំ អនុកម្បតីតិ ។

ដែលអាស្រ័យនូវចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ ប្រការនេះ រមែងជាអ្នកមានឧបការច្រើនដល់អាវាស ។

(១៣៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងជាអ្នកអនុគ្រោះដល់ពួកគ្រហស្ថ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស ណែនាំគ្រហស្ថឲ្យតាំងនៅក្នុងអធិសីល ១ ណែនាំឲ្យឃើញធម៌ ១ ចូលទៅជិតមនុស្សមានជម្ងឺហើយរំលឹកឲ្យមានស្មារតី ថា នែអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយចូរដំកល់ទុកនូវស្មារតី ឲ្យតាំងនៅក្នុងអរហគុណ ១ មានភិក្ខុសង្ឃចូលមកច្រើន ភិក្ខុទាំងឡាយមកអំពីដែនផ្សេងៗ ភិក្ខុចៅអាវាស ចូលទៅប្រាប់ពួកគ្រហស្ថថា ម្នាលអាវុសោទាំងឡាយ មានភិក្ខុសង្ឃចូលមកច្រើន ភិក្ខុទាំងឡាយមកអំពីដែនផ្សេងៗ អ្នកទាំងឡាយ ចូរនាំគ្នាធ្វើបុណ្យ ពេលនេះជាពេលគួរធ្វើបុណ្យ ១ ពួកទាយកប្រគេនភោជនណាដល់ភិក្ខុនោះ ជារបស់សៅហ្មងក្តី ល្អក្តី ខ្លួនឯង ក៏បរិភោគភោជននោះ មិនធ្វើសទ្ធាទេយ្យរបស់ទាយកឲ្យធ្លាក់ចុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌៥ យ៉ាងនេះ រមែងជាអ្នកអនុគ្រោះដល់ពួកគ្រហស្ថ ។

(១៣៦) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា អប្បសាទនីយេ ឋានេ បសាទំ ឧបទំសេតិ អននុវិច្ច អបរិយោគាហេត្វា បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ សទ្ធាទេយ្យំ វិនិបាតេតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា អប្បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ

(១៣៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៤ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៤ យ៉ាងតើអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស មិនបានស្ទាបស្ទង់ពិចារណាមើល ហើយពោលសរសើរគុណបុគ្គលដែលមិនគួរសរសើរ ១ មិនបានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គលដែលគួរសរសើរគុណ ១ មិនបានស្ទាបស្ទង់ពិចារណាមើល ហើយខ្ទាំងខ្ទប់សេចក្តីជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១ មិនបានស្ទាបស្ទង់ពិចារណាមើល ហើយខ្ទាំងខ្ទប់សេចក្តីមិនជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ ញុំាងសទ្ធាទេយ្យរបស់ទាយកឱ្យធ្លាក់ចុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៤ យ៉ាងនេះឯង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៤ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាងតើអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស បានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គលដែលគួរពោលទោស ១ បានស្ទាបស្ទង់ពិចារណាមើល ហើយសរសើរគុណបុគ្គលដែលគួរសរសើរ ១ បានស្ទាបស្ទង់ពិចារណាមើល ហើយខ្ទាំងខ្ទប់សេចក្តីមិនជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១

អនុវិច្ច បរិយោគាហេត្វា បសាទនីយេ ឋានេ បសាទំ ឧបទំសេតិ សទ្ធាទេយ្យំ ន វិនិបាតេតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(១៣៧) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ អាវាសមច្ឆរី ហោតិ អាវាសបលិគេធី កុលមច្ឆរី ហោតិ កុលបលិគេធី សទ្ធាទេយ្យំ វិនិបាតេតិ ។ ឥមេហិ ខោ ។ បេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា

បានស្តាប់ស្ទង់ពិចារណាមើល ហើយបើកល់ទុកនូវសេចក្តីជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ ញ៉ាំងសទ្ធាទេយ្យរបស់ទាយក មិនឲ្យធ្លាក់ចុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។

(១៣៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស មិនបានស្តាប់ស្ទង់ពិចារណាមើល ហើយសរសើរគុណបុគ្គល ដែលមិនគួរសរសើរ ១ មិនបានស្តាប់ស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គល ដែលគួរសរសើរ ១ ជាអ្នកកំណាញ់អាវាស ជាប់ក្នុងអាវាស ១ ជាអ្នកកំណាញ់ត្រកូល ជាប់ក្នុងត្រកូល ១ ញ៉ាំងសទ្ធាទេយ្យរបស់ទាយក ឲ្យធ្លាក់ចុះ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស បានស្តាប់ស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គលដែលគួរពោលទោស ១ បានស្តាប់ស្ទង់ពិចារណាមើល ហើយ

វណ្ណារហស្ស វណ្ណំ ភាសតិ ច អាវាសមច្ឆរី ហោតិ ច អាវាសបលិគេធី ច កុលមច្ឆរី ហោតិ ច កុលបលិគេធី សទ្ធាទេយ្យំ ច វិនិបាតេតិ ។ ឥមេហិ ខោ ។ បេ ។

(១៣៨) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ អាវាសមច្ឆរី ហោតិ កុលមច្ឆរី ហោតិ លាភមច្ឆរី ហោតិ ។ ឥមេហិ ខោ ។ បេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសតិ ន អាវាសមច្ឆរី ហោតិ ន កុលមច្ឆរី ហោតិ ន លាភមច្ឆរី ហោតិ ។ ឥមេហិ ខោ ។ បេ ។

សរសើរគុណបុគ្គល ដែលគួរសរសើរ ១ មិនជាអ្នកកំណាញ់អាវាស មិនជាប់កង្វល់អាវាស ១ មិនជាអ្នកកំណាញ់ត្រកូល មិនជាប់កង្វល់ត្រកូល ១ មិនញុំាងសទ្ធាទេយ្យរបស់ទាយក ឲ្យធ្លាក់ចុះ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស មិនបានស្ទាបស្ទង់ពិចារណាមើល ហើយសរសើរគុណបុគ្គល ដែលមិនគួរសរសើរ ១ មិនបានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គល ដែលគួរសរសើរ ១ ជាអ្នកកំណាញ់អាវាស ១ ជាអ្នកកំណាញ់ត្រកូល ១ ជាអ្នកកំណាញ់លាភ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស បានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គល ដែលគួរពោលទោស ១ បានស្ទាបស្ទង់ពិចារណាមើល ហើយសរសើរគុណបុគ្គល ដែលគួរសរសើរ ១ មិនជាអ្នកកំណាញ់អាវាស ១ មិនជាអ្នកកំណាញ់ត្រកូល ១ មិនជាអ្នកកំណាញ់លាភ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។

(១៣៩) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អាវាសមច្ឆរី ហោតិ កុលមច្ឆរី ហោតិ លាភមច្ឆរី ហោតិ វណ្ណមច្ឆរី ហោតិ សទ្ធាទេយ្យំ វិនិបាតេតិ ។ ឥមេហិ ខោ ។ បេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ ន អាវាសមច្ឆរី ហោតិ ន កុលមច្ឆរី ហោតិ ន លាភមច្ឆរី ហោតិ ន វណ្ណមច្ឆរី ហោតិ សទ្ធាទេយ្យំ ន វិនិបាតេតិ ។ ឥមេហិ ខោ ។ បេ ។

(១៤០) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ អាវាសមច្ឆរី ហោតិ កុលមច្ឆរី ហោតិ លាភមច្ឆរី ហោតិ វណ្ណមច្ឆរី ហោតិ ធម្មមច្ឆរី ហោតិ ។ ឥមេហិ ខោ ។ បេ ។

(១៣៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាអ្នកកំណាញ់អាវាស ១ ជាអ្នកកំណាញ់ត្រកូល ១ ជាអ្នកកំណាញ់លាភ ១ ជាអ្នកកំណាញ់គុណ ១ ជាអ្នកញុំាងសទ្ធាទេយ្យរបស់ទាយក ឲ្យធ្លាក់ចុះ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមិនកំណាញ់អាវាស ១ ជាអ្នកមិនកំណាញ់ត្រកូល ១ ជាអ្នកមិនកំណាញ់លាភ ១ ជាអ្នកមិនកំណាញ់គុណ ១ មិនញុំាងសទ្ធាទេយ្យរបស់ទាយក ឲ្យធ្លាក់ចុះ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។

(១៤០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាអ្នកកំណាញ់អាវាស ១ ជាអ្នកកំណាញ់ត្រកូល ១ ជាអ្នកកំណាញ់លាភ ១ ជាអ្នកកំណាញ់គុណ ១ ជាអ្នកកំណាញ់ធម៌ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។

បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាវាសិកោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ ន អាវាសមច្ឆរី ហោតិ ន កុលមច្ឆរី ហោតិ ន លាភមច្ឆរី ហោតិ ន វណ្ណមច្ឆរី ហោតិ ន ធម្មមច្ឆរី ហោតិ ។ ឥមេហិ ខោ ។ បេ ។

អាវាសិកវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

អាវាសិកោ អប្បិយសោភនា[១] ច
ពហុបការោ អនុកម្បកោ ច
យថាភតញ្ចាបិ អវណ្ណេនា
ចតុត្ថមច្ឆេរបញ្ចកេន ចាតិ ។

---

១ ឱ ម. បិយោ ច សោភនា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមិនកំណាញ់អាវាស ១ ជាអ្នកមិនកំណាញ់ត្រកូល ១ ជាអ្នកមិនកំណាញ់លាភ ១ ជាអ្នកមិនកំណាញ់គុណ ១ ជាអ្នកមិនកំណាញ់ធម៌ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។

ចប់ អាវាសិកវគ្គ ទី ៤ ។

## ឧទ្ទាននៃអាវាសិកវគ្គនោះគឺ

និយាយអំពីភិក្ខុចៅអាវាស ដែលមិនគួរសរសើរ ១ អំពីចៅអាវាស មិនជាទីស្រឡាញ់ដល់ពួកសព្រហ្មចារី ១ អំពីចៅអាវាស ធ្វើអាវាសឲ្យល្អ ១ អំពីចៅអាវាស មានឧបការៈច្រើន ១ អំពីចៅអាវាស មានសេចក្ដីអនុគ្រោះដល់គ្រហស្ថ ១ អំពីចៅអាវាស កើតក្នុងនរក ឬស្ថានសួគ៌ដូចជាគេនាំយកទៅដាក់ ១ អំពីចៅអាវាស ជាអ្នកពោលទោស ១ អំពីចៅអាវាស ជាប់ក្នុងអាវាសនិងត្រកូល ១ អំពីចៅអាវាស មានសេចក្ដីកំណាញ់ជាគំរប់បួន ១ អំពីចៅអាវាស មានកំណាញ់ ៥ យ៉ាង ១ ។

# ទុច្ចរិតវគ្គោ

(១៤១) បញ្ចិមេ ភិក្ខវេ អាទីនវា ទុច្ចរិតេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ឧបវទតិ អនុវិច្ច វិញ្ញូ គរហន្តិ បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា ទុច្ចរិតេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា សុចរិតេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ន ឧបវទតិ អនុវិច្ច វិញ្ញូ បសំសន្តិ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អសម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា សុចរិតេតិ ។

(១៤២) បញ្ចិមេ ភិក្ខវេ អាទីនវា កាយ-ទុច្ចរិតេ ។ បេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា កាយសុចរិតេ ។ បេ ។

## ទុច្ចរិតវគ្គ

[១៤១] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង តិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយ ពិចារណាហើយតិះដៀលបាន ១ កិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ១ វេលាស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង មិនតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយ ពិចារណាហើយសរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ វេលាស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ។

[១៤២] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយកាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ដោយកាយ ។បេ។

[១៤៣] បញ្ចិមេ ភិក្ខវេ អាទីនវា វចីទុច្ចរិតេ ។ បេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា វចីសុចរិតេ ។ បេ ។

[១៤៤] បញ្ចិមេ ភិក្ខវេ អាទីនវា មនោទុច្ចរិតេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ឧបវទតិ អនុវិច្ច វិញ្ញូ គរហន្តិ បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា មនោទុច្ចរិតេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា មនោសុចរិតេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ន ឧបវទតិ អនុវិច្ច វិញ្ញូ បសំសន្តិ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អសម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា មនោសុចរិតេតិ ។

(១៤៣) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយវាចា ។បេ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ដោយវាចា ។បេ។

(១៤៤) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយចិត្ត ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯងតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយ តិះដៀលបាន ១ កិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ១ វេលាស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ ទីនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយចិត្ត ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ដោយចិត្ត ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង មិនតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយក៏សរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ វេលាស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ដោយចិត្ត ។

(១៤៥) បញ្ចិមេ ភិក្ខវេ អាទីនវា ទុច្ចរិតេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ឧបវទតិ អនុវិច្ច វិញ្ញូ គរហន្តិ បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ សទ្ធម្មា វុដ្ឋាតិ អសទ្ធម្មេ បតិដ្ឋាតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា ទុច្ចរិតេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា សុចរិតេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ន ឧបវទតិ អនុវិច្ច វិញ្ញូ បសំសន្តិ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អសទ្ធម្មា វុដ្ឋាតិ សទ្ធម្មេ បតិដ្ឋាតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា សុចរិតេតិ ។

(១៤៦) បញ្ចិមេ ភិក្ខវេ អាទីនវា កាយ-ទុច្ចរិតេ ។ បេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា កាយសុចរិតេ ។ បេ ។

(១៤៥) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯងតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយតិះដៀលបាន ១ កិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ១ ឃ្លៀងឃ្លាតចាកព្រះសទ្ធម្ម ១ តាំងនៅក្នុងអសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺខ្លួនឯង មិនតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយសរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ ឃ្លៀងឃ្លាតចាកអសទ្ធម្ម ១ តាំងនៅក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ។

(១៤៦) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយកាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ដោយកាយ ។បេ។

(១៤៧) បញ្ចិមេ ភិក្ខវេ អាទីនវា វចីទុច្ចរិតេ ។បេ។ បញ្ចិមេ ភិក្ខវេ អានិសំសា វចីសុចរិតេ ។បេ។

(១៤៨) បញ្ចិមេ ភិក្ខវេ អាទីនវា មនោទុច្ចរិតេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ឧបវទតិ អនុវិច្ច វិញ្ញូ គរហន្តិ បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ សទ្ធម្មា វុដ្ឋាតិ អសទ្ធម្មេ បតិដ្ឋាតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា មនោទុច្ចរិតេ ។ បញ្ចិមេ ភិក្ខវេ អានិសំសា មនោសុចរិតេ ។ កតមេ បញ្ច ។ អត្តាបិ អត្តានំ ន ឧបវទតិ អនុវិច្ច វិញ្ញូ បសំសន្តិ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អសទ្ធម្មា វុដ្ឋាតិ សទ្ធម្មេ បតិដ្ឋាតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា មនោសុចរិតេតិ ។

(១៤៧) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយកាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ដោយកាយ ។ បេ ។

(១៤៨) ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយចិត្ត ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង តិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយ តិះដៀលបាន ១ កិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ១ ឃ្លៀងឃ្លាតចាកព្រះសទ្ធម្ម ១ តាំងនៅក្នុងអសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយចិត្ត ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ដោយចិត្ត ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង មិនតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយសរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ ឃ្លៀងឃ្លាតចាកអសទ្ធម្ម ១ តាំងនៅក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ដោយចិត្ត ។

(១៤៩) បញ្ចិមេ ភិក្ខវេ អាទីនវា សីវថិកាយ ។ កតមេ បញ្ច ។ អសុចិ ទុគ្គន្ធា សប្បដិភយា វាឡានំ អមនុស្សានំ អាវាសោ ពហុនោ ជនស្ស អារោទនា ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា សីវថិកាយ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ អាទីនវា សីវថិកូបមេ បុគ្គលេ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អសុចិនា កាយកម្មេន សមន្នាគតោ ហោតិ អសុចិនា វចីកម្មេន សមន្នាគតោ ហោតិ អសុចិនា មនោកម្មេន សមន្នាគតោ ហោតិ ឥទមស្ស អសុចិតាយ វទាមិ សេយ្យថាបិ សា ភិក្ខវេ សីវថិកា អសុចិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ តស្ស អសុចិនា កាយកម្មេន សមន្នាគតស្ស អសុចិនា វចីកម្មេន សមន្នាគតស្ស អសុចិនា មនោកម្មេន សមន្នាគតស្ស បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ ឥទមស្ស ទុគ្គន្ធតាយ វទាមិ សេយ្យថាបិ សា ភិក្ខវេ សីវថិកា ទុគ្គន្ធា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។

[១៤៩] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងព្រៃស្មសាន ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាទីមិនស្អាត ១ មានក្លិនស្អុយ ១ ប្រកបដោយភ័យ ១ ជាទីនៅរបស់ពួកអមនុស្សកាច ១ ជាទីទ្រហោយំរបស់ជនច្រើន ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងព្រៃស្មសាន ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងបុគ្គល ដូចជាព្រៃស្មសាន ក៏ដូច្នោះដែរ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាត នេះតថាគតហៅបុគ្គលនោះថា មិនស្អាត ម្នាលភិក្ខុទាំងឡាយ ដូចជាព្រៃស្មសាននោះ ជាទីមិនស្អាត ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះមានឧបមេយ្យដូច្នោះ ១ ។ កាលបើបុគ្គលនោះ ប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាតហើយ កិត្តិសព្ទដ៏អាក្រក់ក៏ខ្ចរខ្ចាយទៅ នេះតថាគតហៅបុគ្គលនោះថា មានក្លិនស្អុយ ម្នាលភិក្ខុទាំងឡាយ ដូចព្រៃស្មសាននោះ ជាទីមានក្លិនស្អុយ ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះមានឧបមេយ្យដូច្នោះ ១ ។

តមេនំ អសុចិនា កាយកម្មេន សមន្នាគតំ អសុចិនា វចីកម្មេន សមន្នាគតំ អសុចិនា មនោកម្មេន សមន្នាគតំ បេសលា សព្រហ្មចារី អារកា បរិវជ្ជន្តិ ឥទមស្ស សប្បដិភយស្មឹ វទាមិ សេយ្យថាបិ សា ភិក្ខវេ សីវថិកា សប្បដិភយា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ សោ អសុចិនា កាយកម្មេន សមន្នាគតោ អសុចិនា វចីកម្មេន សមន្នាគតោ អសុចិនា មនោកម្មេន សមន្នាគតោ សភាគេហិ បុគ្គលេហិ សទ្ធឹ សំវសតិ ឥទមស្ស កាឡាវាសស្មឹ វទាមិ សេយ្យថាបិ សា ភិក្ខវេ សីវថិកា កាឡានំ អមនុស្សានំ អាវាសោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ តមេនំ អសុចិនា កាយកម្មេន សមន្នាគតំ អសុចិនា វចីកម្មេន សមន្នាគតំ អសុចិនា មនោកម្មេន សមន្នាគតំ បេសលា សព្រហ្មចារី ទិស្វា ខីយធម្មំ អាបជ្ជន្តិ អហោ វត នោ ទុក្ខំ យេ មយំ ឯវរូបេហិ បុគ្គលេហិ សទ្ធឹ សំវសាមាតិ ឥទមស្ស អាកន្ទនាយ វទាមិ

ពួកសព្រហ្មចារីដែលមានសីលជាទីស្រឡាញ់ តែងចៀសវាងនូវបុគ្គលអ្នកប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាតនោះអំពីចម្ងាយ នេះតថាគតហៅបុគ្គលនោះថា ប្រកបដោយភ័យ ម្នាលភិក្ខុទាំងឡាយ ដូចព្រៃស្មសាននោះ ជាទីប្រកបដោយភ័យ ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះមានឧបមេយ្យដូច្នោះ ១ ។ បុគ្គលនោះ ប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាត តែងនៅរួមជាមួយនឹងពួកបុគ្គលស្មើគ្នា នេះតថាគតហៅបុគ្គលនោះថា ជាលំនៅនៃអមនុស្សសាហាវ ម្នាលភិក្ខុទាំងឡាយ ដូចព្រៃស្មសាននោះ ជាទីនៅរបស់អមនុស្សសាហាវ ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះ មានឧបមេយ្យដូច្នោះ១ ។ ពួកសព្រហ្មចារី ដែលមានសីលជាទីស្រឡាញ់ បានឃើញបុគ្គលអ្នកប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាតនោះ តែងតិះដៀលថា ឧហ្ន៎ ពួកយើងរងទុក្ខ ព្រោះតែនៅរួបរួមជាមួយនឹងពួកបុគ្គលយ៉ាងនេះ នេះតថាគតហៅបុគ្គលនោះថា ជាទីទ្រហោយំ

សេយ្យថាបិ សា ភិក្ខវេ សីវថិកា ពហុនោ ជនស្ស អាកេនណា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា សីវថិកូបមេ បុគ្គលេតិ ។

[១៥០] បញ្ចិមេ ភិក្ខវេ អាទីនវា បុគ្គលប្បសាទេ ។ កតមេ បញ្ច ។ យស្មឹ ភិក្ខវេ បុគ្គលេ បុគ្គលោ អភិប្បសន្នោ ហោតិ សោ តថារូបំ អាបត្តឹ អាបន្នោ ហោតិ យថារូបាយ អាបត្តិយា សង្ឃោ ឧក្ខិបតិ តស្ស ឯវំ ហោតិ យោ ខោ ម្យាយំ បុគ្គលោ បិយោ មនាបោ សោ សង្ឃេន ឧក្ខិត្តោតិ ភិក្ខូសុ អប្បសាទពហុលោ ហោតិ ភិក្ខូសុ អប្បសាទពហុលោ សមានោ អញ្ញេ ភិក្ខូ ន ភជតិ អញ្ញេ ភិក្ខូ អភជន្តោ សទ្ធម្មំ ន សុណាតិ សទ្ធម្មំ អសុណន្តោ សទ្ធម្មា បរិហាយតិ អយំ ភិក្ខវេ បឋមោ អាទីនវោ បុគ្គលប្បសាទេ ។ បុន ចបរំ ភិក្ខវេ យស្មឹ បុគ្គលេ បុគ្គលោ អភិប្បសន្នោ ហោតិ សោ តថារូបំ អាបត្តឹ អាបន្នោ ហោតិ យថារូបាយ អាបត្តិយា សង្ឃោ អន្តេ និសីទាបេតិ តស្ស ឯវំ ហោតិ

ម្នាលភិក្ខុទាំងឡាយ ដូចព្រៃស្មសាននោះ ជាទីទ្រហោយំរបស់ជនច្រើន ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះ មានឧបមេយ្យដូច្នោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមាន ក្នុងបុគ្គលមានឧបមេយ្យដូចព្រៃស្មសាន ។

[១៥០] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមាន ក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជ្រះថ្លា ក្នុងបុគ្គលណា បុគ្គលនោះ ត្រូវអាបត្តិ តាមដែលសង្ឃលើកវត្តនោះ បុគ្គលអ្នកជ្រះថ្លានោះ ត្រិះរិះយ៉ាងនេះថា បុគ្គលណា ជាទីស្រឡាញ់ពេញចិត្តរបស់អញ បុគ្គលនោះត្រូវសង្ឃលើកវត្តហើយ ដូច្នេះ ក៏ច្រើនតែមិនជ្រះថ្លា ក្នុងពួកភិក្ខុ កាលមិនជ្រះថ្លាច្រើន ក្នុងពួកភិក្ខុហើយ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលមិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនស្តាប់ព្រះសទ្ធម្ម កាលមិនស្តាប់ព្រះសទ្ធម្មហើយ រមែងសាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ១ ក្នុងសេចក្តីជ្រះថ្លា ចំពោះបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលជ្រះថ្លា ក្នុងបុគ្គលណា បុគ្គលនោះ ត្រូវអាបត្តិ តាមដែលសង្ឃឲ្យបុគ្គលនោះអង្គុយក្នុងទីបំផុតនោះ បុគ្គលអ្នកជ្រះថ្លានោះ ត្រិះរិះយ៉ាងនេះថា

យោ ខោ ម្យាយំ បុគ្គលោ បិយោ មនាបោ សោ សង្ឃេ អន្តេ និសីទាបិតោតិ ភិក្ខូសុ អប្បសាទពហុលោ ហោតិ ភិក្ខូសុ អប្បសាទពហុលោ សមានោ អញ្ញេ ភិក្ខូ ន ភជតិ អញ្ញេ ភិក្ខូ អភជន្តោ សទ្ធម្មំ ន សុណាតិ សទ្ធម្មំ អសុណន្តោ សទ្ធម្មា បរិហាយតិ អយំ ភិក្ខវេ ទុតិយោ អាទីនវោ បុគ្គលប្បសាទេ ។ បុន ចបរំ ភិក្ខវេ យស្មឹ បុគ្គលេ បុគ្គលោ អភិប្បសន្នោ ហោតិ សោ ទិសាបក្កន្តោ ហោតិ ។ បេ ។ សោ វិព្ភន្តោ ហោតិ ។ បេ ។ សោ កាលកតោ ហោតិ តស្ស ឯវំ ហោតិ យោ ខោ ម្យាយំ បុគ្គលោ បិយោ មនាបោ សោ កាលកតោតិ អញ្ញេ ភិក្ខូ ន ភជតិ អញ្ញេ ភិក្ខូ អភជន្តោ សទ្ធម្មំ ន សុណាតិ សទ្ធម្មំ អសុណន្តោ សទ្ធម្មា បរិហាយតិ អយំ ភិក្ខវេ បញ្ចមោ អាទីនវោ បុគ្គលប្បសាទេ ។ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា បុគ្គលប្បសាទេតិ ។

ទុច្ចរិតវគ្គោ បញ្ចមោ ។

បុគ្គលណាជាទីស្រឡាញ់ពេញចិត្តរបស់អញ បុគ្គលនោះ ត្រូវសង្ឃឲ្យអង្គុយក្នុងទីចុងគេបំផុត ដូច្នេះ ក៏មិនជ្រះថ្លាច្រើន ក្នុងពួកភិក្ខុ កាលមិនជ្រះថ្លាច្រើន ក្នុងពួកភិក្ខុហើយ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលបើមិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនបានស្តាប់ព្រះសទ្ធម្ម កាលបើមិនបានស្តាប់ព្រះសទ្ធម្មហើយ ក៏សាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី២ ក្នុងសេចក្តីជ្រះថ្លា ចំពោះបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលជ្រះថ្លា ក្នុងបុគ្គលណា បុគ្គលនោះ ក៏ចៀសចេញទៅកាន់ទិស ។បេ។ បុគ្គលនោះ ក៏សឹកទៅ ។បេ។ បុគ្គលនោះក៏ស្លាប់ទៅ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណា ដែលជាទីស្រឡាញ់ពេញចិត្តរបស់អញ បុគ្គលនោះស្លាប់ទៅហើយ ដូច្នេះ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលបើ មិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនបានស្តាប់ព្រះសទ្ធម្ម កាលមិនបានស្តាប់ព្រះសទ្ធម្មហើយ ក៏នឹងសាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី៥ ក្នុងសេចក្តីជ្រះថ្លា ចំពោះបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ទោស៥ យ៉ាងនេះ រមែងមាន ក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ។

ចប់ ទុច្ចរិតវគ្គ ទី ៥ ។

## តស្សុទ្ទានំ

ទុច្ចរិតំ កាយទុច្ចរិតំ
វចីទុច្ចរិតំ មនោទុច្ចរិតំ
ចតូហិ បរេ ទ្វេ សីវថិកា
បុគ្គលប្បសាទេន ជាតិ ។

បញ្ចមោ បណ្ណាសកោ និដ្ឋិតោ ។

សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត

## ឧទ្ទាននៃទុច្ចរិតវគ្គនោះគឺ

និយាយអំពីទោសនិងអានិសង្សនៃទុច្ចរិត និងសុចរិត ១ អំពីកាយទុច្ចរិត និងកាយសុចរិត ១ អំពីវចីទុច្ចរិត និងវចីសុចរិត ១ អំពីមនោទុច្ចរិត និងមនោសុចរិត ១ អំពីទុច្ចរិតនិងសុចរិត ៤ លើកដទៃទៀតជាពីរដង អំពីព្រៃស្មសាន ១ អំពីសេចក្តីជ្រះថ្លា ចំពោះបុគ្គល ១ ។

ចប់ បណ្ណាសក ទី ៤ ។

# វគ្គសង្គហិតា សុត្តា

(១៨១) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អសេក្ខេន សីលក្ខន្ធេន សមន្នា-គតោ ហោតិ អសេក្ខេន សមាធិក្ខន្ធេន សមន្នា-គតោ ហោតិ អសេក្ខេន បញ្ញាក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វន្តិ ។

(១៨២) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតេន ភិក្ខុនា និស្សយោ ទាតព្វោ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ ។ បេ ។ អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ។ ឥមេហិ ខោ ។ បេ ។

# ពួកសូត្រមិនសង្គ្រោះក្នុងវគ្គ

(១៥១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរញ៉ាំងកុលបុត្តឲ្យឧបសម្បទាបាន ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសីលក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយសមាធិក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយបញ្ញាខន្ធ ជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធ ជាអសេក្ខៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរញ៉ាំងកុលបុត្តឲ្យឧបសម្បទាបាន ។

(១៥២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរឲ្យនិស្ស័យបាន ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ១ ។ បេ ។ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។

(១៥៣) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតេន ភិក្ខុនា សាមណេរោ ឧបដ្ឋាបេតព្វោ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ ។ បេ ។ អសេក្ខេន វិមុត្តិញាណ-ទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ។ ឥមេហិ ខោ ។ បេ ។

(១៥៤) បញ្ចិមានិ ភិក្ខវេ មច្ឆរិយានិ ។ កតមានិ បញ្ច ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច មច្ឆរិយានិ ឥមេសំ(១) ភិក្ខវេ បញ្ចន្នំ មច្ឆរិយានំ ឯតំ បតិក្កិដ្ឋំ យទិទំ ធម្មមច្ឆរិយន្តិ ។

(១៥៥) បញ្ចន្នំ ភិក្ខវេ មច្ឆរិយានំ បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ ។ កតមេសំ បញ្ចន្នំ ។ អាវាសមច្ឆរិយស្ស បហានាយ សមុច្ឆេទាយ ព្រហ្ម-ចរិយំ វុស្សតិ កុលមច្ឆរិយស្ស... លាភមច្ឆរិយស្ស...

---

១ ឱ. ម. ឥមេសំ ខោ ។

(១៥៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរឱ្យសាមណេរបំរើបាន ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ១ ។ បេ ។ ប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខៈ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។

(១៥៤) ម្នាលភិក្ខុទាំងឡាយ សេចក្ដីកំណាញ់នេះមាន ៥ យ៉ាង ។ សេចក្ដីកំណាញ់ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីកំណាញ់ ៥ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បណ្ដាសេចក្ដីកំណាញ់ ៥ យ៉ាងនេះ សេចក្ដីកំណាញ់ធម៌នេះ ជាសេចក្ដីកំណាញ់ ដែលអ្នកប្រាជ្ញតិះដៀល ។

(១៥៥) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីលះបង់ ផ្ដាច់បង់ នូវសេចក្ដីកំណាញ់ ៥ យ៉ាង ។ សេចក្ដីកំណាញ់ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីលះបង់ ផ្ដាច់បង់ នូវសេចក្ដីកំណាញ់អាវាស ១ នូវសេចក្ដីកំណាញ់ត្រកូល ១ .. នូវសេចក្ដីកំណាញ់លាភ ១...

វណ្ណមច្ឆរិយស្ស... ធម្មមច្ឆរិយស្ស បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ មច្ឆរិយានំ បហានាយ សមុច្ឆេទាយ ព្រហ្មចរិយំ វុស្សតីតិ ។

(១៥៦) បញ្ច[១] ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ កតមេ បញ្ច ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មេ អប្បហាយ អភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ បញ្ច ភិក្ខវេ ធម្មេ បហាយ ភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ កតមេ បញ្ច ។ អាវាសមច្ឆរិយំ កុល-មច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មេ បហាយ ភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុន្តិ ។

---

១ ឱ. ម. បញ្ចិមេ ។

នូវសេចក្តីកំណាញ់គុណ ១ ប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីលះបង់ ផ្តាច់បង់នូវសេចក្តីកំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រព្រឹត្តព្រហ្មចរិយ ដើម្បីលះបង់ ផ្តាច់បង់ នូវសេចក្តីកំណាញ់ទាំង ៥ យ៉ាងនេះឯង ។

(១៨៦) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាង មិនគួរដើម្បីបានបឋមជ្ឈាន ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ទាំង ៥ យ៉ាងនេះ មិនគួរដើម្បីបានបឋមជ្ឈានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាងនេះ គួរដើម្បីបានបឋមជ្ឈាន ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសេចក្តីកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ទាំង ៥ យ៉ាងនេះ គួរដើម្បីបានបឋមជ្ឈាន ។

(១៥៧) បញ្ច ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ... សោតាបត្តិផលំ... សកទាគាមិផលំ.. អនាគាមិផលំ... អរហត្តំ សច្ឆិកាតុំ ។ កតមេ បញ្ច ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មេ អប្បហាយ អភព្វោ អរហត្តំ សច្ឆិកាតុំ ។ បញ្ច ភិក្ខវេ ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ បញ្ច ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុន្តិ ។

(១៥៨) បញ្ច ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ កតមេ បញ្ច ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ អកតញ្ញុតំ អកតវេទិតំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មេ អប្បហាយ អភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។

(១៩៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវទុតិយជ្ឈាន... នូវតតិយជ្ឈាន... នូវចតុត្ថជ្ឈាន... នូវសោតាបត្តិផល... នូវសកទាគាមិផល... នូវអនាគាមិផល... នូវអរហត្ត ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាងនេះឯង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាង គួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តបាន ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញលាភ ១ កំណាញ់គុណ ១ កំណាញធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាងនេះឯង គួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តបាន ។

(១៩៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាង មិនគួរដើម្បីបានបឋមជ្ឈាន ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ ជាមនុស្សអកតញ្ញូ អកតវេទី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាងនេះឯង មិនគួរដើម្បីបានបឋមជ្ឈានឡើយ ។

បញ្ច ភិក្ខវេ ធម្មេ បហាយ ភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ កតមេ បញ្ច ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ អកតញ្ញុតំ អកតវេទិតំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មេ បហាយ ភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុន្តិ ។

(១៤៩) បញ្ច ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ.. សោតាបត្តិផលំ... សកទាគាមិផលំ... អនាគាមិផលំ.. អរហត្តំ សច្ឆិកាតុំ ។ កតមេ បញ្ច ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ អកតញ្ញុតំ អកតវេទិតំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មេ អប្បហាយ អភព្វោ អរហត្តំ សច្ឆិកាតុំ ។ បញ្ច ភិក្ខវេ ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ បញ្ច ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាង គួរដើម្បីបានបឋមជ្ឈាន ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ ជាមនុស្សអកតញ្ញូ អកតវេទី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាងនេះឯង គួរដើម្បីបានបឋមជ្ឈាន ។

(១៥៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវទុតិយជ្ឈាន... នូវតតិយជ្ឈាន... នូវចតុត្ថជ្ឈាន... នូវសោតាបត្តិផល... នូវសកទាគាមិផល... នូវអនាគាមិផល... នូវអរហត្តទៀយ ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ ជាមនុស្សអកតញ្ញូ អកតវេទី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាងនេះ មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាង គួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តបាន ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១

អនាគតញ្ញាតំ អនាគតវេទិតំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុន្តិ ។

(១៦០) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ ន សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ឧទ្ទិដ្ឋានុទ្ទិដ្ឋំ ន ជានាតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ ន សម្មន្និតព្វោ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ សម្មន្និតព្វោ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ឧទ្ទិដ្ឋានុទ្ទិដ្ឋំ ជានាតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ សម្មន្និតព្វោតិ ។

(១៦១) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ ន សម្មន្និតព្វោ សម្មតោបិ ន បេសេតព្វោ ។បេ។ សម្មតោ បេសេតព្វោ ។បេ។

ជាមនុស្សអកតញ្ញូ អកតវេទី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាងនេះឯង គួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តបាន ។

(១៦០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង សង្ឃមិនគួរសន្មតឲ្យជាភត្តុទ្ទេសកៈ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺលុះក្នុងឆន្ទាគតិ ១ លុះក្នុងទោសាគតិ ១ លុះក្នុងមោហាគតិ ១ លុះក្នុងភយាគតិ ១ មិនដឹងភត្តដែលខ្លួនគួរសំដែងនឹងមិនគួរសំដែង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង សង្ឃមិនគួរសន្មតឲ្យជាភត្តុទ្ទេសកៈឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង សង្ឃគួរសន្មតឲ្យជាភត្តុទ្ទេសកៈបាន ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺមិនលុះក្នុងឆន្ទាគតិ ១ មិនលុះក្នុងទោសាគតិ ១ មិនលុះក្នុងមោហាគតិ ១ មិនលុះក្នុងភយាគតិ ១ ដឹងនូវភត្ត ដែលខ្លួនគួរសំដែងនឹងមិនគួរសំដែង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង សង្ឃគួរសន្មតឲ្យជាភត្តុទ្ទេសកៈបាន ។

(១៦១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង សង្ឃមិនគួរសន្មតឲ្យជាភត្តុទ្ទេសកៈឡើយ បើសន្មតក៏មិនគួរប្រើ ។ បេ ។ សន្មតហើយ គួរប្រើ ។ បេ ។

ពាលោ វេទិតព្វោ ។ បេ ។ បណ្ឌិតោ វេទិតព្វោ ។ បេ ។ ខតំ ឧបហតំ អត្តានំ បរិហរតិ ។ បេ ។ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ ។ បេ ។ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ បេ ។ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ឧទ្ទិដ្ឋានុទ្ទិដ្ឋំ ជានាតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(១៦៥) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សេនាសនបញ្ញាបកោ ន សម្មន្និតព្វោ... បញ្ញត្តាបញ្ញត្តំ ន ជានាតិ... សេនាសនបញ្ញាបកោ សម្មន្និតព្វោ... បញ្ញត្តាបញ្ញត្តំ ជានាតិ... សេនាសនគ្គាហាបកោ ន សម្មន្និតព្វោ.. បញ្ញត្តាបញ្ញត្តំ ន ជានាតិ... សេនាសនគ្គាហាបកោ សម្មន្និតព្វោ... បញ្ញត្តាបញ្ញត្តំ ជានាតិ... ភណ្ឌាគារិកោ ន សម្មន្និតព្វោ...

បណ្ឌិតគប្បីដឹងថាជាពាល ។បេ។ បណ្ឌិតគប្បីដឹងថាជាអ្នកប្រាជ្ញ ។បេ។ រមែងរក្សាខ្លួន ដែលជីករំលើងគុណចោល ។បេ។ រក្សាខ្លួនដូចជាដើមឈើ ដែលមិនជីករំលើងគុណចោល ។បេ។ រមែងទៅកើត ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។បេ។ រមែងទៅកើត ក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។បេ។ ប្រកបដោយធម៌ ៤ យ៉ាង គឺអ្វីខ្លះ ។ គឺមិនលុះក្នុងឆន្ទាគតិ ១ មិនលុះក្នុងទោសាគតិ ១ មិនលុះក្នុងមោហាគតិ ១ មិនលុះក្នុងភយាគតិ ១ ដឹងនូវភត្ត ដែលខ្លួនគួរសំដែងនឹងមិនគួរសំដែង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈ ប្រកបដោយធម៌ ៤ យ៉ាងនេះឯង រមែងទៅកើត ក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។

(១៦២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបដោយធម៌ ៤ យ៉ាង សង្ឃមិនគួរសន្មតឲ្យជាសេនាសនប្បញ្ញាបកៈ... មិនដឹងនូវសេនាសនៈ ដែលខ្លួនគួរចាត់ចែង នឹងមិនគួរចាត់ចែង... សង្ឃគួរសន្មតឲ្យជាសេនាសនប្បញ្ញាបកៈ... ដឹងនូវសេនាសនៈដែលខ្លួនគួរចាត់ចែង នឹងមិនគួរចាត់ចែង.. សង្ឃមិនគួរសន្មតឲ្យជាសេនាសនគាហាបកៈ... មិនដឹងនូវសេនាសនៈដែលខ្លួនគួរចាត់ចែង នឹងមិនគួរចាត់ចែង... សង្ឃគួរសន្មតឲ្យជាសេនាសនគាហាបកៈ... ដឹងនូវសេនាសនៈដែលខ្លួនគួរចាត់ចែង នឹងមិនគួរចាត់ចែង... សង្ឃមិនគួរសន្មតឲ្យជាភណ្ឌាគារិកៈ...

គុត្តាគុត្តំ ន ជានាតិ... ភណ្ឌាគារិកោ សម្មន្និតព្វោ... គុត្តាគុត្តំ ជានាតិ... ចីវរប្បដិគ្គាហកោ ន សម្មន្និតព្វោ... គហិតាគហិតំ ន ជានាតិ... ចីវរប្បដិគ្គាហកោ សម្មន្និ-តព្វោ... គហិតាគហិតំ ជានាតិ... ចីវរភាជកោ ន សម្មន្និតព្វោ... ភាជិតាភាជិតំ ន ជានាតិ... ចីវរភា-ជកោ សម្មន្និតព្វោ... ភាជិតាភាជិតំ ជានាតិ... យាគុភាជកោ ន សម្មន្និតព្វោ... យាគុភាជកោ សម្មន្និតព្វោ.. ផលភាជកោ ន សម្មន្និតព្វោ... ផលភាជកោ សម្មន្និតព្វោ... ខជ្ជកភាជកោ ន សម្មន្និតព្វោ... ភាជិតាភាជិតំ ន ជានាតិ .. ខជ្ជកភាជកោ សម្មន្និតព្វោ .. ភាជិតាភាជិតំ ជានាតិ... អប្បមត្តកវិស្សជ្ជកោ ន សម្មន្និតព្វោ .. វិស្សជ្ជិតាវិស្សជ្ជិតំ ន ជានាតិ... អប្បមត្តកវិស្សជ្ជកោ សម្មន្និតព្វោ .. វិស្សជ្ជិតាវិស្សជ្ជិតំ ជានាតិ ...

មិនដឹងនូវទ្រព្យដែលខ្លួនគួររក្សាទុក នឹងមិនគួររក្សាទុក ... សង្ឃគួរសន្មតឲ្យជាភណ្ឌាគារិកៈ ... ដឹងនូវទ្រព្យដែលខ្លួនគួររក្សាទុក នឹងមិនគួររក្សាទុក ... សង្ឃមិនគួរសន្មតឲ្យជាចីវរប្បដិគ្គាហកៈ ... មិនដឹងចីវរដែលខ្លួនគួរទទួល នឹងមិនគួរទទួល .. សង្ឃគួរសន្មតឲ្យជាចីវរប្បដិគ្គាហកៈ ... ដឹងនូវចីវរដែលខ្លួនគួរទទួល នឹងមិនគួរទទួល ... សង្ឃមិនគួរសន្មតឲ្យជាចីវរភាជកៈ ... មិនដឹងនូវចីវរដែលខ្លួនគួរចែក នឹងមិនគួរចែក ... សង្ឃគួរសន្មតឲ្យជាចីវរភាជកៈ ... ដឹងនូវចីវរដែលខ្លួនគួរចែក នឹងមិនគួរចែក ... សង្ឃមិនគួរសន្មតឲ្យជាយាគុភាជកៈ (អ្នកចែកបបរ) ... សង្ឃគួរសន្មតឲ្យជាយាគុភាជកៈ ... សង្ឃមិនគួរសន្មតឲ្យជាផលភាជកៈ (អ្នកចែកផ្លែឈើ) ... សង្ឃគួរសន្មតឲ្យជាផលភាជកៈ ... សង្ឃមិនគួរសន្មតឲ្យជា ខជ្ជកភាជកៈ (អ្នកចែកបង្អែម) ... មិនដឹងបង្អែម ដែលខ្លួនគួរចែក នឹងមិនគួរចែក ... សង្ឃគួរសន្មតឲ្យជាខជ្ជកភាជកៈ ... ដឹងបង្អែមដែលខ្លួនគួរចែក នឹងមិនគួរចែក ... សង្ឃមិនគួរសន្មតឲ្យជាអប្បមត្តកវិស្សជ្ជកៈ (ចំណាយរបស់បន្តិចបន្តួច) ... មិនដឹងរបស់បន្តិចបន្តួចដែលខ្លួនគួរចំណាយ នឹងមិនគួរចំណាយ. សង្ឃគួរសន្មតឲ្យជាអប្បមត្តកវិស្សជ្ជកៈ... ដឹងនូវរបស់បន្តិចបន្តួច ដែលខ្លួនគួរចំណាយ នឹងមិនគួរចំណាយ ...

សាដិយគ្គាហាបកោ ន សម្មន្និតព្វោ... គហិតាគហិតំ ន ជានាតិ... សាដិយគ្គាហាបកោ សម្មន្និតព្វោ... គហិតាគហិតំ ជានាតិ .. បត្តគ្គាហាបកោ ន សម្មន្និ-តព្វោ... គហិតាគហិតំ ន ជានាតិ... បត្តគ្គា-ហាបកោ សម្មន្និតព្វោ... គហិតាគហិតំ ជានាតិ .. អារាមិកបេសកោ ន សម្មន្និតព្វោ .. បេសិតាបេសិតំ ន ជានាតិ. .. អារាមិកបេសកោ សម្មន្និតព្វោ. . បេសិតាបេសិតំ ជានាតិ... សាមណេរបេសកោ ន សម្មន្និតព្វោ... សាមណេរបេសកោ សម្មន្និតព្វោ. . សម្មតោបិ ន បេសេតព្វោ... សម្មតោ បេសេតព្វោ... ពាលោ វេទិតព្វោ... បណ្ឌិតោ វេទិតព្វោ. ខតំ ឧបហតំ អត្តានំ បរិហរតិ... អក្ខតំ អនុបហតំ អត្តានំ បរិហរតិ. . យថាភតំ និក្ខិត្តោ ឯវំ និរយេ...

សង្ឃមិនគួរសន្មតឲ្យជាសាដិយគ្គាហាបកៈ (អ្នកប្រើគេឲ្យកាន់យកនូវសំពត់ងូតទឹក)... មិនដឹងសំពត់ងូតទឹក ដែលខ្លួនគួរកាន់យក ទីងមិនគួរកាន់យក... សង្ឃគួរសន្មតឲ្យជាសាដិយគ្គាហាបកៈ... ដឹងនូវសំពត់ងូតទឹក ដែលខ្លួនគួរកាន់យក ទីងមិនគួរកាន់យក... សង្ឃមិនគួរសន្មតឲ្យជាបត្តគ្គាហាបកៈ (អ្នកប្រើគេឲ្យកាន់យកបាត្រ)... មិនដឹងនូវបាត្រ ដែលខ្លួនគួរកាន់យក ទីងមិនគួរកាន់យក... សង្ឃគួរសន្មតឲ្យជាបត្តគ្គាហាបកៈ... ដឹងនូវបាត្រ ដែលខ្លួនគួរកាន់យក ទីងមិនគួរកាន់យក... សង្ឃមិនគួរសន្មតឲ្យជា អារាមិកបេសកៈ (អ្នកប្រើញោមវត្ត)... មិនដឹងញោមវត្ត ដែលខ្លួនគួរប្រើ ទីងមិនគួរប្រើ... សង្ឃគួរសន្មតឲ្យជា អារាមិកបេសកៈ... ដឹងញោមវត្ត ដែលខ្លួនគួរប្រើទីងមិនគួរប្រើ... សង្ឃមិនគួរសន្មតឲ្យជាសាមណេរបេសកៈ (អ្នកប្រើសាមណេរ)... សង្ឃគួរសន្មតឲ្យជាសាមណេរបេសកៈ... បើបានជាសន្មតហើយ មិនគួរប្រើឡើយ បើបានជាសន្មតរួចហើយគួរប្រើ... បណ្ឌិតគប្បីជ្រាបថាជាពាល... បណ្ឌិតគប្បីជ្រាបថាជាអ្នកប្រាជ្ញ... រមែងរក្សាខ្លួន ដែលគាស់ដីករំលើងគុណហើយ... រមែងរក្សាខ្លួនដែលមិនគាស់រំលើងគុណហើយ... រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់...

បេសិតាបេសិតំ ច ជានាតិ ។ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ បេសិតាបេសិតំ ជានាតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ សាមណេរ-បេសកោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(១៦៣) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ អព្រហ្មចារី ហោតិ មុសាវាទី ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ

មិនដឹងសាមណេរដែលគួរប្រើនិងមិនគួរប្រើ ... រមែងទៅកើត ក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺភិក្ខុ មិនលុះក្នុងឆន្ទាគតិ ១ មិនលុះក្នុងទោសាគតិ ១ មិនលុះក្នុងមោហាគតិ ១ មិនលុះក្នុងភយាគតិ ១ ដឹងនូវសាមណេរ ដែលគួរប្រើ និងមិនគួរប្រើ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រើសាមណេរប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើត ក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

(២៦៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើត ក្នុងនរក ដូចគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាអ្នកសំឡាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តធម៌មិនប្រសើរ ១ និយាយកុហក ១ ផឹកទឹកស្រវឹងគឺសុរានិងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើត ក្នុងនរកដូចជាគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើត ក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាអ្នកវៀរចាកការសំឡាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តធម៌មិនប្រសើរ ១ វៀរចាកការនិយាយកុហក ១

សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(១៦៤) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ភិក្ខុនី... សិក្ខមានា... សាមណេរោ... សាមណេរី... ឧបាសកោ... ឧបាសិកា យថាភតំ និក្ខិត្តា ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតិនី ហោតិ អទិន្នាទាយិនី ហោតិ កាមេសុ មិច្ឆាចារិនី ហោតិ មុសាវាទិនី ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋាយិនី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតា ឧបាសិកា យថាភតំ និក្ខិត្តា ឯវំ និរយេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ឧបាសិកា យថាភតំ និក្ខិត្តា ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតា បដិវិរតា ហោតិ អទិន្នាទានា បដិវិរតា ហោតិ កាមេសុ មិច្ឆាចារា បដិវិរតា ហោតិ មុសាវាទា បដិវិរតា ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា ហោតិ ។

វៀរចាកការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើត ក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ១ ។

(១៦៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី... សិក្ខមានា... សាមណេរ... សាមណេរី... ឧបាសក... ឧបាសិកា ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើត ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ១ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាអ្នកសំឡាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ និយាយកុហក ១ ផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើត ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើត ក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាអ្នកវៀរចាកការសំឡាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយកុហក ១ វៀរចាកការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ១ ។

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតា ឧបាសិកា យថាភតំ និក្ខិត្តា ឯវំ សគ្គេតិ ។

(១៦៥) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អាជីវកោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ អព្រហ្មចារី ហោតិ មុសាវាទី ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ អាជីវកោ យថាភតំ និក្ខិត្តោ ឯវំ និរយេតិ ។

(១៦៦) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ និគណ្ឋោ... មុណ្ឌសាវកោ... ជដិលកោ... បរិព្វាជកោ... មាគណ្ឌិកោ... តេទណ្ឌិកោ... អារុទ្ធកោ[1]... គោតមកោ... ទេវធម្មិកោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ អព្រហ្មចារី ហោតិ មុសាវាទី ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ ។

---

១ ឱ. អវិរុទ្ធកោ ។

ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើត ក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

(១៦៥) ម្នាលភិក្ខុទាំងឡាយ អាជីវកប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើត ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាអ្នកសំឡាប់សត្វ ១ លួចទ្រព្យគេ ១ ជាអ្នកប្រព្រឹត្តធម៌ មិនប្រសើរ ១ និយាយកុហក ១ ផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលភិក្ខុទាំងឡាយ អាជីវកប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើត ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។

(១៦៦) ម្នាលភិក្ខុទាំងឡាយ និគ្រន្ថ... មុណ្ឌសាវក... ជដិលកៈ... បរិព្វាជក.. មាគណ្ឌិកៈ ..តេទណ្ឌិក... អារុទ្ធកៈ... គោតមកៈ... ទេវធម្មិកៈ ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើត ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាអ្នកសំឡាប់សត្វ១ លួចទ្រព្យគេ១ ប្រព្រឹត្តធម៌ មិនប្រសើរ១ និយាយកុហក១ ផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ។

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ទេវធម្មិកោ យថាភតំ និក្ខិត្តោ ឯវំ និរយេតិ ។

(១៦៧) រាគស្ស ភិក្ខវេ អភិញ្ញាយ បញ្ច ធម្មា ភាវេតព្វា ។ កតមេ បញ្ច ។ អសុភសញ្ញា មរណសញ្ញា អាទីនវសញ្ញា អាហារេ បដិក្កូលសញ្ញា សព្វលោកេ អនភិរតសញ្ញា ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ បញ្ច ធម្មា ភាវេតព្វាតិ ។

(១៦៨) រាគស្ស ភិក្ខវេ អភិញ្ញាយ បញ្ច ធម្មា ភាវេតព្វា ។ កតមេ បញ្ច ។ អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ បញ្ច ធម្មា ភាវេតព្វាតិ ។

(១៦៩) រាគស្ស ភិក្ខវេ អភិញ្ញាយ បញ្ច ធម្មា ភាវេតព្វា ។ កតមេ បញ្ច ។ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ បញ្ច ធម្មា ភាវេតព្វាតិ ។

ម្នាលភិក្ខុទាំងឡាយ ទេវធម្មិកៈប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើត ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។

(១៦៧) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាង គួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសំគាល់ឃើញថាមិនស្អាត ១ សំគាល់ឃើញក្នុងសេចក្ដីស្លាប់ ១ សំគាល់ឃើញថាមានទោស ១ សំគាល់ឃើញថាគួរខ្ពើម ក្នុងអាហារ ១ សំគាល់ឃើញថាមិនគួរត្រេកអរ ក្នុងលោកទាំងពួង ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ គួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងគួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសំគាល់ឃើញថាមិនទៀង ១ សំគាល់ឃើញថាជាទុក្ខ ក្នុងរបស់មិនទៀង ១ សំគាល់ឃើញថាមិនមែនរបស់ខ្លួន ក្នុងរបស់ជាទុក្ខ ១ សំគាល់ឃើញ ក្នុងធម៌ជាគ្រឿងលះ ១ សំគាល់ឃើញ ក្នុងធម៌ជាគ្រឿងនឿយណាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ គួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។

(១៦៩) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាង គួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ គួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[១៧០] រាគស្ស ភិក្ខវេ អភិញ្ញាយ បញ្ច ធម្មា ភាវេតព្វា ។ កតមេ បញ្ច ។ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ បញ្ច ធម្មា ភាវេតព្វាតិ ។

[១៧១] រាគស្ស ភិក្ខវេ បរិញ្ញាយ ។បេ។ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ បញ្ច ធម្មា ភាវេតព្វា ។បេ។ ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ ។បេ។ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ បញ្ច ធម្មា ភាវេតព្វាតិ ។

បញ្ចកនិបាតោ និដ្ឋិតោ ។

(១៧០) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាង គួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ សទ្ធាពលៈ១ វីរិយពលៈ១ សតិពលៈ១ សមាធិពលៈ១ បញ្ញាពលៈ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង គួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។

(១៧១) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាង គួរចំរើន ដើម្បីកំណត់ដឹងនូវរាគៈ ។ បេ ។ ដើម្បីអស់ទៅ ដើម្បីលះ ដើម្បីក្ស័យ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរំលត់ ដើម្បីលះបង់ ដើម្បីរលាស់នូវរាគៈ ។ បេ ។ ធម៌ ៥ យ៉ាងនេះ គួរចំរើន ដើម្បីដឹងច្បាស់នូវទោសៈ មោហៈ កោធៈ ឧបនាហៈ (ចងក្រោធទុក) មក្ខៈ (មើលគុណ) បលាសៈ (លើកខ្លួនផ្ទឹម) ឥស្សា (ឫស្សា) មច្ឆរិយៈ (កំណាញ់) មាយា (បិទបាំងទោស) សាឋេយ្យៈ (អួតអាង) ថម្ភៈ (មុខរឹង) សារម្ភៈ (ប្រណាំងពស្នា) មានះ (ប្រកាន់ខ្លួន) អតិមានះ (មើលងាយគេ) មទៈ (ស្រវឹង) បមាទៈ (ប្រាសចាកសតិ) ។ បេ ។ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះ ដើម្បីក្ស័យ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរំលត់ ដើម្បីលះបង់ ដើម្បីរលាស់នូវទោសៈ ។

ចប់ បញ្ចកនិបាត ។

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស បញ្ចកនិបាតោ

# ឆដ្ឋោ ភាគោ

---

## តតិយបណ្ណាសកោ

មាតិកា


| | | | |
|---|---|---|---|
| | | | អង្កេ |
| តតិយបណ្ណាសកេ | ផាសុវិហារវគ្គោ | បឋមោ | ១ |
| | អន្ធកវិន្ទវគ្គោ | ទុតិយោ | ១៩ |
| | គិលានវគ្គោ | តតិយោ | ៣០ |
| | រាជវគ្គោ | ចតុត្ថោ | ៤១ |
| | តិកណ្ឌកីវគ្គោ | បញ្ចមោ | ៧៣ |


## ចតុត្ថបណ្ណាសកោ


| | | | |
|---|---|---|---|
| ចតុត្ថបណ្ណាសកេ | សទ្ធម្មវគ្គោ | បឋមោ | ៩២ |
| | អាឃាតវគ្គោ | ទុតិយោ | ១១៤ |

# សុត្តន្តបិដក

# អង្គុត្តរនិកាយ បញ្ចកនិបាត

# ឆដ្ឋភាគ

---

## តតិយបណ្ណាសក

## មាតិកា

លេខទំព័រ


| | | | |
|---|---|---|---|
| តតិយបណ្ណាសក | ផាសុវិហារវគ្គ | ទី ១ ........................ | ១ |
| | អន្ធកវិន្ទវគ្គ | ទី ២ ........................ | ១៩ |
| | គិលានវគ្គ | ទី ៣ ........................ | ៣០ |
| | រាជវគ្គ | ទី ៤ ........................ | ៤១ |
| | តិកណ្ឌកីវគ្គ | ទី ៥ ........................ | ៧៣ |


## ចតុត្ថបណ្ណាសក


| | | | |
|---|---|---|---|
| ចតុត្ថបណ្ណាសក | សទ្ធម្មវគ្គ | ទី ១ ........................ | ៩២ |
| | អាឃាតវគ្គ | ទី ២ ........................ | ១១៤ |

## មាតិកាបត្ថានិ

## មាតិកា


| មាតិកា | | | អង្កេ |
|---|---|---|---|
| ចតុត្ថបណ្ណាសកេ | ឧបាសកវគ្គោ | តតិយោ | ១៥០ |
| | អរញ្ញវគ្គោ | ចតុត្ថោ | ១៨៣ |
| | ព្រាហ្មណវគ្គោ | បញ្ចមោ | ១៨៨ |


## បញ្ចមបណ្ណាសកោ


| | | | |
|---|---|---|---|
| បញ្ចមបណ្ណាសកេ | កិមិលវគ្គោ | បឋមោ | ២៣៧ |
| | អក្កោសកវគ្គោ | ទុតិយោ | ២៤៦ |
| | ទីឃចារិកវគ្គោ | តតិយោ | ២៥៥ |
| | អាវាសិកវគ្គោ | ចតុត្ថោ | ២៦៤ |
| | ទុច្ចរិតវគ្គោ | បញ្ចមោ | ២៧៤ |
| | វគ្គសង្គហិតា | សុត្តន្តា | ២៨៣ |

# សន្លឹកបន្ថែមប្រាប់មាតិកា

## មាតិកា

លេខទំព័រ


| | | |
|---|---|---|
| ចតុត្ថបណ្ណាសក | ឧបាសកវគ្គ ទី៣ ........................ | ១៥០ |
| | អរញ្ញវគ្គ ទី៤ ........................ | ១៨៣ |
| | ព្រាហ្មណវគ្គ ទី៥ ........................ | ១៨៨ |


## បញ្ចមបណ្ណាសក


| | | |
|---|---|---|
| បញ្ចមបណ្ណាសក | កិមិលវគ្គ ទី១ ........................ | ២៣៧ |
| | អក្កោសកវគ្គ ទី២ ........................ | ២៤៦ |
| | ទីឃចារិកវគ្គ ទី៣ ........................ | ២៥៥ |
| | អាវាសិកវគ្គ ទី៤ ........................ | ២៦៤ |
| | ទុច្ចរិតវគ្គ ទី៥ ........................ | ២៧៤ |
| | ពួកសូត្រមិនសង្គ្រោះក្នុងវគ្គ ........................ | ២៨៣ |

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE